សៀវភៅមេរៀន

NON-STATE ACTORS AND LOCAL AUTHORITIES IN DEVELOPMENT – ACTIONS IN PARTNER COUNTRIES (MULTI-COUNTRY) FOR NON-STATE ACTORS

DELGOSEA
Partnership for Democratic Local Governance in Southeast-Asia

# សៀវភៅមេរៀនសម្រាប់ការចំលង និងផ្លាស់ប្តូរបទពិសោធន៍ ឬការអនុវត្តល្អស្តីពី អភិបាលកិច្ចនៅអាស៊ីអាគ្នេយ៍

DELGOSEA

www.DELGOSEA.eu

This project is co-funded by the European Union.

A Project implemented by the consortium: Konrad-Adenauer-Stiftung e.V., Thailand Environment Institute (TEI), Local Government Development Foundation Inc. (LOGODEF), United Cities and Local Governments for Asia and Pacific (UCLG-ASPAC), Association of Indonesian Regency Governments (APKASI), Association of Cities of Vietnam (ACVN), and National League of Communes/Sangkats of the Kingdom of Cambodia (NLC/S).

ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (DELGOSEA) បានចាប់ផ្តើមសកម្មភាពនៅក្នុងខែមិនា ឆ្នាំ២០១០ និង ត្រូវបានសហការឧបត្ថម្ភ ដោយ សហភាពអឺរ៉ុប និង មូលនិធិខុនរ៉ាឌ Konrad-Adenauer-Stiftung (KAS) នៃប្រទេសអាឡឺម៉ង់ តាមរយៈក្រសួងនៃសហប្រតិបត្តិការការអភិវឌ្ឍន៍របស់ប្រទេសអាឡឺម៉ង់។

DELGOSEA មានគោលបំណងបង្កើតបណ្តាញនៃទីក្រុង និង ខេត្តនានា ដើម្បីដាក់ឲ្យប្រើនូវការអនុវត្តតាមការអនុវត្តល្អនៃអភិបាលកិច្ចអន្តរតំបន់ទៅដល់ប្រទេសជាដៃគូនានា ដូចជា កម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និង វៀតណាម។ DELGOSEA គាំទ្រតួនាទីនៃសមាគមរដ្ឋាភិបាលមូលដ្ឋានទាំងឡាយ (LGAs) ក្នុងការផ្តល់ឲ្យ និង ជួយដល់ការផ្ទេរ និង និរន្តន៍ភាពនៃការអនុវត្តតាមការអនុវត្តល្អ នៃអភិបាលកិច្ចមូលដ្ឋានដោយរដ្ឋបាលមូលដ្ឋាន។ អ្វីដែលសំខាន់បំផុតនោះគឺ តាមរយៈ ការផ្លាស់ប្តូរ ការអនុវត្តទាំងនោះ នៅក្នុងតំបន់ DELGOSEA មានបំណងចូលរួមក្នុងការធ្វើឲ្យប្រសើរឡើងនៃស្ថានភាព រស់នៅរបស់ប្រជាជនក្រីក្រនៅតំបន់អាស៊ីអាគ្នេយ៍ដោយ ជួយបង្កើនការចូលរួមរបស់ពួកគេ ក្នុងការធ្វើផែនការណ៍តំបន់ និង ការសម្រេចចិត្ត។

Konrad Adenauer Stiftung

DELGOSEA
Partnership for Democratic Local Governance in Southeast-Asia

# សៀវភៅមេរៀនសម្រាប់ការចំលងនិងផ្លាស់ប្តូរ បទពិសោធន៍ឬការអនុវត្តល្អស្តីពី អភិបាលកិច្ចនៅអាស៊ីអាគ្នេយ៍

| | |
|---|---|
| ជំពូកទី ១ | សេចក្តីផ្តើមនៃគម្រោង DELGOSEA |
| ជំពូកទី ២ | អភិបាលកិច្ចមូលដ្ឋានបែបលទ្ធិប្រជាធិបតេយ្យ |
| ជំពូកទី ៣ | ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត |
| ជំពូកទី ៤ | ការផ្ទេរទស្សនៈ ការបណ្តុះបណ្តាល ការតាមដាន និងការរាយការណ៍នៃការ អនុវត្តតាមការអនុវត្តន៍ល្អ |

រក្សាសិទ្ធិឆ្នាំ២០១១
គម្រោងភាពជាដៃគូ DELGOSEA/www.delgosea.eu
ការចំលងក្នុងទំរង់ផ្សេងៗដោយគ្មានការអនុញ្ញាតិពីគម្រោង ដែលតំណាងដោយមូលនិធិខុនរ៉ាឌ អាឌិនណៅអ៊ែរ នឹងមិនត្រូវបានអនុញ្ញាតិនោះទេ។ ទស្សនៈដែលរៀបរាប់នៅក្នុងសៀវភៅនេះគឺជាទស្សនៈរបស់អ្នកនិពន្ធសៀវភៅនេះហើយនឹងតំណាងឲ្យគម្រោងនោះទេ។ ដូច្នេះគម្រោង នឹងមិនទទួលខុសត្រូវចំពោះករណីដែលអាចមានការប៉ះពាល់ ឬខូចខាតនានា ដែលជាលទ្ធផលកើតឡើងពីព័ត៌មានដែលមាននៅក្នុងសៀវភៅនេះ។

# មាតិកា

អំពីសៀវភៅនេះ ១
បញ្ជីអ្នកនិពន្ធ
ជំពូកទី១៖ សេចក្តីផ្តើមនៃគម្រោង DELGOSEA
១-១ អំពី DELGOSEA
១-២ អ្នកពាក់ពន្ធ័សំខាន់ៗ
១-៣ ទិដ្ឋភាពទូទៅនៃការអនុវត្តល្អ និង រដ្ឋបាលមូលដ្ឋានសម្រាប់សាកល្បង (ទីក្រុង/ក្រុង)Pilot Cities
ជំពូកទី២៖ អភិបាលកិច្ចមូលដ្ឋានបែបលទ្ធិប្រជាធិបតេយ្យ
២-១ អភិបាលកិច្ចមូលដ្ឋានបែបប្រជាធិបតេយ្យ- មូលដ្ឋានគ្រឹះនៃការយល់ដឹង
២-២ អត្ថបទក្នុងបួនវិស័យដែលត្រូវបានជ្រើសរើសសម្រាប់ការផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងគំរូការអនុវត្តល្អនៅក្នុងគម្រោង
២-៣ រចនាសម្ពន្ធ័របស់រដ្ឋបាលមូលដ្ឋាន និង ស្ថានភាពវិមជ្ឈការក្នុងប្រទេសទាំង៥ក្នុងតំបន់អាស៊ីអាគ្នេយ៍
២-៣-១ ប្រទេសកម្ពុជា
២-៣-២ ប្រទេសឥណ្ឌូនេស៊ី
២-៣-៣ ប្រទេសហ្វីលីពីន
២-៣-៤ ប្រទេសថៃ
២-៣-៥ ប្រទេសវៀតណាម
ជំពូកទី៣៖ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត
៣ ប្រធានបទ: ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត
៣-១ ការចូលរួមរបស់ប្រជាជន: ទស្សនៈគោល
៣-១-១ ប្រវត្តិ
៣-១-២ ការបែកចែកអំណាចEmpowerment (Why and How)
៣-១-៣ ការធ្វើស្ថាប័នភាវូបនីយកម្មការចូលរួមរបស់ប្រជាជន
៣-២ ការអនុវត្តល្អ ស្តីពីការចូលរួមរបស់ប្រជាជននៅក្នុងប្រទេសអាស៊ីអាគ្នេយ៍

(ករណីសឹក្សា)

៣-២-១ ការចូលរួមរបស់សហគមន៍ក្នុងការកែលំអរតំបន់ផ្ទះសម្បែងនៅទីក្រុង វិញ ប្រទេសវៀតណាម

៣-២-២ ភាពជាដៃគូររវាងវិស័យសាធារណៈ ឯកជន និងប្រជាជននៅសង្កាត់ទូលសង្កែប្រទេសកម្ពុជា

៣-២-៣ ការធ្វើគោលនយោបាយតាមបែបសហគមន៍ដឹកនាំ និងវិមជ្ឈការនៅទីក្រុង កងកេន ប្រទេសថៃឡង់

៣-៣ កត្តាទាមទារសម្រាប់ការអនុវត្តតាមការអនុវត្តន៍ល្អនេះ

៤ ប្រធានបទទី២៖ អភិបាលកិច្ចស្ថាប័ន

៤-១ ធាតុសំខាន់ៗនៃអភិបាលកិច្ចស្ថាប័ន

៤-១-១ ក្របខណ្ឌ័ជាគន្លឹះសម្រាប់អភិបាលកិច្ចស្ថាប័ននៅថ្នាក់ខេត្តនិងថ្នាក់ក្រុងក្នុងប្រទេសទាំង៥

៤-១-២ ភាពសក្តិសិទ្ធិរបស់ស្ថាប័នដែលអាចសម្រេចបានសម្រាប់អភិបាលកិច្ចមូលដ្ឋាន និងប្រជាធិបតេយ្យ (អត្ថបទដើមរៀបរៀងដោយ បណ្ឌិត Gaudioso C. Sosmena, Jr.)

៤-១-៣ អភិក្រមតាមបែបអ្នកពាក់ព័ន្ធច្រើន

៤-១-៤ តម្លាភាព និង គណនេយ្យភាព ជាគោលការណ៍សំខាន់សម្រាប់ស្ថាប័នរដ្ឋ

៤-២ ការអនុវត្តល្អក្នុងស្ថាប័នរដ្ឋក្នុងអាស៊ីអាគ្នេយ៍ (ករណីសិក្សា)

៤-២-១ រដ្ឋាភិបាលអេឡិចត្រូនិចដើម្បីពង្រឹងការអនុវត្ត និងផ្តល់សេវារបស់ក្រុងយូកយ៉ាកាតាប្រទេសឥណ្ឌូនេស៊ី

៤-២-២ អភិបាលកិច្ចតាមរយៈភាពជាដៃគូរវាងសាលាក្រុង និងសហគមន៍ព្រឹកក្នុងប្រទេសថៃ

៤-២-៣ ការរួមចំណែកក្នុងការធ្វើផែនការទីប្រជុំជន នៃខេត្តហ្គីមារ៉ាស ប្រទេសហ្វីលីពីន

៤-២-៤ ការផ្តួចផ្តើមស្ថាប័នសាធារណៈនៅទីក្រុងឡាំងស៊ុន ប្រទេសវៀតណាម

៤-២-៥ ការពង្រឹងរដ្ឋបាលថ្នាក់មូលដ្ឋានដោយខ្លួនឯងៈ ចំណូល

និងថវិកាក្នុង ខេត្តបាត់ដំបង ប្រទេសកម្ពុជា

៥ ប្រធានបទ: សេវាកម្មសាធារណៈទីក្រុងដោយផ្តោតលើបញ្ហាបរិស្ថានទីប្រជុំជន

៥-១ ធាតុនៃការអភិវឌ្ឍទីក្រុង

៥-១-១ បញ្ហាបរិស្ថានទីក្រុងនៅអាស៊ីអាគ្នេយ៍

៥-១-២ យុទ្ធសាស្ត្រទាំង១០ សម្រាប់ការគ្រប់គ្រងការអភិវឌ្ឍបរិស្ថានទីក្រុង

៥-១-៣ ប្រព័ន្ធគ្រប់គ្រងនៃបរិស្ថានទីក្រុង

៥-១-៤ អភិក្រមចំរុះឈានទៅដោះស្រាយបញ្ហាបរិស្ថានទីប្រជុំជន

៥-២ ការអភិវឌ្ឍល្អសម្រាប់បរិស្ថានទីក្រុង

៥-២-១ គម្រោងសង្គ្រោះបរិស្ថានម៉ារីគីណា (ទីក្រុងMarikina, ហ្វីលីពីន)

៥-២-២ ក្រុមប្រឹក្សាការសម្របសម្រួលគ្រោះមហន្តរាយទីក្រុង OLONGAPO (ទីក្រុងOlongap, ហ្វីលីពីន)

៥-២-៣ ការគ្រប់គ្រងតំបន់ដីសើមសម្រាប់កែលំអទឹកកខ្វក់របស់ទីក្រុងខុដុងថានី ប្រទេសថៃ

៥-២-៤ ទីក្រុងដែលមានជាតិកាបូនទាប (មួងក្លាងMuangklang ប្រទេលថៃ)

៦ ប្រធានបទ: ការគ្រប់គ្រងសារពើពន្ធ

៦-១ តួនាទីនៃរដ្ឋាភិបាលក្នុងការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុកៈ គំនិតសំខាន់

៦-១-១ វិមជ្ឈការនិងការដើរតួដ៏សកម្ម នៃរដ្ឋាភិបាលមូលដ្ឋាន ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចមូលដ្ឋាន

៦-១-២ ការលើកទឹកចិត្ត វិស័យសេដ្ឋកិច្ច និងវិស័យនយោបាយសម្រាប់ការផ្តួចផ្តើមអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក

៦-១-៣ បង្កើតឲ្យមានសេចក្តីផ្តើមគំនិតអភិវឌ្ឍន៍មូលដ្ឋាននៅក្នុងផែនការអភិវឌ្ឍតំបន់និងជាតិ

៦-១-៤ ផ្សារភ្ជាប់អ្នកពាក់ព័ន្ធក្នុងស្រុកតាមរយៈមធ្យោបាយរួមចំណែក (កសិករ អ្នកនេសាទ អ្នកលក់ដូរនៅផ្សារ ពាណិជ្ជករ ឬសហគ្រិនក្នុងស្រុក និងសង្គមស៊ីវិល)

៦-១-៥ ភាពជាដៃគូឯកជន-សាធារណៈសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន

៦-២ គ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុកនិងការជំរុញការវិនិយោគ ក្នុងប្រទេសប្រាំនៅអាស៊ីអាគ្នេយ៍

៦-២-១ គម្រោងសមុទ្រវិប្បកម្ម Tubigon ៖ គ្រប់គ្រងសេដ្ឋកិច្ចនិងបរិស្ថានក្នុងស្រុក

៦-២-២ រៀបចំអ្នកលក់ដូរតាមដងផ្លូវនៅក្នុងទីក្រុងសូឡូ - យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុង

៦-២-៣ វិនិយោគសារជាថ្មីលើក្រុងភូកេតចាស់៖ ទេសចរណ៍វប្បធម៌ជាយុទ្ធសាស្ត្រអភិវឌ្ឍន៍

ជំពូកទី ៤៖ ការផ្ទេរទស្សនៈ ការបណ្តុះបណ្តាល ការតាមដាន និងការរាយការណ៍នៃការអនុវត្តតាមការអនុវត្តន៍ល្អ

៧-១ គោលបំណង និង សារតា

៧-២ អភិក្រមនៃការផ្ទេរទស្សនទាន

៧-២-១ សកម្មភាពត្រៀមរៀបចំ

៧-២-២ ការអភិវឌ្ឍន៍ការផ្ទេរទស្សនៈទានអភិក្រមសម្របសម្រួល-

៧-៣ វគ្គបណ្តុះបណ្តាលសម្រាប់អ្នកពាក់ព័ន្ធមូលដ្ឋាន

៧-៤ ការត្រួតពិនិត្យ និងការរាយការណ៍

៧-៤-១ និយមន័យ និង សេចក្តីផ្តើមនៃការត្រួតពិនិត្យគម្រោង

៧-៤-២ ការតាមដានទីក្រុងសាកល្បង

អំពីសៀវភៅនេះ

សៀវភៅមេរៀននេះគឺជាសមិទ្ធផលដែលកើតចេញពី ក្រុមការងារអន្តរជាតិមួយដែលទទួលខុសត្រូវក្នុងការរៀបចំខ្លឹមសារមេរៀន និងប្លង់មេរៀនដើម្បីជួយសម្រួលដល់អ្នកសម្របសម្រួលដែលគាំទ្រដល់បណ្តាទីក្រុងមួយចំនួនក្នុងដំណើរការអនុវត្តតាមបទពិសោធន៍ល្អនានា។ សៀវភៅសិក្សានិងប្លង់មេរៀនទាំងនេះបានប្រើប្រាស់សម្រាប់ផ្តល់សមត្ថភាពជំនាញចំនួន៧០នាក់មកពីសមាគមន៍រដ្ឋាភិបាលមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលឬ តំណាងមកពីទីក្រុងសាកល្បងនានា លើជំនាញសម្របសម្រួលការអនុវត្តតាមបទពិសោធន៍ល្អៗស្តីពីអភិបាលកិច្ចល្អនៅអាស៊ីអាគ្នេយ៍។ ឯកសារទាំងអស់នេះក៏ត្រូវបានធ្វើការបង្រៀនសាកល្បងរយៈពេល១០ថ្ងៃនៅទីក្រុងប៉ាតាយ៉ាប្រទេសថៃនាចុងឆ្នាំ២០១០ ហើយបានកែសម្រួលនិងបោះពុម្ពជាចុងក្រោយ។

ក្នុងសៀវភៅសិក្សានេះពាក្យថា អ្នកសម្របសម្រួល គឺមានមុខងារចំនួន៣

- ជាគ្រូបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធនៅក្នុងក្រុងសាកល្បងលើការអនុវត្តតាមបទពិសោធន៍ល្អៗនៃអភិបាលកិច្ចមូលដ្ឋាន
- ជាអ្នកបង្វឹកនិងជំនាញការក្នុងដំណើរការអនុវត្តតាមបទពិសោធន៍ល្អៗនេះ
- ជាអ្នកជំនាញការតាមដាននិងវាយតំលៃ

គម្រោង DELGOSEA នឹងបោះផ្សាយសមិទ្ធផលជាពីរលើក ។ លើកទី១គឺជាការបោះផ្សាយឯកសារមេរៀននិងប្លង់មេរៀនសម្រាប់ពង្រឹងសមត្ថភាពអ្នកសម្របសម្រួល។ លើកទី២ គឺជាសៀវភៅសិក្សានេះ។ សៀវភៅសិក្សានេះគឺជាធនធានមួយសម្រាប់អ្នកពាក់ព័ន្ធក្នុងអភិបាលកិច្ចមូលដ្ឋានទាំងអស់។ សៀវភៅនេះត្រូវបានបោះផ្សាយជាពិសេសសម្រាប់អ្នកសម្របសម្រួល អ្នកជំនាញមកពីខាងក្រៅនិងអ្នកពាក់ព័ន្ធនានា ដែលមានបំណងចង់រៀនពីការអនុវត្តល្អលើប្រធានបទចំនួន៤ៈ

១- ការចូលរួមរបស់ប្រជាពលរដ្ឋ

២- អភិបាលកិច្ចស្ថាប័ន

៣- ការផ្តល់សេវាសាធារណៈនៅទីប្រជុំជន

៤- ការធ្វើផែនការវិនិយោគនិងគ្រប់គ្រងសារពើពន្ធ

ជំពូកទី១និងទី២ រៀបរាប់អំពីសារតា របស់គម្រោង DELGOSEA គោលគំនិតដើមស្តីពីអភិបាលកិច្ចបែបប្រជាធិបតេយ្យនៅមូលដ្ឋាន រចនាសម្ព័ន្ធនិងស្ថានភាពវិមជ្ឈការនៅក្នុងប្រទេសចំនួន៥គឺកម្ពុជាឥណ្ឌូនេស៊ី ហ្វីលីពិន ថៃ និងវៀតណាម។

ជំពូក៣ត្រូវបានរៀបចំដើម្បីបង្ហាញជាលំអិតលើទស្សនទានផ្សេងៗក្នុងប្រធានបទទាំង៤ និងការអនុវត្តល្អៗមួយចំនួនផងដែរ។ ជំពូកនេះវិភាគនូវឧកាសនិងបញ្ហាប្រឈមនានាដែលកើតចេញពីការអនុវត្តគម្រោងផ្សេងៗនិងផ្តល់នូវបទពិសោធន៍និងការអនុវត្តល្អៗដែលអាចនឹងអនុវត្តតាមនូវប្រទេសផ្សេងក្នុងតំបន់ក្នុងករណីដែលចាំបាច់ក្នុងការអាន

ការអនុវត្តល្អឲ្យបានលំអិតសូមសិក្សាទៅលើការអនុវត្តល្អៗដែលបានបោះពុម្ពជាប្ញូនវ៉ូលុម តាមរយៈគេហទំព័រwww.delgosea.eu។

ជំពូក៤ផ្តោតការយកចិត្តទុកដាក់ទៅលើជំហានជាក់ស្តែងនៃការអនុវត្តតាមបទពិសោធន៍ល្អៗ ជំពូកនេះក៏សង្កត់ធ្ងន់ដែលថាការអនុវត្តតាមអាចអនុវត្តទៅបានដរាបណាការអនុវត្តល្អណាមួយនោះត្រូវបានកែសម្រួលឲ្យត្រូវតាមបរិបទជាក់ស្តែងនៅមូលដ្ឋាន។ ដូចនេះជំពូកនេះ លើកមកពិភាក្សានូវជំហានចាំបាច់នានាក្នុងការរៀបចំតាក់តែងគម្រោងឬទស្សនទានផ្ទេរ ឲ្យត្រូវតាមបរិបទនៃទីក្រុងសាកល្បង ស្របតាមគោលបំណងជាក់លាក់និងក្របខ័ណ្ឌនយោបាយនិងច្បាប់ក្នុងប្រទេសនោះ។ ជំពូក៤ក៏ផ្តល់នូវគំនិតស្តីពីការរៀបចំប្រព័ន្ធតាមដាននិងធ្វើរបាយការណ៍ដើម្បីធានាឲ្យទទួលបានជោគជ័យក្នុងការអនុវត្តតាមដោយមាននិរន្តភាព។

ឯកសារដែលបានបោះពុម្ពទាំងអស់រួមទាំងសៀវភៅសិក្សាប្លង់មេរៀន ក៏ដូចជាឯកសារស្តីពីការអនុវត្តល្អទាំង១៦អាចរកបាននូវគេហទំព័រ www.delgosea.eu ។ ការស្នើសុំឯកសារទាំងនោះក៏អាចធ្វើឡើងនៅការិយាល័យខុនរ៉ាឌ អាដិនណៅអ៊ែ ស្ទីបទង់ក្នុងប្រទេសហ្វីលីពីន។ (http://www.kas.de/philippinen/).

## List of Authors

This publication has been produced with the support of the project partners and support given by external experts. DELGOSEA would like to address its specific thanks to:

*Dr. Peter Köppinger*, Country Representative of Konrad-Adenauer-Stiftung (KAS) for the Philippines and Project Director of DELGOSEA

*Susanne Stephan*, Project Manager of DELGOSEA

*Dr. Paul Chamniern*, Director of the Thailand Environment Institute (TEI) and Consulting Key Expert of DELGOSEA

*Dr. Gaudiso Sosmena*, Consulting Key Expert of DELGOSEA and Expert on Local Governance

*Professor Edmund Tayao*, Director of Local Government Development Foundation (LOGODEF)

*Min Muny*, DELGOSEA Expert for Institutional Governance and National Coordinator for Cambodia

*Ma. Zenia M. Rodriguez,* DELGOSEA Expert on Urban Environment

*Alfredo Sureta*, DELGOSEA Expert on Peoples Participation

*Dr. Gilbert Llanto*, Expert on Fiscal Management

*Antonio Alvira*, Expert on Fiscal Management

*Ruth Gruber*, International Expert on Training Methodologies, Facilitation and Group Coordination

*Eri Trinurini-Adhi*, DELGOSEA Expert on Monitoring and Curricula Development

# ជំពូកទី១

# សេចក្តីផ្តើមនៃគម្រោង DELGOSEA

ដោយ Dr. Peter Köppinger & Susanne Stephan

# ជំពូកទី១

# សេចក្តីផ្តើមនៃគម្រោង DELGOSEA

## មាតិកា

១-១ អំពី DELGOSEA

១-២ អ្នកពាក់ពន្ធ័សំខាន់ៗ

១-៣ ទិដ្ឋភាពទូទៅនៃការអនុវត្តន៍ល្អ និង រដ្ឋបាលមូលដ្ឋានសម្រាប់សាកល្បង (ទីក្រុង/ក្រុង)Pilot Cities

# ១ លក្ខណៈទូទៅរបស់គម្រោង

## ១-១ អំពី DELGOSEA

ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (DELGOSEA) បានចាប់ផ្តើមសកម្មភាពនៅក្នុងខែមិនា ឆ្នាំ២០១០ និង ត្រូវបានសហការឧបត្ថម្ភដោយសហភាពអឺរ៉ុប និង អង្គការខុនរ៉ាឌ Konrad-Adenauer-Stiftung(KAS) នៃប្រទេសអាឡឺម៉ង់ តាមរយៈក្រសួងនៃសហប្រតិបត្តិការការអភិវឌ្ឍន៍របស់ប្រទេសអាឡឺម៉ង់។ DELGOSEA មានគោលបំណងបង្កើតបណ្តាញទីក្រុង និង ខេត្តនានា ដើម្បីអនុវត្តតាមការអនុវត្តល្អនៃអភិបាលកិច្ចអន្តរតំបន់ទៅដល់ប្រទេសជាដៃគូនានា ដូចជា កម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និង វៀតណាម។ DELGOSEA គាំទ្រតួនាទីនៃសមាគមរដ្ឋាភិបាលមូលដ្ឋានទាំងឡាយ (LGAs) ក្នុងការផ្តល់ឲ្យ និង ជួយដល់ការផ្ទេរ និង និរន្តរភាពនៃការអនុវត្តតាមការអនុវត្តល្អនៃអភិបាលកិច្ចមូលដ្ឋាន ដោយរដ្ឋបាលមូលដ្ឋាន។ អ្វីដែលសំខាន់បំផុតនោះគឺ តាមរយៈការផ្លាស់ប្តូរការអនុវត្តទាំងនោះនៅក្នុងតំបន់និមួយៗ DELGOSEA មានបំណងចូលរួមក្នុងការធ្វើឲ្យប្រសើរឡើងនៃស្ថានភាពរស់នៅរបស់ប្រជាជនក្រីក្រនៅតំបន់អាស៊ីអាគ្នេយ៍ដោយជួយបង្កើនការចូលរួមរបស់ពួកគេ ក្នុងការធ្វើផែនការណ៍តំបន់ និង ការសម្រេចចិត្ត។

នៅក្នុងដំណាក់កាលដំបូងនៃការដាក់អនុវត្តគម្រោង ការស្រាវជ្រាវដ៏ល្អិតល្អន់ត្រូវបានធ្វើឡើង ដើម្បីកំណត់ការអនុវត្តន៍នៃអភិបាលកិច្ចមូលដ្ឋានរបស់ប្រទេសជាសមាជិកទាំងប្រាំ។ ក្រុមនៃអ្នកឯកទេសនិង អ្នកតំណាងនៃអភិបាលកិច្ចមូលដ្ឋានអន្តរជាតិ មកពីសមាគមរដ្ឋាភិបាលមូលដ្ឋានបានពិនិត្យមើល និង ជ្រើសរើសបានការអនុវត្តន៍ល្អចំនួន១៦ចេញពីការអនុវត្តន៍ល្អសរុបចំនួន២៧ដែលបានដាក់ស្នើ។

នៅពេលជ្រើសរើសការអនុវត្តន៍ល្អពីប្រទេសទាំង៥ គម្រោងនេះផ្តោតសំខាន់ទៅលើខ្លឹមសារជាគោលចំនួន៤គឺ

- ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការណ៍និងការសម្រេចចិត្ត

- អភិបាលកិច្ចស្ថាប័ន
- ការរួមបញ្ចូលសេវាកម្មសាធារណៈរបស់ទីក្រុង
- ការរៀបចំសារពើពន្ធ និង ការធ្វើផែនការណ៍វិនិយោគ។

ចាប់តាំងពីខែមករាឆ្នាំ២០១១ ទៅដល់ខែសីហា ឆ្នាំ២០១២ DELGOSEA នឹងបន្តធ្វើការរួមគ្នាជាមួយសមាគមរដ្ឋាភិបាលមូលដ្ឋាន និង រដ្ឋាភិបាលតាមតំបន់នានា ដើម្បីជុំរុញឲ្យមានការអនុវត្តតាមការអនុវត្តល្អ។ ទីក្រុង និង ខេត្តដែលត្រូវយកធ្វើជាទីក្រុងសាកល្បងទាំងឡាយត្រូវបានអញ្ជើញឲ្យមានការកែសម្រួល ឬ កែលម្អការអនុវត្តន៍ល្អនៃច្បាប់ដើមទៅតាមបរិបទក្នុងស្រុករបស់ប្រទេសរៀងៗខ្លួន។ សមាគមរដ្ឋាភិបាលមូលដ្ឋាននៅក្នុងប្រទេសចូលរួមទាំង៥ មានការទទួលប្រឹក្សាយោបល់យ៉ាងជិតស្និទ្ធិ និង ណែនាំទៅដល់រដ្ឋាភិបាលសម្រាប់ការសាកល្បងដែលបានជ្រើសរើសទាំងនោះ ទាំងការផ្ទេរ និង ការប្រតិបត្តិការតាមការអនុវត្តល្អនានា។

### ១-២ អ្នកពាក់ពន្ធ័សំខាន់ៗ

ក្នុងការចាប់ផ្តើមបណ្តាញភូមិភាគ សម្រាប់ការផ្តោះផ្ទូរគំរូការអនុវត្តន៍ល្អក្នុងអភិបាលកិច្ចមូលដ្ឋាន បានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា សមាគមរដ្ឋាភិបាលក្នុងតំបន់គួរតែនៅក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ(សមាគមរដ្ឋាភិបាលមូលដ្ឋាន អង្គភាពសង្គមស៊ីវិល គ្រិះស្ថានអប់រំ អ្នកសម្រេចចិត្តខាងនយោបាយ) នៅក្នុងការចាប់ផ្តើម និង ការអនុវត្តនៃគម្រោង។ ដោយគោរពទៅតាមមុខងាររបស់ខ្លួន សមាគមរដ្ឋាភិបាលមូលដ្ឋានចែករំលែកបទពិសោធន៍ និង ផ្តល់ជូននូវជំនាញការ ការបង្ហាត់ និង ការហ្វឹកហ្វឺនដើម្បីបង្កើនសមត្ថភាពរបស់សមាជិករដ្ឋាភិបាលមូលដ្ឋាន។

សមាគមរដ្ឋាភិបាលមូលដ្ឋាន ដែលគាំទ្រគម្រោង DELGOSEA ក្នុងនាមជាដៃគូសំខាន់ៗមាន:

- ACVN - Association of Cities in Vietnam, Vietnam
- ADEKSI - Indonesian Municipal Councils Association, Indonesia
- ADKASI - Association of Indonesia Regency Legislative Councils, Indonesia
- APEKSI - Association of Indonesian Municipalities, Indonesia

- APKASI - Association of Indonesian Regency Governments, Indonesia
- LCP - The League of Cities, Philippines
- LMP - The League of Municipalities, Philippines
- LPP - The League of Provinces, Philippines
- NLC/S - National League of Communes/Sangkats of the Kingdom of Cambodia, Cambodia
- MLT - Municipal League of Thailand, Thailand

## ១.៣ ទិដ្ឋភាពទូទៅនៃការអនុវត្តល្អ និង រដ្ឋបាលមូលដ្ឋានសម្រាប់សាកល្បង (ទីក្រុង/ក្រុង)Pilot Cities

### ១.៣.១ ការអនុវត្តន៍ល្អ

ក្នុងដំណាក់កាលដំបូងនៃការប្រតិបត្តិគម្រោង ការសិក្សាស្រាវជ្រាវដ៏ល្អិតល្អន់មួយត្រូវបានធ្វើឡើងដើម្បីកំណត់ការអនុវត្តន៍ណាដែលល្អបំផុតសំរាប់អភិបាលកិច្ចមូលដ្ឋានក្នុងប្រទេសទាំងប្រាំដែលចូលរួម។ ការអនុវត្តន៍ល្អត្រូវបានជ្រើសរើសក្នុងផ្នែកបួននៃអភិបាលកិច្ចមូលដ្ឋាន៖

១. ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំផែនការនិងការសំរេចចិត្ត

២. អភិបាលកិច្ចនៃស្ថាប័ន

៣. បរិស្ថានទីក្រុង

៤. វិធីសាស្រ្តការគ្រប់គ្រងសារពើពន្ធឬ លើកកម្ពស់ការវិនិយោគ

ការជ្រើសរើសការអនុវត្តល្អផ្អែកលើលក្ខណៈវិនិច្ឆ័យពីរធំៗ៖ (១) ភាពដែលអាចផ្ទេរ និងអាចទទួលយកបានក្នុងប្រទេសនិងអភិបាលកិច្ចមូលដ្ឋានទាំងឡាយដែលមានសារវតានយោបាយនិងវប្បធម៌ខុសគ្នា; (២) ភាពដែលអាចបង្កើតឥទ្ធិពលពិតប្រាកដក្នុងការធ្វើអោយល្អ

ប្រសើរឡើងលើកស្ទួយលក្ខខ័ណ្ឌរស់នៅរបស់ប្រជាជនទូទៅនិងជាពិសេសប្រជាជនក្រីក្រនិងក្រុមជនងាយរងគ្រោះ។

ជាពិសេស ការអនុវត្តន៍ល្អគួរតែះ

- ប្រើប្រាស់**គំនិតឬវិធីថ្មីៗ**ក្នុងការអនុវត្តផ្នែកណាមួយក្នុងចំណោមផ្នែកទាំងបួនក្នុងអភិបាលកិច្ចមូលដ្ឋាន
- មាន**សក្តានុពលខ្ពស់ក្នុងការផ្ទេរ** ដោយពិចារណាទៅលើបរិស្ថានរដ្ឋបាលនិងនយោបាយ ក៏ដូចជាកត្តាសង្គមវប្បធម៌
- មាន**លក្ខណៈនិរន្តរភាព**
- មានភាពសមហេតុផលក្នុង**ភាពដែលអាចសម្រេចបានក្នុងផ្នែកស្ថាប័ននិងផ្នែកហិរញ្ញវត្ថុ**
- មានភាពសន្សំសំចៃខ្ពស់
- គោរពតាម**គោលការណ៍អភិបាលកិច្ចល្អរបស់អង្គការសហប្រជាជាតិ**

ចេញពីសេចក្តីស្នើចំនួន២៧នេះ គម្រោងបានជ្រើសរើសគំរូការអនុវត្តន៍ល្អចំនួន១៦ សម្រាប់ដាក់ឲ្យអនុវត្តតាមនៅទីកន្លែងផ្សេងៗគ្នា។ ការជ្រើសរើសត្រូវបានធ្វើឡើងក្នុងសិក្ខាសាលាពិភាក្សាមួយដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗទាំងឡាយ។

| **ខ្លឹមសារ ១៖ ការចូលរួមពីប្រជាជនក្នុងការធ្វើផែនការនិងការសម្រេចចិត្ត** | **ខ្លឹមសារ ២៖ អភិបាលកិច្ចនៃស្ថាប័ន** | **ខ្លឹមសារ ៣៖ បរិស្ថានទីក្រុង** | **ខ្លឹមសារ ៤៖ ការរៀបចំផែនការការគ្រប់គ្រងនិងការវិនិយោគសារពើពន្ធ** |
|---|---|---|---|
| ការកសាងគោលនយោបាយតាម | រដ្ឋាភិបាលអេឡិចត្រូនិចជាជំហាន | ស្តាបនាតំបន់ដីសើមសម្រាប់ប្រព្រឹត្តិកម្ម | ការប្តូរទីតាំងមនុស្សនិងការផ្តល់អំណាច |

| ខ្លឹមសារ ១៖ ការចូលរួមពីប្រជាជនក្នុងការធ្វើផែនការនិងការសម្រេចចិត្ត | ខ្លឹមសារ ២៖ អភិបាលកិច្ចនៃស្ថាប័ន | ខ្លឹមសារ ៣៖ បរិស្ថានទីក្រុង | ខ្លឹមសារ ៤៖ ការរៀបចំផែនការការគ្រប់គ្រងនិងការវិនិយោគសារពើពន្ធ |
|---|---|---|---|
| លក្ខណៈវិមជ្ឈការ និង ដឹកនាំដោយសហគមន៍ (ទីក្រុងខងកៀន Khonkean, ប្រទេសថៃ) | ថ្មីក្នុងការពង្រឹងសកម្មភាពនិងសេវាកម្មនៃរដ្ឋាភិបាល (យូកយាកាតា Yogyakarta, ប្រទេសឥណ្ឌូនេស៊ី) | ទឹកកខ្វក់នៅទីក្រុង (ឧដុងថានី Udonthani, ប្រទេសថៃ) | ដល់អ្នកលក់តាមផ្លូវ (សូឡូSolo, ប្រទេសឥណ្ឌូនេស៊ី) |
| ការចូលរួមពីសហគមន៍ក្នុងការធ្វើឲ្យប្រសើរឡើងនូវតំបន់ប្រមូលផ្ដុំទីលំនៅចាស់ (ទីក្រុងវិញVinh, ប្រទេសវៀតណាម) | កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលក្នុងតំបន់ដើម្បីដោះស្រាយតម្រូវការរួម (កាតាមានតូ Kartamantul, ប្រទេសឥណ្ឌូនេស៊ី) | ទីក្រុងដែលមានជាតិកាបូនទាប (ទីប្រជុំជនមួងក្លាង Muangklang, ប្រទេសថៃ) | រក្សាសំណង់ស្ថាបត្យកម្មទីក្រុងចាស់ និងធ្វើឲ្យរស់ឡើងវិញនូវប្រពៃណីទំនៀមទំលាប់ ទុកជាការទាក់ទាញទេសចរណ៍និង ការជំរុញសេដ្ឋកិច្ច (ទីក្រុងភូកេត Phuket, ប្រទេសថៃ) |
| ភាពជាដៃគូនៃប្រជាជន-ឯកជន-សាធារណៈ ដើម្បីកែលម្អហេដ្ឋារចនា | អភិបាលកិច្ចតាមរយៈភាពជាដៃគូរវាងក្រុងនិងសហគមន៍ (ក្រុងព្រឹកPrik, | គម្រោងអ្នកសង្គ្រោះបរិស្ថានមារីគីណា Marikina (ទីក្រុង | គម្រោងសមុទ្រវប្បកម្មទូប៊ីហ្គានTubigon (Tubigon, ប្រទេស |

| ខ្លឹមសារ ១៖ ការចូលរួមពីប្រជាជនក្នុងការធ្វើផែនការនិងការសម្រេចចិត្ត | ខ្លឹមសារ ២៖ អភិបាលកិច្ចនៃស្ថាប័ន | ខ្លឹមសារ ៣៖ បរិស្ថានទីក្រុង | ខ្លឹមសារ ៤៖ ការរៀបចំផែនការការគ្រប់គ្រងនិងការវិនិយោគសារពើពន្ធ |
|---|---|---|---|
| សម្ព័ន្ធក្នុងស្រុក (សង្កាត់ទួលសង្កែ, ប្រទេសកម្ពុជា) | ប្រទេសថៃ) | មារីគីណាMarikina, ភីលីពីន) | ភីលីពីន) |
| | ការរៀបចំផែនការដែលមានការចូលរួម (Guimaras, ប្រទេសហ្វីលីពីន) | ក្រុមប្រឹក្សាសម្រប សម្រួល គ្រោះមហន្តរាយ ក្រុង អូឡុងហ្គាប៉ូOlongapo (Olongapo, ប្រទេសហ្វីលីពីន) | |
| | របៀបបញ្ចូលថ្មីនៃស្ថាប័នសាធារណៈ: (ទីក្រុងឡាងសាន Lang Son, ប្រទេសវៀតណាម) | | |
| | ពង្រឹងការគ្រប់គ្រងមូលដ្ឋានដោយខ្លួន | | |

| ខ្លឹមសារ ១៖ ការចូលរួមពីប្រជាជនក្នុងការធ្វើផែនការនិងការសម្រេចចិត្ត | ខ្លឹមសារ ២៖ អភិបាលកិច្ចនៃស្ថាប័ន | ខ្លឹមសារ ៣៖ បរិស្ថានទីក្រុង | ខ្លឹមសារ ៤៖ ការរៀបចំផែនការការគ្រប់គ្រងនិងការវិនិយោគសារពើពន្ធ |
|---|---|---|---|
| | ឯងជា ៖ ចំណូលនិងគម្រោងថវិកា តម្លាភាពនិងការចូលរួមរបស់ប្រជាពលរដ្ឋ (ក្រុងបាត់ដំបង, ប្រទេសកម្ពុជា) | | |

### ១.៣.២. ទីក្រុងសម្រាប់សាកល្បង

**ទីក្រុងសាកល្បង - ការផ្ទេរ និង អង្គភាពប្រតិបត្តិ នៃការអនុវត្តន៍ល្អ**

គម្រោងនេះធ្វើការជាមួយទីក្រុងសាកល្បងចំនួន១៦ទូទាំងប្រទេសទាំង៥។ ក្នុងស័ព្ទបច្ចេទេសនៃគម្រោង *ទីក្រុងសាកល្បងគឺជារដ្ឋាភិបាលក្នុងស្រុក ឬក្រុងទាំងឡាយណាដែលមានបំណងចង់អនុវត្តតាមមួយឬក៏ច្រើនពីការអនុវត្តល្អពីប្រទេសដទៃ។*

ទីក្រុងសាកល្បងទាំងនេះត្រូវបានស្នើដោយសមាគមន៍រដ្ឋបាលមូលដ្ឋាន និងត្រូវបានពណ៌នាពីលក្ខណ:តាមរយ:លក្ខណ:វិនិច្ឆ័យដូចខាងក្រោម៖

- ប្រវត្តិថ្មីៗនៃអភិបាលកិច្ចល្អ និងរបាយការណ៍តាមដានល្អក្នុងការអនុវត្តតួនាទីអភិបាលកិច្ចមូលដ្ឋាន(គោលការណ៍អភិបាលកិច្ចល្អ)
- សក្តានុពលនៃធនធានមនុស្សដ៏រឹងមាំ និង ភាពគ្រប់គ្រាន់នៃគុណវឌ្ឍនិងភាពអាចរកបានបុគ្គលិក

- គុណភាពអ្នកដឹកនាំនៃអភិបាលក្រុងនិងមន្ត្រីជាន់ខ្ពស់នៃរដ្ឋបាលមូលដ្ឋានមានភាពរឹងមាំ ព្រមទាំងភាពត្រៀមរួចជាស្រេចរបស់ពួកគាត់ក្នុងការធ្វើឲ្យប្រសើរឡើងនៃយុទ្ធសាស្ត្រនិងនិតិវិធីដែលមានស្រាប់សម្រាប់ការរួមចំណែករបស់ប្រជាពលរដ្ឋ។

- បទពិសោធន៍និងសមត្ថភាពគ្រប់គ្រាន់ក្នុងវិស័យទាក់ទង

- ការប្តេជ្ញាយ៉ាងច្បាស់លាស់ដោយមន្ត្រីមូលដ្ឋានក្នុងការក្លាយជាក្រុងសាកល្បង រួមបញ្ចូលទាំងការប្តេជ្ញាខាងវិភាគទានហិរញ្ញវត្ថុ(ឧទាហរណ៍ អាចធ្វើក្នុងរូបភាពជាការងារ ពេលវេលា និងការខិតខំប្រឹងប្រែងដទៃទៀត ឬក៏ជាថវិកា) ប្រសិនបើចាំបាច់។

នៅពេលដែលទីក្រុងសាកល្បងជ្រើសរើសគំរូ "ការអនុវត្តល្អ" ពីប្រទេសដែល "ជោគជ័យ" បានរួចរាល់ហើយ បន្ទាប់មកត្រូវយកមកធ្វើការវាយតម្លៃសម្រាប់ជា "ទស្សនទានសម្រាប់ការផ្ទេរ" ឆ្លុះបញ្ចាំងពីតម្រូវការនិងស្ថានភាពជាក់ស្តែងនៃទីក្រុងសាកល្បងនិមួយៗ។ ទីក្រុងសាកល្បងទាំង ១៦នឹងទទួលបានកម្មវិធីពង្រឹងសមត្ថភាពមួយដើម្បីសម្រួលដល់ការចម្លងតាមនៃការអនុវត្តល្អទាំងនេះ។ ក្នុងកំឡុងពេលប្រតិបត្តិ អ្នកសម្របសម្រួលនឹងត្រួតពិនិត្យស្ថានការណ៍នៃការប្រតិបត្តិ និងផ្តល់យោបល់ដល់ទីក្រុងសាកល្បងបន្ថែមទៀតចំពោះដំណើរការអនុវត្តតាមនេះ។ ទស្សនកិច្ចបន្ថែមរវាងតំបន់ដែល "ជោគជ័យ" និងតំបន់សាកល្បងនឹងបានត្រូវរៀបចំឡើង។ ដំណើរការនៃអភិវឌ្ឍន៍ការផ្ទេរទស្សនទាន ការហ្វឹកហាត់អ្នកពាក់ពន្ធ័មូលដ្ឋាន និង ការត្រួតពិនិត្យនិងការវាយការណ៍ នឹងធ្វើការពិពណ៌នាក្នុងជំពូកទី៤ ក្នុងសៀវភៅនេះ។

នៅចុងបញ្ចប់នៃគម្រោង នឹងមានការប្រគល់រង្វាន់ជូនដល់ទីក្រុងសាកល្បងយ៉ាងតិច៣ សម្រាប់ការខិតខំប្រឹងប្រែងនិងលទ្ធផលល្អក្នុងការលើកកម្ពស់អភិបាលកិច្ចមូលដ្ឋានដែលមានលក្ខណៈបែបលទ្ធិប្រជាធិបតេយ្យ។ ឯកសារមួយដែលទាក់ទងនឹងដំណើរការផ្ទេរនឹងត្រូវបោះពុម្ពជាភាសាអង់គ្លេសនិងភាសាក្នុងស្រុក។

ទីក្រុងសាកល្បងក្នុងបណ្តាប្រទេសទាំងប្រាំនៃគម្រោងDELGOSEA

| ឥណ្ឌូនេស៊ី | ថៃ | វៀតណាម | កម្ពុជា | ហ្វីលីពីន |
|---|---|---|---|---|
| Pangkal | Chiang Rai | Tra Vinh City | Choam Chao | Misamis Oriental |

| ឥណ្ឌូនេស៊ី | ថៃ | វៀតណាម | កម្ពុជា | ហ្វីលីពីន |
|---|---|---|---|---|
| Pinang | City | Vinh City | Sangkat | (ManLuNa and |
| Tarakan | Songkla | Da Nang | Kampot | BinKiSu) |
| Kupang | Yala | | | Bacolod |
| Wakatobi | Pakkret | | | One Pangasinan |
| | | | | Alliance of LGUs |

សេចក្តីពិពណ៌នាពីតំបន់សាកល្បង ពីស្ថានភាពសង្គមសេដ្ឋកិច្ចនិងភាពជាអ្នកដឹកនាំផ្នែកនយោបាយក៏ដូចជាសេចក្តីលំអិតពីព័ត៌មានទំនាក់ទំនងអាចរកបានក្នុងគេហទំព័រ DELGOSEA:www.delgosea.eu.

**បញ្ហា៖ទិដ្ឋភាពទូទៅនៃការអនុវត្តល្អដែលត្រូវបានជ្រើសរើស និងទីតាំងដែលត្រូវចម្លងតាម**

គម្រោង៖ ភាពជាដៃគូនៃអភិបាលកិច្ចមូលដ្ឋានបែបប្រជាធិបតេយ្យនៅអាស៊ីអាគ្នេយ៍

ទំហំករណីសិក្សា៖ ប្រទេសទាំងប្រាំ

| ខ្លឹមសារសំខាន់ | លេខបទពិសោធន៍ល្អ | ខ្លឹមសារ ឬ ចំណងជើងបទពិសោធន៍ល្អ | ប្រទេសប្រភពដើម | ឈ្មោះរដ្ឋាភិបាលមូលដ្ឋាន ឬក្រុង | ប្រភេទនៃរដ្ឋាភិបាលមូលដ្ឋាន | ធ្វើតាមដោយ (១) | ធ្វើតាមដោយ (២) | ធ្វើតាមដោយ (3) | ធ្វើតាមដោយ (៤) |
|---|---|---|---|---|---|---|---|---|---|
| ខ្លឹមសារ១៖ ការចូលរួមរបស់ប្រជាជនក្នុងការធ្វើផែនការនិងការធ្វើសេចក្តីសម្រេចចិត្ត | ១ | ការកសាងគោលនយោបាយតាមលក្ខណៈវិមជ្ឈការនិង ដឹកនាំដោយសហគមន៍ | ថៃ | ទីក្រុងខនកៀន | ក្រុង | | | | |
| ខ្លឹមសារ១៖ ការចូលរួមរបស់ប្រជាជនក្នុងការធ្វើផែនការនិងការធ្វើសេចក្តីសម្រេចចិត្ត | ២ | ការចូលរួមពីសហគមន៍ក្នុងការធ្វើឲ្យប្រសើរឡើងនៃតំបន់ប្រជុំលំនៅដ្ឋានចាស់ៗ | វៀតណាម | ទីក្រុងវិញ | ក្រុង | | | | |
| ខ្លឹមសារ១៖ ការចូលរួមរបស់ប្រជាជនក្នុងការធ្វើផែនការនិងការធ្វើសេចក្តីសម្រេចចិត្ត | ៣ | ភាពជាដៃគូនៃប្រជាជន-ឯកជន-សាធារណៈ: ក្នុងការធ្វើឲ្យប្រសើរឡើងនៃហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន | កម្ពុជា | សង្កាត់ទួលសង្កែ | ថ្នាក់ទីបួននៃរដ្ឋាភិបាល | ទីក្រុង Bacolod ហ្វីលីពីន | | | |
| | | | | | | | | | |
| ខ្លឹមសារ២៖ អភិបាលកិច្ចស្ថាប័ន | ៤ | រដ្ឋាភិបាលអេឡិចត្រូនិចជាជំហានថ្មីក្នុងការពង្រឹងសកម្មភាពនិងសេវាកម្មនៃរដ្ឋាភិបាលមូលដ្ឋាន | ឥណ្ឌូនេស៊ី | យុគយាការតា | ក្រុង | ទីក្រុង Tra Vin | ទីក្រុង Songkla, ថៃ | | |
| ខ្លឹមសារ២៖ អភិបាលកិច្ចស្ថាប័ន | ៥ | កិច្ចសហប្រតិបត្តិការការងាររដ្ឋាភិបាលក្នុងតំបន់ដើម្បីដោះស្រាយតម្រូវការក្រុម | ឥណ្ឌូនេស៊ី | កាតាម៉ាន់តូ | | ទីក្រុង Chiang Rai, ថៃ (មុនBP១៣) | | | |
| ខ្លឹមសារ២៖ អភិបាលកិច្ចស្ថាប័ន | ៦ | អភិបាលកិច្ចតាមរយៈភាពជាដៃគូរវាងក្រុងនិងសហគមន៍ | ថៃ | ក្រុងព្រិក | ក្រុង | | | | |
| ខ្លឹមសារ២៖ អភិបាលកិច្ចស្ថាប័ន | ៧ | ការរៀបចំផែនការដែលមានការចូលរួម | ហ្វីលីពីន | ឃុំម៉ាកាស់ | ខេត្ត | | | | |
| ខ្លឹមសារ២៖ អភិបាលកិច្ចស្ថាប័ន | ៨ | របៀបបញ្ចូលថ្មីនៃស្ថាប័នសាធារណៈ: | វៀតណាម | ទីក្រុងឡាងសុន | ក្រុង | ទីក្រុង Yala, ថៃ | | | |
| ខ្លឹមសារ២៖ អភិបាលកិច្ចស្ថាប័ន | ៩ | ពង្រឹងការគ្រប់គ្រងមូលដ្ឋានដោយខ្លួនឯង៖ ចំណូលនិងគម្រោងថវិកា តម្លាភាពនិងការចូលរួម | កម្ពុជា | ក្រុងបាត់ដំបង | ថ្នាក់ទីបីនៃរដ្ឋាភិបាល | | | | |
| | | | | | | | | | |
| ខ្លឹមសារ៣៖ សេវាកម្មសាធារណៈ: ទីក្រុង | ១០ | ស្ថាបនាតំបន់ដីសើមសម្រាប់ប្រព្រឹត្តិកម្មទឹកកខ្វក់នៅទីក្រុង | ថៃ | ទីក្រុងនត្តុងថានី | ក្រុង | សមាគមធំទីក្រុង | | | |
| ខ្លឹមសារ៣៖ សេវាកម្មសាធារណៈ: ទីក្រុង | ១១ | ទីក្រុងដែលមានជាតិកាបូនទាប | ថៃ | ក្រុងមួងក្លាង | ក្រុង | Wakatobi, ឥណ្ឌូនេស៊ី | | | |
| ខ្លឹមសារ៣៖ សេវាកម្មសាធារណៈ: ទីក្រុង | ១២ | គម្រោងអ្នកសង្គ្រោះបរិស្ថានម៉ារីគីណា | ហ្វីលីពីន | ទីក្រុងម៉ារីគីណា | ទីក្រុង | កំពត កម្ពុជា | ទីក្រុង Vinh វៀតណាម | Tarakan, ឥណ្ឌូនេ | Kupang, ឥណ្ឌូនេស៊ី |
| ខ្លឹមសារ៣៖ សេវាកម្មសាធារណៈ: ទីក្រុង | ១៣ | ក្រុមប្រឹក្សាសម្របសម្រួលគ្រោះមហន្តរាយក្រុងអូឡុងហ្គាប៉ូ | ហ្វីលីពីន | ទីក្រុងអូឡុងហ្គាប៉ូ | ទីក្រុង | | | | |
| | | | | | | | | | |
| ខ្លឹមសារ៤៖ ការលើកកម្ពស់ ការវិនិយោគ និងការគ្រប់គ្រងសារពើពន្ធ | ១៤ | ការប្តូរទីតាំងនិងការផ្តល់អំណាចដល់អ្នកលក់តាមផ្លូវ | ឥណ្ឌូនេស៊ី | ទីក្រុងសូឡូ | ក្រុង | ក្រុង Pakkred | | | |
| ខ្លឹមសារ៤៖ ការលើកកម្ពស់ ការវិនិយោគ និងការគ្រប់គ្រងសារពើពន្ធ | ១៥ | ការរក្សាសំណង់ស្ថាបត្យកម្មទីក្រុងចាស់និងធ្វើឲ្យរស់ឡើងវិញនូវប្រពៃណីទំនៀមទំលាប់ទុកជា | ថៃ | ទីក្រុងភូកេត | ក្រុង | | | | |
| ខ្លឹមសារ៤៖ ការលើកកម្ពស់ ការវិនិយោគ និងការគ្រប់គ្រងសារពើពន្ធ | ១៦ | គម្រោងសមុទ្រវប្បកម្ម ទូបីហ្គាន់ | ហ្វីលីពីន | ទូបីហ្គន | ក្រុង | | | | |

# ជំពូកទី២

## អភិបាលកិច្ចមូលដ្ឋានបែបលទ្ធិប្រជាធិបតេយ្យ

ដោយ លោកដុកទ័រ ពិច័រ កូពីងងរ

# ជំពូកទី២ អភិបាលកិច្ចមូលដ្ឋាននៃប្រជាធិបតេយ្យ

## មាតិការ


២-១ អភិបាលកិច្ចមូលដ្ឋានបែបប្រជាធិបតេយ្យ- មូលដ្ឋានគ្រឹះនៃការយល់ដឹង

២-២ អត្ថបទក្នុងបួនវិស័យដែលត្រូវបានជ្រើសរើសសម្រាប់ការផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងគំរូការអនុវត្តល្អនៅក្នុងគម្រោង

២-៣ រចនាសម្ព័ន្ធរបស់រដ្ឋបាលមូលដ្ឋាន និង ស្ថានភាពវិមជ្ឈការក្នុងប្រទេសទាំង៥ ក្នុងតំបន់អាស៊ីអាគ្នេយ៍

២-៣-១ ប្រទេសកម្ពុជា

២-៣-២ ប្រទេសឥណ្ឌូនេស៊ី

២-៣-៣ ប្រទេសហ្វីលីពីន

២-៣-៤ ប្រទេសថៃ

២-៣-៥ ប្រទេសវៀតណាម

# ២ រដ្ឋាភិបាលមូលដ្ឋានបែបលទ្ធិប្រជាធិបតេយ្យ - ការសាកល្បង

## ២-១ អភិបាលកិច្ចមូលដ្ឋានបែបប្រជាធិបតេយ្យ - មូលដ្ឋានគ្រឹះនៃការយល់ដឹង

ក្នុងជំពូកនេះនឹងអត្ថាធិប្បាយពីចំណេះដឹងគ្រឹះនៃអភិបាលកិច្ចមូលដ្ឋាន បែបប្រជាធិបតេយ្យដែលជាបញ្ហាស្នូលរបស់គម្រោងDELGOSEA។ នៅក្នុងជំពូកនេះដែរ ក៏មានទ្រឹស្តីនិងទស្សន:ដែលមានលក្ខណ:ទូលំទូលាយមួយចំនួនដែលទាក់ទងនឹងបញ្ហានេះ ហើយមិនត្រូវបានយកមកបង្ហាញនោះទេ។ ជាការពិតជំពូកនេះមានបំណងណែនាំដល់អ្នកអានពីការយកចិត្តទុកដាក់ពិសេសលើអ្នកសម្របសម្រួលដែលនឹងត្រូវបានហ្វឹកហ្វឺនសម្រាប់ការកសាងសមត្ថភាព ក្នុងកម្មវិធីរបស់គម្រោងDELGOSEAនេះ ទៅលើធាតុសំខាន់ៗនៃអភិបាលកិច្ចមូលដ្ឋានបែបប្រជាធិបតេយ្យ។

គោលបំណង: ទទួលបានចំណេះដឹងប្រសើរជាងមុនលើការអនុវត្តល្អក្នុងប្រទេសទាំង៥ក្នុងតំបន់អាស៊ីអាគ្នេយ៍

"អភិបាលកិច្ចមូលដ្ឋានតាមបែបលទ្ធិប្រជាធិបតេយ្យ" គឺជាអ្វីដែលគម្រោងស្តីអំពី។ សញ្ញាណនៃ "អភិបាលកិច្ចល្អ" គឺជាទំនាក់ទំនងថ្មីមួយទៀត។ វាមាននិយមន័យជាច្រើនដែលទាក់ទងនឹងពាក្យនេះ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ពាក្យថាអភិបាលកិច្ចតែងតែត្រូវបានរួមបញ្ចូលសកម្មភាពហ្វឹកហាត់កិច្ចការជាច្រើនដែលប្រព្រឹត្តិទៅក្នុងវិធីដែលមានប្រសិទ្ធិភាពនិងសក្តិសិទ្ធិសម្រាប់អត្ថប្រយោជន៍នៃការគ្រប់គ្រងជាតិសាសន៍របស់ខ្លួន។

លក្ខណ:នានាដែលអាចសន្មត់ថាជាលទ្ធផលរបស់អភិបាលកិច្ចល្អមាន៖

- **ភាពស្របច្បាប់:** ការទទួលស្គាល់ជាសាធារណៈនៃសិទ្ធិអំណាចទាំងនោះដែលទទួលការយល់ព្រមក្នុងការអោយមានជីវិតដែលបានបង្កើតក្នុងច្បាប់ ក្នុងដំណើរការនៃគោលការណ៍នានា។
- **គណនេយ្យភាព:** ទាក់ទងនឹងភាពស្របច្បាប់នៃអ្នកកាន់អំណាច ដែលនឹងត្រូវបានការទទួលដឹងនិងស្គាល់ត្រឹមត្រូវតាមផ្លូវច្បាប់ ក្នុងករណីដែលពួកគេមានមុខងារទទួលខុសត្រូវលើកិច្ចការសាធារណៈ។ គណនេយ្យភាពត្រូវបានប្រាកដដោយដំណើរការនៃការជ្រើសរើសអ្នកកាន់អំណាចទាំងឡាយ និងដោយនិតិវិធីនានាដើម្បីឲ្យធានាថារាល់ដំណើរការធ្វើសេចក្តីសំរេចចិត្តមានលក្ខណៈជាសាធារណៈ និងរាល់លទ្ធផលនិមួយៗត្រូវអនុញ្ញាតិឲ្យមានការចូលរួមតាមរយៈការផ្តល់មតិត្រឡប់និងការតាមដានអង្កេតពីសារធារណៈជនផងដែរ។
- **ការគ្រប់គ្រងដែលមានប្រសិទ្ធិភាព:** ទាក់ទិនទៅនឹងវិសាលភាពនៃបច្ចេកទេសដែលប្រសិទ្ធិភាពរបស់វាពាក់ពន្ធ័នឹងសមត្ថភាពការិយាល័យធិបតេយ្យសាធារណៈដែលមានជំនាញពេញលេញ និងទទួលបានផលល្អក្នុងពេលផ្ទេរធនធានសាធារណៈទៅអោយសេវាកម្មនិងហេដ្ឋរចនាសម្ពន្ធ័ដែលឆ្លើយតបទៅនឹងតម្រូវការ ដែលជាសក្តានុពលរបស់សាធារណៈដែលបានកំណត់។ ការណែនាំពីការអនុវត្តការងារនិងនិតិវិធីមានលក្ខណៈតម្លាភាព ដែលជាគន្លឹះមុខសញ្ញានៃការគ្រប់គ្រងសាធារណៈយ៉ាងមានប្រសិទ្ធិភាព។
- **ភាពដែលអាចរកបាននៃព័ត៌មាន:** លំហូរនៃព័ត៌មានគឺជាបណ្តាញរវាងសង្គមស៊ីវិលនិងរដ្ឋាភិបាល។ វាអនុញ្ញាតិអោយសាធារណៈ វិនិច្ឆ័យពីប្រសិទ្ធិភាពនៃអំណាចទាំងនោះក៏ដូចជាទំរង់បែបបទការងារតាមបែបការិយាល័យផងដែរ។ សមត្ថភាពសាធារណៈដើម្បីចូលរួមនិងដើម្បីកាន់អំណាចទាំងនោះអោយបានត្រឹមត្រូវដោយផ្អែកលើភាពអាចរកបាននៃព័ត៌មានទាំងនោះអំពីច្បាប់, គោលការណ៍នានា, និងលទ្ធផលនានាផងដែរ។

សញ្ញាណនេះបានណែនាំចូលក្នុងការសិក្សានិងការពិភាក្សានយោបាយអំពីការអភិវឌ្ឍន៍ប្រទេសនិមួយៗ

- ជាចំណែកដែលជាទស្សនៈបំពេញបង្គ្រប់ទៅលើអភិបាលកិច្ចបែបប្រជាធិប-តេយ្យ
- ជាផ្នែកមួយដែលភ្នាក់ងារ និងស្ថាប័នដែលមិនពាក់ពន្ធ័នឹងនយោបាយ ប្រើប្រាស់ជាវិធីសាស្រ្តដំណោះស្រាយដើម្បីចៀសវាងការតស៊ូនឹងរបបផ្តាច់ការ ហើយនឹងត្រូវជំនួសដោយគោលបំណងសម្រាប់អភិវឌ្ឍន៍រចនាសម្ពន្ធ័ និងគោលនយោបាយនានារបស់លទ្ធិប្រជាធិបតេយ្យវិញ។

អភិបាលកិច្ចបែបប្រជាធិបតេយ្យបានបង្ហាំងនូវភាពស្មុគស្មាញរបស់បញ្ហានានា ដែលទាក់ទងទៅលើទិដ្ឋភាពទាំងឡាយដែលជាសកម្មភាពសាធារណៈនៅលើដែនដីក្រោមការត្រួតត្រា , សេដ្ឋកិច្ច, សង្គម, បរិស្ថាន, នយោបាយ, និងកត្តាវប្បធម៌។ វារុំពទ្ធ័ទៅដោយកត្តាសន្តិសុខផងដែរ។ វាអនុវត្តលើការវិវត្តន៍នៃអន្តរកម្មរវាងតំបន់ទាំងនេះក្នុងការធ្វើអន្តរាគមន៍ពីសំណាក់អ្នកពាក់ពន្ធ័ និងរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ផ្សេងៗគ្នា។ អភិបាលកិច្ចបែបប្រជាធិបតេយ្យសំដៅលើប្រជាធិបតេយ្យភាពដែលមានភាពប្រសើរបំផុតដែលមានគោលបំណងក្នុងការគាំទ្រលើដំណើរការលទ្ធិប្រជាធិបតេយ្យ។ សមាសធាតុសំខាន់ៗខ្លីៗមានដូចជាការបោះឆ្នោត, សិទ្ធិមនុស្ស, ការផ្សព្វផ្សាយ, អង្គនិតិបញ្ញត្តិ, និតិប្រតិបត្តិ, យន្តការត្រួតពិនិត្យផ្នែកស៊ីវិល, ផ្នែកគ្រប់គ្រងសាធារណៈ រួមទាំងហិរញ្ញវត្ថុសាធារណៈនិងរដ្ឋធម្មនុញ្ញផងដែរ។

នៅក្នុងទម្រង់ការងាររបស់គម្រោងនេះ បណ្តាដៃគូនិងអ្នកពាក់ពន្ធ័នានាត្រូវបានធ្វើឲ្យមានការជឿជាក់ថា អភិបាលកិច្ចល្អនឹងនូវតែបន្តភាពពិតប្រាកដហើយដែលមិនអាចសម្រេចដោយគ្មានការចូលរួមនិងត្រួតពិនិត្យដោយលិទ្ធិប្រជាធិបតេយ្យបានឡើយ។ ដូចដែលបានរៀបរាប់ពីខាងដើមមកថាទស្សនៈនៃ"អភិបាលកិច្ចល្អ" ជាធម្មតាត្រូវបានប្រើក្នុងការពិភាក្សាពីស្ថានភាពនិងការអភិវឌ្ឍន៍ប្រទេសនានា។ បណ្តាអ្នកពាក់ពន្ធ័ក្នុងគម្រោងនេះគឺជាអ្នកដែលមកពីរដ្ឋបាលមូលដ្ឋាន, សមាគមន៍ជាតិរបស់ពួកគេ និងអង្គការ សង្គមស៊ីវិលនានាដែលនឹងធ្វើការទាក់ទងនឹងរដ្ឋបាលមូលដ្ឋាន។ សំណួរសួរថា៖ តើអភិបាលកិច្ចល្អមានលក្ខណៈប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ឬនិយាយយ៉ាងខ្លីថាអភិបាលកិច្ចមូលដ្ឋានបែបប្រជាធិប-តេយ្យមានន័យយ៉ាងដូចម្តេច?

យើងអាចជឿជាក់ទទួលយកនូវការអធិប្បាយជាទូទៅថារដ្ឋបាលក្នុងខេត្តនិមួយៗ ទីក្រុងនានាឬ សាលាក្រុងនិមួយៗច្រើនហ្វឹកហាត់ដែលប្រព្រឹត្តិទៅក្នុងផ្លូវដែលមានប្រសិទ្ធិភាពនិងសក្តិសិទ្ធិសម្រាប់អត្ថប្រយោជន៍នៃការគ្រប់គ្រងជាតិសាសន៍ក្នុងតំបន់របស់ខ្លួន។ ប៉ុន្តែភាពខុសគ្នាដែលបានមកពីការពិភាក្សាទៅលើអភិបាលកិច្ចល្អតាមប្រទេសនិមួយៗ និងកំរិតនៃរដ្ឋបាលថ្នាក់ជាតិធ្វើឲ្យយើងមិនអាចស្មានថាផ្នែករដ្ឋបាលមូលដ្ឋានគឺជាអ្នកទទួលបន្ទុកនៃការងារគ្រប់គ្រងយើងមិនអាចស្មានមុនថាអង្គភាពរដ្ឋាភិបាលនៅមូលដ្ឋានគឺអ្នកដែលទទួលខុសត្រូវលើអភិបាលកិច្ចមានសេរីភាពដូចដៃគូរបស់ខ្លួននៅថ្នាក់ជាតិដើម្បីអភិបាលប្រកបដោយប្រសិទ្ធិភាព និងសក្តិសិទ្ធសម្រាប់ជាប្រយោជន៍ដល់ប្រជាជននៅតំបន់រៀងៗខ្លួននោះទេ។

សមត្ថភាពរបស់ពួកគាត់ក្នុងការអនុវត្តអាស្រ័យលើទំហំនៃអំណាចនិងសមត្ថកិច្ចពាក់ព័ន្ធនឹងការងារដោយឯករាជ្យពីការបញ្ជារនិងត្រួតត្រាពីសំណាក់ថ្នាក់លើ និងការចែកចាយពីធនធានមនុស្សនិងហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងការងារនិងសេវាសាធារណៈដែលត្រូវបានប្រគល់ឲ្យពួកគេតាមក្រិតក្រមរដ្ឋធម្មនុញ្ញ និងកតភាពការងារនៃប្រទេសនិមួយៗ។

សំណួរដែលសួរថាតើក្នុងចំងាយណាដែលរដ្ឋធម្មនុញ្ញនិងការបង្កើតច្បាប់ក្នុងប្រទេសនិមួយៗគោរពតាមគោលការណ៍បន្ទាប់បន្សំនិងផ្តល់ឲ្យបានច្រើនដូចដែលអាចធ្វើទៅបានក្នុងអំណាចនៃការសម្រេចចិត្តនិងការងារសាធារណៈលើកំរិតទាបបំផុតដែលអាចមានធៀបទៅនឹងកំរិតកាន់តែជិតជាមួយប្រជាជន ដែលនឹងធ្វើការកំណត់កត្តាសម្រាប់ឱកាសនៃការងារក្នុងអភិបាលកិច្ចល្អលើកំរិតមូលដ្ឋាន។ ភាពខុសគ្នាយ៉ាងសម្បើមរវាងប្រទេស៥នេះគឺការពាក់ពន្ធ័នឹងគម្រោងជាមួយនឹងសំណួរនៃស្ថានភាពវិមជ្ឈការរបស់រចនាសម្ពន្ធ័របស់រដ្ឋនិងបន្ទប់សម្រាប់រដ្ឋបាលមូលដ្ឋានខ្លួនឯងដែលមានព្រំដែនយ៉ាងតឹងរឹងសម្រាប់ទំហំដែលអាចអនុវត្តតាមបទពិសោធន៍នៃអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យពីតំបន់ក្នុងប្រទេសមួយទៅតំបន់ផ្សេងទៀតក្នុងប្រទេសដ៏ទៃទៀត។

## ២-២ អត្ថបទក្នុងបួនវិស័យដែលត្រូវបានជ្រើសរើសសម្រាប់ការផ្លាស់ប្តូរ បទពិសោធន៍ជោគជ័យ និងគំរូការអនុវត្តល្អនៅក្នុងគម្រោង

ការផ្លាស់ប្តូរការអនុវត្តល្អទៅលើអភិបាលកិច្ចមូលដ្ឋានបែបប្រជាធិបតេយ្យនៅក្នុងគម្រោងនេះត្រូវបានពង្រឹងផ្តោតលើបួនវិស័យដូចជា៖

- ការចូលរួមរបស់ប្រជាជន
- អភិបាលកិច្ចស្ថាប័ន
- បរិស្ថាននិងសេវាទីប្រជុំជន
- លើកកម្ពស់ការវិនិយោគ និងការគ្រប់គ្រងសារពើរពន្ធ

ធាតុសំខាន់ៗក្នុងគោលការណ៍ការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានដែលជាហេតុផលសម្រាប់ធ្វើការជ្រើសរើសយកបួនវិស័យនេះមាន៖

(1) ការចូលរួមរបស់ប្រជាជនគឺជាបញ្ហាផ្លូវកាត់មួយក្នុងបញ្ហាពហុវិស័យនានា។ សកម្មភាពផ្នែកអ្វីក៏ដោយក៏សេវា ឬការងាររបស់រដ្ឋបាលមូលដ្ឋានត្រូវតែពាក់ពន្ធ័ ហើយអត្ថិភាពនិងគុណភាពនៃការចូលរួមពីសំណាក់ប្រជាជននៅក្នុងមូលដ្ឋាននិមួយៗអាចជាកត្តាកំណត់មួយថាជា "សញ្ញានៃអភិបាលកិច្ចល្អ" សម្រាប់គ្រប់សកម្មភាព សេវាកម្ម ឬការងារទាំងនេះ។ ជាពិសេសជាមួយនឹងការណែនាំពីផលប្រយោជន៍របស់ប្រជាជាតិទាំងអស់រួមទាំងក្រុមជនងាយរងគ្រោះផងដែរ។ បន្ថែមពីនេះទៅទៀតការធ្វើអន្តរផ្ទេរនៃគំរូការអនុវត្តល្អក្នុងទំរង់នៃការចូលរួមរបស់ប្រជាជនអាចផ្តោតជាអត្ថិភាពមួយដែលជាការបង្កើតរបៀបថ្មីដូចដែលគំរូនិងទំរង់នានាតែងតែវិវត្តន៍មកពីវប្បធម៌ជាក់លាក់មួយនិងតកភាពនយោបាយ និងអាចមានភាពខុសគ្នាច្រើនរវាងប្រទេសផ្សេងគ្នាជាងបច្ចេកទេស ឬសមាសធាតុនៃរដ្ឋបាលរបស់អភិបាលកិច្ចមូលដ្ឋាន។

(2) អភិបាលកិច្ចស្ថាប័នគឺជាបញ្ហាកាត់ទទឹងមួយទៀត។ វាបន្ថែមធាតុខុសគ្នាផ្សេងៗទៀតដូចជាតម្លាភាព គណនេយ្យភាព ភាពដែលអាចជឿជាក់បាន និងប្រសិទ្ធិភាពនៃសកម្មភាពនិងការប្រតិបត្តិការងាររបស់រដ្ឋបាលមូលដ្ឋានក៏ដូចជាភាពច្បាស់លាស់ និងទំនាក់ទំនងការបង្កើតរចនាសម្ពន្ធ័និងគោលការណ៍ច្បាប់ទម្លាប់នានារបស់រដ្ឋបាលមូលដ្ឋាន។

និយាយតាមបែបសាមញ្ញៈ ឧទាហរណ៍ថានៅក្នុងអង្គភាពរដ្ឋាភិបាលមូលដ្ឋានមួយដែលមានរចនាសម្ព័ន្ធរដ្ឋបាលស្មុគស្មាញ និតិវិធីសំពីងសំពោង សមត្ថកិច្ចមិនច្បាស់លាស់ ឬត្រួតស៊ីគ្នា ក្រុមការងារឬច្បាប់ទំលាប់ទូលាយពេក ឬកំហិតខ្លាំងពេក នោះអភិបាលកិច្ចល្អនឹងមិនងាយធ្វើបានទេក្នុងការលើកស្ទួយសេវាសាធារណៈ ដំណើរការរដ្ឋបាល ការកាត់បន្ថយភាពក្រីក្រ ឬ ការអភិវឌ្ឍសេដ្ឋកិច្ច។ ដូច្នេះចាំបាច់ត្រូវដាក់បញ្ចូលបទពិសោធន៍ជោគជ័យមួយចំនួនស្តីពីអភិបាលកិច្ចស្ថាប័នទៅក្នុងគម្រោងផ្លាស់ប្តូរបទពិសោធន៍ល្អថ្នាក់តំបន់នេះ។

(3) បរិស្ថាននិងសេវាទីប្រជុំជាចំនុចសំខាន់បំផុតក្នុងនាមជាប្រជាជននៃជាតិសាសន៍នានានៅក្នុងពេលដែលការបំពុលបរិស្ថានធម្មជាតិរបស់យើងបានឈានដល់កំរិតប្រកាសអាសន្នហើយវានឹងកំពុងបង្កគ្រោះថ្នាក់ដល់សុខភាពរបស់មនុស្សទាំងអស់ ដោយមិនមែនតែចំពោះលទ្ធផលនៃវឌ្ឍនភាពរបស់បច្ចេកវិទ្យា និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប៉ុណ្ណោះទេ ជាពិសេសចំពោះប្រជាជនដែលមានរស់នៅក្នុងជីវភាពក្រីក្រ ដែលពុំមានលទ្ធភាពការពារខ្លួនប្រកបដោយប្រសិទ្ធិភាព ទោះបីនេះចំនុចសំខាន់សម្រាប់ជីវិតជំនាន់ក្រោយក៏ដោយ។ដូច្នេះហើយទើបនេះជាហេតុផលមួយដែលត្រូវបានអ្នកបង្កើតគម្រោងចាត់ទុកជាចំនុចដ៏សំខាន់សម្រាប់បញ្ចូលផ្នែកនេះទៅក្នុងគម្រោងហើយនឹងធ្វើការចែកចាយតាមរយៈការអភិវឌ្ឍន៍ និងការយល់ដឹងបន្ថែមតាមមាត្រដ្ឋាននិងដំណោះស្រាយដែលជោគជ័យក្នុងកំរិតមូលដ្ឋាននៅក្នុងវិស័យនេះដែលជាការកាន់តែជាការព្រួយបារម្ភនិងការទទួលខុសត្រូវរបស់រដ្ឋបាលមូលដ្ឋាន។

(4) លើកកម្ពស់ការវិនិយោគ និងការគ្រប់គ្រងសារពើរពន្ធនៅក្នុងផ្នែករដ្ឋបាលមូលដ្ឋានគឺជាធាតុដ៏សំខាន់នៃការគាំទ្រជាមួយទម្រង់បែបបទនៃការងារសម្រាប់ ការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចលើកំរិតមូលដ្ឋាន។ បទពិសោធន៍បានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនក្នុងការលើកកម្ពស់ជីវភាពខ្សត់ខ្សោយរបស់ប្រជាជន។ ឧទាហរណ៍តាមរយៈការធ្វើឲ្យប្រសើរឡើងនូវសេវាកម្មដែលទាក់ទងនឹងតម្រូវការមូលដ្ឋានដូចជា ការអប់រំ, សុខភាព, ទីជំរក ។ល។ ហើយនៅទីបំផុត អ្វីដែលទទួលបានមានតិចតួច ឬមិនទទួលបានជោគជ័យទាំងស្រុងតែម្តង ព្រោះតែការគ្រប់គ្រងសារពើពន្ធមិនល្អ ឬដោយសារក្នុងអាជីព ឬក្នុងការលើកស្ទួយការវិនិយោគមានភាពស័ក្តសិទ្ធិ។ តាមរយៈការដាក់បញ្ចូលប្រធានបទនេះទៅក្នុងការផ្លាស់ប្តូរការអនុវត្តល្អ ដើម្បីពង្រឹងនូវផលប៉ះពាល់នៃគម្រោងជាមួយនឹងគោលដៅជារួមនៃការសម្រាលភាពខ្សត់ខ្សោយដែលគម្រោងនឹងផ្តល់ឲ្យ។

## ២-៣ រចនាសម្ពន្ធ័នៃរដ្ឋាភិបាលមូលដ្ឋាន និង ការវិវត្តន៍នៃការកំណែទម្រង់វិមជ្ឈការក្នុង៥ប្រទេសនៃតំបន់អាស៊ីអាគ្នេយ៍

មានប្រទេសអភិវឌ្ឍន៍ជាច្រើនរួមទាំងប្រទេសនៅក្នុងតំបន់អាស៊ីផងដែរកំពុងព្យាយាមការផ្លាស់ប្តូរការអភិវឌ្ឍន៍ពីបែបមជ្ឈការទៅរកការអភិវឌ្ឍន៍បែបវិមជ្ឈការ។ ទំនោរទូទៅបែបនេះមានការពាក់ពន្ធ័ទៅនឹងទស្សនទានអភិវឌ្ឍន៍ ដែលមានលក្ខណៈប្រែលប្រួលជាប្រចាំ។ ទោះជាយ៉ាងនេះក្តីមានអ្នកនិពន្ធជាច្រើនលើកទស្សនៈថាវិមជ្ឈការគឺជាការសំរេចចិត្តផ្នែកនយោបាយដែលគេរំពឹងថានឹងទទួលបានភាពល្អប្រសើរផ្នែកសេដ្ឋកិច្ចនិងសុខមាលភាពសាធារណៈ។ ក្នុងស្ថានភាពនេះប្រទេសអភិវឌ្ឍន៍ទាំងនោះ កំពុងតែជួបនឹងបញ្ហាប្រឈមដើម្បីផ្តល់ជាគំនិតផ្តួចផ្តើមនានាសម្រាប់ភាពជោគជ័យកំណែទម្រង់វិមជ្ឈការ។ នៅក្នុងការពិភាក្សាកំរិតអន្តរជាតិ អ្នកនិពន្ធភាគច្រើនលើកឡើងនូវគំនិតថាវិមជ្ឈការដាក់កំហិតខ្លាំងពេកដល់ប្រទេសកំពុងអភិវឌ្ឍន៍។ ការពិតទៅវិមជ្ឈការមិនមែនគ្រាន់តែជាការកំណត់ប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាដំណើរការមួយ។ ដើម្បីវាយតម្លៃវិមជ្ឈការក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចាំបាច់ត្រូវឃ្លាំមើលការរៀបចំនានាដូចជាការធ្វើស្ថាប័នភាវូបនីយកម្មនៃគោលនយោបាយ សេចក្តីណែនាំនានានឹងការពង្រឹងសង្គមស៊ីវិល និងរដ្ឋបាលនៃរដ្ឋាភិបាលមូលដ្ឋាន។

ការតាក់តែងនិងកំណែទម្រង់វិមជ្ឈការមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ កំណែទម្រង់នេះបានទទួលឥទ្ធិពលពីនយោបាយសេដ្ឋកិច្ច វប្បធម៌សង្គមដែលកើតឡើងដោយការចែករំលែកអំណាចនិងប្រភេទវិមជ្ឈការ។ ខាងក្រោមនេះជាការរៀបរាប់សង្ខេបស្តីពីវិមជ្ឈការរចនាសម្ពន្ធ័នៃប្រទេសទាំង៥ក្នុងតំបន់អាស៊ីអាគ្នេយ៍។

### ២-៣-១ ប្រទេសកម្ពុជា

ប្រទេសកម្ពុជាដែលមានទំហំផ្ទៃដី១៨១០៣៥គីឡូម៉ែត្រការេ និងមានចំនួនប្រជាជន១៤លាននាក់គិតក្នុងឆ្នាំ២០១០។ ហើយជាប្រទេសដែលមានធ្លាប់ទទួលការគ្រប់គ្រងបែបមជ្ឈការដ៏តឹងរឹងក្រោយពេលដែលបង្កើតឡើងវិញនូវប្រពន្ធ័ប្រជាធិបតេយ្យបែបពហុបក្ស និងរដ្ឋធមនុញ្ញរាជានិយមក្នុងឆ្នាំ១៩៩៣។ រដ្ឋបាលនៅក្នុងខេត្តនិងស្រុក ជាចំណែកមួយរបស់រដ្ឋាភិបាលកណ្តាលតាមរយៈការគ្រប់គ្រងពីក្រសួងនានានិងថ្នាក់ជាតិ ហើយដែលមាន

អភិបាលមួយនៅពីលើសម្រាប់សម្របសម្រួល ដែលទទួលការតែងតាំងពីរដ្ឋាភិបាលកណ្តាល ប៉ុន្តែចុះបញ្ជីប្រាក់បៀវត្សន៍របស់ក្រសួងមហាផ្ទៃ។

ក្នុងក្របខណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ វិសហមជ្ឈការរបស់ថ្នាក់ជាតិ ការបោះឆ្នោតរបស់ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានកើតឡើងលើកទីមួយនៅក្នុងខែគុម្ភៈឆ្នាំ២០០២ ហើយដែលការបោះឆ្នោតដោយផ្ទាល់តាមរយៈប្រពន្ធ័គណបក្សនយោបាយនោះក្រុមប្រឹក្សាចំនួន ១៦២១នៅថ្នាក់ឃុំសង្កាត់នៅទូទាំងប្រទេសបានទទួលអណត្តិប្រាំឆ្នាំ។ ក្នុងកំរិតទាបបំផុតនៃរដ្ឋាភិបាល រដ្ឋបាលឃុំសង្កាត់ទាំងនោះមានសមត្ថកិច្ចតិចតួច ធនធានហិរញ្ញវត្ថុនិងធនធានមនុស្សដ៏មានកំរិត (មានតែស្មៀនឃុំសង្កាត់មួយប៉ុណ្ណោះ)ដែលដាក់ពង្រាយអោយធ្វើការនៅឃុំសង្កាត់ប៉ុន្តែផ្តល់បៀវត្សន៍ជាមន្ត្រីក្រសួងមហាផ្ទៃ។ ដោយការងារកាន់តែកើនឡើង ក្រុមប្រឹក្សាទាំងនោះត្រូវបានផ្តល់សិទ្ធិអំណាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាមួយចំនួន និងផ្តល់ប្រាក់ឧបត្ថម្ភដល់បុគ្គលិកទាំងនោះពីកញ្ចប់រដ្ឋបាលរបស់ខ្លួន។

ក្នុងជំហានទី២ដោយផ្អែកមួយផ្នែកទៅលើបទពិសោធន៍នៃការអនុវត្តគម្រោងសាកល្បងទីរួមខេត្តធំៗចំនួន២គឺបាត់ដំបងនិងសៀមរាប ដែលបានរៀបចំដោយអង្គការមូលនិធីខុនរ៉ាឌ ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃ និងរដ្ឋាភិបាលចំនួន២ពីសហភាពអឺរ៉ុប ច្បាប់រៀបចំអង្គការឆ្នាំ២០០៨បានផ្តល់រចនាសម្ពន្ធ័តាមបែបស្វ័យគ្រប់គ្រងនិងសមត្ថកិច្ចដល់រាជធានី ខេត្តចំនួន២៣ ទីក្រុងចំនួន២៦ ស្រុកចំនួន១៥៩ និងខណ្ឌនៅក្នុងរាជធានីភ្នំពេញចំនួន៨។ ក្រុមប្រឹក្សាត្រូវបានរៀបចំតាមរយៈការបោះឆ្នោតពីសំណាក់សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ (ដែលទទួលការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ) នៅក្នុងទីតាំងរបស់ខ្លួននិមួយៗតាមរយៈប្រពន្ធ័តំណាងគណបក្សនយោបាយ។ ការិយាល័យច្រកចេញចូលតែមួយ ការិយាល័យប្រជាពលរដ្ឋ និងនិតិវិធីធ្វើផែនការតាមបែបការចូលរួមគឺជាធាតុគន្លឹះសំខាន់ៗនៃរចនាសម្ពន្ធ័អភិបាលកិច្ចបែបលិទ្ធិប្រជាធិបតេយ្យដែលទើបតែបង្កើតថ្មីៗនេះក្នុងទីក្រុងអនុវត្តសាកល្បងមួយចំនួន។

ទោះជាយ៉ាងនេះក្តីអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះហើយដែលមានតួនាទីជាអ្នកដឹកនាំលក្ខណៈឯកភាពនៅតែទទួលការតែងតាំងពីរដ្ឋាភិបាលកណ្តាលដដែល ក្នុង

ពេលដែលការផ្ទេរអំណាច មុខងារ ធនធានទាំងថវិការនិងមនុស្ស រួមបញ្ចូលទាំងអំណាចក្នុងការប្រមូលពន្ធ បាននឹងកំពុងស្ថិតនៅដំណាក់កាលចាប់ផ្តើមប៉ុណ្ណោះ។

### ២-៣-២ ប្រទេសឥណ្ឌូនេស៊ី

ប្រទេសឥណ្ឌូនេស៊ី បានត្រូវបង្កើតឡើងជារដ្ឋឯករាជ្យទោលក្នុងឆ្នាំ១៩៤៥។ ប្រទេសជាប្រជុំកោះមួយនេះ មានកោះជាង១៧០០០ និងមានប្រជាជនប្រហែលជា២២២លាននាក់រស់នៅលើទំហំដី១៩១៩៤៤០គីឡូក្រឡា ក្នុង៣៣ខេត្ត ប្រជាជនឥណ្ឌូនេស៊ីត្រូវបានបែកចែកមិនស្មើគ្នាដែលប្រជាជនច្រើនបំផុតគឺរស់នៅលើកោះចាវ៉ា។

វិមជ្ឈការក្នុងប្រទេសឥណ្ឌូនេស៊ីចាប់ដំណើរការតាំងពីឆ្នាំ១៩៧៤ប៉ុន្តែវាមានលក្ខណៈវិសហមជ្ឈការដោយសារអំណាចតិចតួចណាស់ដែលត្រូវបានផ្ទេរទៅថ្នាក់ក្រោម បន្ទាប់មកដោយសារស្ថានភាពសេដ្ឋកិច្ចមិនស្មើគ្នា ការបរាជ័យក្នុងការអនុវត្តយុទ្ធវិធីពីក្រោមឡើងលើអំពើពុករលួយក្នុងការិយាល័យធិបតេយ្យនិងកលយុគ ផ្នែកថវិការក្នុងឆ្នាំ១៩៩៧ បានធ្វើឲ្យមានការផ្ទេរពីទម្រង់បែបមជ្ឈការទៅបែបវិមជ្ឈការកាន់តែច្រើនឡើងៗ។ វិមជ្ឈការពិតប្រាកដបានចាប់ផ្តើមតាំង១៩៩៩ជាមួយការអនុម័តច្បាប់៣២/១៩៩៩(ច្បាប់ស្វ័យភាពតាមតំបន់) និងបានដាក់អោយអនុវត្តឆ្នាំ២០០១។ ច្បាប់វិមជ្ឈការនេះបានផ្តល់សិទ្ធិអំណាចពេញលេញដល់រដ្ឋាភិបាលថ្នាក់ស្រុកនិងក្រុងដើម្បីក្លាយជាតំបន់មានស្វ័យភាព។ ក្នុងឆ្នាំ២០០៤ច្បាប់នេះត្រូវបានធ្វើវិសោធនកម្ម(ច្បាប់៣២/២០០៤)ដែលមានរួមបញ្ចូលការបោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យក្នុងថ្នាក់ស្រុកនិងអភិបាលថ្នាក់ខេត្ត។

ឥណ្ឌូនេស៊ីមានថ្នាក់រដ្ឋបាលចំនួន៣៖ ថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុកក្រុង។ រដ្ឋាភិបាលថ្នាក់ខេត្តត្រូវបានចាត់ទុកថាជាសេនាធិការរបស់រដ្ឋាភិបាលថ្នាក់កណ្តាលតាមតំបន់នានា ហើយដែលមានតួនាទីក្នុងការសម្របសម្រួលកិច្ចអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។បណ្តាភូមិជនបទ(ដេសា) គឺស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ស្រុក ចំណែកឯភូមិនៅតាមទីប្រជុំជនស្ថិតនៅក្រោមរដ្ឋាភិបាលក្រុង។

អភិបាលនៅថ្នាក់ស្រុកក្រុងត្រូវបានបោះឆ្នោតដោយផ្ទាល់គឺដូចគ្នាទៅនឹងប្រធានា-ធិបតី និងអនុប្រធានាធិបតីរបស់ប្រទេសផងដែរ។ ក្រោយពេលរបបផ្តាច់ការត្រូវបានបញ្ចប់

ក្នុងឆ្នាំ២០០៤ រដ្ឋាភិបាលថ្នាក់ជាតិបានរក្សាទុកនូវវិស័យការពារជាតិ កិច្ចការបរទេស កិច្ចការសាសនា យុត្តិធម៌ រូបិយវត្ថុ សេដ្ឋកិច្ច សារពើរពន្ធ និង មាក្រូសម្រាប់ជាមុខងាររបស់ខ្លួនហើយកិច្ចការដទៃរបស់រដ្ឋាភិបាលត្រូវបានប្រគល់ដល់រដ្ឋអំណាចថ្នាក់តំបន់និងថ្នាក់មូលដ្ឋាន។

ថ្វីត្បិតតែមុខងារសាធារណៈនៅមូលដ្ឋានភាគច្រើនត្រូវបានផ្ទេរទៅរដ្ឋាភិបាលមូលដ្ឋានជាមួយនឹងសិទ្ធិអំណាចក្នុងការចំណាយក៏ដោយ ក៏រដ្ឋាភិបាលមូលដ្ឋានគៀរគរចំណូលមិនបានច្រើននោះទេ។ ដូច្នេះការចំណាយសាធារណៈភាគច្រើននៅតែធ្លាក់ចុះមកថវិកាថ្នាក់ជាតិដដែល។ បន្ថែមពីនេះទៀតមានការត្រួតពិនិត្យដ៏តឹងរឹងទៅលើការអនុវត្តរបស់រដ្ឋាភិបាលថ្នាក់ក្រុងនិងស្រុក ពីសំណាក់រដ្ឋាភិបាលថ្នាក់ជាតិ ជាក់ស្តែងពីក្រសួងមហាផ្ទៃ ក្រសួងហិរញ្ញវត្ថុនិងក្រុមប្រឹក្សាសវនកម្មជាន់ខ្ពស់។ ក្នុងន័យបញ្ចៀសភាពខុសគ្នាទៅតាមតំបន់តាមច្បាប់៣៣/២០០៤ ស្តីពីវិមជ្ឈការសារពើរពន្ធ បានសំរេចទៅលើការផ្ទេរធនធានពីថវិកាជាតិទៅតាមតំបន់នានាដោយប្រើរូបមន្តពិសេសក្នុងន័យ ទូទាត់គំលាតថវិការនៃបណ្តាតំបន់ផ្សេងៗគ្នា។

ក្រោយរយះពេល៩ឆ្នាំនៃការអនុវត្តវិមជ្ឈការ ស្វ័យភាពតាមតំបន់នៅតែមិនទាន់មានពេញលេញនៅឡើយ។ រាល់លិខិតកតិយុត្តនានានៅថ្នាក់តំបន់ត្រូវបានបរាជ័យក្នុងការទាក់ទាញវិនិយោគទុន។ តំរូវការរបស់ប្រជាពលរដ្ឋ នៅមិនទាន់បានឆ្លុះបញ្ចាំងពេញលេញក្នុងផែនការអភិវឌ្ឍន៍នៅឡើយទេ។ ដើម្បីអោយកិច្ចការវិមជ្ឈការនៅឥណ្ឌូនេស៊ីអាចដំណើរការទៅមុខបានការខិតខំប្រឹងប្រែងបន្ថែមទៀតគួរផ្តោតទៅលើះការធ្វើស្ថាប័នភាវូបនីយកម្មគោលនយោបាយនិងសេចក្តីណែនាំនានាសម្រាប់អ្នកអនុវត្តផ្សេងៗគ្នានៅកំរិតរដ្ឋបាលខុសៗគ្នានិងការពង្រឹងអង្គការសង្គមស៊ីវិល ព្រមទាំងកម្មវិធីលើកស្ទួយសមត្ថភាពដល់អ្នកពាក់ពន្ធ័នៅក្នុងថ្នាក់រដ្ឋាភិបាលខុសៗគ្នាទាំងអស់ផងដែរ។

### ២-៣-៣ ហ្វីលីពិន

ហ្វីលីពីនជាប្រទេសប្រជុំដោយកោះជាង៧០០០ និងមានប្រជាពលរដ្ឋប្រហែល៩៦លាននាក់ រស់នៅលើទឹកដីទំហំ២៩៨១៧០គីឡូម៉ែត្រក្រឡា។ កិច្ចខិតខំប្រឹងប្រែងក្នុងការរៀបចំវិមជ្ឈការ ផ្នែកនយោបាយនិងស្វ័យភាពកម្ពុលដ្ឋានក្នុងប្រទេសនេះចាប់ផ្តើមពីឆ្នាំ១៨៩៨ ក្នុងពេលដែលប្រទេសនេះក្លាយជាសាធារណរដ្ឋលើកដំបូង និងក្រោមរដ្ឋធមនុញ្ញម៉ាឡូប៉ូស ទោះជាយ៉ាងនេះក្តី ការខិតខំប្រឹងប្រែងនេះផ្តោតតែទៅលើនយោបាយ និងរចនា

សម្ពន្ធ័របស់រដ្ឋបាលមូលដ្ឋាន ចៀសជាងការរៀបចំទម្រង់អភិបាលកិច្ចជុំកំភួន ដែលអនុញ្ញាតិអោយមានការផ្ទេរអំណាចនោះឡើយ។ នៅក្រោមច្បាប់សង្គ្រាមនិងក្រោមរបបផ្តាច់ការរបស់ប្រធានាធិបតីម៉ាកូស ក៏មានការខិតខំប្រឹងប្រែងទៅលើវិមជ្ឈការនោះផងដែរ ដែលរួមមានៈ ការបង្កើតរដ្ឋាភិបាលថ្នាក់តំបន់ ការិយាល័យថ្នាក់តំបន់របស់ស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍ថ្នាក់តំបន់ នឹងក៏ដូចជាការអនុម័ត អភិក្រមអភិវឌ្ឍតំបន់មានលក្ខណៈចំរុះ។ ទោះជាយ៉ាងនេះក្តីការផ្ទេរសិទ្ធិមិនមានការវិវត្តទៅមុខនោះទេ អំណាចក្នុងពេលដែលមានច្បាប់សង្គ្រាមនោះទេ បើទោះជាមានការកើនឡើងការចូលរួមប្រជាជនក្តី។

ក្នុងរដ្ឋធមនុញ្ញឆ្នាំ១៩៨៧ក្រោយពេលដែលមានបដិវត្តអំណាចរបស់ប្រជាជនប្រឆាំងនឹងរបបម៉ាកូស និងការដាក់ឡើងវិញនូវលទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍរចនាសម្ព័ន្ធរដ្ឋាភិបាលស្វ័យភាពនៅមូលដ្ឋាន និងរចនាសម្ព័ន្ធតាមបែបវិមជ្ឈការមួយ ត្រូវបានដាក់បញ្ចូល។ ក្នុងឆ្នាំ១៩៨១ ក្រមស្តីពីរដ្ឋាភិបាលមូលដ្ឋានដ៏លំអិតមួយត្រូវបានអនុមត័ ដែលផ្តល់ដល់ខេត្តជាចំបងដល់តួនាទី សម្របសម្រួលទីក្រុងនៅសមត្ថកិច្ចមួយចំនួនដ៏ច្បាស់លាស់នៅក្នុងវិស័យកសិកម្ម សុខាភិបាល សេវាសុខមាលភាព និងបរិស្ថាន។ ក្រមស្តីពីរដ្ឋាភិបាលមូលដ្ឋាននេះដោះស្រាយនូវបញ្ហាដែលមានច្រើនទស្សវត្សមកហើយនូវអ្វីដែលជាប្រពន្ធ័មជ្ឈការផ្នែករដ្ឋបាលនឹងនយោបាយ ហើយដែលការសំរេចចិត្តសំខាន់នានាត្រូវបានប្រមូលផ្តុំក្នុងទីក្រុងម៉ានីល ការដាក់អោយប្រើនូវក្រមនេះបានអនុញ្ញាតអោយមានការផ្ទេរការទទួលការខុសត្រូវការផ្តល់សេវាជាមូលដ្ឋានទៅដល់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន ដែលរួមបញ្ចូលទាំងមន្ត្រីបុគ្គលិកទ្រព្យសម្បត្តិសម្ភារៈ កម្មវិធីនិងគម្រោងនានាផងដែរ។ អភិបាលខេត្តក្រុងនិងក្រុមប្រឹក្សាត្រូវបានបោះឆ្នោតរៀងរាល់៣ឆ្នាំម្តង។ ទោះជាយ៉ាងនេះក្តីនៅកន្លែងដ៏ច្រើន ការបោះឆ្នោតត្រូវបានគ្រប់គ្រងដោយបក្ខសម្ពន្ធ័នឹងគ្រួសារដែលមានអំណាច។ ជិត២០ឆ្នាំក្រោយពេលដាក់អោយប្រើនូវក្រមនេះមានតែប្រហាក់ប្រហែល ខេត្តចំនួន៨០ បូរីចំនួន១៥០ និងទីក្រុងចំនួន១៥០០បានអនុវត្តក្រមនេះទូលំទូលាយ។ នេះរួមបញ្ចូលទាំងឱកាសដើម្បីប្រមូលពន្ធនិងកំរៃសេវាផ្ទាល់របស់ខ្លួនផង។ យ៉ាងណាក៏ដោយថវិកាភាគច្រើនរបស់រដ្ឋាភិបាលមូលដ្ឋាននៅតែត្រូវបានផ្តល់ដោយការផ្ទេរឬការឧបត្ថម្ភទុនពីរដ្ឋាភិបាលថ្នាក់ជាតិដដែល។ ដោយឡែកទៅទៀតចំណែកជាក់ស្តែងមូលនិធិនៅក្នុងថវិកាជាតិមានកំរិតទាប ជាងខ្លាំងណាស់ បើប្រៀបធៀបទៅនឹងតួរលេខព្រោះថាចំណូលថ្នាក់ជាតិច្រើនផ្នែកមិនត្រូវបានដាក់

បញ្ចូលចំនួនដែលត្រូវបែងចែកនេះទេ ហើយចំណែកដ៏ធំជាទូទៅត្រូវបានបាត់នូវតាមផ្លូវពីការិយាធិបតេយ្យនៅថ្នាក់ជាតិមករដ្ឋអំណាចមូលដ្ឋាន។ ក្នុងករណីនេះវិមជ្ឈការផ្នែកហិរញ្ញវត្ថុត្រូវបានជ្រើសរើសដើម្បីបង្កើតរចនាសម្ពន្ធ័រដ្ឋបាលមូលដ្ឋានដែលមានការទទួលខុសត្រូវស្ថាប័ន បែងចែកចំណូលផ្ទៃក្នុង បានបង្កើនធនធានហិរញ្ញវត្ថុរបស់បណ្តារដ្ឋាភិបាលមូលដ្ឋាននានាយ៉ាងច្រើន និងកាត់បន្ថយការពឹងផ្អែកផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលថ្នាក់ជាតិផងដែរ។

រដ្ឋបាលនៅថ្នាក់ទាបបំផុតគឺមានច្រើនជាងបួនម៉ឺនភូមិ(បារាងហ្កាយ)ស្ថិតនៅក្រោមបូរី និងទីក្រុងត្រូវបានដឹកនាំដោយកាពីតែន និងសមាជិកក្រុមប្រឹក្សារបស់ខ្លួនដែលអ្នកទាំងនោះត្រូវបានបោះឆ្នោត ដោយបុគ្គលព្រោះថាគណបក្សនយោបាយមិនត្រូវបានអោយចូលរួមបោះឆ្នោតទាំងនេះទេ។ ការចូលរួមប្រជាពលរដ្ឋក្នុងការធ្វើផែនការអភិវឌ្ឍតាមរយះកិច្ចប្រជុំនានាជាទៀងទាត់របស់ក្រុមប្រឹក្សាអភិវឌ្ឍរឬក៏សភានិងជាមួយការចូលរួមរបស់សង្គមស៊ីវិលនៅគ្រប់ថ្នាក់មូលដ្ឋានទាំងអស់ចាប់ផ្តើមពីភូមិរហូតដល់ថ្នាក់ខេត្តសន្មត់ឲ្យកើតឡើងនូវអេឡេម៉ង់ដ៏ខ្លាំងមួយនៃប្រជាធិបតេយ្យនៅមូលដ្ឋាននៅក្នុងប្រពន្ធ័។ ទោះជាយ៉ាងនេះក្តី(១) ការខ្វះមូលនិធិសម្រាប់អភិវឌ្ឍន៍នៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលមូលដ្ឋាន(២) ការគ្មានការផ្សារភ្ជាប់គ្នាការធ្វើផែនការនិងការសំរេចចិត្តរបស់ក្រុមប្រឹក្សាជាមួយស្ថាប័នផែនការអភិវឌ្ឍថ្នាក់ជាតិដែលមានចរិការសន្ទឹកសន្ទាប់ និង(៣) ការបង្កើតអោយមានមូលនិធិពិសេសសម្រាប់គម្រោងដែលស្នើរឡើងដោយគម្រោងព្រឹទ្ធសភាសម្រាប់តំបន់មណ្ឌលបោះឆ្នោតរបស់ខ្លួនបានបង្ករអោយរដ្ឋាភិបាលមូលដ្ឋានខ្សោយ ឧទាហរណ៍នៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័សម្រាប់ការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចជាដើម។

### ២-៣-៤ ប្រទេសថៃ

រាជាណាចក្រថៃឡង់មានប្រជាជនប្រហែល៦៧លាននាក់និងទឹកដី៥១៤០០០គីឡូម៉ែត្រក្រឡា។ មកទល់នឹងទស្សវត្ស១៩៩០ ប្រទេសដែលមានរដ្ឋធម្មនុញ្ញបែបរាជានិយមបានស្ថិតនៅក្នុងរបបមជ្ឈការមួយដល់ជ្រាលជ្រៅ ហើយដែលមាន៧៦ខេត្ត ប្រហែល៨០០រដ្ឋបាលស្រុក (តាំបូន)ប្រហែល៨០០០រដ្ឋាភិបាលទីក្រុង និងអនុស្រុក និងប្រហែល៧០០០០ភូមិ(មូលបាន)។

ដំណើរការវិមជ្ឈការក្នុងទស្សវត្សឆ្នាំ១៩៩០បានកើតឡើងជួនពេលគ្នាជាមួយនឹងដំណើរការប្រជាធិបតេយ្យនៃនយោបាយប្រទេសថៃដែលចាប់ផ្តើមឡើងជាមួយនឹងហេតុការណ៍ "ព្រឹត្តិការណ៍បង្ហូរឈាមខែឧសភា" ក្នុងឆ្នាំ១៩៩២ ដែលធ្វើឲ្យបញ្ចប់របបយោធានិងវិលត្រលប់មកនយោបាយបែបគណបក្សនយោបាយវិញ។ វិមជ្ឈការបានក្លាយទៅជាបញ្ហាដ៏ចំបងក្នុងការបោះឆ្នោតនាខែកញ្ញា១៩៩២។ ចុងក្រោយរដ្ឋធមនុញ្ញនាឆ្នាំ១៩៩២បានបញ្ជាក់ថាវិមជ្ឈការជាគោលនយោបាយគ្រឹះរបស់ជាតិ នឹងត្រូវបានកែសំរួលនៅឆ្នាំ១៩៩៩។កំណែទម្រង់នេះមានគោលបំណងជំរុញអោយមានស្វយ័ភាពមូលដ្ឋាននិងការចូលរួមរបស់ប្រជាពលរដ្ឋ។

រចនាសម្ពន្ធ័របស់ប្រទេសថៃចែកចេញជា៣៖ រដ្ឋបាលកណ្តាល រដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលស្វ័យភាព(ក្រមច្បាប់រដ្ឋបាល១៩៩១) ។ ប្រព័ន្ធថ្នាក់កណ្តាលមានរួមបញ្ចូលក្រសួងនិងនាយកដ្ឋាននានា រដ្ឋបាលថ្នាក់មូលដ្ឋានមានរួមបញ្ចូលខេត្តនិងស្រុក ហើយនិងមានការប្លុកបញ្ចូលគ្នារវាងស្ថាប័នជំនាញនានារបស់ក្រសួងនាយកដ្ឋានកណ្តាលប្រពន្ធ័ស្វ័យភាពមានលក្ខណៈខុសប្លែកពីរដ្ឋបាលថ្នាក់កណ្តាលនិងមូលដ្ឋាន ប្រព័ន្ធនេះរួមបញ្ចូលដោយរដ្ឋអំនាចមូលដ្ឋានចំនួនប្រហែល៨០០០នៅទូទាំងប្រទេស និងត្រូវបានធ្វើចំណាត់ថ្នាក់ជាបួនប្រភេទ: (១)អង្គការចាត់តាំងរដ្ឋបាលនៅថ្នាក់ខេត្ត (២)ទីក្រុងឬទេសាបាន(បូរីទីប្រជុំជននឹងអនុក្រុង) (៣)អង្គការរដ្ឋបាលតាំបូននិងទីបូនគឺទីក្រុងពិសេស(ទីក្រុងបាងកកនិងប៉ាតាយា)។ រដ្ឋអំណាចមូលដ្ឋានទាំងនេះត្រូវបានដាក់នៅក្រោមការតាមដានត្រួតពិនិត្យរបស់អភិបាលខេត្តនិងមន្ត្រីថ្នាក់ស្រុកដែលជាមួយនឹងក្រសួងមហាផ្ទៃ អ្នកទាំងនោះមានសិទ្ធអំណាចអនុម័តផែនការថវិកាប្រចាំឆ្នាំ លិខិតគតិយុត្តិនៅមូលដ្ឋានរំលាយក្រុមប្រឹក្សានៅមូលដ្ឋាននិងបណ្តេញសមាជិកក្រុមប្រឹក្សានៅមូលដ្ឋាន ។ រដ្ឋាភិបាលថៃបានចាប់ផ្តើមរៀបចំផែនការវិមជ្ឈការ និងនិតិវិធីដំណើរការក្នុងឆ្នាំ១៩៩៩ ។វិមជ្ឈការគួរតែមិនត្រឹមតែរួមបញ្ចូលតែការផ្ទេរសេវារដ្ឋបាលប៉ុណ្ណោះទេប៉ុន្តែត្រូវតែមានការផ្ទេរធនធានមនុស្សនិងហិរញ្ញវត្ថុដែលពាក់ព័ន្ធផងដែរ។ ច្បាប់ស្តីពីវិមជ្ឈការ១៩៩៩បានកំណត់រយៈពេលដំណើរការវិមជ្ឈការបួនឆ្នាំជាគោលការណ៍ដែលអាចពន្យាពេលរហូតដល់១០ឆ្នាំ។ទាំងអស់រួមមាន៥០នាយកដ្ឋានថ្នាក់កណ្តាលនិង សេវាចំនួន២៨០ឆ្នាំដែលស្ថិតនៅក្នុងបរិបទ ផែនការវិមជ្ឈការហើយមាន១៨០មុខងារដែលបាននឹងកំពុងស្ថិតនៅដំណើរការផ្ទេរបើគិតមកដល់ដើមឆ្នាំ២០០៧។ អត្រា

ចំណូលរបស់រដ្ឋអំណាចមូលដ្ឋានមានចំនួន២៤,១ភាគរយនៃចំណូលសរុបរបស់រដ្ឋាភិបាល នៅក្នុងឆ្នាំ២០០៦ ដែលស្ថិតនៅក្រោមអត្រាគោលដៅក្នុងឆ្នាំដដែលនោះហើយដែលបានកំណត់រហូតដល់៣៥ភាគរយ។

វិមជ្ឈការក្នុងប្រទេសថៃឡង់បានដាក់ចេញនូវការយកចិត្តទុកដាក់វិសមមាត្រទៅលើការពង្រឹងសមត្ថភាពដល់រដ្ឋាភិបាលមូលដ្ឋានឬរដ្ឋអំណាចមូលដ្ឋាន។ កំណែទម្រង់នេះពុំបានប្រព័ន្ធរដ្ឋាភិបាលពេញលេញនោះទេដែលនាំអោយប្រពន្ធ័នេះស្ថិតនៅដដែល។ វិមជ្ឈការប្រទេសថៃមានគោលបំណងចំនួន៣៖ (១)បង្កើតឡើងនូវរចនាសម្ព័ន្ធ ពីថ្នាក់របស់រដ្ឋអំណាចមូលដ្ឋាន (២) ការអនុវត្តការតាមដានពីក្រោមឡើងលើដោយមានការចូលរួមពីសហគមន៍ (៣) ដាក់បញ្ចូលអោយមានការបោះឆ្នោតដោយផ្ទាល់ថ្នាក់ដឹកនាំនៃរដ្ឋអំណាចមូលដ្ឋាន រួមបញ្ចូលទាំងដំណើរការធ្វើសេចក្តីសម្រេចចិត្តមានភាពច្បាស់លាស់ជាងមុន។

### ២-៣-៥ ប្រទេសវៀតណាម

សាធារណរដ្ឋប្រជាមានិតវៀតណាម ស្ថិតនៅជាយឧបទ្វិបឥណ្ឌូចិនក្នុងតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ត្រូពិក ប្រទេសនេះមានរយះចំងាយ១៦៥០គីឡូម៉ែត្រដែលមានទំហំលើសពី៣៣០០០គីឡូម៉ែត្រក្រឡានិងមានឆ្នេរចំងាយ៣២០០គីឡូម៉ែត្រ និងព្រំដែនគោកចំងាយ៣៧៣០គីឡូម៉ែត្រហើយមានប្រជាជនប្រហែល៨៦លាននាក់។

ក្នុងឆ្នាំ១៩៨៦សមាជលើកទី៦របស់គណបក្សគម្មុយនីសវៀតណាមបានដាក់ចេញនូវកម្មវិធីកំណែទម្រង់សេដ្ឋកិច្ចដ៍មានមហិច្ឆតាមួយឈ្មោះថា ការផ្លាស់ប្តូរថ្មី(ដូយមើយ) បើកទ្វារអោយមានការវិនិយោគនិងទេសចរណ៍បរទេសនិងធ្វើឲ្យប្រទេសវៀតណាមដើរនូវផ្លូវកំណែរទម្រង់ទីផ្សារសេរី។ ចំណងការទូតជាមួយនឹងសហរដ្ឋអាមេរិក ក៏បានចាប់ផ្តើមជាធម្មតាវិញក្នុង១៩៩៥ ស្របពេលដែលប្រទេសវៀតណាមឡើងជាសមាជិកពេញសិទ្ធិរបស់សមាគមអាស៊ាន។ វៀតណាមក៏ត្រូវបានបញ្ចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)ក្នុង២០០៦។

យោងតាមរដ្ឋធម្មនុញ្ញ១៩៩២ រដ្ឋាភិបាលគឺជាអង្គការចាត់តាំងខ្ពស់បំផុតរបស់ប្រទេស និងជាស្ថាប័ននិតិប្រតិបត្តិនៃសភាជាតិ ។ រដ្ឋាភិបាលនាពេលនោះបានដឹកនាំដោយនាយក

រដ្ឋមន្ត្រីង្វៀនតាន ឌុង និងឧបនាយករដ្ឋមន្ត្រីចំនួន៥នាក់ដែលតែងតាំងដោយសភាជាតិ រដ្ឋាភិបាលប្រនិបត្តិអំណាចនិតិប្រតិបត្តិតាមរយៈក្រសួងចំនួន២២ និងភ្នាក់ងារពាក់ពន្ធ័នឹងក្រសួងចំនួន២២ទៀត វៀតណាមត្រូវបានបែងចែករដ្ឋបាលរបស់ខ្លួនជា៥ធំៗ៖ ទីក្រុងហានូយ ហូជីមិញ (ពីមុនហៅថាស័យហ្គូន) ហៃហ្វុង ដាណាង និងទីក្រុងកិនធើ និងខេត្តចំនួន៥៨ ទីក្រុងទាំង៥និងខេត្តចំនួន៥៨នោះត្រូវទទួលខុសត្រូវដោយផ្ទាល់ជាមួយរដ្ឋបាលកណ្តាល ថ្វីត្បិតតែជាក់ស្តែងទីក្រុងនិងខេត្តនីមួយៗមានស្វ័យភាពដោយឡែករបស់ខ្លួនផងដែរ។ ខេត្តមានរួមបញ្ចូលស្រុកនិងឃុំជនបទ ព្រមទាំងទីរួមខត្តនិងទីប្រជុំជននានា។ ទីក្រុងធំៗទាំង៥ និងបណ្តាទីរួមខេត្តមួយចំនួនមានរួមបញ្ចូលស្រុកដែលមានលក្ខណៈជាទីប្រជុំជននិងសង្កាត់ ឃុំនៅជនបទនៅសង្កាត់ទីប្រជុំជន បែងចែកជាឃុំនិងក្រុម។

ផែនការអភិវឌ្ឍដែលមានលក្ខណៈបែបចូលរួមនិងតម្លាភាពក៏ដូចជាការធ្វើផែនការថវិការ គឺជាកត្តាដ៏សំខាន់សម្រាប់ការផ្តល់សេវាសាធារណៈដែលមានប្រសិទ្ធិភាពនៅវៀតណាម។ សារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋនិងតម្លាភាពក្នុងការធ្វើផែនការអភិវឌ្ឍសេដ្ឋកិច្ចត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលវៀតណាម។ គោលការនេះត្រូវដាក់បញ្ចូលទៅក្នុងយុទ្ធសាស្រ្តអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច(២០០១ដល់២០១០)ក៏ដូចជាក្នុងយុទ្ធសាស្រ្តសម្រាប់ការកាត់បន្ថយភាពក្រីក្រនិងការរីកចំរើន២០០២។ គោលការណ៍នេះក៏ជាប្រធានបទនៃគោលនយោបាយនៃរដ្ឋាភិបាលមួយចំនួន ជាពិសេសអនុក្រិត្យលេខ២៩ (ថ្ងៃទី១១ឧសភា១៩៩៨) ហើយក្រោយមកបានកែសម្រួលជាអនុក្រិត្យលេខ៧៩ (ចុះថ្ងៃទី៧កក្កដា២០០៣) ស្តីពីការអនុវត្តប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានក្នុងកំរិតឃុំ។ អនុក្រិត្យលេខ៧៩នេះផ្តល់នូវការណែនាំលំអិតស្តីពីសិទ្ធិរបស់ប្រជាពលរដ្ឋចូលរួមដោយផ្ទាល់ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ជាមួយនឹងអនុក្រិត្យលេខ៧៩រដ្ឋាភិបាលបានដាក់ចេញនូវអនុក្រិត្យ៨៨ស្តីពីការរៀបចំនិងគ្រប់គ្រងសមាគមន៍នានាហើយដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៏សង្គមស៊ីវិលនៅប្រទេសវៀតណាម។ ដើម្បីលើកស្ទួយប្រជាធិបតេយ្យបន្ថែមទៀតស្តីពីការធ្វើអោយប្រសើរឡើងលើបញ្ហាប្រជាពលរដ្ឋនៅថ្នាក់ឃុំត្រូវបានធ្វើឡើងជាបន្តបន្ទាប់។ ក្នុងខែមករា២០០៧ គណកម្មការអចិន្ត្រៃយ៍របស់សភាជាតិ បានពិភាក្សាសម្រាប់ការអនុម័ត លើច្បាប់ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋ ។ សេចក្តីព្រៀងអនុក្រិត្យស្តីពីការចូលរួមរបស់ប្រជាជនដែលអនុវត្តនៅថ្នាក់ឃុំសង្កាត់និងទីប្រជុំជននានាបានដាក់ចេញនូវការ

បង្ហាញជាសាធារណៈស្តីពីផែនការដីធ្លីការរៀបចំផ្ទះនិងសំណង់ បរិយាយពីតួនាទីនិងមុខងាររបស់បុគ្គលិកនិមួយៗនៅថ្នាក់ឃុំនិងតួនាទីរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តគម្រោង និងតាមដានសកម្មភាពអភិវឌ្ឍន៍ និងដាក់ចេញនូវយន្តការដើម្បីផ្តល់មតិត្រលប់និងបោះឆ្នោតលើសេចក្តីទុកចិត្ត។ អនុក្រិត្យស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋនិងច្បាប់ស្តីពីប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានបានត្រូវអនុម័តនិងដាក់អោយប្រើប្រាស់ចាប់ពីថ្ងៃទី១ខែកក្កដាឆ្នាំ២០០៧។

# ជំពូកទី៣

### ប្រធានបទ

# ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត

### -ទស្សនាននិងការអនុវត្តន៍ល្អនានា-

ដោយ លោក មិន មុនី និងបណ្ឌិត Sosmena

# ជំពូកទី៣

## ប្រធានបទ: ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត

### មាតិកា


៣-១ ការចូលរួមរបស់ប្រជាជន: ទស្សនៈគោល

៣-១-១ ប្រវត្តិ

៣-១-២ ការបែកចែកអំណាចEmpowerment (Why and How)

៣-១-៣ ការធ្វើស្ថាប័នភាវូបនីយកម្មការចូលរួមរបស់ប្រជាជន

៣-២ ការអនុវត្តន៍ល្អ ស្តីពីការចូលរួមរបស់ប្រជាជននៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ (ករណីសឹក្សា)

៣-២-១ ការចូលរួមរបស់សហាគមន៍ក្នុងការកែលំអរតំបន់ផ្ទះសម្បែងនៅ ទីក្រុង វិញ ប្រទេសវៀតណាម

៣-២-២ ភាពជាដៃគូររវាងវិស័យសាធារណ: ឯកជន និងប្រជាជននៅ សង្កាត់ទួលសង្កែប្រទេសកម្ពុជា

៣-២-៣ ការធ្វើគោលនយោបាយតាមបែបសហាគមន៍ដឹកនាំ និងវិមជ្ឈការនៅទីក្រុង កងកេន ប្រទេសថៃឡង់

៣-៣ កត្តាទាមទារសម្រាប់ការអនុវត្តតាមការអនុវត្តល្អនេះ

# ៣ ប្រធានបទទី១៖ ការចូលរួមរបស់ប្រជាពលរដ្ឋ

## ៣-១ ការចូលរួមរបស់ប្រជាជន: ទស្សនៈគោល

### ៣-១-១ ប្រវត្តិ

ទស្សនៈនៃការរួមចំណែករបស់ប្រជាជនមិនមែនជាគំរូថ្មីទេ ប៉ុន្តែវាបានកើតមានឡើងតាំងពីសម័យក្រិចបុរាណមកម្ល៉េះ។ ទស្សនៈនៃច្បាប់របស់ប្រជាជន រឺ *Demokratos* ត្រូវបានចាក់ឬសក្នុងបេះដូងរបស់ប្រជាជនពីប្រព័ន្ធច្បាប់អាតែនបន្ទាប់ពីCleisthenes ជារបាយការណ៍មួយរបស់ពួកអាតែននាំឲ្យមានការបះបោរទំលាក់របបអប្បជនាធិបតេយ្យហើយបង្កើតប្រព័ន្ធប្រជាធិបតេយ្យក្នុងអាតែន។ យ៉ាងណាមិញការបរាជ័យនៃប្រព័ន្ធនយោបាយរបស់ពួកអាតែនក្នុងសង្គ្រាម Peloponnesian នាំឲ្យមាន ទស្សនៈមួយនេះត្រូវបានពង្រឹងឡើងវិញក្នុងការសសេររបស់ Plato និង Aristotle ដែលជាអ្នកប្រឆាំងនឹងការផ្តល់អំណាចដល់ប្រជាពលរដ្ឋក្នុងការដឹកនាំ។ គតិបណ្ឌិតក៏បានធ្វើឲ្យមានការប្រែក្លាយទៅជាការយល់ដឹងទូទៅ អំពីបញ្ហានៃអភិបាលកិច្ចប្រជាធិបតេយ្យ។

ការរិះគន់ទៅលើទស្សនៈនេះត្រូវបានធ្វើតាម ដោយអ្នកដឹកនាំនៃសតវត្សទី២១ខ្លះ។ ឧទាហរណ៍លោក Fareed Zakaria, បានប្រឆាំងថា បញ្ហានៃអភិបាលកិច្ចប្រជាធិបតេយ្យសម័យថ្មី កើតចេញមកពីការទាញថ្លុយគ្នា រវាងការបែងចែកអាជីវកម្មរបស់រាជរដ្ឋាភិបាល ទៅឲ្យអ្នកមានជំនាញ (ការប្រគល់សិទ្ធិតាមបែបប្រជាធិបតេយ្យ) និង ការពិគ្រោះយោបល់ជាមួយអ្នកបោះឆ្នោត ក្នុងការសម្រេចចិត្តក្នុងរដ្ឋាភិបាល (ប្រជាធិប-តេយ្យផ្ទាល់)។ គាត់បានបន្តទៀតថាវាមានបញ្ហាទាក់ទងនឹងការផ្តល់ប្រជាធិបតេយ្យផ្ទាល់ច្រើនពេក។

ដើម្បីសង្កត់ធ្ងន់លើចំនុចនេះ គាត់បានលើកយកបញ្ហា ដែលសហរដ្ឋអាមេរិកបានជួបប្រទះនៅក្នុងរដ្ឋកាលីផរញ៉ានៅពេលដែលខ្លួនមិនអាចបញ្ជូនបន្តនូវវិធានការពន្ធដារថ្មី ដោយ

គ្មានការយល់ស្របពីអ្នកបោះឆ្នោត។ វាបានបង្កើតឲ្យមានស្ថានភាពដែលហិរញ្ញវត្ថុ និង គោលនយោបាយរដ្ឋត្រូវពឹងផ្អែកទៅលើអ្នកបោះឆ្នោត ដែលទទួលឥទ្ធិពលពីក្រុមបញ្ចុះបញ្ចូលដែលមានប្រាក់ច្រើនសម្រាប់បញ្ជោតគំនិតសាធារណជនឲ្យយល់ស្របនិងប្រឆាំងនឹងសំណើរណាមួយ។ ផ្ទុយទៅវិញ បានលើកឡើងនូវករណីនៃការរៀបចំគណៈកម្មការនៃគណៈកម្មាធិការអ៊ឺរ៉ុប (EC) មន្ទីរផ្នែកប្រតិបត្តិការនៃសមាជិកទាំង២៧ របស់រដ្ឋនានានៃសហព័ន្ធអ៊ឺរ៉ុបថា ទោះបីជាការសម្រេចចិត្តរបស់ពួកគេប៉ះពាល់ស្ថានភាព រស់នៅរបស់សហគមន៍ជនជាតិអ៊ឺរ៉ុប សមាជិកគណៈកម្មាធិការនៃECមិនត្រូវបានបោះឆ្នោតជ្រើសរើសឡើយ ប៉ុន្តែត្រូវបានចាត់តាំង ពីសំណាក់ប្រទេសជាសមាជិកEurozone ប៉ុណ្ណោះ។

ករណីទាំងពីរ ដែលប្រជាជនមានមុខងារខុសៗគ្នា ក្នុងការសម្រេចចិត្តរបស់រដ្ឋាភិបាល គឺជាចំណុចផ្ទុយគ្នាពីរនៃវិសាលគមនយោបាយប្រជាធិបតេយ្យ។ នៅចំណុចមួយប្រជាជនអាចធ្វើសំណើរពិគ្រោះ ពិភាក្សា យល់ស្រប និង ច្រានចោលគោលនយោបាយ រដ្ឋាភិបាលមួយចំនួនដោយសេរី។ ដោយឡែកនៅចំណុចមួយផ្សេងទៀត ក្រុមអ្នកជំនាញ បច្ចេកទេសកំពុងពេញចិត្តនឹងអភ័យឯកសិទ្ធិ ដែលទទួលពីការជះឥទ្ធិពលនៃក្រុមអ្នកប្រកាន់បក្សពួកដែលក្រុមនោះបានផ្តល់សិទ្ធិអំណាចក្នុងការធ្វើការសម្រេចចិត្តទៅលើគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ការកត់សំគាល់វិជ្ជមានមួយ បានបង្ហាញថាវាមានការចូលរួមរួចមកហើយក្នុងស្ថានភាពទាំងពីរទោះបីជាមានភាពខុសគ្នាលើវិសាលភាព និង ទំលាប់។ ការសំខាន់ដែលគួរយកមកពិចារណាគឺ វត្តមាននៃភាពស្របច្បាប់នៃប្រជាធិបតេយ្យក្នុងប្រព័ន្ធសម្រេចចិត្ត។ បើមិនដូច្នោះទេភាពជោគជ័យនៃការអនុវត្តន៍គោលការណ៍ទាំងនោះនឹងត្រូវបានរារាំង។

ចាប់តាំងពីដំណាក់កាលដំបូងនៃរលកប្រជាធិបតេយ្យនិយមលើកទី៣ ដំណើរអភិវឌ្ឍន៍នៃអភិបាលកិច្ចលទ្ធិប្រជាធិបតេយ្យក្នុងភូមិភាគអាស៊ីអាគ្នេយ៍ (SEA)ត្រូវបានចាប់មានឡើង។ មានកំណែទម្រង់ជាច្រើនត្រូវបានអនុវត្តន៍តាមតំបន់។ ប្រទេសមួយចំនួនដូចជាហ្វីលីពីន ឥណ្ឌូនេស៊ី ថៃ កម្ពុជា និង វៀតណាមបានធ្វើជាស្ថាប័នភាវូបនីយកម្ម ការចូលរួមរបស់ប្រជាជនទៅក្នុងរចនាសម្ព័ន្ធនៃការសម្រេចចិត្តរបស់រដ្ឋាភិបាល។

ក្នុងចំណោមប្រទេសទាំងអស់ ដែលបានរៀបរាប់ខាងលើ ប្រទេសហ្វីលីពីន មានភាពលម្អិតជាងគេ ដោយសារតែកំណែទម្រង់នៃអភិបាលកិច្ចប្រជាធិបតេយ្យ ត្រូវបានចាប់ផ្ដើមឡើងភ្លាមៗ ប្រព្រឹត្តតាមដោយការបង្កើតឡើងវិញនៃភាពមជ្ឈការរបស់រដ្ឋរួមហ្វីលីពីន។ នៅខណៈពេលដែលមិនអនុវត្តន៍រចនាសម្ព័ន្ធសហព័ន្ធនិយម លទ្ធផលនៃអភិបាលកិច្ចមូលដ្ឋានក្នុងឆ្នាំ ១៩៩១ បានហុចឱកាសឲ្យការផ្ទេរសិទ្ធិអំណាចគ្រប់គ្រងជាតិទៅឲ្យអភិបាលកិច្ចមូលដ្ឋានច្រើនជាន់ថ្នាក់។ វិមជ្ឈការនេះបានផ្ដល់សិទ្ធិអំណាចទៅឲ្យអង្គភាពរដ្ឋាភិបាលមូលដ្ឋានដែលកាលពីមុនឡើយពឹងផ្អែកទៅលើបញ្ជារបស់ទីក្រុងម៉ានីល "Imperial Manila"។ វិមជ្ឈការនេះបានផ្ដល់ឱកាសផលគំនិតឆ្នៃប្រឌិត និងការរៀបចំឲ្យមានក្រុមប្រតិបត្តិការ អង្គភាពរដ្ឋាភិបាលមូលដ្ឋានដើម្បីអភិវឌ្ឍន៍តំបន់របស់ពួកគេកុំឲ្យមានការជ្រៀតជ្រៀកពីសំណាក់រាជរដ្ឋាភិបាល។ ជាងនេះទៅទៀត ចាប់តាំងពីមានការបញ្ជាក់ឡើងវិញនូវការចូលរួមយ៉ាងច្រើនពីប្រជាជនក្នុងការរៀបចំគោលការណ៍នៅក្នុងរដ្ឋបាលមូលដ្ឋានឆ្នាំ ១៩៩១ ការចូលរួមពីអង្គភាពសង្គមស៊ីវិលជាច្រើនត្រូវបានពង្រឹងក្នុងការធ្វើផែនការដូចគ្នា។

ប្រទេសជិតខាងឥណ្ឌូនេស៊ី ដែលជារដ្ឋលទ្ធិប្រជាធិបតេយ្យដ៏ធំជាងគេនៅអាស៊ីអាគ្នេយ៍ មានកំណែទម្រង់មួយថ្មីបានរៀបចំឡើងក្រោយពីការដួលរំលំនូវរបបស៊ូហាតូ Suharto ដោយសារបញ្ហាសេដ្ឋកិច្ចនៅអាស៊ី។ នៅក្នុងឆ្នាំ១៩៩៩ សភាប្រជាជនឥណ្ឌូនេស៊ី ឬហៅកាត់ថាMPRបានអនុម័តច្បាប់២២/១៩៩៩ ស្ដីពីរដ្ឋាភិបាលមូលដ្ឋាន(ឬច្បាប់ស្វ័យភាព) ដែលត្រូវបានអនុវត្តន៍ក្នុងឆ្នាំ២០០១។ ច្បាប់នេះផ្ដល់នូវការយកចិត្តទុកដាក់យ៉ាងពិសេសទៅលើវិមជ្ឈការដោយអំណាចរបស់រាជរដ្ឋាភិបាលត្រូវបានបញ្ជូនទៅអ្នកគ្រប់គ្រងតាមខេត្ត និងសាលាក្រុង។ ច្បាប់នេះត្រូវបានចាត់ទុកជាវិមជ្ឈការដ៏ធំបំផុត ដោយក្នុងនោះមានបុគ្គលិកជាង២លាននាក់ត្រូវបានបញ្ជូនទៅធ្វើការនៅតាមស្រុក និងក្រុង ច្បាប់វិមជ្ឈការនេះគឺជាភាពអស្ចារ្យមួយសំរាប់ប្រទេសនេះដែលធ្លាប់តែចាត់ទុកបណ្ដាខេត្តនានាមិនសំខាន់ និងមិនមែនជាស្ថាប័នស្វ័យយ័តនៃរដ្ឋការអភិវឌ្ឍ និងការរួបរួម។ កំណែទម្រង់ក្នុងឆ្នាំ ១៩៩៩នេះ គឺជាភាពបង្កឲ្យមានស្វ័យតភាព និងជាកត្តាលីករមួយសម្រាប់ការអភិវឌ្ឍ។ តាមពិតច្បាប់នេះបានពង្រឹងអំណាចរាជរដ្ឋាភិបាលក្នុងប្រទេសឥណ្ឌូនេស៊ី ក៏ប៉ុន្តែ ច្រើនជាង៨០%នៃថវិការបស់រដ្ឋាភិបាលមូលដ្ឋានពឹងផ្អែកទៅលើការផ្ទេរពីរដ្ឋាភិបាលថ្នាក់ជាតិ។ ច្បាប់ស្វ័យយ័តនេះត្រូវ

បានពិនិត្យឡើងវិញក្នុងឆ្នាំ២០០៤ ហើយការផ្លាស់ប្តូរមួយគួរឲ្យកត់សំគាល់នោះគឺអភិបាលស្រុក និងចៅហ្វាយក្រុងត្រូវបានបោះឆ្នោតដោយផ្ទាល់ពីប្រជាជន។

យ៉ាងណាមិញវិមជ្ឈការរបស់រាជាណាចក្រថៃមានដំណើរការខុសគ្នា ប្រសិនបើប្រៀបធៀបជាមួយនឹងប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី។ តាមប្រពៃណី រាជរដ្ឋាភិបាលមូលដ្ឋានរបស់ប្រទេសថៃ ត្រូវបានចាត់ទុកជាអាវុធរបស់រដ្ឋាភិបាលកណ្តាល។ ទោះបីជារដ្ឋាភិបាលមូលដ្ឋានមានភាពពេញនិយមក្នុងការកាន់កាប់តួនាទីនេះក្តី ពួកគេមានមហិច្ឆតាតិចតួចបំផុតសម្រាប់ស្វ័យតភាព។ ទោះបីជាមានបញ្ហានេះក៏ដោយ គំនិតផ្តួចផ្តើមនៃវិមជ្ឈការនេះបានធ្វើឲ្យមានការប្រើប្រាស់អភិក្រមពីលើទៅ ដែលដឹកនាំដោយក្រសួងមហាផ្ទៃ។ ក៏ប៉ុន្តែដូចគ្នាទៅនឹងករណីជាច្រើនដែល កើតឡើងនៅក្នុងប្រទេសអាស៊ីដទៃទៀត ប្រវត្តិនៃអភិបាលកិច្ចមជ្ឈការបានសាយភាយ គ្រប់ទីកន្លែងដោយរដ្ឋាភិបាលកណ្តាលមានអំណាចជាងក្នុងផ្នែកជាច្រើននៃអភិបាលកិច្ច។ ច្បាប់ស្តីពីគម្រោងរបស់ទីក្រុង និងបរិស្ថានធ្វើឲ្យរដ្ឋាភិបាលមូលដ្ឋានមានវិធានការងាយស្រួលក្នុងការដឹកនាំការអភិវឌ្ឍគម្រោងនោះ។ ទង្វើនេះត្រូវបានធ្វើស្ថាប័នភាវូបនីយកម្មក្នុងរដ្ឋធមនុញ្ញឆ្នាំ១៩៩៧ដែលទាមទារឲ្យបង្កើនការចំណែកប្រាក់ចំណូល និងចំណាយរបស់រដ្ឋាភិបាលមូលដ្ឋាន បែងចែកប្រភពចំណូលច្រើនជាងមុនទៅឲ្យរដ្ឋបាលមូលដ្ឋាន លើកតម្កើងស្វ័យភាពសារពើពន្ធមូលដ្ឋាន និងការពិនិត្យឡើងវិញនូវប្រព័ន្ធនៃការផ្ទេរ អន្តររដ្ឋាភិបាលក្នុងការផ្តល់ការអនុញ្ញាតបន្ថែមដើម្បីងាយស្រួលក្នុងការវាយតម្លៃ។ យោងតាមផែនការនិងនិតិវិធីវិមជ្ឈការក្នុងឆ្នាំ១៩៩៩ រដ្ឋាភិបាលមូលដ្ឋាននឹងត្រូវរាប់បញ្ចូលយ៉ាងហោចណាស់ ២០% នៃថវិការបស់រាជរដ្ឋាភិបាលជាតិមកដល់ឆ្នាំសារពើពន្ធ២០០១ (តុលា២០០០–កញ្ញា២០០១) នៅពេលបញ្ចប់ផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិលើកទី៨ និងយ៉ាងហោចណាស់ ៣៥%មកដល់ឆ្នាំសារពើពន្ធ ២០០៦ (តុលា២០០៥–កញ្ញា២០០៦) នៅពេលបញ្ចប់ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិលើកទី៩។

ចំណែកឯប្រទេសកម្ពុជាវិញ គំនិតផ្តួចផ្តើមវិមជ្ឈការទើបតែចាប់ផ្តើមនៅឆ្នាំ ២០០២ ប៉ុណ្ណោះនៅពេលដែលប្រទេសនេះធ្វើជាម្ចាស់ផ្ទះរបស់អង្គការអាស៊ានប្តូរវេន ដែលក្នុងខណៈពេលដែលមានការបោះឆ្នោតនៅថ្នាក់ឃុំនៅខែកុម្ភះ២០០២។ ការបោះឆ្នោតជ្រើសរើសមន្ត្រីឃុំនេះជាទូទៅបានធ្វើឲ្យមានប្រជាធិបតេយ្យ គ្រប់ជាន់ថ្នាក់នៃរដ្ឋាភិបាលនៅកម្ពុជា។ វាបាន

ធ្វើឲ្យមន្ត្រីរាជការដែលបានជាប់ឆ្នោតចាប់ផ្តើមអនុវត្ត នូវភាពទទួលខុសត្រូវរបស់ខ្លួន និងបានអនុវត្តនូវផែនការអភិវឌ្ឍនានារបស់មូលដ្ឋានដោយគ្មានការកៀបសង្កត់ពីគណបក្សនយោបាយដែលកាន់អំណាចនៅរដ្ឋាភិបាលកណ្តាល។ ទំនួលខុសត្រូវនេះដែរ ក៏កើតឡើងចំពោះមន្ត្រីដែលធ្វើការជាមួយឃុំសង្កាត់នានា។ ឃុំរឺសង្កាត់នេះហើយ គឺជាថ្នាក់ក្រោមបំផុតដែលមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយប្រជាជនក្នុងប្រទេសកម្ពុជា។ ការអនុវត្តគំនិតផ្តួចផ្តើមដើម្បីបង្កើតស្វ័យភាពនេះខុសប្លែកយ៉ាងខ្លាំងពីរបបនយោបាយមជ្ឈការជ្រៅរបស់រដ្ឋាភិបាលមកដល់ការបោះឆ្នោតឆ្នាំ២០០២ នៅពេលដែលមន្ត្រីនៅក្នុង ផ្នែករដ្ឋបាលមូលដ្ឋានដែលត្រូវបានជ្រើសរើសដោយមន្ត្រីក្នុងរដ្ឋាភិបាលកណ្តាល ហើយដែលជាអ្នកជ្រើសរើសចេញពីអ្នកគាំទ្រគណបក្សខ្លួននៅតាមខេត្ត។

ប្រទេសវៀតណាមបានចាប់ផ្តើមអនុម័តច្បាប់រដ្ឋធម្មនុញ្ញនៃឆ្នាំ១៩៩២ ដោយបានរៀបចំរដ្ឋាភិបាលមូលដ្ឋានសារឡើងវិញ ដែលពីមុនលក្ខណៈមជ្ឈការយ៉ាងជ្រាលជ្រៅ ដោយគ្រប់ប្រព័ន្ធរដ្ឋាភិបាលទាំងអស់ត្រូវបានគ្រប់គ្រងដោយអង្គការចាត់តាំងនៃក្រុមប្រឹក្សាប្រជាជនរដ្ឋធម្មនុញ្ញឆ្នាំ១៩៩២ ចាត់ទុករដ្ឋាភិបាលមូលដ្ឋានជាអង្គភាពផ្នែករដ្ឋបាល។ រដ្ឋាភិបាលមូលដ្ឋានរបស់វៀតណាមមានក្រុមប្រឹក្សាដ៏ពេញនិយមមួយហៅថា ក្រុមប្រឹក្សាប្រជាជន ដែលត្រូវបានចាត់ទុកជាអង្គការមូលដ្ឋាននៃរដ្ឋអំណាច។ ក្រុមប្រឹក្សាប្រជាជននេះមិនត្រឹមតែគណនេយ្យភាពចំពោះប្រជាជនមូលដ្ឋានប៉ុណ្ណោះទេ ថែមទាំងចំពោះអង្គការរដ្ឋដទៃទៀតផងដែរ។ ចំណែកឯអ្នកប្រតិបត្តិការដែលហៅថាលក្ខណៈកម្មាធិកាប្រជាជន ចាត់ទុកជាអង្គការមូលដ្ឋាននៃរដ្ឋបាលរដ្ឋ ដោយទទួលខុសត្រូវលើការប្រតិបត្តិឯកសារនានាដែលរៀបចំដោយអង្គការរដ្ឋថ្នាក់ខ្ពស់ ក៏ដូចជាទទួលខុសត្រូវលើដំណោះស្រាយផ្សេងៗរបស់ក្រុមប្រឹក្សាប្រជាជន ។

កំណែទម្រង់នេះត្រូវបានផ្តើមគំនិតស្របពេលជាមួយគ្នាដែលវៀតណាម ធ្វើអន្តរកាលពីសេដ្ឋកិច្ចរដ្ឋកណ្តាលមកជាសេដ្ឋកិច្ចទីផ្សារ។ ការបង្កើតឡើងនៃហេដ្ឋារចនាសម្ព័ន្ធរដ្ឋមូលដ្ឋាននេះកើតឡើងដោយការផ្លាស់ប្តូរសង្គមដែលជាលទ្ធផលនៃការអភិវឌ្ឍ និង ការរីកចំរើន។ វាបានផ្តល់ឲ្យមានគំនិតផ្តួចផ្តើមនៅមូលដ្ឋានសម្រាប់ការអភិវឌ្ឍដើម្បីរីកចំរើនក្នុងការណែនាំពីរដ្ឋកណ្តាល។

### ៣-១-២ ការបែកចែកអំណាចEmpowerment (Why and How)

ការចូលរួមរបស់ប្រជាជនក្នុងតំបន់គឺជាករណីដែលគួរឲ្យកត់សំគាល់ដោយសារប្រទេសអាស៊ីអាគ្នេយ៍ទាំងនេះបានចែករំលែកបទពិសោធន៍ស្រដៀងគ្នាស្ទើរតែទាំងអស់ ការគ្រប់គ្រងបែបពីរដ្ឋមជ្ឈការទាំងស្រុង ឬរាជាណាចក្រមជ្ឈការ។ ក្រោយពីការបំបាត់រដ្ឋទាំងនោះ តាមរយៈបដិវត្តន៍ដូចក្នុងករណីប្រទេសវៀតណាម និងឥណ្ឌូនេស៊ី រឺដោយការស្នងតំណែងដូចប្រទេសហ្វីលីពីន កម្ពុជា និងថៃ ដែលអ្នកបន្តតំណែងរដ្ឋាភិបាលបានទទួលយកវិធីសាស្ត្រអភិបាលកិច្ចតាមបែបមជ្ឈការ។ ប្រជាជនត្រូវបានចាត់ទុកជាអ្នកគ្មានការវិនិច្ឆ័យត្រឹមត្រូវ ដើម្បីជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់រដ្ឋាភិបាលឡើយ។ ខុសពីប្រទេសប្រជាធិបតេយ្យទំនើប ទស្សនៈនៃជីវិតរស់នៅបែបសមាគមរបស់ពួកគេក្នុងសតវត្សទី១៨ ប្រជាជនអាមេរិកមិនត្រូវបានចាប់អារម្មណ៍ដោយរដ្ឋឡើយ។ ផលពិបាកក្នុងការទទួលយកស្មារតីរួបរួមគ្នាតាមបែបសមាគម មានការទាក់ទងទៅនឹងទំនោរមជ្ឈការ នៃអំណាចក្នុងផ្នែកសំខាន់ៗនៃប្រវត្តិសាស្ត្ររបស់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។

ខុសពីប្រវត្តិសាស្ត្ររបស់ប្រទេសបារាំងក្នុងសតវត្សទី ១៨ នៅពេលរដ្ឋធ្វើបដិវត្ត ហើយធ្វើការរៀបចំឲ្យមានប្រសិទ្ធិភាពឡើងវិញនូវធនធានរបស់រដ្ឋដើម្បីធ្វើសង្គ្រាមជាមួយប្រទេសអ៊ឺរ៉ុបជិតខាង បទពិសោធន៍មជ្ឈការរបស់ប្រទេសអាស៊ីអាគ្នេយ៍ ទាំងនេះមិនបានធ្វើឲ្យមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងនោះទេ។ ដោយឡែក Joel Migdal បានហៅមជ្ឈការនៃការិយាល័យរដ្ឋក្នុងប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងប្រាំថា កោះនៃអភិបាលកិច្ច ជាស្ថានភាពដែលអំណាចរបស់រដ្ឋភាគច្រើនស្ថិតក្រោមសង្គម ដោយធ្វើឲ្យផ្នែកខ្លះនៃអភិបាលកិច្ចមានលទ្ធភាពប្រតិបត្តិតាមគោលដៅ។ នៅប្រទេសហ្វីលីពីន ឧទាហរណ៍ដ៏ល្អនោះគឺធនាគារកណ្តាលនៃប្រទេសហ្វីលីពីន BangkoSentralngPilipinas ដែលនៅតែទទួលបានប្រសិទ្ធិភាពក្នុងរយៈពេលក្រោយEDSA ក្នុងខណៈអង្គភាពមួយចំនួនធំនៃរដ្ឋាភិបាលស្ថិតក្រោមឥទ្ធិពលរបស់អ្នកដឹកនាំនយោបាយមូលដ្ឋាន និងថ្នាក់ជាតិ។

ស្ថានភាពនេះបញ្ជាក់ថាមិនត្រឹមតែមានការខ្វះខាតនូវការចូលរួមពីសំណាក់ប្រជាជននោះទេ ថែមទាំងមានបន្ថែមនូវកំលាំងខាងវប្បធម៌នៃភាពពឹងផ្អែកអស់អ្នកបោះឆ្នោតទៅលើអ្នកដឹកនាំរបស់ខ្លួន។ ហេតុដូច្នេះហើយអ្នកដឹកនាំមូលដ្ឋានមានភាពពឹងផ្អែកទាំងស្រុងទៅលើ

សប្បុរសធម៌ពីអ្នកដឹកនាំថ្នាក់ជាតិដែលបង្កើតឲ្យមានទំនាក់ទំនងអតិថិជនឧបត្ថម្ភ ឬបក្សពួក។ នេះគឺជាកំណត់សំគាល់ដ៏ល្អបំផុតក្រោយពីសង្គ្រាមនៅហ្វីលីពីនបានបញ្ចប់នៅពេលដែលអ្នកដឹកនាំថ្នាក់ជាតិធ្វើការបញ្ចុះបញ្ចូលដើម្បីមានការគាំទ្រខាងផ្នែកនយោបាយ ក៏ប៉ុន្តែពួកគេបែរជាបោះបង់ចោលសកម្មភាពក្នុងការពង្រឹងអំណាចនយោបាយនៅក្នុងតំបន់ទៅវិញ។ រដ្ឋសន្តិវង្សមានអំណាចទាំងស្រុងនៅពេលនោះ។ ករណីមួយទាក់ទងនឹងបញ្ហានេះគឺជាករណីមួយនៅពេលដែលកុលសម្ព័ន្ធ Ampatuan clan ដែលបានកាន់អំណាចនៅMaguindanao អស់រយៈពេល៨០ឆ្នាំមុន។ កុលសម្ព័ន្ធនេះ ត្រូវបានដកចេញក្រោយពីមានការសំលាប់រង្គាលពីក្រុមមួយដែលដឹកនាំដោយអភិបាល Datu Unsay Ampatuan, ដែលបានសម្លាប់ជនស៊ីវិលនិងអ្នកសារពត៌មានជាង៥០នាក់។ នេះត្រូវបានចាត់ទុកជានយោបាយហឹង្សាដ៏សាហាវបំផុតដែលបានកើតមានឡើងនៅហ្វីលីពីនចាប់តាំងពីមានការស្តារឡើងវិញនូវលទ្ធិប្រជាធិបតេយ្យ។

ជាលទ្ធផលហេតុការណ៍នៃអំណាចមជ្ឈការ សក្តានុពលភាពរបស់ប្រជាជនក្នុងការចូលរួមចំណែកទៅក្នុងអភិបាលកិច្ចត្រូវបានកំហិតតាមសិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀងផ្សេងៗដែលបានដាក់កំណត់ឲ្យពួកគេដោយរដ្ឋាភិបាល។ ដោយឡែកគោលនយោបាយទាំងនេះតែងតែមើលរំលងល័ក្ខខ័ណ្ឌមូលដ្ឋានធ្វើឲ្យបទពិសោធន៍នៃអភិបាលកិច្ចក្រៅប្រទេសក្លាយជាការឈ្លានពានដល់សហគមន៍មូលដ្ឋាន។ ក្នុងការបាត់បង់ធាតុចូលរួមសំខាន់ៗពីអ្នកចូលរួមមូលដ្ឋាន សហគមន៍មូលដ្ឋានមិនសូវយល់ពីសារៈសំខាន់នៃគោលនយោបាយមួយចំនួន។ ដូច្នេះមិនមានអារម្មណ៍ពាក់ពន្ធ័នឹងកម្មសិទ្ធិនៃធនធានគោលនយោបាយឡើយ។

បទពិសោធន៍របស់ប្រទេសឥណ្ឌូនេស៊ីក្នុងការផ្តល់សិទ្ធិអំណាច ត្រូវបានកើតឡើងក្នុងបរិបទនៃប្រពៃណីដ៏យូរអង្វែងនៃការអភិវឌ្ឍរបស់រដ្ឋាភិបាល។ ទស្សនៈទានទាំងអស់នៃ(គោលការណ៍ទាំងប្រាំ) ប្រជាធិបតេយ្យភាពត្រូវបានដាក់ជាជំនឿនៃការអភិវឌ្ឍរដ្ឋាភិបាល។ នៅពេលដែលរបបSuharto ត្រូវបានដួលរលំដោយបញ្ហាខាងក្រៅ (វិបត្តិហិរញ្ញវត្ថុនៅអាស៊ីនិងវិបត្តិទីម័រខាងកើត) និងខាងក្នុងជាច្រើន(ការធ្លាក់ចុះនៃសេដ្ឋកិច្ច ភាពចលាចលរបស់ប្រជាជននិងការគំរាមគំហែងពីការធ្លាក់ចុះសេដ្ឋកិច្ច) បញ្ហាកំណែទម្រង់រដ្ឋមិនត្រូវបានហាមឃាត់ទៀតទេ។ ក៏ប៉ុន្តែសហព័ន្ធនិយម ដែលធ្លាប់ជាបំរាមសម្រាប់អធិបតីនយោបាយច្បាប់វិមជ្ឈការ

ឆ្នាំ១៩៩៩ មានភាពល្អប្រសើរដោយសារបានទទួលស្គាល់តម្រូវការពិតប្រាកដសម្រាប់ស្វ័យភាពមូលដ្ឋាន។ លើកលែងរយៈពេល១០ឆ្នាំនៃអភិបាលកិច្ចមជ្ឈការ តម្រូវការសម្រាប់ស្វ័យភាពមូលដ្ឋានមានភាពចាំបាច់សម្រាប់បើកការជួបពិភាក្សានៅចុងឆ្នាំនៃរបបSuharto។ មានការព្រួយបារម្ភពីការផ្តល់អំណាចទៅឲ្យខេត្តដែលអាចឲ្យពួកគេមិនចុះសម្រុងនឹងប្រទេសជាតិ។ ការអភិវឌ្ឍដែលជួយឲ្យមានការចូលរួមរបស់ប្រជាជនទៀតនោះគឺតួនាទីនៃប្រធានប្រតិបត្តិការមូលដ្ឋាន ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាជនដោយផ្ទាល់។

ដោយឡែក ច្បាប់មុននៃរដ្ឋាភិបាលមូលដ្ឋានក្នុងឆ្នាំ១៩៩៩ បានបញ្ជាក់ថាមិនមានទំនាក់ទំនងឋានានុក្រមរវាងរដ្ឋាភិបាលខេត្ត និងមូលដ្ឋានឡើយព្រោះរដ្ឋាភិបាលមូលដ្ឋានជារដ្ឋាភិបាលស្វ័យត។ ច្បាប់ថ្មីក្នុងឆ្នាំ២០០៤ បានប្រគល់អំណាចមុនខ្លះៗត្រលប់ទៅឲ្យរដ្ឋាភិបាលខេត្តវិញ។ តាមទស្សនៈរដ្ឋាភិបាលខេត្តធ្វើការជាអ្នកសម្របសម្រួលក្នុងករណីដែលមានសហប្រតិបត្តិការក្នុងខេត្ត ការអភិវឌ្ឍន៍ខេត្ត រួមទាំងការសម្របសម្រួលខាងក្រៅខេត្តផងដែរ។ ច្បាប់នេះបានបង្ហាញពីការត្រួតពិនិត្យ និងរៀបចំផែនការអភិវឌ្ឍ ការរៀបចំផែនការ និងការប្រើប្រាស់ដីធ្លី ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាល ការអប់រំ បញ្ហាសង្គម ពលកម្ម បរិស្ថាន ការតាំងទីលំនៅ និងផ្ទះសំបែង សេវាស៊ីវិល ការវិនិយោគ និងកិច្ចការដទៃទៀតដែលមិនអាចសម្រេចបានដោយរដ្ឋាភិបាលក្រុង។

នៅប្រទេសថៃ តម្រូវការសម្រាប់កំណែទម្រង់ត្រូវបានធ្វើឡើងដោយមានការប្រឆាំងពីរដ្ឋាភិបាលមជ្ឈការ។ តាមរយៈឱកាសសម្រាប់ការចូលរួមដែលត្រូវបានផ្តល់ឲ្យតំបន់នៃផែនការទីក្រុង និងការរៀបចំបរិស្ថាន អ្នកចូលរួមមូលដ្ឋានអាចទុកស្នាមទៅលើផែនការអភិវឌ្ឍជាតិ ដែលត្រូវបានដាក់ពីថ្នាក់លើ ឬរដ្ឋាភិបាលមជ្ឈការ។ ថ្វីបើមានភាពមជ្ឈការខ្ពស់នៃរដ្ឋថៃក៏ដោយ ក៏មានវិធានការជាច្រើនដើម្បីបង្កើនអភិបាលកិច្ចមូលដ្ឋានដែរ។ រាល់ច្បាប់ធម្មនុញ្ញដែលត្រូវបានប្រកាសឲ្យប្រើតាំងពីឆ្នាំ១៩៧៥មានជំពូកនិយាយពីស្វ័យភាពមូលដ្ឋាន។ ដោយឡែកបញ្ញត្តិទាំងនេះមានបរិយាយយ៉ាងទូលាយហើយទាមទារឲ្យរដ្ឋាភិបាលមូលដ្ឋាន ផ្អែកលើគោលបំណងរបស់អ្នកតាំងទីលំនៅមូលដ្ឋាន និងឆ្លុះបញ្ចាំងគោលការនៃស្វ័យអភិបាលកិច្ចតាមរយៈការបោះឆ្នោតជាសាធារណៈ សម្រាប់ប្រធាននៃរដ្ឋាភិបាលមូលដ្ឋាន និងការបោះឆ្នោតផ្ទាល់នៃក្រុមប្រឹក្សា។

ច្បាប់រដ្ឋធម្មនុញ្ញនៃឆ្នាំ១៩៩៧មានភាពច្បាស់លាស់ច្រើនជាង ទៅលើស្វ័យភាពមូលដ្ឋាន ដែលត្រូវការការបង្កើតឡើងនៃគណៈកម្មាធិការវិមជ្ឈការជាតិ(NDC) និងការពិនិត្យឡើងវិញទៅលើច្បាប់ទាក់ទងនឹងបញ្ហាស្វ័យភាពមូលដ្ឋាន។ គម្រោងវិមជ្ឈការ និងច្បាប់នីតិវិធីនៃឆ្នាំ១៩៩៩បង្ហាញពីយន្តការទាំងនេះសម្រាប់បង្កើនស្វ័យភាពមូលដ្ឋាន និងត្រូវបានបន្ថែមដោយច្បាប់បុគ្គលិកអាជ្ញាធរមូលដ្ឋាននៃឆ្នាំ១៩៩៩។ គណៈកម្មាធិការស្តីពីការគ្រប់គ្រងបុគ្គលិកថ្នាក់ក្រុងរបស់ក្រសួងមហាផ្ទៃ មុនដំបូងកំណត់ប្រាក់បៀវត្ស និងការឡើងឋានៈរបស់បុគ្គលិករដ្ឋ។ មាត្រាទី៧៨(២៨២–២៩០) នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៧ តម្រូវឲ្យការតែងតាំងវិមជ្ឈការជាគោលការគ្រឹះនៃរដ្ឋាភិបាល និយមន័យនៃផែនការនិងនិតិវិធីសម្រាប់វិមជ្ឈការនៅក្នុងច្បាប់ដាច់ដោយឡែក និងការបង្កើតនៃគណៈកម្មាធិការវិមជ្ឈការ។ ច្បាប់ផែនការនិងនិតិវិធីវិមជ្ឈការក្នុងឆ្នាំ១៩៩៩ បានធ្វើឲ្យរដ្ឋាភិបាលមូលដ្ឋានទទួលបានជំនួយពីភ្នាក់ងារ និងក្រសួងរដ្ឋាភិបាលនៅដើមឆ្នាំ ២០០១។

ស្របពេលនេះដែរ ការបោះឆ្នោតថៅសង្កាត់ទូទាំងប្រទេសកម្ពុជាក្នុងឆ្នាំ២០០២ បានបន្ថយការត្រួតត្រារបស់គណបក្សនយោបាយថ្នាក់ជាតិ និងអភិបាលកិច្ចប្រជាធិបតេយ្យក្នុងឃុំសង្កាត់។ វិមជ្ឈការបានចូលរួមចំណែកក្នុងការកើនឡើងនៃទំនុកចិត្តទៅលើក្រុមប្រឹក្សាឃុំ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តមូលដ្ឋាន។ ឃុំនិមួយៗបានអនុវត្តគម្រោងមួយចំនួន ដែលភាគច្រើនទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធជនបទ ហើយជាទូទៅក៏បានបង្កើតឱកាសក្នុងផ្នែកជាច្រើនដូចជាកសិកម្ម។ លើសពីនេះវាហាក់ដូចជាអ្នកតាំងទីលំនៅមូលដ្ឋានអាចចូលទៅកាន់ទីផ្សារមន្ទីរពេទ្យ និងសេវាដទៃទៀតបានប្រសើរជាងមុន រួមទាំងការដឹកជញ្ជូនទំនិញ និងសេវាបានងាយស្រួល។ មានឧទាហរណ៍ជាច្រើនសម្រាប់ការរួមចំណែកក្នុងហេដ្ឋារចនាសម្ព័ន្ធ និងទៅលើការងារសេវារដ្ឋបាល ដូចជាការចុះឈ្មោះស៊ីវិល។

ខែមករា ឆ្នាំ២០០១ ច្បាប់សំខាន់ៗ២បានបញ្ជាក់ពីកំណែទម្រង់នយោបាយ។ ច្បាប់ដំបូងគឺជាច្បាប់លើការបោះឆ្នោតក្រុមប្រឹក្សាឃុំ និង ទីពីរគឺច្បាប់លើការគ្រប់គ្រង និងរដ្ឋបាលកិច្ចនៃឃុំនិងសង្កាត់។ ច្បាប់ទាំងនេះផ្តល់ដល់ប្រជាពលរដ្ឋ និងអ្នកដែលត្រូវបានបោះឆ្នោតជ្រើសរើស (ក្រុមប្រឹក្សាឃុំ។ល។) នូវអំណាចច្រើនជាងមុនក្នុងការសម្រេចចិត្តជាសាធារណៈ។ ក្នុងឆ្នាំ២០០២ ការបោះឆ្នោតក្រុមប្រឹក្សាឃុំដំបូងបានកើតឡើង។ ការបង្កើត

ឡើងនៃរចនាសម្ព័ន្ធការគាំទ្រ និង យន្តការ បានចាប់មានឡើងដោយរួមមានការបង្កើតអោយមានគណកម្មាធិការជាតិគាំទ្រឃុំសង្កាត់ លេខាធិការដ្ឋាន នាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្នុងក្រសួងមហាផ្ទៃ មូលនិធិឃុំសង្កាត់ សម្រាប់រដ្ឋបាល និងការអភិវឌ្ឍន៍ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋានក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ល។ ដោយអនុលោមជាមួយនឹងមុខងារតំណាង និងអណត្តិនៃភ្នាក់ងារជាតិ រចនាសម្ព័ន្ធនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទបានបង្កើតឡើងនៅគ្រប់ខេត្ត។

នៅក្នុងប្រទេសវៀតណាម ក្រៅពីរចនាសម្ព័ន្ធនយោបាយមជ្ឈការរបស់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩២ រដ្ឋាភិបាលបានទទួលស្គាល់សារៈសំខាន់នៃគំនិតផ្តួចផ្តើមរបស់ប្រជាជនមូលដ្ឋាន។ នេះបានធ្វើឲ្យមាននូវសនិទាកម្មនៃរចនាសម្ព័ន្ធរដ្ឋាភិបាលមូលដ្ឋាន ហើយធ្វើឲ្យមានការឆ្លើយតបទៅលើតម្រូវការរបស់ប្រជាជន នៅខណៈពេលដែលពួកគេកំពុងស្ថិតក្រោមការដឹកនាំរបស់រដ្ឋាភិបាលជាតិ។ ក្រុមប្រឹក្សាប្រជាជន នៅគ្រប់ថ្នាក់ត្រូវបានជ្រើសរើសតាមការបោះឆ្នោតដោយផ្ទាល់ និងដោយសម្ងាត់។ អាយុសម្រាប់មានសិទ្ធិបោះឆ្នោតគឺ ១៨ឆ្នាំ។ ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាប្រជាជន ប្រព្រឹត្តទៅរយៈពេល៥ឆ្នាំម្តង។ រីឯច្បាប់សម្រាប់ការជ្រើសរើសនេះ កំណត់ចំនួនកៅអីសម្រាប់តំបន់និមួយៗ ដោយយោងតាមចំនួនប្រជាជនស្ថិតក្នុងតំបន់នេះ។ អ្នកបោះឆ្នោតទាំងអស់នឹងត្រូវបែងចែកទៅតាមមណ្ឌលបោះឆ្នោតនិមួយៗ ហើយមានសិទ្ធិ ជ្រើសរើសបេក្ខជនយ៉ាងច្រើនបំផុត៥រូបប៉ុណ្ណោះ (ច្បាប់បោះឆ្នោតឆ្នាំ ២០០៣)។ អ្នកបោះឆ្នោតម្នាក់ៗត្រូវជ្រើសរើសបេក្ខជនយ៉ាងច្រើនស្មើរនឹងចំនួនអ្នកតំណាងតាមមណ្ឌលរបស់ខ្លួន។ បេក្ខជនដែលជាប់ឆ្នោតគឺជាអ្នកដែលទទួលបាននូវសម្លេងច្រើនជាងគេ ហើយតម្រូវឲ្យទទួលបានសម្លេងច្រើនជាងពាក់កណ្តាលនៃចំនួនសន្លឹកឆ្នោតមានប្រសិទ្ធិភាព។

ដោយសារជាទម្រង់នៃការចូលរួមដោយផ្ទាល់ពីប្រជាជនក្នុងកិច្ចការរដ្ឋាភិបាល មូលដ្ឋាន រាជរដ្ឋាភិបាល និងគណៈបក្សផ្សេងៗបានឃោសនានូវការផ្សព្វផ្សាយ និងការប្រតិបត្តិនូវគោលការណ៍ឬសគុលប្រជាធិបតេយ្យទៅក្នុងថ្នាក់ឃុំក្នុងមូលដ្ឋាននិមួយៗ។ កម្រិត និងឋានៈរបស់រដ្ឋាភិបាលបានផ្តល់នូវក្រិត្យក្រមសម្រាប់ការប្រើប្រាស់សិទ្ធិរបស់គេទៅ

តាមការសមស្របដោយអនុលោមទៅតាមពាក្យស្លោក "ប្រជាជនដឹង ប្រជាជនពិភាក្សា ប្រជាជនអនុវត្ត ប្រជាជនតាមដានត្រួតពិនិត្យ" ។

ឃុំជាថ្នាក់ក្រោមបំផុតនៃរដ្ឋាភិបាល ជាធម្មតាឃុំតាមជនបទរួមមានក្រុមនៃចង្កោមភូមិ និងឃុំតាមទីប្រជុំជន ត្រូវបានបែងចែកជាក្រុមតាំងទីលំនៅជាច្រើន។ ភូមិ និងក្រុមអ្នកតាំងទីលំនៅមានលក្ខណៈជាស្ថាប័នគ្រប់គ្រងពាក់កណ្តាលផ្លូវការហើយអនុវត្តនូវច្បាប់គោល-ការណ៍មួយចំនួនកំណត់ក្រោមរដ្ឋអំណាចឃុំសង្កាត់ អ្នកស្រុក ជ្រើសរើសអ្នកដឹកនាំរបស់ពួកគេតាមរយៈការបោះឆ្នោត ដែលគ្មានអ្នកឈរឈ្មោះជាផ្លូវការនោះទេ។ អ្នកស្រុកត្រូវបានឲ្យមានលេខសំងាត់ទៅតាមតំបន់ដើម្បីដាក់កម្រិតទំនាក់ទំនងដែលមានក្នុងសហាគមន៍ ហើយត្រូវមានការយល់ស្របពីប្រធានគណៈកម្មាធិការប្រជាជនថ្នាក់ស្រុកផងដែរ។

### ៣-១-៣ ការធ្វើស្ថាប័នភាវូបនីយកម្មការចូលរួមរបស់ប្រជាជន

ភាពលើសលប់នៃគោលគំនិតនៃការផ្ទេរ ការសម្រេចចិត្តត្រូវបានកត់សម្គាល់ជាការអនុវត្តមួយដ៏ល្អសម្រាប់រដ្ឋាភិបាល។ ការអនុវត្តថ្មីនេះបានប្រែក្លាយទស្សនៈគតិបណ្ឌិតមួយនេះ។ កំណែទម្រង់ថ្មីរបស់រដ្ឋាភិបាលដែលត្រូវបានជំរុញក្នុងប្រទេសទាំង៥នៃអាស៊ីអាគ្នេយ៍ចាប់តាំងពីដើមទស្សវត្សទី៩០ បានផ្តល់នូវគោលការសម្រាប់ប្រជាពលរដ្ឋឲ្យចូលរួមយ៉ាងសកម្មក្នុងកិច្ចការរដ្ឋាភិបាល។ នៅប្រទេសហ្វីលីពីន ក្រោយពីប្រជាជនអាចចូលរួមដោយផ្ទាល់ក្នុងដំណើរការរៀបចំផែនការ ការបញ្ចេញមតិ និងការអនុវត្តនូវការផ្តើមគំនិតរដ្ឋាភិបាលមូលដ្ឋានតាមរយៈការពិភាក្សាជាសាធារណៈ ការបង្ហាញញត្តិ និងក្នុងក្រុមប្រឹក្សាឃុំ។ ប្រទេសថៃ ក៏បានអនុវត្តនូវកំណែទម្រង់សារជាថ្មីដែរសម្រាប់រដ្ឋាភិបាលរបស់គេ ដោយមានបញ្ជាក់ក្នុងចំនុចមួយចំនួនក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៧ និងការអនុម័តច្បាប់វិមជ្ឈការ ឆ្នាំ១៩៩៩ របស់ប្រទេសថៃឡង់។ ប្រទេសកម្ពុជាបានផ្តល់នូវកំណែទម្រង់ស្រដៀងគ្នានេះដែលក្រោមច្បាប់ឃុំសង្កាត់ឆ្នាំ២០០១។ ក្នុងឆ្នាំ២០០៣ ប្រទេសវៀតណាមបានចេញនូវឯកសារគតិយុត្តស្តីពីប្រជាធិបតេយ្យនៅមូលដ្ឋាន ដែលបង្កើនការចូលរួមរបស់ប្រជាជនក្នុងអភិបាលកិច្ចមូលដ្ឋាន។ បរិបទសង្គមមានលក្ខណៈស្រដៀងគ្នាដោយសារតែបទពិសោធន៍ដែលជំរុញឲ្យមានកំរិតផ្តួចផ្តើមបែបវិមជ្ឈការនិង អភិបាលកិច្ចមជ្ឈការបានកើតមានឡើង។

អ្នកដឹកនាំប្រទេសទាំងនេះយល់ថាការផ្សារភ្ជាប់រវាងការចូលរួមរបស់ប្រជាពលរដ្ឋ និង សម្រាប់ពង្រឹងអភិបាលកិច្ចមូលដ្ឋាននេះ អាចជំរុញនូវការអភិវឌ្ឍន៍គោលដៅរបស់ថ្នាក់ដឹកនាំនោះ។ ដោយផ្តល់នូវការពិភាក្សាជាសាធារណៈ ដែលប្រជាជនអាចចូលរួមពិភាក្សាជាប្រចាំទៅលើបញ្ហាគោលការណ៍ផ្សេងៗ រដ្ឋាភិបាលមូលដ្ឋានបានលើកតម្កើងប្រជាពាស្រ្តដោយបញ្ជាក់បានថាប្រជាពលរដ្ឋគ្រប់រូបគឺជាផ្នែកមួយយ៉ាងសំខាន់ ក្នុងដំណើរការសម្រេចចិត្ត។ ដោយបង្កើតនូវទីកន្លែងសម្រាប់សន្ទនា និងផ្លោះផ្លូវមតិយោបល់ រដ្ឋាភិបាលបានបង្កើត និងពង្រឹងនូវទំនាក់ទំនងក្នុងជីវិត និងការចាប់អារម្មណ៍របស់ប្រជាជនទាំងអស់។ ដូចនេះប្រជាពលរដ្ឋទាំងអស់នឹងមិនត្រូវបានកាត់បន្ថយទៅជាក្រុមដែលគ្មានការប្រាស្រ័យទាក់ទងគ្នានោះទេ។

ជំពូកបន្ទាប់នឹងរៀបរាប់ថាតើការចូលរួមរបស់ប្រជាពលរដ្ឋមានលក្ខណៈល្អយ៉ាងណាសម្រាប់ការធ្វើគម្រោងមូលដ្ឋាន។ ករណីនិមួយៗបង្ហាញនូវការប្រតិបត្តិជាក់ស្តែងពីគោលគំនិតនៃការចូលរួមរបស់ប្រជាជននៅក្នុងបរិបទនយោបាយសង្គមខុសៗគ្នា។ ករណីប្រទេសវៀតណាមបានកើតឡើងក្នុងការកំណត់ ដែលបានដាក់ដោយរដ្ឋមជ្ឈការគណបក្សមួយ។ ចំណែកឯករណីប្រទេសកម្ពុជាវិញបានបង្ហាញនូវការដាក់ឲ្យប្រតិបត្តិ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងក្របខ័ណ្ឌនៃការកសាងសន្តិភាព។ ប្រទេសថៃគឺជាឧទាហរណ៍មួយ សម្រាប់ការចូលរួមរបស់ប្រជាជនក្នុងសកម្មភាពមួយនៃប្រជាធិបតេយ្យប្រពៃណីនៅរដ្ឋមជ្ឈការ។ ទោះបីជាប្រទេសដែលត្រូវរៀបរាប់ក្នុងជំពូកបន្ទាប់មានគោលនយោបាយ និងប្រព័ន្ធសេដ្ឋកិច្ចសង្គមខុសៗគ្នាក៏ដោយ ប៉ុន្តែប្រទេសទាំងនោះសុទ្ធតែឈរលើគោលគំនិតក្នុងការពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យដោយប្តូរអំណាចនយោបាយចេញពីអំណាចនយោបាយប្រពៃណីមកជាអង្គការស្ម័គ្រចិត្តផ្លូវការ ដែលធ្វើការយ៉ាងសកម្មជាមួយនឹងគ្រឹះស្ថាននយោបាយផ្លូវការវិញ។ ការធ្វើបែបនេះ អភិបាលកិច្ចប្រជាធិបតេយ្យទីបំផុតកំពុងឈានទៅរកស្ថាប័នស្វ័យតមូលដ្ឋានដែលបានរីកចំរើននៅក្នុងតំបន់តាំងពីមុនការបង្កើតស្ថាប័ននយោបាយមជ្ឈការមកម្ល៉េះ។ ដូចគ្នាដែរទៅនឹងបទពិសោធន៍របស់ប្រទេសអភិវឌ្ឍនៅប៉ែកខាងលិច បំរែបំរួលនៃការចូលរួមស្ម័គ្រចិត្តក្នុងការសម្រេចនូវទ្រព្យសម្បត្តិសាធរណៈ គឺជាភាពពិតប្រាកដបំផុតរបស់អភិបាលកិច្ចប្រជាធិបតេយ្យ។ ដោយយកប្រជាជនជាគោលនៃអភិបាលកិច្ចបរិយាកាសនយោបាយ ដែលមានតម្លាភាព និងការទទួលខុសត្រូវជាងមុនត្រូវបានបង្កើត

ឡើង។ ការធ្វើស្ថាប័នភាវូបនីយកម្មការចូលរួមរបស់ប្រជាជនក្នុងស្ថាប័ននយោបាយនៃប្រទេសទាំងនេះខាងលើបានត្រូវបញ្ចូលក្នុងជំពូកនេះ។

### ៣-២ ការអនុវត្តល្អ ស្តីពីការចូលរួមរបស់ប្រជាជននៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ (ករណីសឹក្សា)

ប្រជាធិបតេយ្យគឺជាទ្រឹស្តីផងនិងការអនុវត្តន៍ផង។ ក្នុងជំពូកមុនបានពិភាក្សារួចមកហើយថា តើថាមភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ជួយដាក់ចេញនូវការផ្តុំឡើងនៃលទ្ធិប្រជាធិបតេយ្យតាមរយៈ លំដាប់ថ្នាក់ជាច្រើននៃអ្នកផ្តើមគំនិតវិមជ្ឈការដោយរបៀបណា។ ក្នុងជំពូកនេះនឹងវាយតម្លៃទៅលើ ទ្រឹស្តី និង ក្របខ័ណ្ឌស្របច្បាប់នៃវិមជ្ឈការតាមបែបប្រជាធិបតេយ្យ ដែលត្រូវបានដាក់ចេញទៅជាមួយនឹងការយកចិត្តទុកដាក់ជាពិសេស ទៅលើរបៀបដែលប្រជាជនបានចូលរួមក្នុងដំណើរការ ក្រោមប្រព័ន្ធវិមជ្ឈការប្រជាធិបតេយ្យ។ ជំពូកនេះនឹងពិនិត្យមើលទៅក្នុងករណីប្រទេស៣ និង វាយតម្លៃថាករណីទាំងនោះបានទទួលជោគជ័យក្នុងការអនុវត្តន៍អភិបាលកិច្ចប្រជាធិបតេយ្យដោយរបៀបណា។

ជំពូកនេះក៏នឹងវិភាគទៅលើឱកាសនិង ការប្រកួតប្រជែងដែលកើតចេញពីករណីនិមួយៗ និងសន្និដ្ឋានលើរបៀបការអនុវត្តន៍ល្អអាចចំលងបានក្នុងតំបន់ផ្សេងៗ។ ករណីនិមួយៗនឹងចាប់ផ្តើមដោយការពិភាក្សាលើបរិបទនយោបាយ និងប្រវត្តិសាស្ត្ររបស់ការផ្តួចផ្តើមគំនិតប្រជាធិបតេយ្យតាមប្រទេសនិមួយៗ បន្ទាប់មកមានការពិភាក្សាលើបទដ្ឋានស្របច្បាប់សម្រាប់វិមជ្ឈការ និងចុងក្រោយមានការវាយតម្លៃការប្រកួតប្រជែងនិងឱកាសក្នុងគំរូការអនុវត្តល្អ។

#### ៣-២-១ ការចូលរួមរបស់សហគមន៍ក្នុងការកែលំអរតំបន់ផ្ទះសម្បែងនៅទីក្រុងវិញ ប្រទេសវៀតណាម

បរិបទនយោបាយ និងច្បាប់ប្រព័ន្ធនយោបាយរបស់ប្រទេសវៀតណាមត្រូវបានដាក់បញ្ចូលក្នុងគោលការណ៍នៃមជ្ឈការកណ្តាល។ នេះបញ្ជាក់ពីស្ថានភាពមជ្ឈការដ៏ជ្រាលជ្រៅនៃរដ្ឋបែបអាណានិគមនៃប្រទេសវៀតណាមលទ្ធិមជ្ឈការនិយមគឺជាគោលការណ៍ចំបងក្នុងការយល់ដឹងពីបរិបទនៃបទពិសោធន៍របស់វៀតណាមជាមួយនឹងវិមជ្ឈការ។ តាមរយៈTruong

and Panganiban ក្នុងគោលការណ៍នៃវិមជ្ឈការប្រជាធិបតេយ្យ វិមជ្ឈការក្នុងប្រទេសដែលពាក់ព័ន្ធនឹងការផ្តល់អំណាចច្រើនជាងមុនទៅឲ្យរដ្ឋបាលថ្នាក់មូលដ្ឋាន ខណៈពេលដែលកំពុងប្រើប្រាស់អំណាចរដ្ឋលើគោលការណ៍ និងកង្វល់របស់ជាតិ។ ដូចនេះហើយរដ្ឋធ្វើឲ្យរដ្ឋបាលមានភាពរួបរួមគ្នា និងគ្រប់គ្រងព្រំដែនទាំងមូលមានប្រសិទ្ធិភាពដោយអាស្រ័យលើច្បាប់ ក្រិតច្បាប់ និងបទបញ្ញត្តិ ហើយបង្កើតបទដ្ឋានច្បាប់ និងបង្កើតម៉ាក្រូនយោបាយសម្រាប់អាជ្ញាធរមូលដ្ឋានដើម្បីអនុវត្ត ហើយសម្រេចផែនការមូលដ្ឋាន បង្កើតមជ្ឈដ្ឋានដែលសមស្របសម្រាប់ថ្នាក់មូលដ្ឋានក្នុងការអនុវត្តគោលដៅរបស់ពួកគេ និងសម្របសម្រួលការងារ និងសកម្មភាព។

មជ្ឈការរបស់វៀតណាមគឺជាលទ្ធផលនៃគោលការណ៍មជ្ឈការដែលបង្កើតឡើងពីភាពមានឥទ្ធិពលរបស់ក្រុមប្រឹក្សាប្រជាជននៅថ្នាក់ជាតិ ដែលដើរតួជាភ្នាក់ងារសំខាន់នៃប្រជាធិបតេយ្យស្របច្បាប់។ បច្ចុប្បន្ននេះ ប្រទេសវៀតណាមមានប្រព័ន្ធរដ្ឋាភិបាលរួបរួម រដ្ឋាភិបាលកណ្តាលជារដ្ឋាភិបាលថ្នាក់ខ្ពស់បំផុត ហើយថ្នាក់បន្ទាប់គឺរដ្ឋបាលមូលដ្ឋាន ដែលរួមមានថ្នាក់ខេត្ត ឃុំ និងសង្កាត់។ ផ្នែកមូលដ្ឋានទាំងនេះមានផ្នែកខេត្ត ៦១ សង្កាត់៦០៤ និងឃុំចំនួន១០ ៣៨៧។

ច្បាប់វិមជ្ឈការសំខាន់ត្រូវបានឃើញមានក្នុងឯកសារជាច្រើនប៉ុន្តែគោលការវិមជ្ឈការអាចដកស្រង់ពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៩២ ដែលបានផ្តល់អំណាចពិសេសទៅឲ្យរដ្ឋបាលផ្នែកមូលដ្ឋាន។ គោលការនៃវិមជ្ឈការត្រូវបានបរិយាយបន្ថែមដោយការអនុម័តច្បាប់ស្តីពីការរៀបចំរដ្ឋាភិបាល ច្បាប់ស្តីពីការរៀបចំក្រុមប្រឹក្សាប្រជាជន និងគណៈកម្មាធិការប្រជាជនគ្រប់ថ្នាក់ ច្បាប់ស្តីពីថវិការ ការវិនិយោគនិងអនុក្រិត្យដទៃទៀតរបស់រដ្ឋាភិបាល។

សម្រង់ច្បាប់ខាងលើបានវិនិយោគនូវអំណាចរដ្ឋាភិបាលពិតប្រាកដដល់រដ្ឋបាលមូលដ្ឋាន។ ប៉ុន្តែប្រហែលចំនុចសំខាន់នោះគឺការរំពឹងទុកក្នុងមាត្រាទី ១១៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩២ ដែលបញ្ជាក់យ៉ាងច្បាស់ពីការបោះឆ្នោតផ្ទាល់នៃសមាជិកក្រុមប្រឹក្សាប្រជាជនដែលធ្វើឲ្យអ្នកទាំងនោះមានភាពទទួលខុសត្រូវចំពោះសភាធម្មនុញ្ញ និងអង្គការរដ្ឋរបស់ជាតិ។ ការបោះឆ្នោតផ្ទាល់នៃសមាជិកក្រុមប្រឹក្សាប្រជាជន ធ្វើឲ្យសហគមន៍អាចធ្វើឲ្យអ្នកដឹកនាំរបស់ខ្លួនមានភាពទទួលខុសត្រូវ ហើយក៏បង្កើតការចូលរួមក្នុងការសម្រេចចិត្ត និងអនុវត្ត

ផែនការអភិវឌ្ឍមូលដ្ឋាន។ បន្ថែមទៅលើច្បាប់ដែលបានដកស្រង់ខាងលើ ច្បាប់សំខាន់មួយទៀតគឺច្បាប់ដីធ្លីក្នុងឆ្នាំ២០០៣ ដែលបានវាបញ្ជាក់ឲ្យឃើញថាប្រជាជនមានសិទ្ធិក្នុងការចូលរួម និងតាមដានដំណើរការ រៀបចំផែនការ។

## ក-ការបរិយាយនិងដើមហេតុឲ្យកើតមានការអនុវត្តល្អ

ករណីរបស់ទីក្រុងវិញ រួមមានករណីទាំង១៩២ របស់ប្រជាជនក្រីក្រដែលតាំងទីលំនៅនៅតាមតំបន់ដែលគ្រប់គ្រងដោយក្រុមប្រឹក្សាប្រជាជនមូលដ្ឋានក្នុងទីក្រុង។ បេសកកម្មរបស់រាជរដ្ឋាភិបាលគឺធ្វើឲ្យមានបំលាស់ប្តូរសហាគមន៍ឲ្យចូលរួមក្នុងការអភិវឌ្ឍស្ថានភាពរស់នៅរបស់ជនក្រីក្រដែលតាំងលំនៅនៅទីនោះ។ គម្រោងនេះក៏ចាប់ផ្តើមភ្លាមដោយធ្វើលំនាំតាមវិធីសាស្រ្តអភិក្រមពីក្រោមឡើងលើ។ ក្រុមប្រឹក្សាមូលដ្ឋានបានជំរុញឲ្យសហាគមន៍ចូលរួមក្នុងការធ្វើគម្រោងមូលដ្ឋានដើម្បីដឹងពីដែនកំណត់នៃដំណើរការធ្វើផែនការចាស់ៗ។ អ្នកទាំងនោះយល់ថាវិធីសាស្រ្តចាស់នៃការធ្វើគម្រោងពីមុនមានលក្ខណៈមិនគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាដោយសារតែវាមិនអាចសម្រួបទៅនឹងការចាប់កើតថ្មីនៃសេដ្ឋកិច្ចវៀតណាមក្នុងទីផ្សារ។

ដូចគ្នាដែរវិធីសាស្រ្តចាស់មិនបានបំពេញនូវតម្រូវការរបស់សហាគមន៍ និងការរំពឹងទុកខ្ពស់នៃអ្នកចូលរួមក្នុងការដោះស្រាយបញ្ហា។ គោលបំណងរបស់គំរូមានដូចជា បង្កើននូវភាពទទួលខុសត្រូវរបស់សហាគមន៍ ពង្រឹងនូវជំនឿទុកចិត្ត និងជំនួយរបស់សហាគមន៍ បំលាស់ប្តូរធនធានឲ្យមានល្អប្រសើរ និងសំខាន់បំផុត ធ្វើឲ្យជីវិតរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរ និងមានបង្កើតផែនការអភិវឌ្ឍទីក្រុងឲ្យមាននិរន្តរភាព។ ដំណើរការនៃការជួយសង្គ្រោះប្រជាជនក្រីក្រនៃទីក្រុងវិញ បានបង្កើតឡើងជាមួយការបង្កើតក្រុមប្រឹក្សាកណ្តាលដោយគណៈកម្មាធិការប្រជាជនរបស់ទីក្រុងវិញ។ សហាគមន៍បានជ្រើសរើសអ្នកតំណាងក្នុងការប្រមូលថវិកាសម្រាប់គម្រោងដែលរួមទាំងមានមូលនិធិផ្តល់ឲ្យដោយសហព័ន្ធអាស៊ានសម្រាប់សិទ្ធិផ្នែកផ្ទះសម្បែង។ គម្រោងដែលផ្តោតទៅលើការចូលរួមរបស់ប្រជាជនចាប់ផ្តើមដោយមានការប្រឹក្សាយោបល់ជារឿយៗរវាងក្រុមប្រឹក្សាប្រជាជនរបស់ទីក្រុង និងក្រុមប្រឹក្សាកណ្តាល។

រាល់ការប្រជុំនិមួយៗសមាជិកត្រូវតែចូលរួមក្នុងការពិភាក្សានៃគម្រោង ហើយរបាយការណ៍ត្រូវបានបង្ហាញ ។ ការទាមទារអប្បរមាសំខាន់ត្រូវបានធ្វើតាមការណែនាំពីសំណាក់ខេត្ត ង៉េ អាន ដែលគ្របដណ្តប់ទីក្រុងវិញ។ គម្រោងនេះតំរង់ទៅគ្រួសារចំនួន១១០ ដែលរស់នៅក្នុងផ្ទះទ្រុឌទ្រោម។ ប្រជាពលរដ្ឋភាគច្រើនជាអ្នកសំណង់ដែលមានប្រាក់ចំណូលទាប។ ក៏ប៉ុន្តែសហគមន៍ទទួលរងឥទ្ធិពលមានតិចដើម្បីក្លាយជាតំបន់មុខព្រួញសម្រាប់ការអភិវឌ្ឍឡើងវិញតាមក្រិតក្រមរបស់ខេត្តង៉េ អាន។

ឆ្លងតាមការប្រឹក្សាជាមួយ គ្រួសារដែលទទួលរងឥទ្ធិពលបានយល់ព្រមក្នុងការតាំងលំនៅថ្មី និងក្នុងពេលជាមួយគ្នានេះដែរវិនិយោគក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងលំនៅស្ថានរបស់ពួកគាត់ដោយមានជញ្ជាំងដាច់ពីគ្នានិងមានគ្រិះ។ ការប្រតិបត្តិជោគជ័យនៃគម្រោងនេះគឺជាលទ្ធផលនៃការសម្របសម្រួលរវាងរដ្ឋាភិបាល អង្គភាពសង្គមស៊ីវិល និងការចូលរួមដ៏សកម្មរបស់សហគមន៍។ ប្រើប្រាស់អភិក្រមពីក្រោមឡើងលើ សមាជិករបស់សហគមន៍អាចតាមដាន ប្រតិបត្តិ និងអាចរួមចំណែកដោយផ្ទាល់ក្នុងភាពជោគជ័យនៃគម្រោងនេះ។ តាមរយៈការសម្របសម្រួលផ្តល់ដោយក្រុមប្រឹក្សាប្រជាជនក្រុងវិញ ដែលទទួលស្គាល់ការបង្កើតនៃគណកម្មាធិការកណ្តាល គម្រោងបានប្រព្រឹត្តទៅយ៉ាងជោគជ័យចាប់តាំងពីក្រុមប្រឹក្សាប្រជាជន មានទទួលស្គាល់សារៈសំខាន់ នៃការចូលរួមរបស់សហគមន៍។ ការយល់ដឹងនេះបានធ្វើឲ្យមានគំលាតគ្រប់គ្រាន់ក្នុងការដាក់ផែនការឲ្យទទួលបានការយល់ស្របពីអ្នកចូលរួមផ្សេងៗទៀត។

ទីក្រុងវិញមានប្រជាជនតាំងទីលំនៅជាង ២៩៥ ០០០នាក់ រស់នៅក្នុងទំហំដី ១០៤.៩៦គម[២]។ ទីក្រុងនេះស្ថិតនៅប្រហែល៣០០គម ពីទីក្រុងហាណូយពីខាងជើង និង ១៤០០គមពីទីក្រុងហូជីមិញពីខាងត្បូង។ សំរាប់ផ្នែករដ្ឋាភិបាល ទីក្រុងវិញ ត្រូវបានចាត់ទុកជាទីក្រុងទី១នៃខេត្តង៉េ អាន។ ទីក្រុងវិញគឺជាមជ្ឈមណ្ឌលនយោបាយ រដ្ឋបាល សេដ្ឋកិច្ច និងវប្បធម៌នៃខេត្ត ង៉េ អាន និងស្ថិតនៅភាគខាងជើងនៃប្រទេសវៀតណាម។ ទីក្រុងមាន១៦ សង្កាត់ និង៩ឃុំ។

### ខ - ឱកាស និង បញ្ហាប្រឈម

មានមេរៀនសំខាន់ជាច្រើនដែលអាចរៀនពីគំរូការអនុវត្តល្អបាន។ មេរៀនទី១ ផ្តោតទៅលើសារៈសំខាន់នៃការធ្វើជាម្ចាស់នៃគម្រោងអភិវឌ្ឍមូលដ្ឋាន។ ក្រុមប្រឹក្សាប្រជាជននៃទីក្រុងវិញមានអណាត្តិផ្លូវច្បាប់ដើម្បីធ្វើការដោយខ្លួនឯងក្នុងការដោះស្រាយបញ្ហាលំនៅស្ថាន យ៉ាងណាក៏ដោយពួកគេនៅតែសម្រេចចិត្តធ្វើការតាមយន្តការសម្របសម្រួលមួយដែលរួមមានអ្នកចូលរួមដែលបានទទួលរងឥទ្ធិពលនៃផែនការអភិវឌ្ឍ។ នៅពេលដែលបានដឹងពីដែនកំណត់ក្នុងដំណើរការផែនការ ក្រុមប្រឹក្សាទីក្រុងបានទទួលធ្វើជំហានដូចខាងក្រោម

១- សមាជិកក្រុមប្រឹក្សាបានបង្កើតគណៈកម្មការមួយដែលបានតួនាទីប្រឹក្សាយោបល់ផ្ទាល់និងប្រមូលធនធានដើម្បីប្រតិបត្តិផែនការ។

២- គណៈកម្មការនេះបានផ្តល់ឲ្យអ្នកចូលរួមនូវកន្លែងសម្រាប់ធ្វើការប្រឹក្សាយោបល់និងការសម្រេចចិត្ត។

៣- គណៈកម្មាការបានស្នើសុំសមាជិកដើម្បីរួមចំណែកផ្នែកហិរញ្ញវត្ថុក្នុងគម្រោង។

៤- គណៈកម្មការបានទទួលជោគជ័យក្នុងការទទួលបានធនធានសមស្របសម្រាប់មូលនិធិតាមរយៈការរួមចំណែក ឬដោយស្ម័គ្រចិត្តក្នុងការកែលំអទំហំបន្ទប់ សម្រាប់ផ្ទះនិមួយៗ។

៥- ផែនការអភិវឌ្ឍបានក្លាយជាគម្រោងមូលដ្ឋានសម្រាប់សហាគមន៍ពិត។ ស្របពេលជាមួយគ្នាដែរគម្រោងអាចបន្ថែមស្មារតីសហាគមន៍ទៀតផង។ ការយល់ដឹងលើការជួយខ្លួនឯង គឺជាចរិតលក្ខណៈមួយដែលត្រូវបានបណ្តុះឲ្យមាននៅក្នុងប្រទេសវៀតណាម

៦- ក្រៅពីប្រព័ន្ធនយោបាយមជ្ឈការ ទំនាក់ទំនងដ៏រឹងមាំរបស់សហាគមន៍ត្រូវបានសង្កាត់ប្រើប្រាស់ដោយគណៈកម្មាការហើយអារម្មណ៍ផ្សារភ្ជាប់គ្នា នៅតែជ្រួតជ្រៀបក្នុងសហាគមន៍ទោះបីជាមានឧបសគ្គនៃភាពស៊ីវីល័យក៏ដោយ។

គម្រោងនេះក៏បញ្ជាក់បានថា ការចូលរួមរបស់ប្រជាជនដោយប្រជាធិបតេយ្យពិតជាអាចធ្វើការរួមគ្នាជាមួយនឹងបេក្ខជនជាប់ឆ្នោតរបស់ក្រុមប្រឹក្សាប្រជាជន។ ដោយបានអនុវត្តយ៉ាងល្អត្រឹមត្រូវ ប្រជាជនទាំងអស់ពិតជាអាចធ្វើជាភ្នាក់ងារនៃការអភិវឌ្ឍន៍ នៅពេល

ដែលគាត់បានទទួលនូវលទ្ធភាព ក្នុងការធ្វើការសម្រេចចិត្តរកអ្វីដែលល្អសម្រាប់សហគមន៍ក្នុងបរិបទនៃយន្តការស្ថាប័នដ៏សមស្របមួយ។ ការអនុវត្តនូវអភិក្រមពីក្រោមឡើងលើសម្រេចបានលទ្ធផលដូចខាងក្រោមៈ

១- វាបានបង្កើតនូវយន្តការប្រឹក្សាយោបល់អចិន្ត្រៃយ៍ ដែលអនុញ្ញាតឲ្យសហគមន៍មិនត្រឹមតែទទួលបានការសម្របសម្រួលល្អនោះទេ ថែមទាំងធ្វើឲ្យគម្រោងមានតម្លាភាពដោយសារតាំងពីដំបូងឡើយពួកគាត់មានសមត្ថភាពអាចមើលដឹងពីជំហាននៃការប្រតិបត្តិគម្រោង។

២- ដោយសារតែការខិតខំប្រឹងប្រែងរបស់គណៈកម្មាការ ពួកគេអាចចរចារដើម្បីបញ្ចុះតម្លៃគម្រោងពីក្រុមហ៊ុនសាងសង់។

៣- ការរួមចំណែករបស់អ្នកស្ម័គ្រចិត្តដែលរួមមានអ្នកធ្វើការ និងសំខាន់ជាងនេះទៅទៀតនោះគឺអ្នកគូរប្លង់គម្រោង។

៤- គម្រោងនេះបានធ្វើឲ្យមានតុល្យភាពនូវចំនួនសមស្របពីសំណាក់សមាជិកជាច្រើននៅក្នុងសហគមន៍។

៥- ការរួមចំណែកមិនត្រឹមតែជាថវិការ និងកម្លាំងអ្នកស្ម័គ្រចិត្តប៉ុណ្ណោះទេ។ អ្នកទទួលផលក្នុងគម្រោងលំនៅស្ថានសំខាន់នោះមិនបានបដិសេធក្នុងការផ្លាស់ប្តូរទំហំដីរបស់ពួកគេទេ ពីព្រោះពួកគេយល់ពីការរួមសហការជាមួយនឹងលក្ខខត្តិកៈរបស់គម្រោង។ វាបានធ្វើឲ្យគណៈកម្មាការបង្កើតអភិក្រមពីក្រោមឡើងលើក្នុងការអនុវត្តផែនការអភិវឌ្ឍន៍។

៦- វាក៏បានរិតបន្តឹងភាពទុកចិត្តរវាងសមាជិកនៅក្នុងសហគមន៍ និងសមាជិកជាប់ឆ្នោតនៃសហគមប្រជាជន ដែលអនុញ្ញាតឲ្យមានឱកាសសម្រាប់គម្រោងអនាគតដែលបង្កើនភាពសហការរវាងសហគមន៍ និងក្រុមប្រឹក្សាប្រជាជន នេះហើយដែលធ្វើឲ្យមានស្ថាប័នភាវូបនីយកម្ម ការចូលរួមរបស់ប្រជាជននៅក្នុងទីក្រុងវិញ។

បញ្ហាលំបាកមួយក្នុងការធ្វើតាមគម្រោងដែលស្រដៀងគ្នានោះគឺ ការស្ម័គ្រចិត្តពីសហគមន៍ និងរដ្ឋជាច្រើនក្នុងការធ្វើការជាមួយគ្នា។ សម្រាប់ទីក្រុងវិញ ដោយសារតែបទពិសោធន៍នៃកិច្ចសហប្រតិបត្តិការមានលក្ខណៈនៅថ្មី ហើយសមត្ថភាពក្នុងការអភិវឌ្ឍន៍កំពុងតែលូតលាស់ ភាពទុកចិត្តរវាងសហគមន៍ និងរដ្ឋមានកម្រិតខ្ពស់ដូចគ្នាដែរ បទពិសោធន៍នៃការបោះឆ្នោតផ្ទាល់របស់អ្នកនយោបាយមានលក្ខណៈថ្មី ដូចនេះសម្រាប់សហប្រតិបត្តិការមិនមានការជំរុញឲ្យមានការទទួលបានផលចំនេញទៅលើគម្រោងឡើយ។

សហគមន៍ក៏មានទំនុកចិត្តខ្ពស់ដោយអាចបង្ហាញបានតាមការស្ម័គ្រចិត្តក្នុងការចូលរួម និងស្ម័គ្រចិត្តចំណាយពេលវេលា និងថវិកាសម្រាប់សេចក្តីសម្រេចនូវភាពជោគជ័យរបស់គម្រោង។

ជាមួយគ្នានេះដែរក៏មាននូវអវត្តមាននៃកម្លាំងនយោបាយបែបប្រពៃណី ក្នុងសហគមន៍ដែលអាចរារាំងដល់ការអនុវត្តគម្រោង។ ការរិះគន់មួយដែលអាចប្រឆាំងនឹងការធ្វើតាមគម្រោងមានដូចខាងក្រោមៈ

១- ទំហំនៃគម្រោងដែលមានត្រឹមតែ ១១៨គ្រួសារ អាចជាហេតុផលមួយ ដែលគម្រោងនេះមានភាពជោគជ័យ។ ដោយសារតែគ្រួសាររងគ្រោះមានចំនួនតិច ដូចនេះការបញ្ចុះបញ្ចូលក្រុមគាត់ឲ្យផ្លាស់ប្តូរតាមរយៈការពិភាក្សាមានលក្ខណៈងាយស្រួលជាងក្រុមធំដែលរស់នៅក្នុងតំបន់ដែលមានប្រជាជនរស់នៅកុះកុញ។

២- តំបន់ដែលបានរៀបរាប់ គឺជាតំបន់រៀបចំផ្ទះសំបែងសម្រាប់អ្នកជំរក។ ដូចនេះហើយ សហគមន៍ទាំងមូលសុទ្ធតែមានម្ចាស់កម្មសិទ្ធិទៅលើដីរបស់គាត់ ដោយសារតែវាត្រូវបានរៀបចំជាតំបន់រស់នៅរបស់គាត់ឲ្យមានលក្ខណៈស្របច្បាប់។ ករណីនេះប្រហែលជាមិនមានទេសម្រាប់ប្រទេស ដែលការធ្វើម្ចាស់កម្មសិទ្ធិដីធ្លីមានការកំណត់ហើយក៏ត្រូវឲ្យមានដើមទុនខ្ពស់។

៣- ផ្នែកមួយទៀតដែលអាចចាត់ទុកថាជាឧបសគ្គ និងឱកាសគឺភាពងាយស្រួលនៃនិតិវិធីនៃការអនុវត្តគម្រោង។ ក្រិត្យក្រមវែងអន្លាយដែលមានច្រើនក្នុងតំបន់ ដែលនិតិវិធីរដ្ឋាភិបាលមជ្ឈការប្រើជានិយាម អាចប៉ះពាល់យ៉ាងពិសេសដល់គម្រោងរួម

ជាមួយនឹងការខ្វះខាតតម្លាភាពដែលអាចនាំឲ្យមានអំពើពុករលួយ។ យ៉ាងណាមិញ ដូចដែលបានរៀបរាប់ពីបញ្ហាខាងលើ ភាពសំខាន់របស់វាគឺគម្រោងនេះមានលទ្ធផលជោគជ័យថ្មីបើមានប្រពៃណីមជ្ឈការយូរណាស់ក៏ដោយនៅប្រទេសវៀតណាម។ គម្រោងនេះសរបញ្ជាក់ថាដោយទទួលបានការគាំទ្រពីសំណាក់អាជ្ញាធរកណ្តាល និងមូលដ្ឋាន និងមានការរួមសហការពីអ្នកចូលរួមមូលដ្ឋានពីការបង្កើតឡើងនៃគម្រោងនេះ ផែនការអភិវឌ្ឍមជ្ឈមណ្ឌលប្រជាជនពិតប្រាកដអាចដំណើរការបាន ដែលធ្វើឲ្យគម្រោងនេះក្លាយជាគំរូមួយក្នុងតំបន់សម្រាប់ការចូលរួមរបស់ប្រជាជនក្នុងអភិបាលកិច្ចមូលដ្ឋាន។

យ៉ាងណាមិញ ក្រៅពីឧបសគ្គដែលអាចកើតឡើងក្នុងការចំលងគម្រោង បញ្ហាទាំងនោះមិនអាចជំនះបានឡើយ។ ដោយមានការវិភាគយ៉ាងល្អិតល្អន់ទៅលើសក្តានុពលភាពនៃគម្រោង យើងអាចឃើញភ្លាមៗថាមានកត្តាសំខាន់ៗចំនួនបួនដែលចាំបាច់សម្រាប់ទទួលបានជោគជ័យៈ

១- វត្តមាននៃមន្ត្រីរដ្ឋាភិបាលដែលមានការស្ម័គ្រចិត្តខ្ពស់ដើម្បីទទួលយកលក្ខណៈកំណែទម្រង់យកទៅអភិវឌ្ឍ។

២- មានការរៀបចំច្បាប់ត្រឹមត្រូវដើម្បីផ្តល់កំលាំងច្បាប់ទៅឲ្យកម្មវិធីណាដែលត្រូវបានធ្វើដោយក្រុមប្រឹក្សាមូលដ្ឋាន។

៣- វត្តមាននៃអង្គភាពសង្គមស៊ីវិលនិងអ្នកដឹកនាំសហគមន៍សកម្ម។

៤- ធនធានហិរញ្ញវត្ថុអប្បបរមាដែលផ្តល់ឲ្យសម្រាប់ការសម្របសម្រួលក្នុងពេលប្រជុំនិងបណ្តុះបណ្តាលអ្នកចូលរួមសំខាន់ៗ។ តម្រូវការហិរញ្ញវត្ថុអាចត្រូវបានបំពេញបន្ថែមដោយការគាំទ្រហិរញ្ញវត្ថុផ្ទាល់ពីជំនួយរបស់រដ្ឋាភិបាលកណ្តាល និងមូលនិធិអភិវឌ្ឍពីអង្គការក្នុងនិងក្រៅប្រទេស។ សំណេរព្រាងនៃសំណើគម្រោងដើម្បីស្នើសុំជំនួយហិរញ្ញវត្ថុពីអង្គការទាំងនោះធ្វើឡើងក្រោមកិច្ចសហការជាមួយនឹងរដ្ឋាភិបាលជាតិ។

### ៣-២-២ ភាពជាដៃគូរវាងវិស័យសាធារណៈ ឯកជន និងប្រជាជននៅសង្កាត់ ទូលសង្កែប្រទេសកម្ពុជា

#### បរិបទនយោបាយ និងផ្លូវច្បាប់

វិមជ្ឈការប្រជាធិបតេយ្យនៃកម្ពុជាត្រូវបានចាប់ផ្តើមឡើងក្នុងឆ្នាំ២០០២ ជាមួយនឹងការបោះឆ្នោតផ្ទាល់នៃក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស។ ដោយទើបតែងើបឡើងពីសង្គ្រាមស៊ីវិលក្នុងទសវត្ស១៩៩០ ផលប៉ះពាល់វានៅតែឃើញមានច្រើននៅតាមតំបន់ជនបទ។ កម្ពុជាកំពុងតែទទួលរងការលំបាកពីគ្រាប់មីនរាប់ពាន់ និងសំណល់ពីសង្គ្រាមស៊ីវិលកំពុងតែជះឥទ្ធិពលដល់ជីវិតប្រចាំថ្ងៃរបស់ប្រជាជន។ យោងតាមស្ថានភាពទាំងនេះហើយ ទើបធ្វើឲ្យមានវត្តមានរបស់UNនៅក្នុងប្រទេស បើតាមការពិតរបាយការណ៍បានបង្ហាញថាកម្ពុជាជាបេសកកម្មរបស់UNមួយក្នុងចំណោមបេសកកម្មធំជាងគេទូទាំងពិភពលោក។ កត្តាទាំងនេះធ្វើឲ្យស្ថានភាពកម្ពុជាត្រូវបានចាត់ទុកជាករណីពិសេស ដោយសារតែជាប្រទេសកំពុងតែងើបពីសង្គ្រាម និងកំពុងតែស្ថិតក្នុងដំណើរការក្រោយជម្លោះ។

ស្ថានភាពខាងលើបូករួមទាំងកង្វះសមត្ថភាព និងធនធានមានកំណត់នាំឲ្យស្ថាប័នរដ្ឋមានភាពទន់ខ្សោយ។ ទោះបីជាមានឧបសគ្គទាំងនេះ កម្ពុជានៅតែបន្តទៅមុខក្នុងការស្តារឡើងវិញនូវស្ថាប័ននយោបាយ។ បន្ទាប់ពីការចុះហត្ថលេខានៃសន្ធិសញ្ញាសន្តិភាពក្នុងឆ្នាំ១៩៩១ បញ្ចប់សង្គ្រាមស៊ីវិល កម្ពុជាបានចាប់ផ្តើមធ្វើស្ថាប័នភាវូបនីយកម្មឡើងវិញជាបន្ទាន់នៃរចនាសម្ព័ន្ធរដ្ឋាភិបាល ដោយមានជំនួយពីអង្គការសហប្រជាជាតិ និងប្រទេសផ្តល់ជំនួយជាច្រើន។ ក្នុងឆ្នាំ២០០២ប្រទេសកម្ពុជាបានទទួលរងឥទ្ធិពលកំណែទម្រង់មួយទៀតនៅពេលដែលមានការបោះឆ្នោតសម្រាប់រដ្ឋបាលមូលដ្ឋាន។

តាមរយៈលោកOberndof ក្នុងអត្ថបទបោះផ្សាយសម្រាប់គ្រឹះស្ថានធនធានអភិវឌ្ឍកម្ពុជា ការផ្តើមគំនិតវិមជ្ឈការកើតចេញពីដំណើរការសាកល្បងវិមជ្ឈការក្នុងកម្ពុជា។ ដំណើរការនោះកើតចេញពីកម្មវិធីសីលា "CARERE/SEILA[i] initiatives ដែលចាប់ផ្តើមក្នុងឆ្នាំ១៩៩៦ ក៏ដូចជា ជាមួយនឹងការអនុម័តច្បាប់ទៅលើការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ (១៩ កុម្ភៈ ២០០១) និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល (១៩ មិនា ២០០១) រដ្ឋាភិបាលបានដាក់

ដំណើរការវិមជ្ឈការជាផ្លូវការ។ ចំណុចសំខាន់ៗនៃច្បាប់នោះបានដាក់ឲ្យមានការបោះឆ្នោតឃុំខែកុម្ភៈ ឆ្នាំ២០០២ នៅពេលដែលក្រុមប្រឹក្សាឃុំចំនួន ១ ៦២១ត្រូវបានជាប់ឆ្នោត។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំត្រូវបានចាត់ទុកជាជោគជ័យដ៏ធំមួយ និងត្រូវបានចាត់ទុកជាការបង្ហាញពីជំហានសំខាន់ដើម្បីទៅដល់គោលដៅនៃកំណែទម្រង់។

ក្រោយការបោះឆ្នោត ការងារជាច្រើនត្រូវបានធ្វើដោយរដ្ឋាភិបាលដើម្បីគាំទ្រដំណើរការវិមជ្ឈការ។ ការបោះឆ្នោតក្រុមប្រឹក្សាក្នុងឆ្នាំ២០០២មិនត្រឹមតែផ្តល់ប្រជាធិប-តេយ្យភាពដល់អភិបាលកិច្ចមូលដ្ឋានប៉ុណ្ណោះទេ ថែមទាំងធ្វើវិមជ្ឈការនយោបាយទៀតផង។ លទ្ធផលនៃការបោះឆ្នោតបានបង្ហាញថាកៅអីថ្នាក់ខ្ពស់ភាគច្រើនត្រូវបានទៅគណៈបក្សប្រជាជនកម្ពុជា ដែលត្រូវចែករំលែកអំណាចជាមួយគណបក្សសម រង្ស៊ី និងគណបក្សហ្វុនស៊ីប៉ិច។ ក្នុងបទពិសោធន៍មជ្ឈការនៃប្រទេសកម្ពុជា គេសង្កត់ធ្ងន់ទៅលើរដ្ឋបាលថ្នាក់ក្រោមបំផុតដែលជារដ្ឋាភិបាលឃុំ រឺសង្កាត់។ ក្នុងថ្នាក់ឃុំសង្កាត់ ភាពអាចធ្វើទៅបាននៃការផ្តួចផ្តើមរដ្ឋាភិបាលមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាជនធ្វើឲ្យមានប្រតិបត្តិការចាប់ផ្តើមការអភិវឌ្ឍ។ ទោះជារដ្ឋបាលមូលដ្ឋានស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងមហាផ្ទៃក៏ដោយ ក៏វិមជ្ឈការនៃរដ្ឋបាលសង្កាត់បានផ្តល់កន្លែងសម្រាប់ការចាប់កំណើតនៃអភិបាលកិច្ចដោយផ្អែកទៅលើប្រជាជនផងដែរ។ ឧទាហរណ៍ដែលបានប្រើប្រាស់ក្នុងការសិក្សានេះគឺជាបទពិសោធនៃសង្កាត់ទួលសង្កែ។

### ក- ការបរិយាយ និង មូលហេតុដែលនាំឲ្យមានការអនុវត្តល្អ

ភាពអស្ចារ្យនៃបទពិសោធរបស់ទួលសង្កែគឺស្ថិតនៅក្នុងតួនាទីរបស់ក្រុមប្រឹក្សាជាប់ឆ្នោត។ មុនពេលគម្រោងនេះត្រូវបានបង្កើតឡើង ក្រុមប្រឹក្សាផែនការមូលដ្ឋានពឹងផ្អែកទាំងស្រុងទៅលើមូលនិធិដែលបានមកពីក្រសួងថ្នាក់ជាតិ។ មូលនិធិទាំងនេះមិនមានភាពគ្រប់គ្រាន់ឡើយដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍។ ក្រៅពីនេះ ដោយសារតែស្ថានភាពរងសម្ពាធនយោបាយខ្លាំងក្លា ដំណើរការធ្វើផែនការ និងប្រតិបត្តិការ ការបែងចែក

មូលនិធិទាំងនោះភាគច្រើនផ្តោតសំខាន់ទៅលើការទទួលបានសម្លេងគាំទ្រសម្រាប់ការបោះឆ្នោតលើកក្រោយ ច្រើនជាងបំពេញជាមួយតម្រូវការជាក់ស្តែងរបស់ប្រជាជន។

ក្រុមប្រឹក្សាសន្យានឹងធ្វើផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ តាមរយៈការរួមសហការពីគណបក្សនយោបាយផ្សេងៗក្នុងក្រុមប្រឹក្សា។ លក្ខណៈសំខាន់នៃគម្រោងគឺការធ្វើស្ថាប័នភាវូបនីយកម្មបណ្តាញស្ម័គ្រចិត្តនៃការចូលរួមឯកជនក្នុងដំណាក់កាលទាំងអស់នៃវដ្តគម្រោង។ ចាប់ផ្តើមពីការបណ្តុះគំនិត រហូតដល់ការប្រតិបត្តិ និងការរក្សាគម្រោង ដៃគូឯកជនត្រូវបានរក្សាទុកធ្វើឲ្យករណីនេះជាឧទាហរណ៍ដ៏ល្អនៃការចូលរួមរបស់ប្រជាជនក្នុងអភិបាលកិច្ចមូលដ្ឋាន។

ទួលសង្កែគឺជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង៧៦ក្នុងទីក្រុងភ្នំពេញ ដែលស្ថិតក្នុងកំរិតទី៤ ហើយក៏ជាថ្នាក់ក្រោមគេបង្អស់របស់រដ្ឋាភិបាលប្រទេសកម្ពុជា ហើយស្ថិតនៅក្នុងតំបន់ទើបតែអភិវឌ្ឍ។ ប្រហែល១០ឆ្នាំមុន សង្កាត់នេះមានដីទំនេរច្រើនតែជាតំបន់លិចទឹក។ ឥឡូវមានអាគារធំ តូចជាច្រើនអាគារផ្ទះស្នាក់នៅល្អៗ ក៏ដូចជាផ្លូវ ប្រព័ន្ធលូ ប្រព័ន្ធអគ្គិសនី និងប្រព័ន្ធទឹកម៉ាស៊ីន។ សង្កាត់នេះមានទីតាំងនៅខាងជើងនៃទីក្រុងភ្នំពេញ ហើយមានប្រជាជនចុះបញ្ជីសរុប ៤៩ ៦៣៦ (រឺប្រហែល១០០ ០០០ប្រជាជនពេលថ្ងៃដោយសារមានរោងចក្រកាត់ដេរជាច្រើន) នៅសង្កាត់ទួលសង្កែ។ សង្កាត់នេះត្រូវបានដឹកនាំដោយក្រុមប្រឹក្សាជាប់ឆ្នោត១១រូប ដែលត្រូវបានគាំទ្រដោយស្មៀនដែលក្រសួងមហាផ្ទៃចាត់តាំងមួយរូប (និងប៉ូលិសប៉ុស្តិ៍២០នាក់) និងបុគ្គលិកស្ម័គ្រចិត្ត១១រូប (២នាក់ជាស្ត្រី)។ ក្រុមប្រឹក្សា១១រូបរួមមាន ៦នាក់ពីគណបក្សប្រជាជន (២ជានារី) និង ៥ពីគណបក្សសមរង្ស៊ី ដែលជាគណបក្សប្រឆាំង។

### ខ- ឱកាស និងបញ្ហាប្រឈម

ដូចដែលបានរៀបរាប់ខាងលើ ចំនុចសំខាន់នៃភាពជោគជ័យនៃគម្រោងនេះពិសេសជាឧទាហរណ៍មួយនៃគម្រោងការចូលរួមរបស់ប្រជាជនប្រកបដោយជោគជ័យគឺឱកាសផ្តល់ឲ្យដោយការបោះឆ្នោត ក្នុងឆ្នាំ២០០២។ ទោះបីជា គណៈបក្សប្រជាជនមានសមាជិកច្រើនក្នុងក្រុមប្រឹក្សាសង្កាត់ វត្តមាននៃគណបក្សផ្សេងទៀតដូចជាសមរង្ស៊ី និង ហ្វុនស៊ីនប៉ិច បានបង្កើតបរិយាកាសនយោបាយពហុនិយម។ ឱកាសទីពីរនៃការបោះឆ្នោតក្រុមប្រឹក្សាគឺការបង្កើតភាពជឿទុកចិត្តក្នុងអភិបាលកិច្ចនៃសង្កាត់។ ចាប់តាំងពីសមាជិកក្រុមប្រឹក្សាបានជាប់ឆ្នោតសមាជិកក្រុមប្រឹក្សាមានភាពទទួលខុសត្រូវ មិនត្រឹមតែជាមួយរដ្ឋកណ្តាលនោះទេ

តែសំខាន់បំផុតចំពោះអ្នកបោះឆ្នោតរបស់ពួកគេ។ ក្នុងបរិបទនៃបរិយាកាសនយោបាយពហុនិយមនេះ ក្រុមប្រឹក្សាសង្កាត់ត្រូវឆ្លងកាត់ដំណាក់កាលដូចខាងក្រោម៖

១- ក្រុមប្រឹក្សាក្រុមបានបង្កើតគណៈកម្មាធិការផែនការនិងថវិកា

២- បានក្លាយជាភ្នាក់ងារបឋមក្នុងការប្រតិបត្តិគម្រោង

៣- កិច្ចការក្នុងការបង្កើត រៀបចំផែនការ និងប្រតិបត្តិ និងតាមដានគម្រោង

៤- កិច្ចការក្នុងការបង្កើតប្រភពទុនបន្ថែមដើម្បីជួយមូលនិធិរបស់សង្កាត់

៥- ក្រុមប្រឹក្សាទួលសង្កែបានប្រើប្រាស់ការចូលរួមរបស់ប្រជាជនក្នុងការកំណត់តម្រូវការរបស់សង្កាត់

៦- ក្រុមប្រឹក្សាបានកំណត់ និងជំរុញឲ្យមានការចូលរួមស្ម័គ្រចិត្តជាពិសេសក្នុងចំណោមអ្នកធូរធារនៃសហគមន៍។ ប៉ុន្តែក៏បានស្វាគមន៍នូវគ្រប់ការចូលរួមដែលត្រូវបានកត់ត្រាត្រឹមត្រូវក្នុងសហគមន៍។

គឺជាបទពិសោធន៍ដំបូងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ក្រុមប្រឹក្សារបស់ទួលសង្កែ។ ក្រៅពីការកំណត់មូលនិធិក្នុងការផ្តល់សម្រាប់តម្រូវការរបស់សហគមន៍ ការងារនេះបានផ្តល់ដល់សហគមន៍ និងក្រុមប្រឹក្សានូវបទពិសោធន៍ក្នុងការប្រើប្រាស់មូលនិធិទាំងនោះសម្រាប់ការអភិវឌ្ឍរបស់ខ្លួន។ ក្រោយពីទទួលស្គាល់នូវការកំណត់មូលនិធិ ក្រុមប្រឹក្សាបានពង្រីកអណត្តិផែនការមូលដ្ឋាន ដោយបញ្ចូលបន្ថែមបុគ្គលឯកជន និងក្រុមសង្គមស៊ីវិលក្នុងវដ្តគម្រោងទាំងអស់នៃផែនការអភិវឌ្ឍ។ ការខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាសង្កាត់បានធ្វើឲ្យ

១- គម្រោងបានធ្វើឲ្យមានការស្ម័គ្រចិត្តដែលផ្តើមចេញពីបុគ្គលឯកជន ដែលបានលះបង់ពេលវេលា និងទ្រព្យធនក្នុងការអភិវឌ្ឍគម្រោង

២- យន្តការដែលដាក់បញ្ចូលបន្ថែមទៅក្នុងគណៈកម្មាធិការផែនការថវិកាបានអនុញ្ញាតិឲ្យមានតម្លាភាព និងគណនេយ្យភាពក្នុងការប្រតិបត្តិថវិកាគម្រោង និងធានាថវិកាចាយវាយ មិនមានភាពមិនប្រក្រតីនោះទេ។

៣- ការបង្កើតភាពជាកម្មសិទ្ធិទៅលើគម្រោងត្រូវបានបង្កើតដំបូងនៅពេលក្រុមប្រឹក្សាសង្កាត់អាចជុំរុញឲ្យអ្នកចូលរួមនៃផ្នែកឯកជន និងCSO តាមរយៈការផ្តល់ភាពជាកម្មសិទ្ធិរបស់សហគមន៍ក្នុងផែនការអភិវឌ្ឍ

៤- ក្រុមប្រឹក្សាទូលសង្កែ និងបុគ្គលិកអាចរក្សាបាននូវការកត់ត្រាច្បាស់នៃគម្រោងនិមួយៗ និងពង្រឹងរបាយការណ៍សម្រេចបានប្រចាំឆ្នាំចាប់ពីឆ្នាំ២០០២(ក្នុងអណត្តិទី១)។ ការរួមបញ្ចូលគ្នានៃមូលនិធិឃុំ សង្កាត់ និងបដិភាគចូលរួមស្ម័គ្រចិត្តបានបង្កើនហេដ្ឋារចនាសម្ព័ន្ធពី២០០៥ដល់២០០៩ ក្រោមការផ្តើមគំនិតដែលរួមបញ្ចូលផ្លូវថ្នល់ស៊ីម៉ង់ ប្រព័ន្ធលូ ប្រឡាយ និងមានការថែរក្សានូវគម្រោងទាំងនោះ ប្រឡាយ និងមានការថែរក្សានូវគម្រោងទាំងនោះ។

ដោយឡែកមេរៀនពីការអនុវត្តខាងលើការរួមបញ្ចូលនូវបញ្ហាប្រឈមផងដែរ

ដែលរួមមាន:

១- មេរៀនដ៏សំខាន់គឺវត្តមាននៃអ្នកនយោបាយដែលស្ម័គ្រចិត្តក្នុងការចាប់ផ្តើមបង្កើតនូវភាពជាម្ចាស់ទៅលើគំរោងអភិវឌ្ឍ។ ជាទូទៅនៅក្នុងតំបន់អាស៊ាន គំរោងអភិវឌ្ឍគឺជាកិច្ចការពីលើមកក្រោម ដែលប្រមូលផ្តុំទៅដោយក្រុមនយោបាយជាន់ខ្ពស់ទោះជាក្នុងរាជធានីឬនៅសាលាក្រុង។ ពួកគេសុទ្ធតែមានចំណែកក្នុងការបង្កើតគំរោងអភិវឌ្ឍនេះ។

កត្តានេះជុំរុញឲ្យមានភាពលំបាកសំរាប់ភាពជោគជ័យប្រសិនបើមានក្រុមនយោបាយច្រើនខុសគ្នាធ្វើការគ្រប់គ្រងទៅលើក្រុមប្រឹក្សាក្នុងមូលដ្ឋាន។

២- បទពិសោធន៍ដ៏គួរឲ្យកត់សំគាល់មួយដែលទូលសង្កែបានជួបប្រទះនោះគឺ ទោះបីជាមានការប៉ះទង្គិចគ្នាលើបញ្ហារវាងគណបក្សនយោបាយនៅក្នុងប្រទេសកម្ពុជាក្តី ក៏គណបក្សទាំងនោះបានរួបរួមសាមគ្គីគ្នាដើម្បីដោះស្រាយ បើទោះបីជាពួកគេមានទំនាស់នឹងគ្នាជាយូរឆ្នាំមកហើយ។ រុករកវិធីដើម្បីពង្រួបពង្រួមគណបក្សនយោបាយគឺជាឧបសគ្គមួយក៏ប៉ុន្តែយោងតាមឧទាហរណ៍ដែលបានកើតឡើងនៅទូលសង្កែ ប្រសិនបើពួកគេអាចរួបរួមគ្នាអភិវឌ្ឍប្រឆាំងនឹងសង្គ្រាមបានពួកគេក៏អាចក្លាយទៅជា

គណបក្សចំរុះមួយដែលពោរពេញទៅដោយអ្នកនយោបាយមកពីប្រភពខុសគ្នាដើម្បីធ្វើការអភិវឌ្ឍផងដែរ។

៣- កត្តាមួយទៀតដែលអាចនឹងមានផលប៉ះពាល់ទៅដល់គម្រោងនេះគឺវត្តមានតែមួយគត់នៃស្ថានភាពនយោបាយប្រទេសកម្ពុជា។ វត្តមាននៃភ្នាក់ងារអ្នកអភិវឌ្ឍដែលមានចំនួនច្រើនដែលសម្របសម្រួលដោយ United Nations អាចជួយភ្នាក់ងារ បរទេសទាំងនេះក្លាយជាអ្នកឃ្លាំមើលអចិន្ត្រៃយ៍ហើយវត្តមាននេះក៏ជួយផ្តល់នូវការលើកទឹកចិត្តយ៉ាងរឹងមាំសំរាប់សកម្មភាពធ្វើការរបស់ក្រុមប្រឹក្សាក្នុងមូលដ្ឋានផងដែរ។

៤- ភាពទន់ខ្សោយផ្នែកស្ថាប័ននយោបាយក្នុងមូលដ្ឋានជាបញ្ហាមួយដែលត្រូវតាមដានឃ្លាំមើលជិតដិតក្នុងការធ្វើស្ថាប័នភាវូបនីយកម្ម ខ្សែគណនេយ្យភាពរវាងមន្ត្រីសាធារណៈនិងអ្នកបោះឆ្នោតក្នុងតំបន់។

៥- ទំនុកចិត្តពីសំណាក់ប្រជាជនក៏ជាកត្តាសំខាន់ដែរក្នុងការរួបរួមជាមួយក្រុមនយោបាយជាន់ខ្ពស់។ ប្រសិនបើអ្នកនយោបាយទាំងនោះមិនអាចបង្កើតឲ្យមាននូវការទុកចិត្តទៅលើអ្នកបោះឆ្នោតខ្លួនទេ ឧបសគ្គក្នុងការកោះហៅប្រជាជនឲ្យចូលរួមក្នុងការធ្វើគំរោងនឹងកើតមានឡើង។ ករណីនេះកើតឡើងនៅពេលដែលអ្នកបោះឆ្នោតទាំងអស់ត្រូវបានស្នើសុំអោយស្ម័គ្រចិត្តចូលរួមក្នុងការធ្វើគំរោងអភិវឌ្ឍដែលនឹងត្រូវត្រួតពិនិត្យឡើងវិញដោយគណៈកម្មការជាច្រើនរូប។

ទោះជាបញ្ហាប្រឈមយ៉ាងនេះក្តី សង្កាត់ទួលសង្កែបានមានលទ្ធភាពដើម្បីកៀរគរសមត្ថភាពពីអ្នកបោះឆ្នោតរបស់ខ្លួនក្នុងការចូលរួមដ៏មានអត្ថន័យ រកឃើញដំណោះស្រាយសមស្របចំពោះបញ្ហា ដែលជួបប្រទះក្នុងសហគមន៍។ ការបង្កើតឲ្យមានស្ថាប័ននិងយន្តការសម្រាប់បញ្ជូនតម្រូវការរបស់ប្រជាជនគឺជាគុណប្រយោជន៍មួយក្នុងចំណោមគុណប្រយោជន៍មួយចំនួនក្នុងប្រព័ន្ធ។ ជំនួសដោយការពឹងផ្អែកតែលើការដោះស្រាយបញ្ហាបែបបណ្តោះអាសន្ន ដំណើរការនោះបានក្លាយជាយន្តការអចិន្ត្រៃយ៍របស់សង្កាត់។ នោះជាផ្នែកមួយនៃដំណើរការនិងប្រព័ន្ធផ្លូវការរបស់រដ្ឋាភិបាល។

## ៣-២-៣ ការធ្វើគោលនយោបាយតាមបែបសហគមន៍ដឹកនាំ និងវិមជ្ឈការនៅទីក្រុង កងកេន ប្រទេសថៃឡង់

### បរិបទនយោបាយ និងប្រវត្តិសាស្ត្រ

ចាប់តាំងពីរជ្ជកាលនៃការត្រួតត្រាបែបរាជាធិបតេយ្យទាំងស្រុងមក ប្រទេសថៃត្រូវបានគ្រប់គ្រងដោយបែបមជ្ឈការ។ ដោយការបន្សល់ទុកនូវរបបរដ្ឋបាលអាណានិគមអង់គ្លេស រដ្ឋដ៏រឹងមាំនេះត្រូវបានរៀបចំដើម្បីត្រួតត្រាទៅលើខេត្តនានានៅក្នុងប្រទេស។ ការធ្វើមជ្ឈការថ្នាក់ខ្ពស់នេះនៅតែបន្តមានក្រោយការដួលរលំនៃរាជាធិបតេយ្យទាំងស្រុងនៅក្នុងឆ្នាំ១៩៣២ ការឈ្លានពានពីប្រទេសជប៉ុន កុបកម្មកុម្មុយនិស្ត និងរដ្ឋកុម្មុយនីសបែបឈ្លាពាន។ យ៉ាងណាក្តី ជាមួយនឹងការស្តារឡើងវិញនូវរបបប្រជាធិបតេយ្យនៅឆ្នាំ១៩៩៧ កម្រិតថ្មីនៃវិមជ្ឈការត្រូវបានអនុវត្ត។ ទោះបីជាវិមជ្ឈការរបស់រដ្ឋាភិបាលមូលដ្ឋានត្រូវបានបង្ហាញទៅលើគ្រប់រដ្ឋធម្មនុញ្ញមុនៗ របស់ប្រទេសថៃក៏ដោយ ក៏រដ្ឋធម្មនុញ្ញក្នុងឆ្នាំ១៩៩៧មានការបរិយាយលម្អិត និងផ្តោតទៅលើសារៈសំខាន់នៃការអភិវឌ្ឍរបស់រដ្ឋាភិបាលមូលដ្ឋាន។ យោងទៅតាមច្បាប់ធម្មនុញ្ញឆ្នាំ១៩៩៧ ធនធានហិរញ្ញវត្ថុច្រើនទៀត និងអំណាចស្របច្បាប់ត្រូវបានផ្តល់ឲ្យផ្នែករដ្ឋាភិបាលមូលដ្ឋាន។

ការរីកចំរើនទាំងនេះត្រូវបានផ្តល់ឲ្យកាន់តែជ្រាលជ្រៅជាមួយនឹងផ្លូវនៃវិមជ្ឈការក្នុងឆ្នាំ១៩៩៩។ ក្រៅពីការអូសទាញដ៏ខ្លាំងក្លា ពីក្រសួងមហាផ្ទៃទៅកាន់មជ្ឈការ ការរីកចំរើនកាន់តែបន្តក្នុងករណីដែលផ្នែករដ្ឋាភិបាលអាចអនុវត្តគំនិតឆ្នៃប្រឌិតក្នុងការព្រាង និងអនុវត្តគម្រោងអភិវឌ្ឍ ដែលបន្តបញ្ជាក់ពីផលវិជ្ជមានក្នុងការផ្តល់អំណាចទៅឲ្យផ្នែករដ្ឋាភិបាលក្នុងប្រទេសថៃ។ ករណីខាងក្រោមនេះនឹងវិភាគនូវការអនុវត្តល្អពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើគម្រោង និងការអភិវឌ្ឍគម្រោងសារជាថ្មីជាមួយនឹងបរិបទនៃអភិបាលកិច្ចក្នុងទីក្រុងកងកែន។

សាលាក្រុងកងកែន ស្ថិតនៅក្នុងសង្កាត់មឿង ខេត្តកងកែន។ ទីក្រុងកងកែនគឺជាទីក្រុងសំខាន់មួយដែលស្ថិតក្រោមគម្រោងអភិវឌ្ឍសេដ្ឋកិច្ចជាតិរួមជាមួយនឹងឈៀងម៉ៃ សងក្លា នាក់ខនរ៉ាត់ចាស៊ីមា និង ឈុនបូរី។ សព្វថ្ងៃនេះទីក្រុងកងកែន គឺជាតំបន់

មជ្ឈមណ្ឌលសម្រាប់ការអប់រំ សេដ្ឋកិច្ច ភ្នាក់ងាររដ្ឋាភិបាល និងការដឹកជញ្ជូន។ ជាងនេះទៅទៀតសម្រាប់ចំនួនប្រជាជនដើមរបស់គេ ទីក្រុងកងកែន សំបូរទៅដោយប្រជាជនថៃកាត់ចិន។ ពួកគេរស់នៅជាសហាគមន៍យ៉ាងធំ និងមានតួនាទីយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចដូចនឹងប្រជាជនថៃ–វៀតណាម និងជនបរទេសដទៃទៀតដែលស្នាក់នៅក្នុងខេត្តកងកែន ។ សព្វថ្ងៃសន្ទុះនៃប្រជាជនក្នុងទីក្រុងកងកែន បានថយចុះជាពិសេសក្នុងកំឡុងឆ្នាំ២០០៣–២០០៦។ វាត្រូវបាននាំមកដោយការពង្រីកនៃតំបន់តាំងទីលំនៅដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងទំរង់សាងសង់លំនៅដ្ឋានទីប្រជុំជន។ សព្វថ្ងៃទីក្រុងកងកែនមានប្រជាជនសរុបចំនួនប្រហែល ៥៥០ ០០០នាក់។

### ក- ការបរិយាយ និង មូលហេតុដែលនាំឲ្យមានការអនុវត្តល្អ

ការអនុវត្តល្អរបស់ទីក្រុងកងកែនវិលជុំវិញការអនុវត្តតាមផែនការដោយអ្នកប្រតិបត្តិការរដ្ឋាភិបាលមូលដ្ឋាន។ វិធីសាស្ត្រផែនការនៃក្រុមប្រឹក្សាទីក្រុងកងកែនទាក់ទងនឹងជំហានដូចខាងក្រោម៖

១- ក្រុមប្រឹក្សាទីក្រុងបានបង្កើតសន្និសិទ្ធិសម្រាប់សាធារណៈជនអំពីការពិនិត្យឡើងវិញ និងការបញ្ចេញយោបល់ដើម្បីបង្កើតគម្រោងអភិវឌ្ឍផ្ទាល់សម្រាប់តម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។

២- ទីក្រុងតូចៗដែលស្ថិតនៅក្នុងទីក្រុងធំ ដោយឡែកគឺជាទម្រង់នៃការចូលរួមក្នុងផែនការអភិវឌ្ឍសហាគមន៍ ដែលសមាជិករបស់សហាគមន៍ត្រូវបានស្រូបយកដើម្បីបង្កើតគម្រោងអភិវឌ្ឍផ្ទាល់សម្រាប់តម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។

៣- ក្រុមប្រឹក្សាទីក្រុងបានរៀបចំការជួបប្រជុំនិងសិក្ខាសាលាជាច្រើន ដែលសមាជិកនៃសហាគមន៍អាចចូលរួមយ៉ាងសកម្ម

៤- ក្រុមប្រឹក្សាទីក្រុងបានបង្កើតភ្នាក់ងារអចិន្ត្រៃយ៍នៅក្នុងក្រុមប្រឹក្សាទីក្រុងដើម្បីដើរតួជាភ្នាក់ងារសំខាន់នៃក្រុមប្រឹក្សាទីក្រុង និងការសម្របសម្រួលសហាគមន៍។ វាបានបង្កើតការិយាល័យនៃការចូលរួម និងការបង្កើនអំណាចវិមជ្ឈការ

៥- ចៅហ្វាយក្រុងបានរៀបចំក្រុមឯកទេសដោយផ្ទាល់ក្នុងក្រុមប្រឹក្សាទីក្រុងក្នុងការសម្របសម្រួលផ្ទាល់ជាមួយអ្នកចូលរួមទីក្រុងមូលដ្ឋានជាច្រើនដែលរួមមាន អ្នកសិក្សាស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងសមាជិកសហគមន៍

៦- បុគ្គលិករបស់ក្រុមប្រឹក្សាទីក្រុងចូលរួមយ៉ាងសកម្មក្នុងដំណាក់ផ្សេងៗនៃគម្រោង

៧- សាកលវិទ្យាល័យកងកែនបានក្លាយទៅជាប្រភពសម្រាប់អ្នកជំនាញ និងទីតាំងដែលសំបូរទៅដោយគំនិត និងយោបល់ពីសំណាក់សហគមន៍ និងក្រុមប្រឹក្សាទីក្រុង

៨- វិទ្យុសហគមន៍ក៏បានក្លាយទៅជាប្រភពសំខាន់មួយសម្រាប់ការផ្លាស់ប្តូរព័ត៌មាន និងផ្សព្វផ្សាយគំនិត។

**ខ- ឱកាសនិងបញ្ហាប្រឈម**

ភាពជោគជ័យនៃការអនុវត្តគម្រោងអភិវឌ្ឍសហគមន៍បានផ្តល់ឲ្យនូវការរីកចំរើនជាច្រើនរួមមាន៖

១- ការបង្កើតនូវស្លូប សម្រាប់ច្រកចូលទីក្រុង និងតំបន់បៃតងដើម្បីបង្កើនការកំសាន្ត និងជាមួយគ្នានេះដែរបានដោះស្រាយ នូវបញ្ហាចរាចរណ៍

២- ក្រៅពីការមើលទៅលើលទ្ធផលទាំងនោះ ការរួមចំណែកយ៉ាងសំខាន់មួយនៃការអនុវត្តល្អគឺ យន្តការនានាត្រូវបានបង្កើតឡើងដែលអនុញ្ញាតឲ្យប្រជាជន និងក្រុមសង្គមស៊ីវិល អាចចូលរួមយ៉ាងទៀងទាត់

៣- ករណីសិក្សាដំបូងទាក់ទងវិធីសាស្រ្តពីក្រោមមកលើក្នុងការស្វែងរកតម្រូវការរបស់ប្រជាជន។ ករណីនៃការចូលរួមរបស់ប្រជាជនក្នុងទីក្រុងកងកែន ជាប់ទាក់ទងនឹងការបង្កើតកិច្ចជួបប្រជុំ ដែលប្រជាពលរដ្ឋអាចចូលរួមបញ្ចេញជម្រើស មតិយោបល់ និងការពិនិត្យឡើងវិញទៅលើគោលការណ៍នានាដែលបានដាក់ឲ្យប្រើដោយទីក្រុង

៤- ការប្រែក្លាយដំណើរការសម្រេចចិត្តរបស់ក្រុងឲ្យក្លាយជាយន្តការមានលក្ខណៈចូលរួមរដ្ឋាភិបាលដែលប្រជាជនក្លាយជាផ្នែកនៃដំណើរការសម្រេចចិត្តពីការបង្កើតនៃគំនិតទាក់ទងនឹងគម្រោងជាច្រើនរហូតដល់ពេលដែលគម្រោងនោះត្រូវបានអនុវត្ត

៥- ករណីទីពីររួមមានការបង្កើតឡើងនូវការិយាល័យនៃការចូលរួម និងការបង្កើនអំណាចវិមជ្ឈការនៅក្នុងទីក្រុងកងកែន។ ការិយាល័យនេះគឺជាផ្នែកមួយនៃប្រព័ន្ធផ្លូវការរបស់រដ្ឋាភិបាល។

ជោគជ័យនៃការអនុវត្តល្អពឹងផ្អែកទៅលើវត្តមាននៃកត្តាសំខាន់ៗ៤៖

១- ការដឹកនាំយ៉ាងសកម្មរបស់អ្នកប្រតិបត្តិការមូលដ្ឋាន

២- សមត្ថភាពគាំទ្ររបស់បុគ្គលិកនៅក្នុងការិយាល័យនានារបស់ទីក្រុង

៣- ការរួមសហការពីសំណាក់សហគមន៍មូលដ្ឋាន

៤- ភាពដែលអាចធ្វើបាននៃវិទ្យាស្ថានអប់រំបញ្ចុះបញ្ចូលស្រាវជ្រាវនៃមហាវិទ្យាល័យកងកែន។

ការប្រមូលផ្តុំការគាំទ្រពីសហគមន៍ដើម្បីចូលរួមក្នុងដំណាក់កាលការរៀបចំទៅកាន់ដំណាក់កាលការអនុវត្តគម្រោងគឺជាផលពិបាកបំផុតនៅក្នុងការអនុវត្តល្អនេះ។ ការប្រមូលផ្តុំការគាំទ្រពីសហគមន៍នេះមានការពឹងផ្អែកទាំងស្រុងទៅលើការដឹកនាំរបស់ស្ថាប័នមូលដ្ឋាន។ ការអនុវត្តល្អដែលបានរៀបរាប់ខាងលើនេះ គឺជាការរួមផ្សំគ្នារវាងការដឹកនាំយ៉ាងសកម្មជាមួយនឹងជំនួយរបស់ការិយាល័យការចូលរួម និងអំណាចការចូលរួម។ ការផ្តួចផ្តើមរបស់ក្រុមប្រឹក្សានេះបានធ្វើឲ្យកើតមាននូវការគាំទ្រជានិរន្តន៍ពីសំណាក់សហគមន៍ទាំងអស់នៅក្នុងប្រទេស។

អាចជាផលពិបាកមួយដើម្បីអនុវត្តតាមលំនាំខាងលើក្នុងបរិបទមួយផ្សេងទៀតនៅពេលដែលមានការខុសគ្នាពីតម្រូវការសម្រាប់ការចូលរួមរបស់ប្រជាជន និងការទប់ស្កាត់ទៅលើបញ្ហានានាដែលអាចនឹងកើតមានឡើងពីការចូលរួមរបស់រដ្ឋាភិបាលទីក្រុង។ លើសពីនេះទៅទៀត ការស្វែងរកអ្នកដឹកនាំដ៏សកម្មពីមន្ត្រីដែលបានជាប់ឆ្នោត និងសមាជិករចនា

សម្ព័ន្ធ និងការសហការរបស់អង្គការសង្គមស៊ីវិលគឺជាកត្តាដែលត្រូវតែពិចារណាក្នុងការអនុវត្តតាមការអនុវត្តល្អនោះ។ ដោយមានការចូលរួមល្អនៃអ្នកដឹកនាំ អ្នកផ្តើមគំនិត និងការគាំទ្រពីសាធារណៈ ការអនុវត្តល្អនេះអាចធ្វើតាមបានដែលបង្កើតឲ្យមានប្រព័ន្ធសមស្របសម្រាប់ការចូលរួមរបស់ប្រជាជន។

## ៣-៣ កត្តាទាមទារសម្រាប់ការអនុវត្តតាមការអនុវត្តល្អនេះ

- បុគ្គលិក

វត្តមាននៃបុគ្គលិកដែលមានជំនាញសម្រាប់សម្រួលក្នុងការប្រជុំ និងការសម្របសម្រួលជាមួយក្រុម គឺជាភាពជោគជ័យយ៉ាងសំខាន់នៃកម្មវិធីការអនុវត្តល្អនេះ។ ក្នុងករណីសង្កាត់ទួលសង្កែ ភាពដឹកនាំនៃគណៈបក្សនយោបាយ៣សំខាន់ក្នុងក្រុមប្រឹក្សាសង្កាត់ក្នុងការផ្តល់ជំនាញខាងផ្នែកដឹកនាំដើម្បីជួយដល់ភាពជោគជ័យនៃគម្រោងរបស់ខ្លួន។ សមត្ថភាពនៃអង្គការសង្គមស៊ីវិល និងវត្តមាននៃអ្នកធ្វើការស្ម័គ្រចិត្តក្នុងសហគមន៍ក៏សំខាន់ដែរដោយសារការរួបរួមគ្នារវាងក្រុមប្រឹក្សា អង្គការសង្គមស៊ីវិល និងអ្នកស្ម័គ្រចិត្តបានបង្កើតនូវខ្លឹមសារនៃការអនុវត្តល្អនេះ។

- ការទទួលយកផ្នែកសង្គមនិងវប្បធម៌

ទំនុកចិត្តដ៏ជ្រាលជ្រៅតែងតែកើតមានក្នុងសហគមន៍មួយដោយសារតែពួកគេមានប្រពៃណី និងសារធាតុល្អដែលពួកគេតែងតែប្រកាន់ខ្ជាប់រួមគ្នា។ ទំនុកចិត្តនេះនៅតែមានទោះបីជាមានវត្តមាននៃស្ថានភាពនយោបាយដែលដឹកនាំដោយគណបក្សបីផ្សេងគ្នាក៏ដោយ។ មុនពេលដែលមានវិមជ្ឈការ គណបក្សនីមួយៗបានរក្សាឲ្យមាននូវគម្រោងផ្សេងៗសម្រាប់អ្នកគាំទ្ររបស់ពួកគេរៀងៗខ្លួន។ ស្ថានភាពនយោបាយដ៏ប្រកួតប្រជែងនេះបែរជាមិនមែនជាឧបសគ្គតែផ្ទុយទៅវិញជាវិធីសាស្ត្រមួយសម្រាប់កិច្ចសហប្រតិបត្តិការរបស់ក្រុមនយោបាយអ្នកដឹកនាំទៅវិញ។

- ការទាមទារចំពោះអង្គការសង្គមស៊ីវិល

អង្គការសង្គមស៊ីវិលគួរតែត្រៀមលក្ខណៈក្នុងការសហប្រតិបត្តិការជាមួយក្រុមនយោបាយផ្សេងៗប្រសិនបើមានបំណងក្នុងការចូលរួមក្នុងការអនុវត្តល្អនេះ។ អង្គការសង្គមស៊ីវិល ត្រូវតែមានគំនិតបើកចំហដើម្បីទទួលយកនូវគំនិត និងមតិពីមជ្ឈដ្ឋាននានាអំពីការចូលរួមក្នុងគម្រោងនេះ។ អង្គការសង្គមស៊ីវិល ត្រូវតែចេះបត់បែនក្នុងការកែតម្រូវដើម្បីកែប្រែតវិយាបថ និងផែនការស្នើដោយអាជ្ញាធរក្រុមប្រឹក្សាមូលដ្ឋាន។

- ការទាមទារផ្នែកភស្តុភារ

ទីកន្លែងសម្រាប់ប្រជុំ និងសិក្ខាសិលាត្រូវតែមានជាប្រចាំ។ ក្រុមប្រឹក្សាមូលដ្ឋានមានតួនាទីផ្តល់នូវថវិកាយ៉ាងតិចណាស់សម្រាប់ផ្គត់ផ្គង់សំភារៈសម្រាប់ការបណ្តុះបណ្តាល។ ក្រុមប្រឹក្សាក៏ត្រូវរៀបចំថវិកាសម្រាប់ថ្លៃដើមព័ត៌មានដែលត្រូវការចាំបាច់ក្នុងការសម្របសម្រួលការផ្សព្វផ្សាយនៃព័ត៌មានថ្មីៗស្តីពីគម្រោង។

- ការទាមទារផ្នែកច្បាប់និងរដ្ឋបាល

អនុស្សារណៈនៃការយោគយល់មួយគួរតែត្រូវបានរៀបចំ និងកត់ត្រារវាងអ្នកចូលរួមទាំងអស់ក្រោយពីការបញ្ចប់នៃសិក្ខាសាលានិមួយៗ។ អនុស្សារណៈនេះគួរតែមានរៀបរាប់នូវភាពទទួលខុសត្រូវរបស់ភាគីនីមួយៗក្នុងគម្រោង។ ក្រុមប្រឹក្សាត្រូវតែព្រាងដំណោះស្រាយមូលដ្ឋានក្នុងការគាំទ្រគម្រោងនេះដើម្បីផ្តល់សិទ្ធិស្របច្បាប់ទៅឲ្យអ្នកចូលរួមនិមួយៗក្នុងគម្រោង។ អនុស្សារណៈ និងដំណោះស្រាយត្រូវតែអនុលោមតាមច្បាប់ជាតិទៅលើនិតិវិធីរដ្ឋបាលរដ្ឋាភិបាលមូលដ្ឋាន។

- ការអនុវត្តតាមគំរូនានាសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ

បំណងក្នុងការចំលងការអនុវត្តល្អត្រូវបានរៀបរាប់ក្នុងជំពូកនេះ មានក្បួនច្បាប់សំខាន់មួយចំនួនត្រូវបានយកមកពិចារណា។ ជាដំបូងស្ថានភាពច្បាប់នៃតំបន់មូលដ្ឋាន ទីពីរគឺស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ទីក្រុង និងអ្នកតាំងជំរក និងចុងបញ្ចប់គុណភាព និងសមត្ថភាពនៃអ្នកចូលរួមក្នុងសហគមន៍ ដែលរួមមានជំនាញដឹកនាំនៃអ្នកប្រតិបត្តិការ និងសមត្ថភាពនៃអ្នកបច្ចេកទេសសមត្ថភាពរបស់តួអង្គមិនមែនរដ្ឋាភិបាលនានានៅក្នុងតំបន់ ហើយសំខាន់នោះដែរគឺសមត្ថភាពនៃប្រជាជនដើម្បីចូលរួមយ៉ាងសកម្ម និងមានន័យពេញ

លេញក្នុងដំណើរការនៃការអភិវឌ្ឍ។ ទីក្រុងដែលមានបំណងក្នុងការចំលងដំណើរការនេះត្រូវឆ្លងកាត់សវនកម្មនៃសមត្ថភាព និងភាពខ្សោយជាមុនសិន។ បន្ទាប់មកមានដំណើរការដូចខាងក្រោមដែលអាចប្រើប្រាស់ក្នុងការជួយពេលអនុវត្តតាមការអភិវឌ្ឍនៃកម្មវិធីការចូលរួមរបស់ប្រជាជន៖

១- ជាដំបូងអ្នកប្រតិបត្តិជាមួយនឹងបុគ្គលិកការងារ អ្នកដឹកនាំអង្គការសង្គមស៊ីវិល និងសមាជិករបស់សហគមន៍ត្រូវតែធ្វើការវាយតម្លៃទៅលើធនធានរបស់ខ្លួនជាមុនសិន ដើម្បីដឹងច្បាស់ពីចំនុចខ្លាំង និងចំនុចខ្សោយរបស់ពួកគេ។ គោលបំណងនៃជំហាននេះគឺដើម្បីបង្កើតនូវការយល់ដឹងទៅវិញទៅមករវាងសមាជិករបស់សហគមន៍ និងមេដឹកនាំនៃរដ្ឋាភិបាលមូលដ្ឋាន។ វាក៏អាចជួយសម្រួលនូវទំនាក់ទំនងល្អ និងទំនុកចិត្តខណៈពេលដែលពួកគេទាំងអស់ខិតខំប្រឹងប្រែងធ្វើសហប្រតិបត្តិការសម្រាប់ពេលអនាគត។

២- ជំហានដែលសំខាន់ទី២នោះគឺការពង្រឹងរួមគ្នានូវសមត្ថភាព និងធនធានរបស់ផ្នែកនីមួយៗរួមមានរដ្ឋាភិបាលមូលដ្ឋានអង្គការសង្គមស៊ីវិលនិងសមាជិកទាំងអស់របស់សហគមន៍។ ចរិកាសម្រាប់ការអភិវឌ្ឍនេះអាចបានមកពីរដ្ឋាភិបាលថ្នាក់ជាតិដែលជាអ្នកផ្តល់នូវការហ្វឹកហាត់ដល់សមាជិកមូលដ្ឋាន រឺភ្នាក់ងារអភិវឌ្ឍនានា រឺមកពីរដ្ឋាភិបាលមូលដ្ឋានផងដែរ ដែលពួកគេអាចធ្វើការហ្វឹកហាត់រឺសិក្ខាសិលាតាមលំនៅស្ថានរបស់ពួកគេ ហើយអ្នកហ្វឹកហាត់អាចជួលមកពីស្ថាប័នមូលដ្ឋានផ្សេងៗ (មហាវិទ្យាល័យ សហគ្រិន –ល–។)។ ដៃគូរទាំងអស់នៃគម្រោងត្រូវតែចូលរួមក្នុងសិក្ខាសិលាទាំងអស់នោះដើម្បីធ្វើឲ្យមានសហប្រតិបត្តិការនេះកាន់តែស៊ីជំរៅ។

៣- សិក្ខាសាលាត្រូវតែបានធ្វើការវាយតម្លៃទៅលើតម្រូវការរបស់សាលាក្រុង។ សេចក្តីវាយតម្លៃនេះត្រូវតែធ្វើរួមគ្នាជាមួយនឹងរដ្ឋាភិបាលមូលដ្ឋាន និងអ្នកតំណាងក្រៅរដ្ឋាភិបាលរួមមានអង្គការសង្គមស៊ីវិល និងសមាជិករបស់សហគមន៍។ ដូចទៅនឹងករណីទាំង៣ ដែលបានដកស្រង់មកខាងលើ ភាពជោគជ័យរបស់គេគឺពឹងផ្អែកទាំងស្រុងទៅលើការវិះរកនូវបញ្ហារបស់សហគមន៍របស់ពួកគេ។ ក្រោយពីជ្រាបច្បាស់

ពីបញ្ហាហើយ ពួកគេនឹងអាចដឹងថាបញ្ហាណាដែលសំខាន់ និងអាចដោះស្រាយបានយ៉ាងឆាប់ជាងមុន។

៤- ក្រោយពីកំណត់បញ្ហាហើយ ផែនការអភិវឌ្ឍដើម្បីដោះស្រាយបញ្ហាទាំងនោះត្រូវតែចាប់ផ្តើមបង្កើតឡើង។ ថវិកាដែលគ្រោងទុកក្នុងការធ្វើការសិក្សាទៅលើដំណោះស្រាយនោះអាចបានមកពីប្រភពជាច្រើន។ យោងតាមបទពិសោធន៍នៃករណីការអនុវត្តល្អលើការចូលរួមរបស់ប្រជាជន ជំនួយថវិកាអាចបានមកពីហិរញ្ញប្បទានរដ្ឋ (ដូចបានបង្ហាញដោយការអនុវត្តល្អពីប្រទេសវៀតណាម កម្ពុជា និងថៃ) គំរប់បំពេញដោយអ្នកស្ម័គ្រចិត្តនានា (វៀតណាម និងកម្ពុជា) និងពីធនធានហិរញ្ញវត្ថុមូលដ្ឋានរបស់ទីក្រុង។

៥- ការអនុវត្តគម្រោងត្រូវតែមានការទទួលខុសត្រូវ និងតម្លាភាពចាប់តាំងពីពេលចាប់ផ្តើម។ វាមានសារៈសំខាន់ណាស់ដែលការចំណាយ និងធនធានទាំងអស់ដែលប្រើប្រាស់ទៅលើគម្រោងត្រូវបើកជាសាធារណៈសម្រាប់ការត្រួតពិនិត្យពីសំណាក់មហាជន និងមានច្បាប់កំណត់ថាត្រូវតែមានគណនេយ្យសាធារណៈក្នុងការអនុវត្តគម្រោង។ ព័ត៌មានលម្អិតទៅលើការចំណាយថវិការបស់ថ្នាក់ជាតិ និងថវិកាដែលបានមកពីក្រុមអ្នកស្ម័គ្រចិត្ត (ដូចករណីទីក្រុងវិញ និងទូលសង្កែ) ត្រូវតែមានលក្ខណៈបើកចំហរសាធារណៈ។

៦- តួនាទីនៃភាពដឹកនាំសកម្មភាពមានសារៈសំខាន់ទាក់ទងរាល់សកម្មភាពទាំងអស់។ សហគមន៍ត្រូវតែអាចកំណត់សមត្ថភាពរបស់អ្នកដឹកនាំនៃប្រតិបត្តិការមូលដ្ឋាន។ កង្វះនៃភាពដឹកនាំនេះអាចបំពេញដោយការគាំទ្ររបស់សមាជិកនៃរដ្ឋាភិបាលមូលដ្ឋាន។ ករណីទីក្រុងកងកែនគឺជាឧទាហរណ៍ ដែលភាពជាអ្នកដឹកនាំនៃចៅហ្វាយក្រុងត្រូវបានបំពេញដោយសមត្ថភាពនៃការិយាល័យផែនការមូលដ្ឋាន។ អ្នកដឹកនាំអង្គការសង្គមស៊ីវិល ពីសហគមន៍តែងតែអាចជួយក្នុងការអនុវត្តការអភិវឌ្ឍដោយផ្អែកលើប្រជាជន

៧- នយោបាយមូលដ្ឋានក៏ជាការពិចារណាសំខាន់ក្នុងការបោះឆ្នោតប្រជាធិបតេយ្យសម្រាប់ថ្នាក់សហគមន៍មូលដ្ឋាន។ ពួកគេត្រូវតែអាចប្រើប្រាស់ចន្លោះសាធារណៈរាល់ពេលដែលគេត្រូវបញ្ចេញមតិទាក់ទងនឹងបញ្ហាសហគមន៍។ ដោយបង្កើតការចាប់អារម្មណ៍ទៅលើបញ្ហាជាក់លាក់ក្នុងសហគមន៍ ក្រុមអាជ្ញាធរប្រតិបត្តិមូលដ្ឋានអាចនឹងមានសេចក្តីក្លាហាន ឬទំនុកចិត្តក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដោយស្រូបយកសភាវគតិល្អនានារបស់មន្ត្រីសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយសកម្មភាពរបស់មន្ត្រីសាធារណៈក្នុងការកៀរគរការគាំទ្រសម្រាប់គាំទ្រកម្មវិធីណាមួយត្រូវតែធ្វើឡើងដោយមានការពិចារណាទៅលើការកំណត់ផ្លូវច្បាប់ដើម្បីបញ្ចៀសនូវអំពើហឹង្សា និងការបំភិតបំភ័យពីគូបដិបក្ខនៃកំណែទម្រង់ និងសូម្បីតែភ្នាក់ងារសុវត្ថិភាពមូលដ្ឋាន។

# ជំពូកទី៣

## ប្រធានបទទី២៖

# អភិបាលកិច្ចស្ថាប័ន

**-ទស្សនានិងការអនុវត្តន៍ល្អនានា-**

ដោយ លោក មិន មុនី

# ជំពូកទី៣

# ប្រធានបទទី២៖ អភិបាលកិច្ចស្ថាប័ន

**មាតិការ**


៤ ប្រធានបទទី២៖ អភិបាលកិច្ចស្ថាប័ន

៤-១ ធាតុសំខាន់ៗនៃអភិបាលកិច្ចស្ថាប័ន

៤-១-១ ក្របខណ្ឌជាគន្លឹះសម្រាប់អភិបាលកិច្ចស្ថាប័ននៅថ្នាក់ខេត្តនិងថ្នាក់ក្រុងក្នុងប្រទេសទាំង៥

៤-១-២ ភាពសក្តិសិទ្ធិរបស់ស្ថាប័នដែលអាចសម្រេចបានសម្រាប់អភិបាលកិច្ចមូលដ្ឋាន និងប្រជាធិបតេយ្យ (អត្ថបទដើមរៀបរៀងដោយ បណ្ឌិត Gaudioso C. Sosmena, Jr.)

៤-១-៣ អភិក្រមតាមបែបអ្នកពាក់ព័ន្ធច្រើន

៤-១-៤ តម្លាភាព និង គណនេយ្យភាព ជាគោលការណ៍សំខាន់សម្រាប់ស្ថាប័នរដ្ឋ

៤-២ ការអនុវត្តន៍ល្អក្នុងស្ថាប័នរដ្ឋក្នុងអាស៊ីអាគ្នេយ៍ (ករណីសិក្សា)

៤-២-១ រដ្ឋាភិបាលអេឡិចត្រូនិចដើម្បីពង្រឹងការអនុវត្ត និងផ្តល់សេវារបស់ក្រុងយូកយ៉ាកាតាប្រទេសឥណ្ឌូនេស៊ី

៤-២-២ អភិបាលកិច្ចតាមរយៈភាពជាដៃគូរវាងសាលាក្រុង និងសហគមន៍ព្រឹកក្នុងប្រទេសថៃ

៤-២-៣ ការរួមចំណែកក្នុងការធ្វើផែនការទីប្រជុំជន នៃខេត្តហ្គីមារ៉ាស

ប្រទេសហ្វីលីពីន

៤-២-៤ ការផ្តួចផ្តើមស្ថាប័នសាធារណៈនៅទីក្រុងឡាំងស៊ុន ប្រទេសវៀតណាម

៤-២-៥ ការពង្រឹងរដ្ឋបាលថ្នាក់មូលដ្ឋានដោយខ្លួនឯងៈ ចំណូល និងថវិកាក្នុងខេត្តបាត់ដំបង ប្រទេសកម្ពុជា

### ៤-១ ធាតុសំខាន់ៗនៃអភិបាលកិច្ចស្ថាប័ន

អភិបាលកិច្ចស្ថាប័នក្នុងសៀវភៅនេះគឺសំដៅទៅលើការអនុវត្តកិច្ចការងារ មានលក្ខណៈត្រឹមត្រូវមានភាពសក្តិសិទ្ធរបស់ស្ថាប័ននានារបស់ទីក្រុង ក្នុងការផ្តល់សេវានានាដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន ដែលកាន់តែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ នៅក្នុងបរិបទនេះអភិបាលកិច្ចស្ថាប័ន ទាមទារអោយមានការផ្តល់សេវាដែលមានគុណភាព ប្រសិទ្ធិភាព និងទាន់ពេលវេលា របស់រដ្ឋាភិបាលទីក្រុងតាមរយៈមធ្យោបាយតាមបែបប្រជាធិបតេយ្យ។

#### ៤-១-១ ក្របខណ្ឌជាគន្លឹះសម្រាប់អភិបាលកិច្ចស្ថាប័ននៅថ្នាក់ខេត្តនិងថ្នាក់ក្រុងក្នុងប្រទេសទាំង៥

ទោះបីជាប្រទេសនិមួយៗមានស្ថានភាពវប្បធម៌ ភូមិសាស្ត្រនិងចរឹកលក្ខណៈរបស់អង្គភាពរដ្ឋបាលទាំងនោះខុសៗគ្នា និងលើសពីនេះទៀតប្រទេសទាំងនោះស្ថិតនៅក្នុងដំណាក់កាលកំណែទម្រង់វិមជ្ឈការមិនដូចគ្នាយ៉ាងណាក៏ដោយ ក៏កំណែទម្រង់វិមជ្ឈការនិងអភិបាលកិច្ចមូលដ្ឋានហាក់មានមូលហេតុស្រដៀងគ្នា

"កាត់បន្ថយភាពមិនពេញចិត្តរបស់ប្រជាជនចំពោះប្រពន្ធ័គ្រប់គ្រង តាមបែបមជ្ឈការរបស់រដ្ឋាភិបាល និងនាំមកនូវសំលេងរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការអភិបាលកិច្ច ក្នុងគោលបំណងលើកស្ទួយ ការឆ្លើយតបនិងគណនេយ្យភាពនៃស្ថាប័នរដ្ឋាភិបាលនិងមន្ត្រីពាក់ពន្ធ័ក្នុងការអនុវត្តមុខងាររបស់ខ្លួន"។

ក្នុងន័យនេះគោលដៅរួមនៃកំណែទម្រង់គឺ:

- បង្កើតឡើងនូវវប្បធម៌ប្រជាធិបតេយ្យតាមបែបការចូលរួមនៅមូលដ្ឋានហើយមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ

- កែលម្អសេវាសាធារណៈនិងហេដ្ឋារចនាសម្ពន្ធ័

- នាំមកនូវការអភិវឌ្ឍន៍សង្គមកិច្ចនិងសេដ្ឋកិច្ច

- ចូលរួមកាត់បន្ថយភាពក្រីក្រ

គោលដៅដ៏មានមហិច្ឆតាទាំងនេះនឹងមិនអាចសម្រេចបាននោះទេ ប្រសិនមិនមានរដ្ឋបាលមួយដ៏ត្រឹមត្រូវ។ រចនាសម្ពន្ធ័របស់រដ្ឋបាលមួយចំនួនជាទូទៅគឺផ្អែកទៅលើទំហំភូមិសាស្ត្រនិងប្រជាសាស្ត្រ នៃមណ្ឌលបោះឆ្នោតរបស់ខ្លួន។សម្រាប់ប្រទេសទាំង៥នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្រៅពីមានក្រុមប្រឹក្សាដែលបានបោះឆ្នោតដោយសកល ឬ អសកល រដ្ឋបាលទីក្រុងជាទូទៅមានរួមបញ្ចូលអភិបាលឬគណអភិបាលដែលបានបោះឆ្នោតដោយផ្ទាល់ឬអសកល ឬតែងតាំងឡើង និងមានបុគ្គលិក ដែលជាទូទៅជាមន្ត្រីសាធារណៈឬក៏ជាអ្នកបម្រើការជាអាជីព ឬ/និង បុគ្គលិកជាប់កិច្ចសន្យា។ ដោយតម្រូវការរបស់ប្រជាជនកាន់តែកើនឡើងថ្នាក់គ្រប់គ្រងនិងមន្ត្រីដែលមានជំនាញនិងអាជីពខ្ពស់ចាំបាច់ត្រូវដាក់ពង្រាយនៅថ្នាក់រដ្ឋបាលនេះ ដើម្បីទទួលយកកិច្ចការពាក់ពន្ធ័នឹងការផ្តល់សេវាសាធារណៈនានាឆ្លើយតបទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ ហើយយោងទៅតាមគោលនយោបាយដំណោះស្រាយនិងការណែនាំនានានៅមូលដ្ឋាន។ ក្នុងន័យនេះយើងចាំបាច់ត្រូវស្វែងយល់អំពីក្របខណ្ឌ័រចនាសម្ពន្ធ័នៅថ្នាក់ក្រោមជាតិនៅប្រទេសទាំង៥។

## កម្ពុជា

ក្រុមប្រឹក្សាឃុំសង្កាត់(ថ្នាក់ក្រោមបំផុតនៃរដ្ឋាភិបាល) ត្រូវបានបោះឆ្នោតដោយសកលតាមរយៈប្រពន្ធ័បោះឆ្នោតសមមាត្រ មានធនធានថវិកា តាមរយៈការផ្ទេរប្រចាំឆ្នាំពីថ្នាក់ជាតិ (អោយឈ្មោះថាមូលនិធិឃុំសង្កាត់) និង មានបុគ្គលិកមួយចំនួន (រួមបញ្ចូលទាំងស្មៀនម្នាក់ដែលតែងតាំងដោយថ្នាក់ជាតិ)។ រហូតមកដល់បច្ចុប្បន្នក្រុមប្រឹក្សាដែលទទួលដោយការបោះឆ្នោតនៅតែមានការទទួលខុសត្រូវសិទ្ធិអំណាច និងធនធានមានកំរិតនៅឡើយ។

ថ្នាក់ក្រុងស្រុករាជធានីខេត្ត ដែលមានរាជធានីចំនួនមួយ ខេត្តចំនួន២៣ ក្រុងចំនួន២៦ស្រុកចំនួន១៥៦ខណ្ឌចំនួន៨(ខណ្ឌគឺជាស្រុកទីប្រជុំជននៅក្នុងរាជធានីភ្នំពេញ) ហើយដែលមានក្រុមប្រឹក្សាត្រូវបានបោះឆ្នោតឡើងកាលពីខែឧសភាឆ្នាំ២០០៩។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងនោះបានធ្វើឡើងខុសពីការបោះឆ្នោតនៅឃុំសង្កាត់ ហើយដែលមានតែសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ (១១៣៥៣នាក់) ប៉ុណ្ណោះដែលមានសិទ្ធិបោះឆ្នោត

ជ្រើសរើសនៅក្រុមប្រឹក្សានៅថ្នាក់ខាងលើ។ ជាមួយនឹងគណៈអភិបាលដែលបានតែងតាំងដោយរដ្ឋាភិបាលថ្នាក់កណ្តាល ក្រុមប្រឹក្សានិងអភិបាលទាំងនោះជាតំណាងរបស់រដ្ឋាភិបាលនៅថ្នាក់រដ្ឋបាលរបស់ខ្លួន។

មុននឹងមានការបង្កើតឡើងនូវរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ ការផ្តល់សេវាសាធារណៈ របស់រដ្ឋាភិបាលត្រូវបានផ្តល់ដោយក្រសួងថ្នាក់ជាតិនិងតាមរយៈបុគ្គលិកបច្ចេកទេសរបស់ខ្លួនដែលមានទីតាំងនៅថ្នាក់ខេត្តនិងស្រុក(មិនមាននៅថ្នាក់ឃុំសង្កាត់ទេ)។ បច្ចុប្បន្ននេះរាជរដ្ឋាភិបាលស្ថិតនៅក្នុងដំណាក់កាលពិនិត្យឡើងវិញនូវមុខងារផ្តល់សេវាសាធារណៈទាំងនោះនិងកំពុងពិចារណាទៅលើការផ្ទេរមុខងារទៅថ្នាក់រដ្ឋបាលក្រោមជាតិទាំងនោះជាបណ្តើរៗ។

## <u>ប្រទេសឥណ្ឌូនេស៊ី</u>

ប្រទេសឥណ្ឌូនេស៊ីជាសាធារណរដ្ឋបង្រួបបង្រួមមួយដោយរដ្ឋធមនុញ្ញ និងរដ្ឋបាលដែលបែងចែកជា៣៣ខេត្ត (រួមបញ្ចូលដោយខេត្តពិសេសចំនួន៣ និងទីក្រុងចាកាតា)។ ខេត្តត្រូវបានបែងចែកបន្តទៅជាស្រុកចំនួន៣៤៩ និងក្រុងចំនួន ៩១។ ភូមិជនបទ (ដេសា) ស្ថិតនៅក្រោមការត្រួតត្រារបស់ស្រុក និងភូមិទីប្រជុំជន(គេលូរាហាន) ស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋបាលក្រុង។ អភិបាលខេត្ត ស្រុក និងរដ្ឋបាលក្រុងត្រូវបានបោះឆ្នោតដោយផ្ទាល់ ដែលមានលក្ខណៈស្រដៀងទៅនឹងប្រធានាធិបតី ឬអនុប្រធានាធិបតីរបស់ប្រទេសដែរ។ សក្តានុពលនៃសេវាសាធារណៈត្រូវបានគ្រប់គ្រងដោយរដ្ឋបាលស្រុក និងក្រុងតាមរយៈភ្នាក់ងារបច្ចេកទេសរដ្ឋបាលមូលដ្ឋាន។

## ប្រទេសហ្វីលីពីន

រដ្ឋធមនុញ្ញឆ្នាំ១៩៨៧ បានផ្តល់ឱកាសដល់កំណែទម្រង់វិមជ្ឈការ និងស្វ័យភាពមូលដ្ឋាន។ រដ្ឋធមនុញ្ញនេះក៏ជាមូលដ្ឋានគ្រឹះសម្រាប់ច្បាប់រដ្ឋាភិបាលមូលដ្ឋានឆ្នាំ១៩៩១ផងដែរហើយក៏បានផ្តល់អង្គភាពរដ្ឋបាលមូលដ្ឋាននូវការទទួលខុសត្រូវទៅលើការផ្តល់សេវាសាធារណៈ មូលដ្ឋានមួយចំនួន និងកៀរគរចំណូលផ្ទាល់ សម្រាប់ការចំណាយ នៅមូលដ្ឋាន។ វិមជ្ឈការនៃការផ្ទេរអំណាចនិងសិទ្ធិសម្រេច ពីរដ្ឋាភិបាលថ្នាក់ជាតិទៅរដ្ឋាភិបាល

ថ្នាក់មូលដ្ឋានបានផ្តល់ឱកាសយ៉ាងធំធេងសម្រាប់ការអនុវត្តផ្ទាល់នូវថ្នាក់មូលដ្ឋានដែលខុសពីសម័យដែលមិនទាន់មានច្បាប់ស្តីពីវិមជ្ឈការ ដែលពេលនោះរដ្ឋាភិបាលថ្នាក់ជាតិឬថ្នាក់កណ្តាល ប្រើប្រាស់សិទ្ធិអំណាចកុងត្រូល ទៅលើស្ទើរតែគ្រប់ផ្នែកទាំងអស់នៃរដ្ឋបាល និងអភិបាលកិច្ចមូលដ្ឋាន។

## ប្រទេសថៃឡង់

រដ្ឋាភិបាលថ្នាក់ក្រុងនៅប្រទេសថៃចែកចេញជាបីប្រភេទ គឺមានថ្នាក់ក្រុង ថ្នាក់បូរី និងថ្នាក់អនុស្រុក នៅថ្នាក់ក្រុងមានសភា និងអភិបាលដែលបោះឆ្នោតដោយផ្ទាល់ដែលមានអណត្តិ៤ឆ្នាំ ។ រហូតមកដល់បច្ចុប្បន្នចំនួនទីក្រុងមានប្រហែល១២២៩ (ថ្នាក់ក្រុងចំនួន២០ ទីប្រជុំជនចំនួន៨៤ ថ្នាក់អនុស្រុកចំនួន១០២៥) ។

ផ្អែកតាមប្រវត្តិសាស្រ្តរដ្ឋអំណាចមូលដ្ឋាននៅប្រទេសថៃមិនមានតួនាទីក្នុងការផ្តល់សេវាសាធារណៈនោះទេនៅមុនកំណែទម្រង់វិមជ្ឈការក្នុងទសវត្ស១៩៩០ បើប្រៀបធៀបទៅនឹងរដ្ឋាភិបាលកណ្តាលនិងការិយាល័យខ្សែរបណ្តោយរបស់ខ្លួន។ ក្នុងន័យនេះកំណែទម្រង់វិមជ្ឈការក្នុងប្រទេសថៃគឺជាការព្យាយាមដើម្បីផ្ទេរសេវារដ្ឋបាល និងធនធានមនុស្សនិងហិរញ្ញវត្ថុ ទៅដល់រដ្ឋអំណាចមូលដ្ឋានហើយជាបណ្តើរៗអភិវឌ្ឍសមត្ថភាពរដ្ឋបាលទាំងនោះក្នុងការផ្តល់សេវាសាធារណៈ។

## ប្រទេសវៀតណាម

វៀតណាមថ្នាក់ក្រោមជាតិចែកចេញជាបីកំរិត គឺថ្នាក់ខេត្តស្រុកនិងឃុំ ថ្នាក់ទីមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិគឺថ្នាក់ខេត្តនិងក្រុង រហូតមកដល់២០០៥ វៀតណាមមានខេត្ត៥៩ខេត្តនិងទីក្រុងធំៗចំនួន៥ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីថ្នាក់ជាតិ។ នៅថ្នាក់បន្ទាប់រួមមានស្រុកមានចំនួន៦៦២ស្រុកដែលរួមបញ្ចូលដោយទីរួមខេត្តចំនួន២៥ ស្រុកប្រជុំជនចំនួន៤២ ទីក្រុង(Town) ចំនួន៥៩ និងស្រុកជនបទចំនួន៥៣៦ ។ ថ្នាក់ទីបីគឺឃុំដែលមានចំនួន១០៧៧៦ ហើយក្នុងនោះមានឃុំទីប្រជុំជនចំនួន១១៨១(សង្កាត់) ចំនួន១១៨១ ទីរួមស្រុកចំនួន៥៨៣ និងឃុំជនបទ ចំនួន៩០១២។

ថ្នាក់និមួយៗ គឺមានតំណាងប្រជាពលរដ្ឋមួយដែលឲ្យឈ្មោះថាក្រុមប្រឹក្សាប្រជាជន។ ក្រុមប្រឹក្សាប្រជាជននៅថ្នាក់ទាំងបីខាងលើត្រូវបានបោះឆ្នោតឡើងដោយផ្ទាល់ពីអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់នៅក្នុងមណ្ឌលបោះឆ្នោតនិមួយៗ។ ការបោះឆ្នោតនៅមូលដ្ឋានទាំងនោះអាចធ្វើឡើងក្នុងពេលខុសគ្នា។ យោងតាមច្បាប់ស្តីពីរដ្ឋបាលមូលដ្ឋាន ក្រុមប្រឹក្សាប្រជាជននៅក្នុងថ្នាក់និមួយៗត្រូវជ្រើសរើស ប្រធាន អនុប្រធាននិងសមាជិក គណកម្មការប្រជាជន (ដូចគ្នានឹងគណៈអភិបាល) និងប្រធាននិងសមាជិកគណកម្មកាជំនាញនានារួមបញ្ចូលទាំងតុលាការប្រជាជនផងដែរ។ គណកម្មការប្រជាជនជាអង្គភាពប្រតិបត្តិដែលសម្របសម្រួលជាមួយការិយាល័យបច្ចេកទេសជំនាញទាំងអស់ក្នុងការផ្តល់សេវាសាធារណៈ។

### ៤-១-២ ភាពសក្តិសិទ្ធិរបស់ស្ថាប័នដែលអាចសម្រេចបានសម្រាប់អភិបាលកិច្ចមូលដ្ឋាន និងប្រជាធិបតេយ្យ (អត្ថបទដើមរៀបរៀងដោយ បណ្ឌិត Gaudioso C. Sosmena, Jr.)

ស្ថាប័ននានាត្រូវបានបង្កើតឡើងដើម្បីអនុវត្តមុខងារនិងបំពេញបំណងជាក់លាក់។ ដោយមូលហេតុថាស្ថាប័ននានាត្រូវសំរេចបាននូវគោលដៅនិងគោលបំណងជាក់លាក់ ការគ្រប់គ្រងល្អគឺជាកត្តាកំណត់ដ៏ចាំបាច់សម្រាប់សម្រេចបាននូវប្រសិទ្ធភាពស្ថាប័ន។ ភាពផ្លាស់ប្តូរបរិយាកាសការងាររបស់ស្ថាប័នជាញយៗ ក៏ទាមទារអោយមានភាពបត់បែនរបស់អង្គការចាត់តាំងរបស់ស្ថាប័នផងដែរ។

ស្ថាប័ននិងភ្នាក់ងារសាធារណៈនៅមូលដ្ឋានដែលពាក់ព័ន្ធការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន និងការអនុវត្តន៍តាមបែបប្រជាធិបតេយ្យចាំបាច់ត្រូវមានភាពបត់បែននៃអង្គការចាត់តាំង ក៏ដូចជាសមត្ថភាពដែលអាចប្រមើលមើលទៅលើឱកាសនានាជាមុន ដើម្បីអភិវឌ្ឍនូវយុទ្ធសាស្ត្រចាំបាច់នានា ឈានដល់ការសម្រេចបាននូវគោលបំណងជាក់លាក់។ សេចក្តីណែនាំជាមូលដ្ឋានខាងក្រោមនេះដែលបញ្ជាក់ថាតើស្ថាប័នមួយ អាចអនុវត្តជាអតិបរមាដើម្បីសម្រេចបាននូវអណត្តិរបស់ខ្លួនត្រូវបានរៀបរៀងឡើងជាឧបករណ៍គ្រប់គ្រងមួយសម្រាប់រដ្ឋាភិបាលមូលដ្ឋាន ហើយអាចនឹងត្រូវធ្វើការពិនិត្យឡើងវិញអោយស្របតាមបរិបទដោយឡែកៗពីគ្នា។ ដូចគ្នាផងដែរ សេចក្តីណែនាំសម្រាប់ប្រសិទ្ធិភាពស្ថាប័នទាំងនេះត្រូវបានរៀបចំឡើងជាពិសេស សម្រាប់ស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋាន ដែលមានរួមបញ្ចូលរដ្ឋបាលក្រុង ស្រុក

និងសមាគមន៍រដ្ឋបាលមូលដ្ឋាននានាដែលពាក់ពន្ធ័នឹងយុទ្ធសាស្រ្តគ្រប់គ្រងនៅមូលដ្ឋាន ឈានដល់អភិបាលកិច្ចមូលដ្ឋានដែលមានប្រសិទ្ធិភាព៖

### ក- ការពិនិត្យឡើងវិញទៅលើអណត្តិផ្លូវច្បាប់ស្ថាប័ន

គោលបំណង៖ គឺដើម្បីបង្កើតឡើងនូវបង្គោលកំណត់មួយច្បាស់លាស់ ថាតើអ្វីជាការរំពឹងទុកនៅក្នុងការបង្កើតស្ថាប័ននេះជាឧទាហរណ៍ថាតើរដ្ឋាភិបាល ឬក៏ស្ថាប័នសាធារណៈមូលដ្ឋានត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ច្បាប់ ឬឯកសារគតិយុត្តផ្សេងៗទៀត។

វាជាការចាំបាច់ណាស់ដើម្បីអោយទាំងអស់គ្នាយល់ដឹងអំពីក្របខណ្ឌច្បាប់ នៃភារកិច្ចរបស់បុគ្គលិកទាំងអស់គ្នាហើយនឹងការសម្រាប់ដំណើរការធ្វើកម្មវិធីនានាផងដែរ។

ស្ថាប័នដូចជារដ្ឋាភិបាលមូលដ្ឋាននានា ចាំបាច់ត្រូវបង្កើតឡើងនឹងអនុវត្តមុខងារ យោងទៅតាមច្បាប់សាធារណៈ ឬរដ្ឋធមនុញ្ញនៃប្រទេស។ ចំពោះប្រទេសទាំង៥ដែលកំពុងពិភាក្សានេះ អណត្តិផ្លូវច្បាប់រដ្ឋបាលក្រុងស្រុក ត្រូវបាននិយាយលំអិតក្នុងច្បាប់រៀបចំអង្គការវិមជ្ឈការ ឬក៏លិខិតគតិយុត្តស្តីពីរដ្ឋបាលមូលដ្ឋាននានា។

### ខ- គោលការណ៍ក្នុងការគ្រប់គ្រងអង្គការចាត់តាំងតាមបែប "រចនាសម្ព័ន្ធទៅតាមមុខងារ "

គោលបំណង៖ គឺដើម្បីរំលឹកដល់ថ្នាក់ដឹកនាំរដ្ឋាភិបាលមូលដ្ឋាននឹងអ្នកជំនាញផ្នែកគ្រប់គ្រងថាចាំបាច់ត្រូវមានការយល់ដឹងអំពីអណត្តិជាផ្លូវការមុននឹងសម្រេចថាតើស្ថាប័នមូលដ្ឋានត្រូវរៀបចំរបៀបដូចម្តេច ។ មានន័យថាទំហំការងារគឺជាកត្តាកំណត់ចំពោះទីចាត់ការនិងអង្គភាពនានារបស់ស្ថាប័ន គោលបំណងមួយនៅក្នុងចំណោមគោលបំណងសំខាន់ៗនានាក្នុងការបង្កើតទីចាត់ការ និងអង្គភាពទាំងនោះគឺដើម្បីធានាថាតម្រូវការរបស់ប្រជាពលរដ្ឋត្រូវបានកំណត់ត្រឹមត្រូវ និងថារដ្ឋបាលរបស់ខ្លួនត្រូវបានរៀបចំទៅតាមផ្លូវដ៏ល្អបំផុតដើម្បីឆ្លើយតបទៅលើតំរូវការទាំងនោះ។

ទីក្រុង ទីចាត់ការ និងអង្គភាពនានាដែលកំពុងតែពិភាក្សានេះ មានអណត្តិដើម្បីផ្តល់នូវសេវាដែលមានគុណភាព និងទាន់ពេលវេលាទៅដល់ប្រជាពលរដ្ឋដោយមានភាពងាយស្រួលក្នុងការទទួលបាន មានតម្លាភាព ក៏ដូចជាមានលទ្ធភាពនិងតំលៃទាប។ ក្នុងន័យនេះថ្នាក់

ដឹកនាំទីក្រុងត្រូវចាំបាច់បង្កើតរចនាសម្ព័ន្ធ មុខងារដែលបានផ្ទេរទៅអោយទៅតាមទំហំតម្រូវការរបស់ប្រជាជននិងធនធាន

## គ- ការកំណត់គោលនយោបាយ គោលដៅនិងកម្មវិធីនានារបស់អង្គការចាត់តាំង

គោលបំណង៖ គឺដើម្បីផ្តល់ការចង្អុលបង្ហាញផ្នែកគោលនយោបាយ និងគោលដៅរបស់អង្គការចាត់តាំង រួមបញ្ចូលទាំងគម្រោងនិងសកម្មភាពនានាដែលបុគ្គលិកទទួលខុសត្រូវដើម្បីអនុវត្តនិងសម្រេច។

ការរៀបចំគោលនយោបាយនិងកម្មវិធីនានារបស់អង្គការចាត់តាំង/ស្ថាប័ន គឺជាជំហានមួយដ៏ចាំបាច់ដើម្បីអនុញ្ញាតិអោយ រដ្ឋាភិបាលមូលដ្ឋានឬក៏អង្គការចាត់តាំងមូលដ្ឋាននានាអនុវត្តនូវកិច្ចការរបស់ខ្លួន មានប្រសិទ្ធភាព និងប្រសិទ្ធផលប្រសើរជាងមុន។ ទីក្រុងនានានៃប្រទេសទាំង៥ បានឆ្លងកាត់នូវដំណើរការរៀបចំផែនការណ៍រយៈពេលវែងមធ្យមនិងប្រចាំឆ្នាំ រួមទាំងថវិការបស់ខ្លួនផងដែរ។ ដូច្នេះហើយទីក្រុងនានា ចាំបាច់ត្រូវតែទទួលបាននូវការរំលឹកណែនាំស្តីអំពីដំណើរការធ្វើផែនការតាមបែបប្រជាធិបតេយ្យចូលរួមនៅពេលធ្វើការតាក់តែងឬក៏ពិនិត្យឡើងវិញនូវផែនការទាំងនោះរបស់ខ្លួន។

## ឃ- ការតាក់តែងកម្មវិធីពង្រឹងសមត្ថភាពដល់បុគ្គលិករដ្ឋាភិបាលស្ថាប័នមូលដ្ឋាននានា

គោលបំណង៖ គឺដើម្បីរក្សាបាននូវប្រសិទ្ធភាពខ្ពស់បំផុត នឹងផលិតកម្មមួយដែលមានប្រសិទ្ធផលរបស់រដ្ឋាភិបាលនិងស្ថាប័នមូលដ្ឋានក៏ដូចជាដើម្បីអភិវឌ្ឍនូវវប្បធម៌ សម្រេចបាននូវស្នាដៃខ្ពស់ក្នុងរដ្ឋបាលមូលដ្ឋាននៅក្នុងភាពជាអ្នកដឹកនាំនយោបាយ។

កម្មវិធីពង្រឹងសមត្ថភាពចាំបាច់ត្រូវរួមបញ្ចូលនូវការផ្តល់វគ្គបណ្តុះបណ្តាលផ្សេងៗ។

ទី១ការខិតខំផ្តល់សមត្ថភាពត្រូវផ្អែកលើមូលដ្ឋានចំណេះដឹង អ្នកអប់រំនានាតែងហៅបញ្ហានេះថាជាលំហាត់បែបបញ្ញា និងការយល់ដឹង។ វាអាចជាចំណេះដឹងមួយជាក់លាក់ដោយយោងទៅតាមតម្រូវការនៃតួនាទីមួយច្បាស់លាស់។ ឧទារហាណ៍សម្រាប់អ្នកដឹកនាំរដ្ឋបាលមូលដ្ឋាន បញ្ហានេះគឺពាក់ព័ន្ធទៅនឹងភាពជាអ្នកដឹកនាំ និងនយោបាយតាមបែបវិជ្ជមាននៅមូលដ្ឋាន ។ សម្រាប់សមាជិកក្រុមប្រឹក្សារដ្ឋបាលមូលដ្ឋានដែលអ្នកទាំងនោះមាន

ឧត្តមគតិនយោបាយខុសៗគ្នា ប្រធានបទពាក់ពន្ធ័ទៅនឹងការពិភាក្សានយោបាយតាមបែបស្ថាបនា ក្នុងការតាក់តែងគោលនយោបាយ ផែនការ និងថវិកាមូលដ្ឋាន គឺជាប្រធានបទដ៏សំខាន់មួយ ការពិភាក្សាបែបនេះចាំបាច់ត្រូវរួមបញ្ចូល នូវប្រធានបទស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋ និងការយកចិត្តទុកដាក់ជាពិសេសទៅដល់ក្រុមជនដែលងាយរងគ្រោះ និងក្រុមជនដែលមានការចាប់អារម្មណ៍ផ្សេងៗគ្នាផងដែរ។

ទី២ គឺការអភិវឌ្ឍជំនាញ គឺមានការពាក់ពន្ធ័ជំនាញបច្ចេកទេសទាំងផ្លូវសតិបញ្ញា និងកំលាំងពលកម្ម ទៅតាមតម្រូវការនៃតួនាទីនិមួយៗ។ ឧទាហរណ៍ ជំនាញកុំព្យូទ័រ ឬជំនាញធ្វើសេចក្តីសម្រេចចិត្តដែលមានប្រសិទ្ធិភាព ហើយដែលការអភិវឌ្ឍជំនាញទាំងនោះជាការគាំទ្របន្ថែមទៅលើការបណ្តុះបណ្តាបែបចំណេះដឹង។

ចំណុចទី៣ គឺជាការបណ្តុះបណ្តាលសំដៅទៅលើអកប្បកិរិយា និងការអនុវត្តផ្សេងៗ បញ្ហានេះគឺមានពាក់ពន្ធ័ជាចំបងទៅលើការអភិវឌ្ឍ ប្រកាន់អកប្បកិរិយាបែបវិជ្ជមាននៃតួនាទីចាំបាច់នានា។ ការធ្វើការកែប្រែទំលាប់ធ្វើការងារគឺមានសារៈសំខាន់សម្រាប់អោយមន្ត្រីទាំងនោះបង្កើនសមត្ថភាពរបស់ខ្លួនសម្រាប់ផលិតការងារ ក្នុងស្ថានភាពដទៃផ្សេងទៀត បុគ្គលិកចាំបាច់ត្រូវប្រាស្រ័យជាមួយសហគមន៍ដើម្បីស្វែងយល់ពីការលំបាក និងតម្រូវការរបស់ពួកគាត់ចៀសជាងរងចាំប្រជាពលរដ្ឋមករកគាត់ជានិច្ចជាកាលដើម្បីសុំការផ្តល់សេវា។

ដើម្បីអោយបុគ្គលិកនិមួយៗអាចអនុវត្តកិច្ចការងារសម្រេចបានលទ្ធផលនឹងភាពពេញចិត្តខ្ពស់ចាំបាច់ត្រូវមានការទាមទារយ៉ាងតិច៥៖

- ចំណេះដឹងខ្ពស់និងទូលំទូលាយ

- មានការវិភាគ

- មានភាពអង់អាច

- មានភាពស្មោះត្រង់

- មានភាពសមញ្ញ

ង- ការផ្តល់ដល់បុគ្គលិកនូវការទទួលខុសត្រូវច្បាស់លាស់

គោលបំណង៖ គឺដើម្បីអនុញ្ញាតិអោយបុគ្គលិកនីមួយៗបានស្គាល់និងយល់អំពីតួនាទីរបស់ខ្លួន ក្នុងការចូលរួមសម្រេចអណត្តិរបស់រដ្ឋាភិបាលនិងស្ថាប័នមូលដ្ឋាននានា។

ដើម្បីអោយបុគ្គលិកនិមួយៗបំពេញការងារត្រឹមត្រូវចាំបាច់អោយមានការបរិយាយស្តីពីទំហំការងារ បានត្រឹមត្រូវ។ នៅពេលដែលបុគ្គលិកនិមួយៗស្គាល់ពីការងាររបស់ខ្លួនបានច្បាស់លាស់ ការផ្តល់ការណែនាំក៏នឹងថយចុះមកកំរិតអប្បបរមា ហើយនឹងផ្តល់ឱកាសអោយអ្នកដឹកនាំមានលទ្ធភាពដកឃ្លាមកពិចារណារិះរកគំនិតថ្មីប្រឌិតនានាឬក៏មកគិតគូរទៅលើការធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយ ដោយមានការប្រឹក្សាយោបល់ជាមួយនឹងប្រជាពលរដ្ឋរបស់ខ្លួន។ ស្ថាប័ននិងអង្គការចាត់តាំងមួយចំនួនបានទាមទារអោយបុគ្គលិកទាំងអស់ចុះហត្ថលេខាលើឯកសារបរិយាយការងាររបស់ខ្លួនដើម្បីធានាថាបុគ្គលិកទាំងអស់នោះបានយល់ពីការងាររបស់ខ្លួនពេញលេញ។

ច- ការកំណត់ឧបករណ៍គ្រប់គ្រងចាំបាច់នានាសម្រាប់ស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន

គោលបំណង៖ គឺដើម្បីធ្វើអោយប្រសើរឡើងបច្ចេកវិទ្យា និងបច្ចេកទេសនានាទៅតាមសមត្ថកិច្ចរបស់រដ្ឋាភិបាលមូលដ្ឋាន។

ឧបករណ៍ឌីជីតលដូចជាកុំព្យូទ័រ ជីភីអេស គឺជាឧបករណ៍សំខាន់ការធ្វើទំនើបកម្មនៃស្ថាប័នរដ្ឋបាលមូលដ្ឋានក្នុងការសិក្សានៅបណ្តាទីក្រុងនៃប្រទេសទាំង៥ ការធ្វើកុំព្យូទ័រនីយកម្មត្រូវបានជំរុញដោយថ្នាក់ដឹកនាំទីក្រុងនានា។ ឧទាហរណ៍នៅទីក្រុងយ៉ូកយាកាប្រទេសឥណ្ឌូនេស៊ីបុគ្គលិកទាំងអស់ត្រូវបានដាក់កំណត់អោយបុគ្គលិកទាំងអស់ត្រូវមានចំណេះដឹងកុំព្យូទ័រ។

ឆ- ការធ្វើវិមជ្ឈការមុខងារនិងអំណាចរបស់រដ្ឋាភិបាលមូលដ្ឋានទៅដល់អង្គភាព និងអង្គការចាត់តាំងនានារបស់ខ្លួន

គោលបំណង៖ គឺដើម្បីរៀបចំឋានានុក្រមនៃថ្នាក់ធ្វើសេចក្តីសម្រេចចិត្តនានាដែលជាផ្នែកមួយក្នុងគោលការណ៍គ្រប់គ្រងល្អ។

ស្ថាប័នឬក៏រដ្ឋបាលមូលដ្ឋានមួយដែលមានការធ្វើវិមជ្ឈការនិងការផ្ទេរមុខងារនិងអំណាចបានត្រឹមត្រូវ គឺជានាបាននូវប្រតិបត្តិការមួយដែលមានភាពរលូនរបស់ស្ថាប័ននោះបើទោះជាថ្នាក់ដឹកនាំការិយាល័យ ឬក៏រដ្ឋបាលមូលដ្ឋាននោះមិនបាននៅទីកន្លែងក៏ដោយ។

មុននឹងធ្វើសេចក្តីសម្រេចចិត្តណាមួយចាំបាច់ត្រូវសួរសំណួរចំនួន៣ដូចខាងក្រោម៖

- តើការសម្រេចនេះស្របទៅតាមច្បាប់ឬក៏យោងទៅតាមក្រម លិខិតគតិយុត្តនានាដែរឬទេ?
- តើការសម្រេចចិត្តនេះផ្អែកទៅលើគោលការណ៍សាធារណៈដែរឬទេ?
- តើការសម្រេចចិត្តនឹងទទួលបានការគាំទ្រដែរឬទេ?

ជ- ការកំណត់ទៅលើតម្រូវការនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ស្ថាប័នរដ្ឋបាលមូលដ្ឋាន

គោលបំណង៖ គឺដើម្បីបង្កើតនូវប្រពន្ធ័គ្រប់គ្រងព័ត៌មាន។ ប្រព័ន្ធព័ត៌មានរបស់ស្ថាប័នណាមួយគឺមានសារៈសំខាន់ណាស់សម្រាប់ធ្វើការសម្រេចចិត្តអោយមានប្រសិទ្ធភាព រដ្ឋបាលមូលដ្ឋាននានាចាំបាច់ត្រូវអភិវឌ្ឍអំណាចដោយផ្អែកទៅលើព័ត៌មានរបស់ស្ថាប័នខ្លួនដែលកត្តានេះអាចធ្វើអោយរដ្ឋបាលមូលដ្ឋានទាំងនោះនឹងទទួលបានការកត់សំគាល់ជាពិសេស។

ប្រព័ន្ធគ្រប់គ្រងព័ត៌មានដែលមានប្រសិទ្ធភាពកែលំអដល់កេរ្តិ៍ឈ្មោះនៃរដ្ឋបាលមូលដ្ឋាន និងធ្វើអោយរដ្ឋបាលមូលដ្ឋាននោះមានលក្ខណៈដោយឡែកខុសពីភ្នាក់ងារដទៃទៀត។ រដ្ឋបាលទីក្រុងនានាក្នុងប្រទេសតែមួយតែងតែស្ថិតនៅក្នុងដំណាក់ការផ្សេងៗគ្នាក្នុងដំណើរការអភិវឌ្ឍ។ ដូច្នេះហើយទីក្រុងនិមួយៗអាចសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក។

ឈ- ការគ្រប់គ្រងថវិការបស់រដ្ឋាភិបាលមូលដ្ឋានអោយមានប្រសិទ្ធភាព

គោលបំណង៖ គឺដើម្បីគ្រប់គ្រងធនធានរបស់រដ្ឋបាលមូលដ្ឋានដែលមានតិចតួចសម្រាប់លទ្ធផលខ្ពស់បំផុត។

ថវិការបស់រដ្ឋបាលមូលដ្ឋានណាមួយគឺជាឈាមរបស់រដ្ឋបាលមូលដ្ឋាននោះ។ ការកំណត់ថវិកាសម្រាប់គាំទ្រការអនុវត្តរបស់បុគ្គលិកនិមួយៗមានសារសំខាន់ក្នុងការគ្រប់គ្រងថវិកា និងការវិភាគចំណាយ។

ញ- ការអភិវឌ្ឍប្រព័ន្ធវាស់វែងការអនុវត្តរបស់រដ្ឋបាលមូលដ្ឋាន

គោលបំណង៖ គឺដើម្បីអាចមានលទ្ធភាពដឹងថាតើរដ្ឋបាលមូលដ្ឋានបានអនុវត្តការងារបានដូចម្តេច។

ដើម្បីធ្វើកិច្ចការនេះមានលក្ខណៈវិនិច្ឆយ័មួយចំនួនអាចយកមកប្រើប្រាស់៖

- ភាពត្រឹមត្រូវ

- ការឆ្លើយតប

- សមធម៌

- ភាពទាន់ពេលវេលា

- ប្រសិទ្ធភាព

- ប្រសិទ្ធផល

ក្នុងន័យនេះរដ្ឋបាលមូលដ្ឋានអាចរៀបចំប្រព័ន្ធផ្តល់ការលើកទឹកចិត្ត ផ្តល់រង្វាន់ និងវិន័យផ្ទៃក្នុងរបស់ខ្លួន។ គោលបំណងក្នុងការរៀបចំនេះគឺដើម្បីផ្តល់ការលើកទឹកចិត្តផ្នែកសតិអារម្មណ៍នឹងហិរញ្ញវត្ថុដល់បុគ្គលិកណាដែលមានស្នាដៃខ្ពស់។ ប្រពន្ធ័នេះក៏ដាក់ជាទោសទណ្ឌ ដល់បុគ្គលិកណាដែលមិនបានបំពេញតួនាទី និងមានគណនេយ្យភាពត្រឹមត្រូវផងដែរ។

ដ- ការអភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យតាមដាននិងវាយតំលៃ

គោលបំណង៖ គឺដើម្បីវាស់វែងការអនុវត្តរបស់ស្ថាប័ននិងចងក្រងជាការសម្រេចលទ្ធផល ឧទាហរណ៍ សូចនាករស្តីពីជោគជ័យឬការមិនសម្រេចបាននានា។

ប្រព័ន្ធត្រួតពិនិត្យតាមដាននិងវាយតំលៃនេះផ្តល់នូវលទ្ធផលមួយសំខាន់ សម្រាប់អោយមានការរៀបចំតាក់តែងនិងធ្វើផែនការណ៍ឡើងវិញ។

រដ្ឋបាលមូលដ្ឋានចាំបាច់ត្រូវបង្កើតប្រព័ន្ធនេះដើម្បីវាស់វែងការអនុវត្តស្ថាប័នរបស់ខ្លួន ការយល់ដឹងពីតំលៃប្រតិបត្តិការរបស់ខ្លួន គឺជាការព្រួយបារម្មណ៍ពីថវិកាមួយដ៏ស្របច្បាប់។ ប្រព័ន្ធតាមដាននិងត្រួតពិនិត្យក៏អនុញ្ញាតិអោយស្ថាប័ននោះមានការពិចារណាបាន ត្រឹមត្រូវទៅលើឱកាសផ្សេងៗទៀតនិងទៅលើផលលំបាកដែលជះមកលើខ្លួនជារដ្ឋបាល មូលដ្ឋាននោះផងដែរ។

ឋ- ការធ្វើសវនកម្មគ្រប់គ្រង

គោលបំណង៖ ដើម្បីវាយតំលៃទៅលើប្រព័ន្ធផ្ទៃក្នុងរបស់ស្ថាប័ន និងកំណត់ថា តើអណត្តិរបស់ខ្លួនត្រូវបានសម្រេចដែរឬយ៉ាងណា?

ការធ្វើសវនកម្មគ្រប់គ្រងចាំបាច់ប្រព័ន្ធនិងនិតិវិធីរបស់រដ្ឋបាលឬស្ថាប័នប្រជាធិបតេយ្យ នៅមូលដ្ឋាន។ ក្នុងន័យនេះស្តង់ដារនៃការអនុវត្តរបស់បុគ្គលិកត្រូវបានធ្វើការវាយតំលៃ ហើយការវិភាគទៅលើផលប្រយោជន៍ទៅលើចំណាយក៏នឹងត្រូវធ្វើឡើង ដើម្បីផ្តល់ពិន្ទុទៅ ដល់ស្ថាប័នអនុវត្តទាំងមូល។ ដំណើរការនេះនឹងអាចអោយរដ្ឋបាលមូលដ្ឋានស្ថិតក្នុងភាព ប្រុងប្រយ័ត្នជានិច្ច។

**៤-១-៣ អភិក្រមតាមបែបអ្នកពាក់ព័ន្ធច្រើន**

ក្នុងសៀវភៅនេះ អភិក្រមតាមបែបអ្នកពាក់ព័ន្ធច្រើនសំដៅទៅលើទំនាក់ទំនងមួយ ដែលទាមទារការចូលរួមពីសំណាក់បុគ្គលិករដ្ឋ ឬអ្នកផ្តល់សេវាពាក់ព័ន្ធនានាដើម្បីធ្វើការ ជាមួយគ្នាក្នុងការលើកស្ទួយនូវគុណភាព ប្រសិទ្ធភាពនិងការផ្តល់សេវាទាន់ពេលវេលារបស់ ទីក្រុង។ ក្នុងការធ្វើរបៀបនេះ ការិយាល័យនានារបស់ទីក្រុងនានាតម្រូវឲ្យធ្វើការក្រោមប្រព័ន្ធ រួមមួយ ដែលមានទាំងទម្រង់និងនិតិវិធីរួមហើយពេលខ្លះមានទាំងរចនាសម្ព័ន្ធគ្រប់គ្រងរួម ផងដែរ។

បណ្ដាទីក្រុងនានានៅក្នុងប្រទេសទាំង៥នេះ ធ្លាប់ទទួលបាននូវបទពិសោធខុសៗគ្នាជាមួយនឹងភ្នាក់ងាររដ្ឋាភិបាល ដើម្បីធ្វើការជាមួយគ្នាក្នុងការផ្ដល់នូវសេវាសាធារណៈ។ ការផ្ដួចផ្ដើមគំនិតទាំងនេះមានទាំងការបង្កើតរដ្ឋាភិបាលអេឡិចត្រូនិច និងការិយាល័យច្រកចេញចូលតែមួយផងដែរ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានធ្វើឡើងក្នុងទំរង់ជាការសាកល្បងដោយផ្ដើមគំនិតផ្ទាល់ ហើយនឹងត្រូវលើកយកមកពិភាក្សាក្នុងជំពូកទី៤ខាងក្រោម។

ក្រោមការធ្វើការជាមួយគ្នាក្នុងទំរង់និងប្រព័ន្ធតែមួយ ភ្នាក់ងារផ្សេងគ្នាមានលទ្ធភាពផ្ដល់នូវតំលៃទាបជាង និងទាន់ពេលវេលា ជាមួយនឹងតម្លាភាពលើបែបបទនានា។ ក្នុងពេលជាមួយគ្នានេះផងដែរ ប្រជាពលរដ្ឋ និងអ្នកដែលទទួលសេវាកម្ម ចំណេញបាននូវពេលវេលា និងធនធានយ៉ាងច្រើន ក្នុងការស្វែងរក ឬទទួលបាននូវព័ត៌មានពីការិយាល័យរដ្ឋាភិបាលផ្សេងៗគ្នា។

## ៤-១-៤ តម្លាភាព និង គណនេយ្យភាព ជាគោលការណ៍សំខាន់សម្រាប់ស្ថាប័នរដ្ឋ

តម្លាភាពក្នុងស្ថាប័នរដ្ឋទាមទារឲ្យការសម្រេចចិត្តទាំងអស់ និង ការដាក់ចេញនៃការអនុវត្តការសម្រេចចិត្តទាំងនោះដោយពឹងផ្អែកលើក្របខ័ណ្ឌច្បាប់ ដែលមានន័យថារាល់ព័ត៌មានដែលទាក់ទងទៅនឹងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្តត្រូវតែសាមញ្ញ និងពិតប្រាកដ និងការចែករំលែកដោយបើកចំហរ និងងាយស្រួលទទួលបានជាសាធារណៈជាពិសេសសម្រាប់អ្នកដែលនឹងទទួលឥទ្ធិពលពីការធ្វើសេចក្ដីសម្រេចចិត្ត និងការអនុវត្តន៍នោះ។

ពាក្យថា គណនេយ្យភាព មាននិយមន័យច្រើនយ៉ាងក្នុងន័យជាអន្តរជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ គណនេយ្យភាព ក្នុងឯកសារការអនុវត្តល្អនេះសំដៅលើភាពទទួលខុសត្រូវរបស់អ្នកណាម្នាក់ និងសិទ្ធិអំណាចដើម្បីប្រតិបត្តិទៅតាមមុខងារ និងផលលំបាកដែលទទួលបានពីការអនុវត្តមុខងារនោះ។ មានន័យថាស្ថាប័នរបស់ទីក្រុងប្រតិបត្តិនូវមុខងាររបស់ខ្លួនតាមបែបវិមជ្ឈការ និងទទួលខុសត្រូវពេញលេញទៅលើការងាររបស់ខ្លួនតាមរយៈការធ្វើរបាយការណ៍ និងពន្យល់នូវហេតុផលសម្រាប់ការធ្វើសេចក្ដីសម្រេចចិត្ត។ ជនទាំងនោះ

ក៏ទទួលបាននូវផលលំបាកពីការងាររបស់ខ្លួនយ៉ាងពេញលេញផងដែរ។ គេត្រូវតែទទួលខុសត្រូវ និងមានគណនេយ្យភាពជាមួយអ្នកទទួលសេវា និងការជះឥទ្ធិពលពីសកម្មភាពរបស់ខ្លួនមកវិញ។

តម្លាភាព និងគណនេយ្យភាព ដែលបានផ្សព្វផ្សាយក្នុងទំរង់ផ្សេងៗនានា ក្នុងចំណោម៥ប្រទេសដែលបានប្រតិបត្តិមានស្ថានភាពនិងលក្ខណៈខុសគ្នាយ៉ាងខ្លាំង។ តាមរយៈការផ្តល់សេវាកម្មសាធារណៈរបស់ខ្លួន ដែលមានដូចជាច្បាប់បញ្ញត្តិ នៃប្រទេសទាំង៥ខាងលើបង្កើតបានជាមូលនិធិ និងក៏អាចផ្តល់ការលើកទឹកចិត្តដល់ទីក្រុងក្នុងការចែករំលែកនូវព័ត៌មានជំរុញឲ្យមានការចូលរួមពីប្រជាជន ការប្រឹក្សា ក៏ដូចជាការត្រួតពិនិត្យតាមដាន និងវាយតំលៃទៅលើការងារនៃស្ថាប័នសាធារណៈ។ ដូច្នេះរដ្ឋាភិបាលក្រុងមួយគួរតែផ្តោតសំខាន់លើឧបករណ៍សមរម្យក្នុងការលើកកម្ពស់នូវតម្លាភាព និងគណនេយ្យភាពសម្រាប់ការផ្តល់នូវសេវាសាធារណៈរបស់ខ្លួន។ ឧបករណ៍ទាំងនោះមានដូចជា:

- ការចែករំលែកនូវសេចក្តីព្រាងអំពីសេចក្តីសម្រេចដល់សាធារណៈជាមុន
- ការចែករំលែកឯកសារនានា និងរបាយការណ៍
- សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការស្វែងរកនិងទទួលបាននូវព័ត៌មាន និងការបង្ហាញនូវសេចក្តីសម្រេចរបស់ក្រុង (រួមមាន អត្រាសេវាកម្ម និងថ្លៃ)
- សាមាជ/ការប្រឹក្សា/ដំណើរការពិគ្រោះយោបល់
- ការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត
- ការផ្តល់ព័ត៌មានពីការអនុវត្តការងារ
- ការពិភាក្សាជាសាធារណៈពីការងារប្រចាំឆ្នាំរបស់ការិយាល័យសាធារណៈ
- ការត្រួតពិនិត្យ ឬផ្តល់មតិត្រលប់

ឯកសារស្តីពី"ការអនុវត្តតាមបែបការចូលរួមរបស់សហព័ន្ធទីក្រុងកាណាដា (FCM)" បានបរិយាយយ៉ាងលំអិតពីឧបករណ៍អនុវត្តទាំង១៥ក្នុងការបង្កើននូវគំរិតនៃការយល់ដឹង

នៃការចេញផ្សាយពីផែនការ និងសេចក្តីសម្រេចរបស់សាលាក្រុងជា សាធារណៈដើម្បីផ្តល់ដល់អ្នកដឹកនាំរដ្ឋបាលមូលដ្ឋានជាមួយនឹងដំណោះស្រាយដ៏ល្អសម្រាប់អាទិភាពជាសាធារណៈ ក៏ដូចជាជំរុញសាធារណៈឲ្យមានការ ពាក់ព័ន្ធកាន់តែខ្លាំងនៅក្នុងការងាររដ្ឋាភិបាល។ សេចក្តីលំអិតអំពីវិធីរៀបចំ និងចាត់ចែងទាំងនេះមានដូចតទៅ:

- ការផ្សព្វផ្សាយព័ត៌មាន
- មជ្ឈមណ្ឌលធនធានព័ត៌មាន
- ការធ្វើការប្រឹក្សាជាមួយសហគមន៍
- ក្តារប្រកាសព័ត៌មានអេឡិចត្រូនិច
- ការប្រជុំសាធារណៈ
- ដំណឹងសាធារណៈ
- ការរៀបចំផ្ទះចំហរ
- សិក្ខាសាលា
- ការពិគ្រោះយោបល់លើផែនការជាក់លាក់ដោយឡែក
- ក្រុមគោលដៅ
- ការអង្កេត
- ការចូលរួមក្នុងកម្មវិធីទូរទស្សន៍
- ការចរចារ
- ការបង្កើតក្រុមប្រជាជនផ្តល់ការពិគ្រោះយោបល់
- ការធ្វើប្រជាមតិ

ឧបករណ៍ទាំងនេះជាកូនសោរដ៏សំខាន់សម្រាប់រដ្ឋបាលក្រុង ក្នុងការផ្តោតទៅលើការជំរុញឲ្យមានតម្លាភាព និងគណនេយ្យភាពក្នុងការិយាល័យសាធារណៈរបស់ខ្លួន។ សម្រាប់ប្រទេសទាំង៥ក្នុងតំបន់អាស៊ីអាគ្នេយ៍មានឧបករណ៍ខ្លះល្អជាងប្រទេសផ្សេងទៀត ហេតុនេះហើយគួរផ្តោតការយកចិត្តទុកដាក់ទៅលើឧបករណ៍ទាំងនោះ។ បន្ថែមពីនេះទៀត ក៏មានឧទាហរណ៍ជាក់ស្តែងនានាពីលក្ខណៈនៃឧបករណ៍ខ្លះ ដែលនឹងត្រូវយកមកពិភាក្សាក្នុងការអនុវត្តន៍ល្អរបស់ប្រទេសនិមួយៗនៅផ្នែកខាងក្រោម។

ដើម្បីលើកស្ទួយគណនេយ្យភាព និងធ្វើឲ្យប្រសើរឡើងនូវការផ្តល់សេវាប្រទេសខ្លះបានបង្ហាញ ពីការបង្កើតនូវប្រព័ន្ធបណ្តឹង/យន្តការមតិរិះគន់ ដែលមានអត្ថន័យផ្សេងៗគ្នាតាមរយៈប្រអប់មតិរិះគន់ ទូរស័ព្ទ ទូរសារ សារជាអក្សរ អ៊ីម៉ែល ឬការិយាល័យប្រជាពលរដ្ឋ។ ក្នុងន័យនេះដែរការិយាល័យប្រជាពលរដ្ឋ មានន័យថាបុគ្គលឬការិយាល័យ ឯករាជ្យដែលត្រូវបានផ្តល់ដោយរដ្ឋធម្មនុញ្ញរបស់ប្រទេស ឬដោយច្បាប់លិខិតគតិយុត្តិនានារបស់រដ្ឋាភិបាល អាចត្រូវបានតែងតាំងដោយក្រុមប្រឹក្សាបញ្ញត្តិ ឬត្រូវបានជ្រើសរើស ដោយក្រុមចំរុះ (ដែលមាន ក្រុមប្រឹក្សាក្រុង តំណាងពីអង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុនពាណិជ្ជកម្ម) ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការទទួលពាក្យបណ្តឹងពីជនរងគ្រោះពីសំណាក់មន្រ្តី និងបុគ្គលិកភ្នាក់ងារសាលាក្រុង។ ក្នុងករណីខ្លះ ការិយាល័យប្រជាពលរដ្ឋ មានអំណាចក្នុងការធ្វើអធិការកិច្ចទៅលើឯកសារសំខាន់ទាំងអស់ ផ្តល់មតិក្នុងការកែតម្រូវ ចេញនូវរបាយការណ៍ឯករាជ្យនានាដល់ ក្រុមប្រឹក្សាក្រុង រឺក៏អង្គការចាត់តាំងថ្នាក់លើ (មានដូចជា ក្រសួងមហាផ្ទៃ) ឬក៏ចចារជាមួយនឹងរដ្ឋបាលរបស់ក្រុង។

តាមរយៈការបកស្រាយខាងលើ យើងអាចធ្វើការសន្និដ្ឋានមួយថា ការិយាល័យប្រជាពលរដ្ឋ ថែរក្សាការពារ និងរក្សាភាពស្អាតស្អំរបស់រដ្ឋបាលក្រុងពីអំពើពុករលួយ និងការរំលោភសិទ្ធិអំណាច។ ក្នុងន័យនេះដែរការបង្កើតនូវមុខងាររបស់ការិយាល័យប្រជាពលរដ្ឋជួយដល់រដ្ឋបាលក្រុងក្នុងការលើកកម្ពស់នូវគុណភាព ប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈទាន់ពេលវេលាទៅតាមយុត្តាធិការរបស់ខ្លួន ហើយនេះជាមូលហេតុដែលធ្វើឲ្យភាពមិនពេញចិត្តពីសំណាក់ប្រជាពលរដ្ឋចំពោះរដ្ឋាភិបាលសាលាក្រុងមានភាពថយចុះ ។

### ៥-២ ការអនុវត្តល្អក្នុងស្ថាប័នរដ្ឋក្នុងអាស៊ីអាគ្នេយ៍ (ករណីសិក្សា)

ដូចដែលបានបកស្រាយក្នុងជំពូកមុនៗរួចមកហើយថា ប្រទេសទាំង៥ក្នុងតំបន់អាស៊ីអាគ្នេយ៍នេះស្ថិតក្នុងដំណាក់កាលនៃវិមជ្ឈការខុសៗគ្នា ដោយយោងទៅលើប្រវត្តិសាស្ត្រ ស្ថេរភាពនយោបាយ រដ្ឋបាល បរិបទសារពើពន្ធ និងលទ្ធភាពនៃឧស្សាហកម្មរៀងៗខ្លួន។ ដោយយោងតាមរយៈភាពខុសគ្នាទាំងនេះ សៀវភៅនេះធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងបាននូវការអនុវត្តល្អខ្លះអំពីកិច្ចខិតខំប្រឹងប្រែងដែលក្រុងនានាបានអនុវត្ត ក្នុងគោលដៅលើកស្ទួយនូវប្រសិទ្ធភាពស្ថាប័នពីក្នុងបណ្តាប្រទេសទាំង៥នេះ។ គំរូនៃការអនុវត្តល្អទាំងនេះមិនអាចធ្វើការប្រៀបធៀបគ្នាបានទេ (ដោយសារភាពខុសគ្នាដោយឡែកកើតមាននៅក្នុងស្រុកទៅតាមនយោបាយនៃប្រទេសនិមួយៗ និងបរិបទនៃការអនុវត្តវិមជ្ឈការ) ប៉ុន្តែអាចផ្តល់នូវដំណោះស្រាយមួយដែលអាចទៅរួច និងគំនិតផ្តួចផ្តើមដល់ទីក្រុងនានាក៏ដូចជាអង្គការនានាដែលពាក់ព័ន្ធ ជាមួយនឹងស្ថានភាព នយោបាយ និងលទ្ធភាពខុសគ្នា ក្នុងការព្យាយាមធ្វើឲ្យប្រសើរនូវប្រសិទ្ធភាពនៃស្ថាប័នរដ្ឋ។

### ៤-២-១ រដ្ឋាភិបាលអេឡិចត្រូនិចដើម្បីពង្រឹងការអនុវត្ត និងផ្តល់សេវារបស់ក្រុងយ៉ូកយ៉ាកាតាប្រទេសឥណ្ឌូនេស៊ី

យ៉ូកយ៉ាកាតា គឺជាតំបន់ទីរួមខេត្តមួយ និងមានទីតាំងនៅកណ្តាលតំបន់ពិសេសរបស់ខេត្តយ៉ូកយ៉ាកតា។ ខេត្តនេះមានស្រុកនិងក្រុងសរុមចំនួនបួន គឺ បានដុល ស្លេមាន ហ្គូណាំង គីឌុល និងគូលុនប្រូហ្គោ។ ទីក្រុងយ៉ូកយ៉ាកាតា ស្ថិតនៅរយៈកំពស់១១៤ម៉ែត្រពីកំរិតនៃទឹកសមុទ្រ។ ទីក្រុងយ៉ូកយ៉ាកាតា មានទំហំ៣២,៥ គីឡូម៉ែត្រការេ ឬ ១.០២៥ភាគរយនៃទំហំសរុបរបស់ខេត្តយ៉ូកយ៉ាកាតា។

យោងតាមការស្រង់ស្ថិតិប្រជាជននាឆ្នាំ២០១០ ទីក្រុងយ៉ូកយ៉ាកាតាមានប្រជាជនចំនួនប្រហែល ៣៨៨,០៨៨ ឬ ១១.២ ភាគរយនៃតំបន់ពិសេសខេត្តយ៉ូកយ៉ាកតាដែលមានចំនួនប្រជាជន ៣,៤៥២៣៩ លាន (ប្រុស=១,៧០៥,៤០៤ និង ស្រ្តី=១,៧៤៦,៩៨៦)។ សេដ្ឋកិច្ចទីក្រុងយ៉ូកយ៉ាកាតា ត្រូវបានពឹងផ្អែកលើផលិតផលមិនមែនជាធនធានប្រេង និងឧស្ម័ន។ ទីក្រុងយ៉ូកយ៉ាកាតាបាននាំចេញផលិតផលមានតំលៃ២៩,៩៥២,៨៣៧.០៧ ក្នុងឆ្នាំ២០០៨។

## រដ្ឋាភិបាល ឬរដ្ឋបាលអេឡិចត្រូនិច

រដ្ឋាភិបាលតាមបែបអេឡិចត្រូនិច គឺជាការបង្កើតឲ្យមានទំនាក់ទំនង ប្រកបដោយភាពងាយស្រួល តម្លាភាព និងមានតំលៃទាប រវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ រវាងរដ្ឋាភិបាល និងសហគ្រាស ក្រុមហ៊ុននានា រួមនឹងទំនាក់ទំនងរវាងភ្នាក់ងារនានា របស់រដ្ឋាភិបាលខ្លួនឯងផងដែរ។ មិនតែប៉ុណ្ណោះ វិស័យ internet បានបង្កើតនូវឱកាសថ្មីៗជាច្រើន ដែលធ្វើឲ្យការធ្វើទំនាក់ទំនងរវាងរដ្ឋាភិបាលនិងអ្នកគ្រប់គ្រងតាមតំបន់ អាចឆ្លងឆ្លើយជាមួយនឹងប្រជាជនរបស់ខ្លួនតែមានភាពងាយស្រួល។ អាជ្ញាធរមូលដ្ឋានជាច្រើនទាំងទីក្រុងក្នុងប្រទេសអភិវឌ្ឍនិងកំពុងអភិវឌ្ឍន៍ បានបង្កើតនូវគេហទំព័រសម្រាប់ ប្រទេសរបស់ខ្លួន។ ប្រទេសខ្លះថែមទាំងប្រើប្រព័ន្ធអ៊ិនតែណិតសម្រាប់ធ្វើប្រតិបត្តិការលើសេវាជាច្រើនជាមួយនឹងអ្នកទទួលសេវា និងប្រជាពលរដ្ឋទូទៅ ក្នុងពេលដែលប្រទេសខ្លះស្ថិតនៅក្នុងដំណាក់កាលបង្កើតនូវគោលការណ៍និងការអនុវត្តរដ្ឋបាលបែបអេឡិចត្រូនិចនេះ។ ភាពខុសគ្នានេះបញ្ជាក់ឲ្យឃើញថាការអនុវត្តនេះមិនអាចបើកទូលាយឲ្យប្រទេសដែលមានប្រព័ន្ធinternet មានកំណត់នោះទេក៏ប៉ុន្តែវាក៏ជាសញ្ញាណមួយនៃការបង្កបង្កើតគំនិតនិងបរិបទការងារថ្មីផងដែរ។ រដ្ឋបាលតាមបែបអេឡិចត្រូនិច ជាទូទៅអាចអនុវត្តបានលុះត្រាណាតែប្រជាពលរដ្ឋក្នុងសហគមន៍អាចប្រើប្រាស់អ៊ិនតែណិតរបស់ខ្លួនបាន ក្នុងន័យចូលរួមលើកស្ទួយតម្លាភាព និងការតាមដានការអនុវត្តនានា។

រាល់ព័ត៌មានដែលបង្ហោះទៅលើអ៊ិនធ័រណិតត្រូវផ្តល់ភាពងាយស្រួលឲ្យប្រជាពលរដ្ឋទាំងអស់អាចចូលអានបាន។ ជាការពិតណាស់ ត្រូវមានការឆ្លងកាត់ជាមុនសិន ក្នុងការសម្រេចចិត្តផ្នែកនយោបាយ ដើម្បីដាក់ព័ត៌មានទាំងនោះជាសាធារណៈ។ ការផ្តល់ឲ្យនូវព័ត៌មាន ទាំងផ្នែកទូទៅ ឬជាក់លាក់ណាមួយទៅក្នុងគេហទំព័រ នឹងអាចពង្រឹងទំនាក់ទំនងរួមទាំងការជឿទុកចិត្តរវាងអ្នកចូលរួម និងភ្នាក់ងារសាធារណៈ ហើយការធ្វើបែបនេះ និង

ចូលរួមបង្កើតឲ្យមានប្រជាពលរដ្ឋប្រកបដោយចំណេះដឹង និងសហាគមន៍មួយប្រកប ដោយតម្លាភាព។

វត្ថុបំណង

- ដើម្បីបង្កើនបរិមាណព័ត៌មានស្តីពីសកម្មភាពរបស់រដ្ឋបាលមូលដ្ឋានជូនដល់សាធារណជន
- ដើម្បីបង្កើនប្រសិទ្ធភាពជាអតិបរមាក្នុងការភ្ជាប់បណ្តាញជាមួយប្រជាពលរដ្ឋ (ពង្រីកសក្តានុពលភាពបណ្តាញទំនាក់ទំនង និងធ្វើឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាងសាធារណៈទូទៅនិងភ្នាក់ងារនានាមានល្បឿនលឿន)

**ធាតុសំខាន់ៗ**

រដ្ឋបាលតាមបែបអេឡិចត្រូនិច ប្រើប្រាស់internetក្នុងការចែករំលែកព័ត៌មាន។ ជាដំបូងគេត្រូវការឲ្យមានការប្តេជ្ញាចិត្ត ដោយរដ្ឋាភិបាលមូលដ្ឋាន ឬអង្គភាព ដែលដាក់បង្ហាញព័ត៌មានក្នុងគេហទំព័រ និងរក្សាឲ្យមានគេហទំព័រទាន់ហេតុការណ៍។ ដូច្នេះ គេត្រូវការធនធានមនុស្ស និងហិរញ្ញវត្ថុ ក៏ដូចជាគ្រឿងអេឡិចត្រូនិចពីអង្គភាពទទួលខុសត្រូវ។ ដើម្បីធ្វើឲ្យវិធីសាស្ត្រនេះអាចដំណើរការបាន និង ដើម្បីឲ្យមានលទ្ធផលល្អក្នុងទីក្រុងណាមួយ ក្រុងសង្កាត់ ឬភូមិ ត្រូវបានតួនាទីក្នុងការផ្សព្វផ្សាយចំណេះដឹង ផ្នែកកុំព្យូទ័រ និងភាពងាយស្រួលក្នុងការចូលទៅកាន់internet សម្រាប់ប្រជាជនក្នុងតំបន់។ រដ្ឋបាលតាមបែបអេឡិចត្រូនិចអាចប្រើប្រាស់បានសម្រាប់៖

- ផ្តល់ព័ត៌មានទូទៅក្នុងក្រុង
- ត្រួតពិនិត្យការបោះឆ្នោតមូលដ្ឋាន
- ផ្សាយជាសាធារណៈពីការជួបប្រជុំ ឬការដោះស្រាយ ។ល។
- រាយការណ៍ពីការប្តឹង ការព្រួយបារម្ភ និងគ្រោះអាសន្នរបស់សហាគមន៍មូលដ្ឋាន
- ការរក្សាទុកនូវលិខិតអនុញ្ញាតនានាពីសំណាក់ប្រជាជនក្នុងតំបន់
- បើកឲ្យមាននីតិវិធី និងការដេញថ្លៃ ឬការស្នើសុំផ្នែកស៊ីវិលនានា ។ល។

## <u>ករណីរដ្ឋបាលតាមបែបអេឡិចត្រូនិច ក្រុងយូកយ៉ាកាតាប្រទេសឥណ្ឌូនេស៊ី</u>

គោលបំណងរបស់ក្រុងយូកយ៉ាកាតាក្នុងការបង្កើត និងអនុវត្តការអនុវត្តល្អនៃរដ្ឋបាលអេឡិចត្រូនិចនេះគឺៈ

- ប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្ហាញពីតម្លាភាព រដ្ឋបាលរបស់រដ្ឋាភិបាល
- បង្កើតឲ្យមានការចូលរួមពីសំណាក់សាធារណជនតាមរយៈសកម្មភាព អភិវឌ្ឍន៍របស់រដ្ឋាភិបាលគ្រប់ដំណាក់កាលទាំងអស់តាំងពីដំណាក់ការរៀបចំធ្វើផែនការ ការអនុវត្ត រហូតដល់ដំណាក់កាលវាយតម្លៃ
- ពង្រីកបន្ថែមរាល់ទម្រង់ការងាររបស់រដ្ឋបាលក្រុងសម្រាប់ការផ្តល់សេវាសាធារណៈ

### សមាសធាតុនានានៃរដ្ឋបាលតាមបែបអេឡិចត្រូនិច ក្រុងយូកយ៉ាកាតា

### រដ្ឋបាលអេឡិចត្រូនិច និងច្រកចេញចូលតែមួយដែលមានប្រព័ន្ធរដ្ឋបាលដូចគ្នា

តាមរយៈវិធីសាស្ត្រនេះ ប្រជាពលរដ្ឋម្នាក់ៗអាចបញ្ចប់ការងារដែលពាក់ព័ន្ធនឹងរដ្ឋបាលរៀងៗខ្លួនក្នុងពេលជាមួយគ្នាតាមរយៈព័ត៌មានកាន់តែច្បាស់ តំលៃសមរម្យ និងទាន់ពេលវេលា។ បន្ទាប់មកទីក្រុងយូកយ៉ាកាតាបានទទួលយកប្រព័ន្ធនេះដាក់ចូលជាសេវាមួយក្នុងរដ្ឋាភិបាលអេឡិចត្រូនិចសម្រាប់បំរើដល់សាធារណជន។

- ពន្ធតាមប្រព័ន្ធអេឡិចត្រូនិចៈ ជាមួយនឹងប្រព័ន្ធ online នេះប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងនេះ ឥឡូវ អាចស្វែងរកព័ត៌មានពីពន្ធដី និងផ្ទះដែលវាស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ក្រុងយូកយ៉ាកាតា និងយល់ដឹងពីប្រភេទពន្ធអាករផ្សេងៗទៀត។

- អាជ្ញាប័ណ្ណអេឡិចត្រូនិច

  ក្នុងឆ្នាំ២០០៦ក្រុងយូកយ៉ាកាតា បានសម្រេចក្នុងការរៀបចំនូវសេចក្តីអនុញ្ញាតនានាដែលពាក់ព័ន្ធគ្រប់សេវាទាំងអស់ ស្ថិតនៅក្រោមស្ថាប័នមួយដែលមានឈ្មោះថាការិយាល័យអាជ្ញាប័ណ្ណ ដែលប្រើប្រាស់ដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ក្រោយមកប្រជាពលរដ្ឋក្នុងទីក្រុងយូកយ៉ាកាតាអាចដាក់ពាក្យ

និងស្វែងរកបាននូវអាជ្ញាប័ណ្ណជាច្រើនប្រភេទដែលមាននៅក្នុងគេហទំព័ររបស់ក្រុង។ រហូតមកដល់បច្ចុប្បន្ននេះមានអាជ្ញាប័ណ្ណចំនួន២៩ដែលទាក់ទងនឹងការគ្រប់គ្រងនិងប្រើប្រាស់សម្បទានសាធារណៈនៅក្នុងទីក្រុងយូកយ៉ាកាតា។ សេវាទាំងនេះរួមមាន ការចុះបញ្ជីក្រុមហ៊ុន បណ្ណាគារ ការដាក់ពាក្យខ្ចីប្រាក់ និងធ្វើអត្តសញ្ញាណប័ណ្ណ។ល។

- ការផ្តល់ប្រឹក្សាពីការរៀនសូត្រដល់សិស្សនិសិត្សតាមប្រព័ន្ធអ៊ិនធរណែត៖នេះគឺជាការផ្តល់ការប្រឹក្សាសិក្សាតាមអ៊ិនធ័រណែតសម្រាប់សិស្សអនុវិទ្យាល័យនិងវិទ្យាល័យ ដែលសិស្សទាំងនោះអាចចូលទៅក្នុងគេហទំព័រ www.jogjakota.go.id ឬតាមលេខទូរស័ព្ទពិសេស និងអ៊ីមែលផងដែរ។ ការផ្តល់ប្រឹក្សាជារបៀបមួយដែលអនុញ្ញាតឲ្យសិស្សទាំងអស់ពិភាក្សាអំពីប្រធានបទនានា ឬទិដ្ឋភាពនានាជាមួយគ្រូទទួលបន្ទុកចំនួន២នាក់ (កាលវិភាគត្រូវបានរៀបចំដោយរដ្ឋាភិបាល) ដែលមិនប៉ះពាល់ដល់ម៉ោងសិក្សារបស់សិស្សទាំងនោះឡើយ។

- ទំនាក់ទំនងអន្តរនាយកដ្ឋាន៖ នាយកដ្ឋាន និងផ្នែកផ្សេងៗទៀតទាក់ទងគ្នាទៅវិញទៅមកតាមរយៈគេហទំពរ័មួយ ដែលអាចចែករំលែកព័ត៌មានពីគ្នាទៅវិញទៅមក សំណូមពរ ពាក្យបណ្តឹងនានាដែលខ្លួនទទួលបាន។ សម្រាប់ប្រជាពលរដ្ឋវិញ អន្តរទំនាក់ទំនងនេះធ្វើឲ្យគាត់ទទួលបានព័ត៌មានពីក្នុងបណ្តាញរដ្ឋបាលក្រុងកាន់តែប្រសើរជាងមុន ។

**ប្រព័ន្ធអេឡិចត្រូនិចសម្រាប់កិច្ចការផ្ទៃក្នុង រួមមាន**

- ការជ្រើសរើសបុគ្គលិកតាមប្រព័ន្ធអេឡិចត្រូនិច
- ការធ្វើលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិច

**ផ្នែកទំនាក់ទំនងសាធារណៈតាមបែបអេឡិចត្រូនិច រួមមាន**

- វេទិកាប្រជាពលរដ្ឋតាមប្រព័ន្ធអ៊ិនធរណែត

- សេវាកម្មព័ត៌មាន និងផ្នែកទទួលពាក្យបណ្តឹង

**លទ្ធផលសង្ខេប**

កំណែទម្រង់ថ្មី និងប្រតិបត្តិការពីរដ្ឋបាលអេឡិចត្រូនិចរបស់ទីក្រុងយូកយ៉ាកាតាបានបង្ហាញឲ្យឃើញនូវលទ្ធផលដ៏ជាក់ស្តែង និងជះឥទ្ធិពលទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដូចជា:

លទ្ធផលដែលបានមកពីកម្មវិធី "On-line Student Learning Consultation" មានសាលារាប់ពាន់ដែលក្នុងកំរិតពីថ្នាក់បឋមរហូតដល់វិទ្យាល័យមានលទ្ធភាពទទួលបាននូវកន្លែងសម្រាប់វឌ្ឍនភាពនៃការសិក្សាតាមរយៈ Student Learning Consultation នេះ។ នេះគឺជាវិធីដោះស្រាយតាមអ៊ិនធរណែតមួយដែលអនុញ្ញាតិឲ្យសិស្សរៀនសូត្រពីគ្នាទៅវិញទៅមកតាមអ៊ិនធរណែតដោយពិភាក្សាពីសំណួរសម្រាប់ប្រលងនៅសាលាជាច្រើនទៀត។

The on-line procurement system ពាក់ព័ន្ធជាមួយនឹងការបង្កើតក្រុមការងារចំនួន៧ក្រុមដែលមានសិទ្ធិក្នុងការជ្រើសរើស និងសម្រេចទៅលើពាក្យស្នើសុំដេញថ្លៃ។ ដើម្បីចៀសវាងកុំឱ្យការសម្រេចនោះពឹងលើមនុស្សតែម្នាក់ក្នុងដំណើរការដេញថ្លៃ ដូចនេះE-Procurement System បានជួយកាត់បន្ថយការសូកប៉ាន់ទៅលើមន្ត្រីរដ្ឋាភិបាលក្រុង។

ចំណែកឯតម្លាភាពវិញ អាជ្ញាប័ណ្ណខ្លះដែលកាលពីមុនប្រើរយៈពេលក្នុងកិច្ចដំណើរការអស់១៤ថ្ងៃ ដែលឥលូវនេះអាចបញ្ចប់ក្នុងរយៈពេលតែ២ឬ៣ថ្ងៃប៉ុណ្ណោះ។ សាធារណជនអាចតាមដាននូវស្ថានភាពនៃការសុំអាជ្ញាប័ណ្ណរបស់ខ្លួនយ៉ាងងាយស្រួល។ មន្ត្រីរដ្ឋាបាលក្រុងមិនអាចទារថ្លៃលើសខុសពីច្បាប់ក្នុងទម្រង់ "enveloped money" បានទៀតទេចាប់តាំងពីរាល់តំលៃទាំងអស់ត្រូវបានដាក់បង្ហាញជាសាធារណៈនៅក្នុងគេហទំព័ររបស់ក្រុងមក។ ការអង្កេតពីសំណាក់ក្រុមហ៊ុនហិរញ្ញវត្ថុអន្តរជាតិមួយក្នុងឆ្នាំ២០០៩ បានឲ្យពិន្ទុទីក្រុងយូកយ៉ាកាតាជាប់ចំណាត់ថ្នាក់លេខ៥ខាង Investment-Friendly ក្នុងចំណោម១៨៣ទីក្រុងទៀតក្នុងពិភពលោក។

ក្នុងករណីខ្លះ គេហទំព័រក៏មានឥទ្ធិពលក្នុងការទាក់ទាញការវិនិយោគដល់ក្រុងយូកយ៉ាកាតាផងដែរ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០០៩ ទីក្រុងនេះបានទទួលរង្វាន់

ដែលមានឈ្មោះថា "ទីក្រុងទទួលបានដើមទុនវិនិយោគទុនច្រើនជាងគេប្រចាំឆ្នាំ២០០៩" ដោយផ្តល់ដោយNational Coordinating Body Capital Investment (BKPM)។ ទីក្រុងយូកយ៉ាកាតាបានឈ្នះពានរង្វាន់ទីមួយក្រោមប្រធានបទពីរគឺៈ ប្រសិទ្ធភាពពេលវេលា និងការកាត់បន្ថយ លុយក្រោមតុ សម្រាប់ដំណើរការអាជ្ញាប័ណ្ណ។

## ៤-២-២ អភិបាលកិច្ចតាមរយៈភាពជាដៃគូរវាងសាលាក្រុង និងសហាគមន៍ព្រឹកក្នុងប្រទេសថៃ

### ក- ការអត្ថាធិប្បាយពីសាលាក្រុងព្រឹក

សាលាក្រុងព្រឹកមានទីតាំងស្ថិតនៅឃុំព្រឹក ស្រុកសាដាវ ខេត្តសងក្លា ភាគខាងត្បូងនៃប្រទេសថៃ។ ក្រុងនេះស្ថិតជាប់នឹងព្រំប្រទល់ថៃ-មាឡេស៊ីក្នុងចំងាយតែ៨គីឡូម៉ែត្រប៉ុណ្ណោះដែលមានប្រជាជនចំនួន ៦១១៥នាក់ និង១៥១២គ្រួសារក្នុងឆ្នាំ២០០៩។ ទីក្រុងព្រឹកមាន៧សហាគមន៍ដែលមាន សហាគមន៍ព្រឹកទុក សហាគមន៍ វ៉ានណៃ សហាគមន៍ ថាឡាដតៃបានក្លាង សហាគមន៍ ថាឡាដព្រឹក សហាគមន៍ ថុងអោក សហាគមន៍ សោនមុំ និងសហាគមន៍ព្រឹកតៃ ដែលសកម្មភាពសំខាន់ៗរបស់ពួកគេ គឺសកម្មភាពសាសនា និងមុខរបរប្រចាំក្រុម។

- សហាគមន៍ព្រឹកទុកបានបង្កើតឡើងតាំងពីឆ្នាំ១៩៣៨ និងមានប្រជាជន រស់នៅក្នុងសហាគមន៍នេះចំនួន៨៨៩ ដែលក្នុងនោះមានប្រុស៤៨៧ និងស្ត្រី៤០២ (តាមទិន្នន័យខែមិនាឆ្នាំ២០១០)។ មុខរបរចំបងប្រចាំក្រុមនៅក្នុងសហាគមន៍នោះគឺបំពងខ្ទឹមបារាំង និងចិញ្ចឹមត្រីឆ្លាំង។

- សហាគមន៍ វ៉ានណៃ ដែលមានឈ្មោះពីមុនគេហៅថា បានថាឡាដនក (ស្ថិតនៅខាងក្រៅផ្សារ) ហើយមានប្រជាជនចំនួន៦៣២ ប្រុស៣១២ និងស្ត្រីចំនួន ៣២០ (តាមទិន្នន័យ ខែមិនាឆ្នាំ២០១០)។ មុខរបរប្រចាំក្រុមនៅក្នុងសហាគមន៍ វ៉ានណៃ នេះគឺ ធ្វើបង្អែមប្រពៃណីថៃ។

- សហគមន៍ ថាឡាដតែបានក្លាង កើតចេញមកពីតំបន់ភាគខាងត្បូងនៃសហគមន៍ថាឡាដទុក (ថាឡាដតៃ) ហើយសហគមន៍នេះមានទីតាំងនៅចំកណ្ដាលទីក្រុងព្រឹក (បានក្លាង)។ ក្នុងអំឡុងសង្គ្រាមលោកលើកទី២ សហគមន៍នេះបានក្លាយជាជំរុំសម្រាប់ទ័ពជប៉ុន។ ដែលមានប្រជាជនរស់នៅចំនួន១០៥៦ ប្រុស៥២៨ និងស្ត្រី៥២៨ (តាមទិន្នន័យខែមិនាឆ្នាំ២០១០)។ មុខរបរចំបងប្រចាំក្រុមរបស់សហគមន៍នេះគឺ ធ្វើបង្អែម និងទឹកម្ទេស។ លើសពីនេះទៀតការធ្វើធនាគារកែច្នៃសម្រាមបានចាប់ផ្ដើមពីសហគមន៍នេះឯង។

- សហគមន៍ ថាឡាដព្រឹក ធ្លាប់ជាតំបន់សំខាន់សម្រាប់សហគមន៍ផ្សារ។ ប្រជាពលរដ្ឋខ្លះក្នុងតំបន់នេះបានធ្វើចំណាកពីសហគមន៍ដោយសារខនភាពនៃសេដ្ឋកិច្ច។ ប៉ុន្តែបន្ទាប់ពីសហគមន៍នេះទទួលបានសន្តិភាពឡើងវិញ ប្រជាជនទាំងនោះក៏បានវិលត្រលប់មករស់នៅទីនេះវិញ។ សហគមន៍នេះមានប្រជាពលរដ្ឋរស់នៅទាំងអស់៩៣៣នាក់ ហើយក្នុងមានប្រុស៣៧៦ ស្ត្រី ៥៥៧នាក់ ដែលក្នុងនោះភាគច្រើនជាជនជាតិថៃកាត់ចិន (តាមទិន្នន័យខែមិនាឆ្នាំ២០១០)។ មុខរបរចំបងប្រចាំក្រុមគឺដាំផ្កាស្រស់។

- សហគមន៍ ថុងអោក បានតាំងលំនៅលើតំបន់សំខាន់ៗចំនួន២ គឺ (១) តំបន់វាលស្មៅ និង(២) តំបន់ខ្ពង់រាប ដែលគេហៅថា " គោកអ៊ីរ៉ាំង " ។ សហគមន៍នេះមានប្រជាពលរដ្ឋចំនួន ៩០០ ដែលមានប្រុស ៤៥៩ និងស្ត្រី ៤៤១ (តាមទិន្នន័យខែមិនាឆ្នាំ២០១០)។ មុខរបរប្រចាំក្រុមក្នុងសហគមន៍នេះគឺធ្វើខ្ទិះដូងស្រស់។

- សហគមន៍ សោនមុំ គឺជាតំបន់ដែលសំបូរទៅដោយដើមដូង និងដើមត្នោតប្រេង ដែលត្រូវបានគេដាំក្នុងសហគមន៍នេះ រួមទាំងដើមត្នោតប្រេងមុនដំបូងគេដែលបានដាំនៅក្នុងទីក្រុងព្រឹក ហើយនៅតែមានរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងសហគមន៍នេះមានប្រជាពលរដ្ឋចំនួន១៣២០ ប្រុស៦៦៣ ស្ត្រី៦៥៧ (តាមទិន្នន័យខែមិនាឆ្នាំ២០១០)។ មុខរបរប្រចាំក្រុមគឺធ្វើទឹកការី និង កាត់ដេរ។

- សហគមន៍ ព្រឹកតៃ មានប្រជាពលរដ្ឋចំនួន ៣៧៩នាក់ ប្រុស១៨០ ស្ត្រី១៩៩ (តាមទិន្នន័យខែមិនាឆ្នាំ២០១០)។ ប្រជាជនដែលមករស់នៅក្នុងសហគមន៍នេះគឺជា

អ្នកដែលធ្វើអន្តោប្រវេស្តន៍ពីតំបន់ដទៃទៀតជិតតំបន់នេះមានដូចជា ស្រុកហាត់យៃ ស្រុកក្លងហៃ និង ស្រុក ក្លងរ៉េន។ មុខរបរប្រចាំក្រុមរួមមាន ក្រុមចិញ្ចឹមត្រីឆ្លាំង និងក្រុមកាត់ដេរ។

## ខ- ការបរិយាយនិងដើមហេតុឲ្យកើតមានការអនុវត្តល្អ

ទីក្រុងព្រឹកបានដាក់ទស្សនទានលើអភិបាលកិច្ចល្អតាមរយៈភាពជាដៃគូដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចរដ្ឋបាលនៃអនុស្រុកដែលមានសុខភាពល្អ(តាំប៊ូន)។ ទីក្រុងបានព្យាយាមធ្វើការដោយយកភាពជាដៃគូជាគោល និងផ្ទេរពីគោលការណ៍រដ្ឋាភិបាលមូលដ្ឋាន ទៅជាគោលការណ៍អភិបាលកិច្ចមូលដ្ឋាន។

សមាសធាតុនៃការផ្តួចផ្តើមដែលបានបង្ហាញនៅក្នុងគំរូការអនុវត្តល្អមានដូចជា (១) សមាសធាតុទាំងអស់របស់អភិបាលកិច្ចល្អត្រូវពាក់ព័ន្ធ (២) បែបផែនរដ្ឋបាលត្រូវមានភាពបត់បែន គេហៅថា "ប្រព័ន្ធរដ្ឋបាលទីក្រុងព្រឹក" ដែលត្រូវបានយកមកអនុវត្ត (៣) គម្រោងសុខភាព តាំប៊ូន ឆ្ពោះទៅកាន់សហាគមន៍និរន្តរភាព និងជីវភាពដែលអាស្រ័យលើទស្សនអភិបាលកិច្ចល្អ។

គ- ការរៀបចំចាត់ចែង

ការរៀបចំឲ្យមានសមាជិកស្នូលរបស់សហគមន៍គឺផ្អែកលើអភិក្រមបែបចូលរួមសកម្មក្នុងការផ្តល់សេវាជាមូលដ្ឋានរបស់រដ្ឋាភិបាល។ ចាប់តាំងពីរដ្ឋាភិបាលមូលដ្ឋាន មានទំនាក់ទំនងច្រើនជាមួយប្រជាជនដើម្បីជាមូលដ្ឋានផ្តល់សេវាមក ពួកគេពិតជាត្រូវការបណ្តាញដែលស្ថិតនៅថ្នាក់ប្រជាជនក្នុងការអនុវត្តការងារនេះឲ្យមានប្រសិទ្ធភាព។

មុខរបរប្រចាំក្រុមបានប្រមូលផ្តុំពួកគេ និង ក្លាយជា "មជ្ឈមណ្ឌលសិក្សាមួយ " សម្រាប់ទីក្រុងផ្សេងទៀត។ ក្រុមទាំងនោះមាន ក្រុមធ្វើទឹកការី ក្រុមធ្វើខ្ទិះដូង ក្រុមដុតនំប្រពៃណីថៃ ក្រុមកាត់ដេរ ក្រុមដាំផ្កាស្រស់ និងក្រុម ធ្វើបង្អែម។

ក្រុមប្រឹក្សារៀបចំសហគមន៍ត្រូវបានចាត់ចែងឡើងក្នុងឆ្នាំ២០០៨ដែលធ្វើការក្នុងទិសដៅស្របគ្នាជាមួយនឹងក្រុមប្រឹក្សាក្រុងដើម្បីធ្វើអធិការកិច្ច និងជំរះបញ្ជីទៅលើការអនុវត្ត

សិទ្ធិអំណាចរបស់ក្រុង។ បន្ថែមពីលើនេះមានទាំងតួនាទីនៃក្រុមសាលាថ្នាក់មូលដ្ឋាន មេដឹកនាំសាសនា និងមេដឹកនាំធម្មជាតិ។

ឃ- ការបង្កើតភ្នាក់ងារ និងដៃគូ

ទស្សនវិស័យមួយរបស់ទីក្រុងគឺ ការអភិវឌ្ឍដោយផ្តោតលើមនុស្ស ដូច្នេះហើយទើបក្នុងឆ្នាំ ១៩៩៩ លោកអភិបាលក្រុងដាក់គោលនយោបាយនេះឲ្យប្រើប្រាស់ ហើយក៏បានជួលបណ្តាញបុគ្គលឹកក្រុងដែលរួមមាន វិទ្យាស្ថានសិក្សា និងអង្គការខាងក្រៅ ដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការវិស័យសាធារណៈ និងអាជ្ញាធរមូលដ្ឋាននានា។ បច្ចុប្បន្ននេះទីក្រុងព្រឹកធ្វើការដោយយកគោលការណ៍បណ្តាញជាមូលដ្ឋានជាមួយនឹងអង្គការគ្រប់កំរិតថ្នាក់រួមមាន ថ្នាក់ខេត្ត អង្គការនានាដែលមានដូចខាងលើ ព្រមទាំងអង្គការថ្នាក់ជាតិដូចជាមូលនិធិលើកស្ទួយសុខភាពប្រជាជនថៃជាដើម។

ចាប់តាំងពីឆ្នាំ ១៩៩៩ មកមានអង្គការអន្តរជាតិដំបូងគេ គឺអង្គការមូលនិធិHanns Seidel បានចូលរួមសហការជាមួយនឹងទីក្រុងព្រឹក។ បន្ទាប់មកទៀត មានអង្គការផ្សេងទៀតដូចជាជំនាញការថ្នាក់ជាតិ ឧទាហរណ៍: LDI និង អង្គការក្នុងស្រុកនានាបានបង្កើតគម្រោងផ្សេងៗសម្រាប់គាំទ្រសហគមន៍ឲ្យនៅតែមាននៅក្នុងទីក្រុងព្រឹក។

ង- បុគ្គលិក

ក្នុងទីក្រុងព្រឹកបានជ្រើសរើសក្រុមការងារពិសេសប្រចាំតាំបូន ហើយការងាររបស់ពួកគេគឺការគ្រប់គ្រងធនធាន។ គម្រោងនេះអនុញ្ញាតឲ្យប្រជាជនក្នុងសហគមន៍កាន់កាប់ការងារដោយពួកគេផ្ទាល់ ហើយមន្ត្រីសាលាក្រុងក៏បានចូលរួមដូចសមាជិកក្រុមពិសេសដែរ។ The PTT (អាជ្ញាធរប្រេងកាតរបស់ថៃ) ថ្នាក់តំបន់ និង មន្ត្រីតាំបូនបានធ្វើការជាមួយគ្នាយ៉ាងជិតស្និត និងគ្រប់គ្រងក្រុមពិសេសរបស់សហគមន៍ដើម្បីដំណើរការគម្រោងទៅតាមរបទនៃសេដ្ឋកិច្ចបរិបូណ៌។

មន្ត្រីសាលាក្រុងត្រូវកាន់កាប់មុខងារសំខាន់ៗក្នុងសាលាក្រុងដែលក្នុងនោះគេចែកចេញជា៨ផ្នែក:

១- ការិយាល័យស្មៀនក្រុងគឺជាកន្លែងដែលទទួលខុសត្រូវលើកិច្ចការរដ្ឋបាល គោលនយោបាយ និងផែនការរបស់ក្រុង។ ការិយាល័យនេះដើរតួដូចក្រុមប្រឹក្សាក្រុងដែរ ចំណែកឯមន្ត្រីស្មៀនរបស់លោកអភិបាលវិញទទួលបន្ទុកផ្នែកកិច្ចការរដ្ឋបាល ការងារបុគ្គលិក ការងារប្រយុទ្ធប្រឆាំងនឹងគ្រោះមហន្តរាយ និងកិច្ចការចុះបញ្ជីស្នាម ។ល។ ដែល កិច្ចការទាំងអស់នោះត្រូវបានចាត់ទៅតាមផ្នែកដោយឡែកៗពីគ្នា។

២- ផ្នែកកិច្ចការសាធារណៈ គឺទទួលបន្ទុកកិច្ចការពាក់ព័ន្ធទៅនឹងការសាងសង់ និងជួសជុល មានដូចជា ផ្លូវអាគារត្រួតពិនិត្យ ការចេញអាជ្ញាប័ណ្ណ និងជួសជុល ថែទាំប្រព័ន្ធបង្ហូរទឹក ជាដើម។

៣- ផ្នែកហិរញ្ញវត្ថុគឺជាផ្នែកទទួលខុសត្រូវលើកិច្ចការហិរញ្ញវត្ថុ និងការគ្រប់គ្រងគណនេយ្យ ដូចជាការប្រមូលចំណូល ប្រាក់បង់ពន្ធ និងការចុះបញ្ជីទ្រព្យសម្បត្តិ។

៤- ផ្នែកសុខមាលភាពសង្គម គឺជាផ្នែកទទួលខុសត្រូវលើសេវាសុខមាលភាពសង្គម ជាពិសេសមាតា និងទារក សេវាយុវវ័យ និងការអភិវឌ្ឍន៍សហគមន៍។

៥- ផ្នែកអនាម័យ និងបរិស្ថាន គឺទទួលខុសត្រូវលើរដ្ឋបាលសុខភាពសាធារណៈ លើកស្ទួយសុខភាពសាធារណៈ រៀបចំមជ្ឈមណ្ឌលគាំពារសុខភាពសាធារណៈ ការសំអាតទីក្រុង ការថែរក្សាអនាម័យការចិញ្ចឹមសត្វពាហនៈ ការការពារជំងឺរុំរ៉ៃ ព្រមទាំងត្រួតពិនិត្យ និង ដាក់ផ្លាកសាធារណៈពីការយល់ដឹងពីសុខភាព ។ល។

៦- ផ្នែកបច្ចេកទេស និងផែនការ គឺជាផ្នែកទទួលខុសត្រូវលើគោលនយោបាយ និងវិភាគពីផែនការការស្រាវជ្រាវ និងវាយតំលៃពីគោលនយោបាយ និងផែនការណ៏របស់ក្រុង កិច្ចការងារផ្លូវច្បាប់ ការកំណត់ថវិកា និងសេវាព័ត៌មានសាធារណៈ។ល។

៧- ផ្នែកអប់រំ គឺជាផ្នែកទទួលខុសត្រូវលើប្រតិបត្តិការ និង អភិវឌ្ឍសាលាបឋម និង អនុវិទ្យាល័យនានានៅក្នុងក្រុង។ ផ្នែកនេះក៏បានធ្វើការទៅលើការអប់រំក្រៅកម្មវិធីសិក្សា សាសនា វប្បធម៌ និងសកម្មភាពកំសាន្តនានា។

៨- ផ្នែកកិច្ចការរដ្ឋករ គឺទទួលខុសត្រូវលើសេវារដ្ឋករសាធារណៈ

### ច- ប្រព័ន្ធ និងទម្រង់ការ

ទីក្រុងព្រឹក មានរចនាបថនៃរដ្ឋបាលផ្ទាល់ខ្លួន រួមមានគម្រោងហ្វឹកហ្វឺន ការកសាងការយោគយល់គ្នា ចំណេះដឹង និងទស្សនៈយល់ដឹង។ គម្រោងហ្វឹកហ្វឺនគឺសំដៅលើការបន្តការអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈទស្សនៈមូលដ្ឋានគ្រឹះ ដែលការអភិវឌ្ឍន៍នោះអាចធ្វើឲ្យប្រសើរឡើងសម្រាប់មនុស្សជាតិទាំងអស់។ ទស្សនៈ"Learning Organization" នេះត្រូវបានបង្កើតឡើងនៅពេលដែលជោគជ័យទាំងអស់បានមកពីការសិក្សារួមគ្នាពីសំណាក់សមាជិកអង្គភាពទាំងអស់។

ការកសាងការយោគយល់គ្នា ចំណេះដឹង និងទស្សនៈនៃការយល់ដឹង គឺសំដៅលើការកែលំអមន្ត្រីសាលាក្រុង ក្នុងការផ្លាស់ប្តូររចនាបថការងារ ពីបែបការិយាធិបតេយ្យទៅជាបែបមានភាពបត់បែនកាន់តែច្រើន។

ឆ- សេវាកម្ម

- ក្រុងព្រឹកបានបង្កើតមជ្ឈមណ្ឌលសិក្សាសម្រាប់ការគ្រប់គ្រងបរិស្ថាន និងការធ្វើថាមពលឲ្យមានឡើងវិញ ដោយមានការផ្តល់នូវការបង្រៀន នឹងផ្តោតសំខាន់ទៅលើ ការផលិតជី អ៊ីអឹម (E.M) ការផលិតធ្យូងឧសសាប៊ូជីវសាស្ត្រ ហ្គាសជីវសាស្ត្រ សាប៊ូ និងការបែងចែកសម្រាមតាមគ្រួសារនិមួយៗ។ល។
- សហាគមន៍សេដ្ឋកិច្ច សុខមាលភាព និង ប្រព័ន្ធកសិកម្ម មានសុវត្ថិភាព ដែលមានផ្តល់នូវការបង្រៀន និងការបង្ហាញសកម្មភាពនានាតាមរយៈការបង្ហាញពីមុខរបរជាក្រុម ឬការសន្សំប្រាក់ជាក្រុម ដូចជាការធ្វើផ្កាថ្នាំបុរាណថៃ ធ្វើនំនិងបង្អែមបែបថៃ ការធ្វើទឹកម្ទេស ខ្ទិះដូង ទឹកការី កាត់ដេរ និងបង្អែម ក្នុងស្រុកថៃ។
- ទីក្រុងព្រឹកក៏បានបង្កើតនូវមជ្ឈមណ្ឌលសិក្សាសម្រាប់អ្នករៀនដោយខ្លួនឯង និងប្រព័ន្ធអប់រំ ដែលមានផ្តល់នូវការបង្រៀន

និងការបង្ហាញដោយសិស្សក្នុងការផលិតនូវជី អ៊ីអឹម (E.M) ការផលិតសាប៊ូជីវសាស្ត្រ ហ្គាសជីវសាស្ត្រ សាប៊ូ និង ដំណើរការធនាគារឡើងវិញ។

- ប្រព័ន្ធថែរក្សាសុខភាពស្ម័គ្រចិត្ត: សកម្មភាពដែលចំបងគឺការផ្តល់មេរៀន និងការបង្ហាញពីវិធីក្នុងការថែរក្សាជាក់ស្តែងជាមួយក្រុមប្រជាជន ក៏ដូចជាមួយអ្នកជំងឺដោយផ្ទាល់។
- ប្រព័ន្ធទំនាក់ទំនង: សកម្មភាពដែលសំខាន់នោះគឺវិទ្យុសហាគមន៍រួមមានការផ្តល់នូវអត្ថបទ និងការបង្ហាញពីការដំណើរការកម្មវិធីដូចជា D.J.

ជ- គុណសម្បត្តិ

គ្រប់មជ្ឈមណ្ឌលសិក្សាទាំងអស់ខាងលើមានគោលបំណងដូចតទៅ:

- អាចឲ្យអ្នកចូលរួមចែករំលែក និងរៀនសូត្រពីការគ្រប់គ្រងសម្រាម ការបង្កើតនូវការយល់ដឹងរបស់អ្នកចូលរួម និងអនុវត្តក្នុងករណីរបស់ពួកគេផ្ទាល់ ក៏ដូចជាការផ្តល់នូវជំរើសជាច្រើនសម្រាប់ប្រព័ន្ធគ្រប់គ្រងសម្រាម និងផ្តល់តំលៃជាអតិប្បរមាដល់សម្រាម។
- ផ្តល់នូវទស្សនៈគ្រិះ និងឧទាហរណ៍ក្នុងការបង្កើតទម្រង់ក្រុម និងការបង្កើតឲ្យមានសកម្មភាពប្រចាំក្រុម ចំពោះក្រុមសហាគមន៍ ក៏ដូចជាមុខរបរប្រចាំក្រុមផងដែរ។
- អាចឲ្យអ្នកចូលរួមសិក្សាយល់ដឹងពីការបង្កើតប្រព័ន្ធអប់រំដើម្បីបំរើការសហាគមន៍មូលដ្ឋាន ជាពិសេសសង្គមអ៊ីស្លាម ដែលបានផ្តល់នូវគោលការណ៍ណែនាំពីការអនុវត្តមូលដ្ឋានគតិបណ្ឌិត និងមាគ៌ាឆ្ពោះទៅរកសេដ្ឋកិច្ចបរិបូណ៌ ការបង្រួបបង្រួមប្រព័ន្ធការសិក្សារវាងសាលារៀន និងសហាគមន៍ ក៏ដូចជាការផ្តល់នូវការយល់ដឹង និងចំណេះដឹងសម្រាប់អ្នកចូលរួមទាំងអស់តាមរយៈការអប់រំសម្រាប់គ្រប់វ័យ។

- ផ្តល់សេវាថែរក្សាសុខភាពដល់ក្រុមប្រជាពលរដ្ឋមួយចំនួន ឧទាហរណ៍ ក្រុមអសមត្ថភាព មាតានិងទារក ស្រ្តីមានផ្ទៃពោះ ចាស់ជរា និងអ្នកជំងឺរ៉ាំរ៉ៃ។
- ដើម្បីទទួលបានការចូលរួមពីសិស្ស និសិត្ស ដូចជាក្រុមស្ម័គ្រចិត្តបឋមដើម្បីបង្កើនការយល់ដឹងការងាររបស់ពួកគេសម្រាប់ជួយដល់ក្រុមជនងាយរងគ្រោះ។
- ផ្តល់ទស្សនៈគ្រិះនិងបណ្តាញឧទាហរណ៍សម្រាប់ជាការទំនាក់ទំនងពីរផ្លូវ

**ឈ- អ្នកទទួលផលប្រយោជន៍**

ជាបឋមដំណើរការកសាងសមត្ថភាពរបស់មន្រ្តីសាលាក្រុងត្រូវតែប្រាកដថាពួកគេយល់ និងអាចធ្វើការក្នុងកំរិតសហគមន៍ដើម្បីឲ្យទៅដល់ប្រជាពលរដ្ឋក្នុងសហគមន៍នោះបាន។ ទាំងនេះនឹងដឹកនាំពួកគេឲ្យមានគំនិតជាអ្នកផ្តល់សេវា និងលះបង់សម្រាប់ទឹកដីកំណើតរបស់ពួកគេផ្ទាល់។ ជាបន្ទាប់មកទៀត មន្រ្តីសាលាក្រុងដែលនៅក្នុងក្រុមពិសេសរបស់សហគមន៍នឹងត្រូវបានចាត់ឲ្យធ្វើការទៅតាមសហគមន៍និមួយៗក្នុងនាមជា "អ្នកសម្របសម្រួលក្នុងសហគមន៍" ។ តួនាទីរបស់ពួកគេគឺត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ដើម្បីឲ្យគម្រោងមានដំណើរការបាន។ ដូច្នេះនេះជាការប្រាកដថាការប្រើប្រាស់សិទ្ធិអំណាចរបស់ក្រុងតាមរយៈមន្រ្តីទាំងនេះ គឺជាបណ្តាញតភ្ជាប់រវាងរដ្ឋបាលមូលដ្ឋានជាមួយនឹងប្រជាពលរដ្ឋក្នុងសហគមន៍។ នៅក្នុងកម្មវិធីកិច្ចពិភាក្សាទីក្រុងព្រឹក ក្រុមមន្រ្តីខ្លះត្រូវបានគេដាក់ចូលទៅក្នុងមជ្ឈមណ្ឌលសិក្សាដែលគេហៅថា "ភ្នាក់ងារផ្លាស់ប្តូរអ្នកដឹកនាំសហគមន៍" ។ ឥលូវនេះពួកគេបានក្លាយទៅជាអ្នកជំនាញក្នុងការគាំទ្រសកម្មភាពរបស់គម្រោងអនុស្រុកដែលមានសុខភាពល្អ។ ហើយចុងក្រោយ និន្នាការនៃសិទ្ធិអំណាចរបស់ក្រុងគឺការផ្តល់នូវការកសាងសមត្ថភាពដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ដោយមានការកើតឡើងពីដំណើរការការអភិវឌ្ឍន៍នៃការចូលរួម និង ការចែករំលែក ព្រមទាំងសកម្មភាពសិក្សាមូលដ្ឋានគ្រិះផងដែរ។

ញ- កត្តានិរន្តរភាព

គំរូនេះអាចទទួលបាននូវនិរន្តរភាពព្រោះថាទីក្រុងនេះត្រូវបានប្រើជា "មជ្ឈមណ្ឌលសិក្សារៀនសូត្រ" សម្រាប់អ្នកខាងក្រៅ ដែលយ៉ាងហោចណាស់ក្នុងមួយខែៗ មានរដ្ឋបាលមូលដ្ឋានផ្សេងទៀតជាង១០បានមកធ្វើទស្សនកិច្ចនៅទីក្រុងព្រឹកនេះជាប្រចាំ។ ចាប់តាំងពីឆ្នាំ ២០០៩មក មូលនិធិលើកកម្ពស់សុខភាពប្រជាជនថៃបានលើកយកទីក្រុងព្រឹកជាតំបន់សាកល្បងសម្រាប់គម្រោង " បណ្តាញអនុស្រុកដែលមានសុខភាពល្អ " ដែលមានន័យថាទីក្រុងព្រឹកនិង សហាគមន៍របស់ខ្លួនត្រូវតែមានតួនាទីមួយទៀតក្នុងនាមជាគំរូសម្រាប់អង្គការរដ្ឋបាលតាំបូន(TAOs) មកពីភាគខាងជើងនៃប្រទេសថៃដើម្បីរៀនសូត្រតាម។ ក្នុងនោះមាន:

- ធនធានរបស់ទីក្រុងព្រឹកអាចមើលឃើញជាធនធានរបស់សហាគមន៍ដែលក្នុងនោះមាន បរិស្ថានវិទ្យា ហិរញ្ញវត្ថុ ធនធានមនុស្ស និងទីក្រុងឧត្តមគតិ។
- សម្រាប់ធនធានផ្នែកបរិស្ថានវិទ្យាគឺជាកត្តាអំណោយផលផ្នែកភូមិសាស្ត្រ ដែលអាចឲ្យប្រជាពលរដ្ឋភាគច្រើនធ្វើចំការកៅស៊ូ និងចំការផ្កាអ័រគីដេ ដែលនាំអោយចំណូលកាន់តែប្រសើរជាងមុន។
- សម្រាប់ធនធានហិរញ្ញវត្ថុវិញ មិនមែនដោយសារប្រជាពលរដ្ឋក្នុងស្រុកនៃទីក្រុងព្រឹកប្រកបរបរដោយពឹងលើកសិកម្មតែមួយមុខហើយធ្វើឲ្យពួកគាត់អាចបន្តទទួលបានកំរៃនោះទេ ប៉ុន្តែវាអាស្រ័យដោយសកម្មភាពជាច្រើនទៀតរបស់សហាគមន៍ដែលបង្កើតបានជាចំណូលនិងប្រាក់សន្សំ។
- ធនធានសង្គមអាចត្រូវបានមើលឃើញតាមរយៈទំនាក់ទំនងក្នុងបណ្តាសហាគមន៍នានាក្នុងមូលដ្ឋាន។ ដោយសារតែ៩០ភាគរយនៃប្រជាពលរដ្ឋមូលដ្ឋានគឺជាជនជាតិអ៊ីស្លាម ដូចនេះធនធានសង្គមគឺត្រូវពឹងលើបណ្តាញភាពជាសាច់ញាតិ និងវប្បធម៌ក្នុងស្រុក។
- ធនធានមនុស្សអាចបង្ហាញតាមរយៈក្រុមពិសេសរបស់សហាគមន៍ដែលបាននឹងកំពុងបន្តការអភិវឌ្ឍន៍នូវដំណើរការសិក្សារបស់គាត់។
- ទីក្រុងឧត្តមគតិ, ចាប់តាំងពីក្រុមពិសេសរបស់សហាគមន៍មូលដ្ឋានត្រូវបានពង្រឹងមក ពួកគេបានដាក់សមត្ថភាពពួកគេចូលទៅក្នុងការអនុវត្ត។ ដាក់ស្តែងក្រុម

ការងារពិសេសរបស់សហគមន៍គឺជាអ្នកនាំពាក្យពីមជ្ឈមណ្ឌលសិក្សាសម្រាប់សហគមន៍។

ដោយឡែកក្រៅពីធនធានសហគមន៍ មានកត្តាដទៃទៀតដែលជួយឲ្យជោគជ័យ ហើយកត្តាទាំងនោះមានតួនាទីសមាជិកនៃក្រុមការងារពិសេសរបស់សហគមន៍ តួនាទីរបស់អភិបាលក្រុង និងមន្ត្រីពាក់ព័ន្ធ ព្រមទាំងតួរនាទីនៃភ្នាក់ងារខាងក្រៅក្នុងការគាំទ្រសាលាក្រុង និងសកម្មភាពសហគមន៍ ក៏ដូចជាគម្រោងនានាផងដែរ។

**៤-២-៣ ការរួមចំណែកក្នុងការធ្វើផែនការទីប្រជុំជន នៃខេត្តហ្គីមារ៉ាស ប្រទេសហ្វីលីពីន**

ក- ខេត្តហ្គីមារ៉ាស

ហ្គីមារ៉ាសគឺជាខេត្តកោះមួយដែលលាតសន្ធឹងនៅទិសអាគ្នេយ៍ជាប់នឹងកោះ ប៉ាណៃ ហើយភាគឥសានជាប់នឹងកោះនីគ្រុស។ កោះនេះត្រូវដាច់ចេញពីកោះប៉ាណៃដោយដៃសមុទ្រអ៊ីល័រឡូ និងញែកចេញពីខេត្តនីគ្រុសដោយដៃសមុទ្រហ្គីមារ៉ាស។

ខេត្តផ្សំដោយទីក្រុងចំនួន៥ដែលមានឈ្មោះ៖ បូណាវីស្តា ជដាន់ ណូវ៉ា-វ៉ាលីនស្យាសាន់-ឡូរិនហ្សូ និង ស៊ីបូណាង។ ទីក្រុងសំខាន់ជាងគេគឺទីក្រុងជដាន់។ កាលពីដើមខេត្តនេះត្រូវបានផ្សំឡើងដោយទីក្រុងចំនួនបីប៉ុណ្ណោះ។ ទីក្រុងសាន់-ឡូរិនហ្សូ និង ស៊ីបូណាងជាទីក្រុងទើបតែបង្កើតថ្មីក្នុងឆ្នាំ១៩៩៥។ ហ្គីមារ៉ាសមានបារាងហ្គាយ ចំនួនសរុប ៩៨ មានទំហំ ៦០៤៥៧ ហិកតា ដែលជិតស្មើនឹង៣ភាគរយនៃ២,០០២,៣២០ហិកតាតំបន់សរុប។ ដីចំនួន ៥៩,៦០០ហិកតាមានអ៊ីណាំប៉ូឡូហ្គាន ប៉ាណូបូឡូន និងកោះហ្គូវ៉ានន ដែលក្នុងនោះដីសល់ ៨៥៧ហិកតាទៀតបានក្លាយជាដីកោះដែលនៅទំនេរ។

ប្រជាជននៅក្នុងខេត្តនេះមានចំនួន១៤១,៤៥០នាក់ ដោយយោងទៅតាមការជំរឿនក្នុងឆ្នាំ២០០០ ដែលនេះជាការជំរឿនលើកចុងក្រោយបំផុតដែលគេបានធ្វើ។ ចំនួនសរុបមាន ២៧,៤៦៥គ្រួសារក្នុងឆ្នាំ២០០០។ ក្នុងចំណោមទីក្រុងទាំង៥ក្នុងហ្គីមារ៉ាស មានទីក្រុងបូណាវីស្តា គឺជាទីក្រុងដែលមានចំនួនប្រជាជនច្រើនជាងគេ ពោលគឺមាន២៩.៥ភាគរយនៃចំនួនប្រជាជនសរុបក្នុងខេត្តទាំងមូល។ នៅថ្នាក់ជាតិហ្គីមារ៉ាសមានចំនួន ០.១៨ភាគរយប៉ុណ្ណោះបើធៀបទៅនឹងចំនួនប្រជាជន ៧៦.៥ លាននៃចំនួនប្រជាជនហ្វីលីពីន ទាំងអស់។

សេដ្ឋកិច្ចរបស់ហ្គីមារ៉ាសត្រូវបានពឹងផ្អែកទាំងស្រុងទៅលើវិស័យសំខាន់ជាងគេគឺ វិស័យកសិកម្ម ដែលក្នុងនោះមាន កសិកម្ម នេសាទ និងព្រៃឈើ។ ការនាំចេញផ្លែស្វាយ គឺជាឱកាសនៃសេដ្ឋកិច្ចសំខាន់ជាងគេដែលក្នុងនាមជាខេត្តមួយជាអ្នកនាំចេញនូវផ្លែស្វាយ ដែលមានគុណភាពនៃប្រទេសហ្វីលីពីន ទៅកាន់សហរដ្ឋអាមេរិក។ ក្រៅពីការនាំចេញ ផ្លែស្វាយ ហ្គីមារ៉ាសត្រូវបានគេស្គាល់ថាជាតំបន់ឆ្នេរសមុទ្របុរាណ និងជាតំបន់ទាក់ទាញ ទេសចរណ៍ដែលមានស្រាប់ក៏ដូចជាតំបន់ដែលមានសក្តានុពលទេសចរណ៍ដែលគេអាច អភិវឌ្ឍអោយក្លាយជាទីកន្លែងកំរិតពិភពលោក។

ខេត្តនេះដឹកនាំដោយលោកអភិបាលម្នាក់ដែលគាត់ក៏ជាអ្នកដឹកនាំនៅក្រុមប្រឹក្សា អភិវឌ្ឍខេត្តដែរ (PDC) ។ សហការីដែលនៅធ្វើការជាមួយលោកអភិបាលគឺជាសមាជិករបស់ PDC។ អភិបាលនៃទីក្រុងទាំងអស់ប្រធាននៃគណកម្មាធិការនានា ព្រឹទសភា ឬតំណាង និង តំណាងអង្គការមិនមែនរដ្ឋាភិបាលជាសមាជិកយ៉ាងតិចមួយភាគបួននៃក្រុមប្រឹក្សា(PDC)។

### ខ- សមាសធាតុថ្មីនៃការអនុវត្តល្អ

ដំណើរការនៃការធ្វើផែនការណ៍របស់ ហ្គីម៉ារ៉ាសត្រូវចាត់ទុកជាការអនុវត្តល្អព្រោះថា វាគឺជាមូលដ្ឋានគ្រិះបំផុត។ វាពិតជាចាប់ផ្តើមពីផែនការល្អនិងស្រុះស្រួលគ្នាបំផុត ដោយ គ្រប់ៗគ្នាយល់ពីអ្វីដែលខេត្ត និងរដ្ឋាភិបាលមូលដ្ឋានស្រម៉ៃចង់ធ្វើក្នុងពេល៣០ឆ្នាំខាងមុខ។ ក្នុងករណីនេះវាបានក្លាយទៅជាផែនការ៣០ឆ្នាំរបស់ខេត្ត(PPFP)។ (PPFP) នឹងធ្វើការផ្លាស់ ប្តូរទៅតាមគំនិតថ្មីណាមួយដែលបានផុសឡើង ក្នុងកំឡុងពេលដំណើរការទោះបីជាក្នុង រយៈពេលខ្លី ឬមធ្យមក៏ដោយ។

មានលក្ខណៈជាច្រើននៃដំណើរការនៃការធ្វើផែនការណ៍ដែលអាចចាត់ទុកជាការ អនុវត្តល្អបាន មានដូចតទៅៈ

- វាគឺជាផែនការមួយដែលអាចឈានទៅដល់ការយល់ព្រមមួយ រវាងថ្នាក់ ខេត្តជាមួយនឹងបណ្តាទីក្រុងទាំង៥ ជាពិសេសទៅលើមុខងារ តួនាទីរបស់ ទីក្រុងនីមួយៗ។ ដំណើរការនៃការធ្វើផែនការនេះក៏មានភាពស៊ីគ្នាទៅនឹង

ផែនការរបស់ទីក្រុងនិមួយៗផងដែរ។ហើយទីក្រុងនិមួយៗក៏យល់ព្រមក្នុងការដើរតួទៅតាមមុខងាររបស់ពួកគេរៀងៗខ្លួន។

- គម្រោងការណ៍នេះរួមបញ្ចូលផ្នែកទេសចរណ៍ និងកសិកម្ម ដែលជាចលនាសេដ្ឋកិច្ចចំបងរបស់ខេត្ត។ ការអភិវឌ្ឍន៍សេដ្ឋកិច្ចគឺជាកំលាំងជំរុញមួយ ដែលជាហេតុធ្វើឲ្យផែនការថ្នាក់ខេត្តនិងក្រុងទទួលយកទេសចរណ៍បែបកសិកម្ម។
- ផែនការនេះគឺជាផែនការណ៍ដ៏ល្អិតល្អន់មួយសម្រាប់ខេត្តកោះជាមួយនឹងនិរន្តរភាពស្របនឹងគោលដៅដំបូងដែលវាមិនមានផលប៉ះពាល់ដល់បរិស្ថានកោះនេះ។
- ដំណើរការនៃការធ្វើផែនការនេះផ្តល់នូវអត្ថន័យថ្មីមួយសម្រាប់ពាក្យថាពិគ្រោះយោបល់។ នៅក្នុងដំណើរការនៃការធ្វើផែនការរបស់ខេត្ត ការពិគ្រោះយោបល់ត្រូវបានគេបញ្ចូលតាំងពីដំណាក់កាលដំបូងនៃការវិភាគទិន្នន័យម្លេះ ហើយក្នុងការកើតឡើងនូវជម្រើសអភិវឌ្ឍនានា។
- ដំណើរការនៃការធ្វើផែនការនេះនាំឲ្យអ្នកពាក់ព័ន្ធទាំងអស់ទទួលអារម្មណ៍ថាពួកគាត់ជាម្ចាស់លើគម្រោងការនេះ។ អ្នកពាក់ព័ន្ធនានាបានចូលរួមក្នុងផែនការដែលនាំឲ្យត្រលប់ទៅរកបទបញ្ញត្តិនៃគម្រោងជាច្រើនរបស់ពួកគាត់។ ក្នុងករណីនេះពួកគាត់មានរបស់ជាបន្ទាល់សម្រាប់ការពារអះអាងពីលទ្ធផលរបស់ខ្លួន។ បន្ថែមពីនេះទៅទៀតព្រឹត្តិការណ៍ដែលគួរចាប់អារម្មណ៍នោះគឺអ្នកដែលបានមកពាក់ព័ន្ធចាប់តាំងពីដំណាក់ការដំបូថនៃការធ្វើផែនការនេះនឹងនៅតែជាបន្តការគាំទ្រយ៉ាងពេញទំហឹងរហូតមកដល់សព្វថ្ងៃនេះទោះបីជាពួកគាត់បានផ្លាស់ប្តូរតំណែង និងការិយាល័យក៏ដោយ។

គ- ដំណាក់ការអនុវត្ត

សកម្មភាពដំបូងនៃកម្មវិធីនេះគឺជាការបង្ហាញឲ្យស្គាល់ និងការចាត់ចែងនៃរចនាសម្ព័ន្ធផែនការមូលដ្ឋាន ដែលចាប់ផ្តើមធ្វើក្នុងខែធ្នូ ឆ្នាំ២០០៤។ នេះជាលើកទីមួយដែលគម្រោងត្រូវបានណែនាំឲ្យស្គាល់ ក្នុងសិក្ខាសាលានៃការចាប់ផ្តើមដំបូងស្តីពីការរៀបចំនិង

វិភាគទិន្នន័យផែនការដែលធ្វើតាមរយៈអាជ្ញាធរអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដែលហៅកាត់ថា NEDA។

បន្ទាប់ពីបទបង្ហាញ និងសិក្ខាសាលាថ្នាក់ដំបូងមក សកម្មភាពដែលបង្កើនសន្ទុះឆ្ពោះទៅកាន់ការកសាងសមត្ថភាពត្រូវបានធ្វើសម្រាប់សមាសភាពអ្នកបច្ចេកទេសនៃរចនាសម្ព័ន្ធផែនការមូលដ្ឋានដែលពាក់ព័ន្ធនឹងការផ្តល់ទីប្រឹក្សាបញ្ចូលក្នុងទម្រង់ចាំបាច់នៃក្របខ័ណ្ឌទស្សនៈទាន និង ឧបករណ៍សិក្សាវិភាគជាមួយនឹងបច្ចេកទេសនានា លំហាត់គំរូ និងកិច្ចការរយៈពេលយូរ តាមរយៈកិច្ចប្រជុំសិក្ខាសាលាផ្សេងៗ។ ឆ្លងតាមវិធីសាស្ត្រនេះ អ្នកពាក់ព័ន្ធផ្ទាល់ជាអ្នកទទួលខុសត្រូវលើការផលិតនូវរាល់ទិន្នផលអន្តរការី និងទិន្នផលសម្រេច។ មានការផ្តល់ការប្រឹក្សាដើម្បីធានាពីគុណភាពនៃទិន្នផលតាមរយៈដំណើរការហ្វឹកហ្វឺន និងទិន្នផលដែលបានទទួលការទិទៀនកែលំអរួចហើយតាមវិធីសាស្ត្រថ្មីនេះផងដែរ។

មួយវិញទៀត ដំណើរការនៃការចូលរួម និងការផ្តល់ប្រឹក្សាត្រូវបានប្រើជាយុត្តាធិការសម្រាប់ទទួលបានការចូលរួមពីសំណាក់អ្នកនយោបាយ និងអ្នកមានសិទ្ធិសម្រេចចិត្តនានាផងដែរ។ គោលបំណងកិច្ចពិភាក្សាសាធារណៈត្រូវបានគេធ្វើឡើងយ៉ាងល្អិតល្អន់ក្នុងជំនួបដែលបានកំណត់ច្បាស់ក្នុងដំណើរការផែនការនេះ។

ឃ- បុគ្គលិក

- ដំណើរការផែនការណ៍ចាប់ផ្តើមនិងត្រូវបានបញ្ចប់ទៅវិញក្នុងអណត្តិថៅហ្វាយខេត្ត គឺលោក JC Rahman Navaហើយបច្ចុប្បន្នជាសមាជិកសភា។ លោកអភិបាល ណាវ៉ា មេដឹកនាំអ្នកធ្វើផែនការក្នុងដំណើរការផែនការនេះ។ អភិបាលខេត្តបច្ចុប្បន្នគឺលោកអភិបាល Felipe Hilan Nava គាត់ជាអភិបាលក្រុងជរដាន់ពីមុន។
- ការិយាល័យផែនការថ្នាក់ខេត្តនិងអភិវឌ្ឍន៍ PPDO បានសម្របសម្រួលកាលវិភាគសកម្មភាពជាមួយនឹងអ្នកពាក់ព័ន្ធនានា ដើម្បីធានាថាសកម្មភាពទាំងអស់ត្រូវបានធ្វើយ៉ាងល្អ។ ជាងនេះទៅទៀត ការិយាល័យនេះត្រូវទទួល

ខុសត្រូវក្នុងការធ្វើសេចក្ដីព្រាងរបាយការណ៍ និងដាក់វត្ថុធាតុដើមបញ្ចូលគ្នាដើម្បីបោះពុម្ព។

- សមាជិក SP បានបង្ហាញពីការមមាញឹកជាមួយនឹងកិច្ចប្រជុំស្ដីពីគោលដៅបញ្ញត្តិតាមរយៈការជ្រើសរើសយុទ្ធសាស្ត្រដែលចង់បានជាង និងល្អបំផុតសម្រាប់ខេត្ត ក្នុងបញ្ញត្តិគោលនយោបាយប្រើប្រាស់ដីនិងទឹក។

- ផ្ដល់នូវគោលការណ៍នៃគម្រោងវិមជ្ឈការដែលក្នុងនោះមន្ត្រីសាលាក្រុង និងខេត្តដើរតួយ៉ាងសំខាន់ក្នុងដំណើរការផែនការនេះ។ អ្នកសម្របសម្រួលក្នុងបណ្ដាការិយាល័យផែនការក្រុងនិងអភិវឌ្ឍន៍ទាំងអស់ត្រូវរ៉ាប់រ៉ងការអញ្ជើញមន្ត្រីខ្លួនឯង និងតំណាងពីវិស័យផ្សេងៗឲ្យចូលរួមកិច្ចប្រជុំដើម្បីផ្ដល់មតិខុសៗគ្នានិងក្នុងកិច្ចពិភាក្សាសាធារណៈផងដែរ។ ក្រុងនិមួយៗបានទទួលធ្វើសិក្ខាសាលាតាមកាលវិភាគក្នុងតំបន់ដែលពួកគេទទួលខុសត្រូវ។

- អភិបាលរងនិមួយៗក៏ជាតួរអង្គយ៉ាងសកម្មក្នុងដំណើរការផែនការនេះដោយសារស្ថិរភាពនៃវត្តមាននិងការចូលរួមរបស់ពួកគាត់។

- ចាប់តាំងពីផែនការនេះទទួលយកអ្នកពាក់ព័ន្ធចម្រុះ អ្នកចូលរួមផ្សេង និងការប្រឹក្សាសាធារណៈមកធ្វើឲ្យមានការទាក់ទិនយ៉ាងខ្លាំងពីសំណាក់អ្នកពាក់ព័ន្ធជាច្រើននៅក្នុងខេត្តហ្វីម៉ារ៉ាសនេះក្នុងការវាយតំលៃទៅលើការបង្ហាញជំរើសយុទ្ធសាស្ត្រជាច្រើន។ សកម្មភាពពាក់ព័ន្ធមិនមែនគ្រាន់តែជាការបោះឆ្នោតថ្នាក់ក្រុងនិងខេត្ត តែងតាំងមន្ត្រី និងភ្នាក់ងាររដ្ឋាភិបាលថ្នាក់ជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏មានការពាក់ព័ន្ធជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល អង្គការរបស់ប្រជាពលរដ្ឋ និងវិស័យសាសនាផងដែរ។

### ង- បែបបទ និងទម្រង់ការ

ដំណើរការផែនការត្រូវបានរចនាឡើងទៅតាមកម្មវិធីកម្មសិក្សាមាន៨ម៉ូឌុលដែលស្របទៅតាមវិធីសាស្ត្រកសាងសមត្ថភាព។ សេចក្ដីសង្ខេបតាមម៉ូឌុលនិមួយៗត្រូវបានបកស្រាយទៅតាមសកម្មភាព ធនធាន និងទិន្នផល ដូចខាងក្រោម:

- ម៉ូឌុលទី១ - បង្កើតទិន្នន័យផែនការដែលក្នុងនោះមានស្ថិតិ និងផែនទីឧបករណ៍វិភាគ ជ្រើសរើសការដាក់ពាក្យ និងបច្ចេកទេសសម្រាប់អនុវត្តឲ្យទៅជាសូចនាករជាច្រើន ការអភិវឌ្ឍ និង បញ្ហាប្រឈម និងឱកាសសម្រាប់អភិវឌ្ឍន៍ផងដែរ។

  ទិន្នផលរបស់ក្រុមនេះរួមមានវឌ្ឍនភាពនៃការមើលឃើញពីបរិស្ថានវិទ្យាស្ថិតិនៃការសាងសង់ត្រួសត្រួស និងតារាងដំណោះស្រាយពេញលេញមួយ។

- ម៉ូឌុលទី២ - រៀបចំគោលដៅថ្មីៗយ៉ាងជាក់លាក់ ឬធ្វើឲ្យមានសុពលភាពឡើងវិញ និង/ឬកែលំអទស្សនៈវិស័យដែលមានស្រាប់។ លទ្ធផលដែលចេញពីម៉ូឌុលនេះគឺការកែតម្រូវឡើងវិញនូវទស្សនទានធាតុផ្សេងៗរបស់ផែនការសូចនាករនិងគោលដៅនានា។

- ម៉ូឌុលទី៣ - រៀបចំPPFPសម្រាប់ខេត្ត និងCLUPសម្រាប់ក្រុង។ នៅក្នុងម៉ូឌុលនេះមានសកម្មភាពសំខាន់ៗបីគឺ (១) ទាញយកយុទ្ធសាស្ត្រចេញពីជំរើសចូលទៅក្នុងគណនេយ្យ លំហយុទ្ធសាស្ត្ររបស់ថ្នាក់តំបន់ និងថ្នាក់ខេត្ត និងជ្រើសរើសជំរើសណាដែលត្រូវការជាងគេសម្រាប់ខេត្ត និងក្រុង (២) រៀបចំគោលនយោបាយស្តីពីការស្នាក់នៅ ផលិតកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងតំបន់ដែលត្រូវការការពារដែលស្របទៅតាមយុទ្ធសាស្ត្ររៀបចំដែនដី និង នយោបាយជាតិ (៣)រៀបចំឧបករណ៍ប្រតិបត្តិ។

- ម៉ូឌុលទី៤ - រៀបចំនូវកម្មវិធីអភិវឌ្ឍន៍វិនិយោគទុនមូលដ្ឋានសម្រាប់ រយៈពេល ៣ឆ្នាំ (LDIP) តាមក្រុងនិមួយៗ។

ច- សេវាកម្ម - លទ្ធផលចំលងចេញពីផែនការ

ក្នុងនាមជាខេត្តកោះមួយ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដែលសំខាន់ជាងគេនៅក្នុងហ្គីម៉ារ៉ាសគឺទាក់ទងនឹងផ្លូវទឹក។ ខេត្តកោះនេះក៏ត្រូវបានប្រើប្រាស់ជាស្ពានឆ្លងរវាងកោះដែលមានទំហំធំៗជាងកោះនេះគឺកោះប៉ាណៃ និងកោះនីគ្រូស។អញ្ចឹងហើយ ការធ្វើស្ពានលើកដាក់បាន គឺជាបញ្ហាហេដ្ឋារចនាសម្ព័ន្ធដ៏សំខាន់។ នៅភាគខាងលិច ត្រូវបានគេសម្រេចថាផែរបស់

ក្រុងជរដាន់ និង បូណាវីស្តាត្រូវបានអភិវឌ្ឍឲ្យក្លាយទៅជាផែតែមួយក្នុងរយៈពេលវែង។ នៅភាគខាងកើតវិញ ទីក្រុងសាន់ឡូរីនស្សូ និង ស៊ីបូណាង បានយល់ព្រមចែករំលែកមុខងារ RORO រវាងពួកគេជាមួយនឹងការផ្តល់ស្បៀងអាហារ របស់សាន់ឡូរីនស្សូដើម្បីសម្រាលចរាចររបស់អ្នកដំណើរក្នុងខណៈដែលទីក្រុងស៊ីបូណាងមានសេវាកម្មសម្រាប់នាវាធំផ្ទុកទំនិញធ្ងន់ៗ។

សម្រាប់កំពង់ផែវិញការធ្វើផែអូសសណ្តោងមិនជាជម្រើសល្អនោះទេ ហើយទីក្រុងជរដាន់ និង នូវ៉ា វាលិនស្សា បានសម្រេចបង្កើតឡើងមួយម្នាក់នៅទីក្រុងឡាវី និង កាបាឡាណាន់។

### ឆ- គុណសម្បត្តិ

ក្នុងនាមជាកន្លែងសំបូរអង្ករ និងត្រីតែមួយមុខមិនអាចធ្វើឲ្យប្រជាពលរដ្ឋនៃហ្គីម៉ារ៉ាសមានភាពសុខសាន្តពេញលេញទេ។ ទើបគេសម្រេចបង្កើននូវកំរិតការបំពេញឲ្យគ្រប់គ្រាន់ទៅលើគ្រឿងបរិភោគ ដូចជា មើម បន្លែ និងសាច់ជាដើម។ ការសំអាតដីឲ្យទូលាយជាច្រើនកន្លែងត្រូវបានគេយកចិត្តទុកដាក់ធ្វើដើម្បីគាំទ្រក្នុងការពង្រីកឧស្សាហកម្មបសុសត្វ។ គ្រប់ទីក្រុងទាំងអស់ក៏ត្រូវបានគេលើកទឹកចិត្តដើម្បី ចិញ្ចឹមមានបក្សី ដោយសារទីផ្សារអាហារសរីរាង្គមានការរីកដុះដាល និងដើម្បីគាំទ្រលើឧស្សាហកម្មទេសចរណ៍ផង។

ក្នុងហ្គីម៉ារ៉ាស សកម្មភាពផលិតកម្មដែលមានទំនាស់ជាងគេគឺការជីកយករ៉ែថ្មកំបោរ ហើយមានការជំទាស់ ក្នុងការរុករកជនដែលហេតុផលចំបងនេះគឺក្នុងការប្រឆាំងជាមួយនឹងសកម្មភាពនេះដោយសារមានផលប៉ះពាល់លើបរិស្ថាន។

### ជ- កត្តានិរន្តរភាព

រដ្ឋាភិបាលថ្នាក់ខេត្តបានបង្ហាញពីការសុខចិត្តបន្តនូវការអនុវត្តផែនការ និងទទួលយកទិន្នផល ក៏ដូចជាលទ្ធផលដែលបានដំណើរការមកជាយូរហើយនេះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកពាក់ព័ន្ធសំខាន់ៗបានកំណត់កត្តាខ្លះៗ ទៅលើកត្តានិរន្តរភាពនៃផែនការ និងដំណើរការផែនការនេះដូចជា ស្ថិរភាពនយោបាយ ការយល់ដឹងជាមុនរបស់ប្រជាពលរដ្ឋ កត្តាខាងក្រៅ និងកំលាំងជំរុញ។

ទាក់ទិននឹងស្ថិរភាពនយោបាយ នេះគឺជាការគំរាមគំហែងមួយដែលថាទស្សនៈបង្រួបបង្រួមមិនត្រូវបានគេទទួលយកក្នុងខណៈដែលគម្រោងអភិវឌ្ឍន៍ទទួលបានលទ្ធផលពីផែនការនោះមិនត្រូវបានសម្រេចដោយអ្នកនយោបាយនៅជំនាន់ថ្មី។ ការសម្រេចចិត្តបានធ្វើរួចហើយ វានឹងអាស្រ័យលើការសម្រេចរបស់អ្នកដឹកនាំថ្នាក់ខេត្តនៅអណត្តិបន្ទាប់ទៀតថានឹងរក្សាផែនការនេះឬអត់នោះទេ។ ដូចនេះគួរតែមានការគិត ទៅលើមនសិការខិតខំប្រឹងប្រែងក្នុងចំណោមអ្នកដឹកនាំកំណត់អាទិភាពសញ្ញាបរិស្ថាន មុននឹងសញ្ញាវិនិយោគទុនដើម្បីផ្តល់នូវការត្រួតពិនិត្យការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព។

ក្នុងស្ថានភាពយល់ដឹងរបស់ប្រជាពលរដ្ឋហ្គីម៉ារ៉ាស ស្តីពីសារៈសំខាន់នៃការចូលរួមក្នុងការការពារបរិស្ថានរបស់ពួកគេត្រូវបានអនុវត្តរួចហើយ។ ករណីជាក់ស្តែងគឺថាប្រជាពលរដ្ឋបានប្រឆាំងភ្លាមៗនៅពេលមានការស្នើសុំរុករករ៉ែ។ ជាងនេះទៅទៀត កត្តាខាងក្រៅមាននយោបាយថ្នាក់ជាតិដែលអាចធ្វើឲ្យមានហានិភ័យដល់ការព្រួយបារម្មណ៍នៅថ្នាក់មូលដ្ឋាន។ ឧទាហរណ៍មួយដែលអាចជាបទពិសោធន៍សំខាន់នោះគឺការបង្វែរប្រេងព្រោះថាគ្មាននយោបាយថ្នាក់ជាតិណាមួយដែលកំណត់ឲ្យច្បាស់ពីប្រភេទនាវាណាដែលអាចដឹកតាមដៃសមុទ្រហ្គីម៉ារ៉ាសឬដៃសមុទ្រអ៊ីលយឡូទេ គេចាត់ទុកថានេះជាតំបន់ងាយប៉ះទង្គិច។

នយោបាយដទៃទៀតដែលអាចជះឥទ្ធិពលច្រើនទៅលើផែនការនេះគឺនយោបាយទេសចរណ៍ និងបញ្ហាសន្តិសុខ។ ដោយយោងទៅលើការិយាល័យផែនការថ្នាក់ខេត្តនិងអភិវឌ្ឍន៍គ្រប់បណ្តាទីក្រុងទាំងអស់គួរតែដឹងពីបញ្ញត្តិដែលត្រូវបានបង្កើត ក៏ដូចជាខ្លឹមសារមានចែងនៅក្នុងបញ្ញត្តិទាំងអស់នោះផងដែរ។ មន្ត្រីសាលាក្រុងគួរតែយល់ថាពួកគេក៏ជាកងកំលាំងមួយក្នុងកិច្ចដំណើរការនេះ។

ភាពជោគជ័យនៃផែនការបង្រួបបង្រួម និងដំណើរការផែនការត្រូវបានគេសន្មត់ថាជាលទ្ធផលមកពីកត្តាជាច្រើនរួមមានឆន្ទៈរបស់អ្នកដឹកនាំនយោបាយ សមត្ថភាពរបស់អ្នកពាក់ព័ន្ធនានា និងការលើកទឹកចិត្តបន្តរបស់ហ្គីម៉ារ៉ាស។ ទាក់ទិនទៅនឹងឆន្ទៈរបស់ថ្នាក់ដឹកនាំនយោបាយក្នុងហ្គីម៉ារ៉ាស គឺលោកអភិបាល និងអភិបាលរងគឺពួកគាត់ចំណាយពេលច្រើនម៉ោងក្នុងកិច្ចពិភាក្សា និងចូលរួមសរសេរនៅលើ ក្រដាសតូចៗ ក្នុងការប្រមូលគំនិតនានាក្នុងសិក្ខាសាលាផ្សេងៗ។ ពួកគាត់គឺជាអ្នកគិតពីផែនការដំបូងគេ និងមិនអាចពឹង

លើក្រុមបច្ចេកទេសរបស់ពួកគាត់ឲ្យធ្វើកិច្ចការនេះម្នាក់ឯងបានទេ។សកម្មភាពជាច្រើននៅក្នុងការវិវត្តន៍នៃដំណើរការផែនការនេះគឺផ្តោតទៅលើការកសាងសមត្ថភាពដោយមិនមែនសម្រាប់តែមន្ត្រីប៉ុណ្ណោះទេពោលគឺសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ផងដែរ។

ការផ្សព្វផ្សាយពីផែនការថ្នាក់ខេត្តមិនធ្វើតែក្នុងប្រទេសហ្វីលីពីនប៉ុណ្ណោះទេ ក៏មានផ្សព្វផ្សាយទៅក្រៅប្រទេសផងដែរ នេះជាការត្រួសត្រាយផ្លូវសម្រាប់ការទទួលបានមូលនិធិ និងទទួលបាននូវអភ័យឯកសិទ្ធិដ៏រឹងមាំមួយ ក៏ដូចជាដៃគូមូលនិធិមកពីស្ថាប័នផ្សេងៗជាច្រើន។ ជាមួយនឹងការបន្តនូវការផ្សព្វផ្សាយនេះ ស្ថាប័នមូលនិធិនានាអាចធ្វើការកត់ចំណាំពីអ្វីដែលហ្គីម៉ារ៉ាសបានផ្តល់ឲ្យ និងជាសក្តានុពលរបស់ខេត្ត។

## ៤-២-៤ ការផ្តួចផ្តើមស្ថាប័នសាធារណៈនៅទីក្រុងឡាំងស៊ុន ប្រទេសវៀតណាម

ទីប្រជុំជនឡាំងស៊ុនត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩២៥ ប៉ុន្តែត្រូវបានគេទទួលស្គាល់ឈ្មោះជាទីក្រុងឡាំងស៊ុន ជាទីក្រុងរបស់ខេត្តឡាំងស៊ុន នៅក្នុងឆ្នាំ២០០២។ ទីក្រុងនេះមានចំងាយ១៥៤គីឡូម៉ែត្រពីទីក្រុងហាណូយ និងមានទំហំ ៧៩.១៨គីឡូម៉ែត្រការេ មានប្រជាជនប្រហែល១៤០,០០០នាក់ រួមមានក្រុមជនជាតិភាគតិចចំនួន៤ក្រុម (គិញ តាយ នុង និង ហោ) និងមានក្រុមជនជាតិភាគតិចផ្សេងទៀត (កោឡាន ដៅ សានដុយ ។ល។)។

សេដ្ឋកិច្ចរបស់ទីក្រុងភាគច្រើនពឹងផ្អែកទៅលើទេសចរណ៍ និងសេវាកម្ម ជាពិសេសគឺវិស័យពាណិជ្ជកម្ម។ កំរិតGDPស្មើនឹង១,២០០ដុល្លារក្នុងប្រជាជនម្នាក់ ជាមួយនឹងសេចក្តីថ្លែងការពីការរីកចម្រើនកើនឡើងនូវខ្ទង់ថវិកា ពី៣៣,៩៣៩លានដុង ក្នុងឆ្នាំ២០០២ ទៅ១២២កោដដុងក្នុងឆ្នាំ២០០៧។

ក្នុងទំហំដីទីក្រុងចំនួន៧៩.១៨គីឡូម៉ែត្រការេ ក្នុងនោះមានដីកសិកម្មចំនួន១៥.៦៦% និងព្រៃឈើចំនួន២២.៧៨%។ ធនធានរ៉ែរបស់ទីក្រុងឡាំងស៊ុនសំខាន់នោះគឺ ថ្មកំបោដែល

ល្អសម្រាប់ផលិតជាស៊ីម៉ង់ និងផលិតនូវវត្ថុធាតុដើមសម្រាប់សំណង់នានា មាន ដីឥដ្ឋ ខ្សាច់ និងគ្រួសតូច ធំជាដើម។

### ខ- ការបរិយាយនិងដើមហេតុឲ្យកើតមានការអនុវត្តល្អ

រដ្ឋាភិបាលវៀតណាមបានដាក់កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈក្នុងរយៈពេល ១០ឆ្នាំ(PAR) គម្រោងមេ២០០១-២០១០ ដែលមានបំណងចង់សាងសង់នូវលទ្ធិប្រជាធិបតេយ្យ សុខភាព និរន្តរភាព វិជ្ជាជីវៈ ប្រសិទ្ធភាព និងសុពលភាពរដ្ឋបាល ប្រកបដោយគុណភាព និងបុគ្គលិកដែលមានសមត្ថភាពឲ្យស្របជាមួយនឹងការកើនឡើងតម្រូវការនៃដំណើរការអភិវឌ្ឍន៍ក្រុង។ នេះគឺជាផ្នែកមួយនៃកម្មវិធី (PAR) ទីក្រុងឡាំងស៊ុនត្រូវបានទទួលស្គាល់ និងបានទទួលរង្វាន់ ISO 9001:2000 សម្រាប់២ផ្នែកៈ (១) ការិយាល័យច្រកចេញចូលតែមួយ ម៉ូឌែល "នាយកដ្ឋានទទួលនិងផ្តល់" និងម៉ូឌែល "ការអភិវឌ្ឍវិស័យអេឡិចត្រូនិច"។

One stop shop model បានផ្តួចផ្តើមឡើងក្នុងឆ្នាំ២០០៤ក្នុងគោលបំណងៈ

- កាត់បន្ថយផលវិបាកសម្រាប់បុគ្គល អង្គការ និងស្ថាប័នជំនួញនានាក្នុងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងគោលការណ៍រដ្ឋបាលសាធារណៈ
- ជំរុញការប្រឆាំងនឹងការិយាធិបតេយ្យ និងអំពើពុករលួយ
- កែលំអរគុណភាពសេវា ចំណេះដឹងពីរបៀបវិន័យ ក៏ដូចជាការទទួលដឹង និងអកប្បកិរិយារបស់ប្រជាពលរដ្ឋដែលប្រើសេវា ហើយនាយកដ្ឋាន និងផ្នែកនិមួយៗមានតួនាទីនិងការទទួលខុសត្រូវច្បាស់លាស់នៅពេលដែលធ្វើការពាក់ព័ន្ធនឹងបញ្ហានានារបស់ប្រជាពលរដ្ឋ
- ផ្តល់នូវបុគ្គលិកដែលមានសមត្ថភាពប្រសើរជាងមុន កំណែទម្រង់ភ្នាក់ងារអង្គការរដ្ឋបាលសាធារណៈក្នុងលក្ខណៈរិតបន្តឹង ប្រសិទ្ធភាព និងរបៀបរបបប្រកបដោយសុពលភាព

ផ្នែកអភិវឌ្ឍន៍វិស័យអេឡិចត្រូនិច បានចាប់ផ្តើមអនុវត្តតាមល័ក្ខខណ្ឌ័ប្រព័ន្ធត្រួតពិនិត្យគុណភាព ISO 9001:2000 ក្នុងគោលបំណង:

- ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានអំពីអាជ្ញាធរមូលដ្ឋាន ភ្នាក់ងារ និងនាយកដ្ឋាន ផ្នែកក្រោមបង្គាប់ មជ្ឈមណ្ឌលបោះឆ្នោត និងឃុំ
- ផ្តល់ព័ត៌មានសំខាន់ៗដល់ប្រជាពលរដ្ឋអំពីសេវាសាធារណៈ ដែលពាក់ព័ន្ធជាមួយនឹងយន្តការរបស់ One stop shop ដែលបានដាក់ចូលក្នុងវិស័យនេះឲ្យអនុវត្តនៅនាយកដ្ឋានទទួលនិងបញ្ជូនតបវិញរបស់គណៈកម្មការប្រជាពលរដ្ឋក្រុង មជ្ឈមណ្ឌលបោះឆ្នោត និងឃុំ
- ផ្សព្វផ្សាយពីរូបភាពរបស់ទីក្រុងឡាំងស៊ុន និងសក្តានុពលទេសចរណ៍របស់ទីក្រុង ការធ្វើពាណិជ្ជកម្ម និងបង្កើតវេទិកាសម្រាប់វិស័យពាណិជ្ជកម្មនេះ
- ចាប់ផ្តើមពីការប្រើកុំព្យូទ័រក្នុងការគ្រប់គ្រងរបស់រដ្ឋទៅជាការអនុវត្តគម្រោងរដ្ឋាភិបាលអេឡិចត្រូនិចប្រកបដោយជោគជ័យ

### ខ- គន្លឹះនៃដំណើរការការអនុវត្តល្អ

ដើម្បីដំណើរការការងារនេះបានយ៉ាងរលូន ចាំបាច់ទីក្រុងត្រូវតែដើរតាមសកម្មភាពមួយចំនួនដូចតទៅ:

- បើកវគ្គបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងអ្នកបំរើការងារក្នុងវិស័យសាធារណៈទាំងអស់នៅក្នុងទីក្រុង ដែលនេះជាតម្រូវការមូលដ្ឋានដែល មិនអាចខ្វះបាន និងជាមាតិការបស់កម្មវិធី PAR
- បទបញ្ញតិនៃផែនការប្រចាំឆ្នាំរបស់PAR សម្រាប់ទីក្រុង
- ដាក់ចេញនូវការណែនាំនានាក្នុងគោលបំណងពង្រឹងការអនុវត្តកម្មវិធីPAR គោរពតាមក្រមនិងវិន័យរដ្ឋបាល និងរៀបចំអង្គការចាត់តាំងនិងដាក់ឲ្យដំណើរការនាយកដ្ឋានទទួលនិងប្រគល់។

- បង្កើតកន្លែង សាងសង់អាគារជាមួយនឹងឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងនាយកដ្ឋាន
- ចាត់តាំងមន្ត្រីដែលមានជំនាញបច្ចេកទេសដើម្បីធ្វើការក្នុង ឃុំ និង មជ្ឈមណ្ឌលបោះឆ្នោត
- ចុះផ្ទាល់ និង ធ្វើទស្សនកិច្ចសិក្សា ទៅទីក្រុង ណាដែលមានអនុវត្តនូវគោលនយោបាយ One stop shop នេះមុន
- បើកវគ្គបណ្តុះបណ្តាលលើមុខជំនាញពាក់ព័ន្ធដើម្បីអនុវត្ត One stop shop
- បង្កើតនូវកម្មវិធីបច្ចេកវិទ្យាដោយយោងទៅលើយន្តការរបស់ One stop shop
- ចុះត្រួតពិនិត្យ និងវាយតំលៃដើម្បីវាស់កំរិតសមិទ្ធផលដែលសម្រេចបាន
- ដាក់បញ្ចូលនូវប្រព័ន្ធត្រួតពិនិត្យគុណភាព ISO 9001:2000 ទៅក្នុងការប្រតិបត្តិរបស់ភ្នាក់ងាររដ្ឋបាលសាធារណៈក្នុងខេត្តឡាំងស៊ុន ក្នុងកំឡុងឆ្នាំ២០០៧-២០១០
- បង្កើត e-portal, LAN, អ៊ិនធរណែត រវាងនាយកដ្ឋានមជ្ឈមណ្ឌលបោះឆ្នោត និងឃុំដែលស្ថិតនៅក្រោមគណៈកម្មាធិការប្រជាពលរដ្ឋក្រុង ព្រមជាមួយនឹងការដាក់ការវិនិយោគទៅលើឧបករណ៍បច្ចេកវិទ្យា និងដាក់កម្មវិធីប្រើប្រាស់ក្នុងប្រព័ន្ធកុំព្យូទ័រទៅក្នុងការគ្រប់គ្រង។

**គ- អ្នកពាក់ព័ន្ធនានា**

គណៈកម្មាធិការប្រជាពលរដ្ឋក្រុងគឺជាតួអង្គគម្រោងទាំងមូលក្នុងការគ្រប់គ្រងក្នុងគំរូនេះ និងបង្កើតគម្រោងកិច្ចសហប្រតិបត្តិការរវាងអង្គការជាច្រើន និងផ្នែកនានាក្នុងទីក្រុង។ អង្គការនិងផ្នែកដែលពាក់ព័ន្ធរួមមានស្ថានីយវិទ្យុក្រុង នាយកដ្ឋានវប្បធម៌ ការឃោសនានិងព័ត៌មាន គណៈកម្មាធិការប្រជាពលរដ្ឋក្នុងមជ្ឈមណ្ឌលបោះឆ្នោត និងឃុំ។

ដំណោះស្រាយទំនាក់ទំនងមានភាពចម្រុះប្រទាក់ក្រឡាគ្នា ដូចជាតាមរយៈការជួបប្រជុំនៅតាមភ្នាក់ងារ អង្គការ និងផ្នែកនិមួយៗ សកម្មភាពជាមួយនឹងក្រុមតាមផ្លូវ តាមរយៈប្រព័ន្ធព័ត៌មានទ្រង់ទ្រាយធំដូចជា វិទ្យុនិងទូរទស្សន៍ក្រុង។កិច្ចប្រជុំជាមួយអង្គការធំៗនានា កិច្ចប្រជុំជាមួយនឹងសហព័ន្ធយុវជន សមាគមន៍ស្ត្រី អ្នកសង្គ្រាមជើងចាស់ ។ល។ ក៏ត្រូវបានធ្វើផងដែរ។

ជាមួយនឹងសមាគមន៍ទីក្រុងនៃប្រទេសវៀតណាម (ACVN) និងវិទ្យាស្ថានជាតិនៃរដ្ឋបាលសាធារណៈក្នុងទីក្រុងឡាំងស៊ុនដែលជ្រើសរើសដោយ Net-com AG ជាក្រុមហ៊ុនរបស់អាល្លឺម៉ង់ដែលបានអនុវត្តគម្រោងមួយក្នុងការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈ និងធ្វើឲ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ។

នាយកដ្ឋានទទួលឯកសារនិងផ្តល់លទ្ធផល ដឹកនាំដោយប្រធានម្នាក់ និងអ្នកជំនាញ៥នាក់ទៀតហើយស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីការិយាល័យក្រុមប្រឹក្សាប្រជាពលរដ្ឋនិងគណកម្មការប្រជាពលរដ្ឋក្រុង។ មន្ត្រីជំនាញទាំង៥នោះទទួលខុសត្រូវលើការទទួលនិងបញ្ជូនលទ្ធផលត្រលប់ទៅវិញដែលពាក់ព័ន្ធនឹងផ្នែកចុះបញ្ជីពាណិជ្ជកម្ម ចេញវិញ្ញាបណ្ណប័ត្រ និងច្បាប់អនុញ្ញាតិឲ្យសាងសង់។ The E-portal ប្រតិបត្តិនិងផ្តល់នូវព័ត៌មានពីគោលការណ៍ណែនាំចុងក្រោយបង្អស់និងគោលនយោបាយរបស់គណបក្សនិងរដ្ឋ គណកម្មការគណបក្ស និងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាព័ត៌មានពីប្រតិបត្តិការតាមនាយកដ្ឋានរបស់រដ្ឋាភិបាលនិមួយៗ អង្គការនានា មជ្ឈមណ្ឌលបោះឆ្នោត និងតាមបណ្តាឃុំផងដែរ។

**ឃ- ថវិកា**

ដើមទុនសម្រាប់វិនិយោគរបស់គំរូ២នេះគឺ ២.៤៩៧កោដិដុងវៀតណាម។ ចំណាយទាំងនេះសម្រាប់ថ្លៃការសាងសង់អាគារ និងបរិក្ខា ឧបករណ៍បច្ចេកវិទ្យាសម្រាប់ប្រព័ន្ធកុំព្យូទ័ររួមមានអ្នកបំរើសេវាកម្ម កន្លែងធ្វើការ ម៉ាស៊ីនស្កេន ម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនហ្វូតូកូពី ម៉ាស៊ីនដាក់បង្ហាញបែបទំនើបសម្រាប់ផ្សព្វផ្សាយពីនិតិវិធីនានាប្រព័ន្ធបន្ទុកស្វ័យប្រវត្តិនិងម៉ាស៊ីនថត និងឧបករណ៍ជាច្រើនទៀត។

ការបង្កើត E-portal តាមរយៈហិរញ្ញប្បទានដោយក្រុមហ៊ុន The Net-Com AG ។ ក្រុមហ៊ុនផ្តល់ការគាំទ្រដល់ការគូរប្លង់ដំបូង និងការអភិវឌ្ឍ ចំណែករាល់ការចំណាយសម្រាប់ប្រតិបត្តិការនិងការជុសជុលPortal ជាបន្ទុករបស់ថវិការដ្ឋដែលឲ្យទៅក្រុង។

**ង- សមិទ្ធផលសំខាន់ៗ និងផលប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ**

ការអនុវត្តកំណែទម្រង់រដ្ឋបាលក្នុងទីក្រុងឡាំងស៊ុនបានទទួលលទ្ធផលសម្រេចល្អ និងផលប៉ះពាល់វិជ្ជមានទៅលើប្រជាជន និងអង្គការនានាក្នុងទីក្រុងនេះ។

ក្នុងផ្នែកច្រកចេញចូលតែមួយ ឯកសារផ្លូវច្បាប់ តាមលំដាប់លំដោយ ពេលវេលា ថ្លៃសេវាកម្ម ត្រូវបានប្រកាសពីតម្លាភាព។ ភាពងាយស្រួលនៃច្បាប់រដ្ឋបាលមានភាពច្បាស់លាស់ សមញ្ញ បើកចំហរ និងត្រឹមត្រូវតាមនិតិវិធី ត្រូវបានសម្របសម្រួលដោយមានឯកសារភស្តុតាង និងភាពងាយស្រួលដល់ប្រជាពលរដ្ឋ និងអង្គការផ្សេងៗ។ ទាំងអស់នេះបានធ្វើឲ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានមានការសប្បាយចិត្តយ៉ាងខ្លាំងនិងពេញចិត្តចំពោះការគ្រប់គ្រងរបស់ក្រុង។

អន្តរវិស័យយន្តការ One stop shop បានអភិវឌ្ឍគុណភាពសេវាកម្ម បំពេញតាមតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ទៅលើសេវាសាធារណៈ សេវាឆ្លើយតបកាន់តែប្រសើរ និងការពង្រីកនូវរូបភាពនៃអាជ្ញាធរមូលដ្ឋាន កាត់បន្ថយគម្លាតរវាងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋមូលដ្ឋាន កាត់បន្ថយការរំខាន និង ការបញ្ជាក់របស់មន្ត្រី និងអ្នកបំរើការស៊ីវិល។

លក្ខខ័ណ្ឌសង្គមសេដ្ឋកិច្ចរបស់ទីក្រុងមានភាពអភិវឌ្ឍកើនឡើងដោយសារបុគ្គល និងអង្គការនិមួយៗអាចផ្តល់ឲ្យនូវភាពច្បាស់លាស់ និង ព័ត៌មានប្រាកដប្រជា និងគោលការណ៍ណែនាំ អំពើខុសច្បាប់ និងកាត់បន្ថយករណីសាងសង់ដោយគ្មានការអនុញ្ញាតិ ។

ករណីអវិជ្ជមានដូចជា អំពើរពុករលួយត្រូវបានកាត់បន្ថយយ៉ាងខ្លាំងក្លាបំផុត។ ប្រជាពលរដ្ឋមូលដ្ឋានគាំទ្រកម្មវិធីPAR និងជឿជាក់ទៅលើគោលការណ៍ណែនាំ និងគោលនយោបាយរបស់គណបក្សនៃរដ្ឋ ក៏ដូចជាអាជ្ញាធរមូលដ្ឋានដែរ។

### ច- កត្តាគន្លឹះសម្រាប់ជោគជ័យ

កត្តាសំខាន់ៗក្នុងការកំណត់កត្តាជោគជ័យក្នុងគំរូ PAR នៃទីក្រុងឡាំងស៊ុន មានដូចតទៅ:

- ភាពច្បាស់លាស់ គោលការណ៍ណែនាំត្រឹមត្រូវក្នុងការធ្វើកំណែទម្រង់ជាថ្មី ពីសំណាក់រដ្ឋាភិបាលវៀតណាម
- គណៈកម្មាការគណបក្ស អាជ្ញាធរទីក្រុងឡាំងស៊ុន ការឆ្លើយតបរបស់ប្រជាពលរដ្ឋរស់នៅអចិន្ត្រៃយ៍ ការគាំទ្រវិជ្ជាមានសម្រាប់ ការធ្វើកំណែទម្រង់ ទៅលើគោលការណែនាំនេះឡើងវិញ
- ភាពស្វាហាប់ ភាពរស់រវើក និងការកំណត់ប្រតិបត្តិការរបស់រដ្ឋាភិបាល ទីក្រុងគំរូនេះ និងដោះស្រាយបញ្ហាក្នុងកំឡុងពេលអនុវត្តការងារ
- ពិនិត្យជាប្រចាំ ត្រួតពិនិត្យក្នុងកំឡុងពេលប្រតិបត្តិការ
- យកចិត្តទុកដាក់និងការបណ្តុះបណ្តាល ហ្វឹកហ្វឺនរំលឹកឡើងវិញសម្រាប់ គ្រូបង្ហាត់ និងមន្ត្រីរដ្ឋាភិបាល
- បន្ថែមល្បឿនជាប្រចាំ ទំនើបកម្ម យុត្តិកម្ម គ្រប់សកម្មភាពដែលបានធ្វើក្នុង ប្រតិបត្តិការ
- និន្នាការចែករំលែកព័ត៌មាន និងការផ្សព្វផ្សាយឃោសនា ទៅដល់ក្រុមគ្រូបង្ហាត់ និងមន្ត្រីរដ្ឋាភិបាលក៏ដូចជាគណៈកម្មាការនិមួយៗផងដែរ។
- ដាក់ចេញនូវអង្គការសង្គមស៊ីវិល គណៈកម្មការអចិន្ត្រៃយ៍ដែលជាចំណែកមួយ ក្នុងកិច្ចដំណើរការប្រតិបត្តិ ការចូលរួម ក្នុងការត្រួតពិនិត្យ
- សិក្សាបទពិសោធន៍ពីបណ្តាទីក្រុងក្នុងវិសាលភាពជាតិ ក្នុងការដាក់បញ្ចូល យ៉ាងត្រឹមត្រូវទៅក្នុងល័ក្ខខណ្ឌមូលដ្ឋាន

- ពង្រឹងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ទទួលយកអត្ថប្រយោជន៍ពីការគាំទ្រពីសំណាក់អង្គការអន្តរជាតិនានា

### ឆ- បញ្ហាប្រឈម

បញ្ហាប្រឈមដ៏ធំបំផុតសម្រាប់តម្រូវការការកសាងប្រសិទ្ធភាព តម្លាភាព ប្រព័ន្ធអំណាចរដ្ឋបាល គឺភាពទុនខ្សោយនៃបរិបទរដ្ឋបាលនានា អំពើពុករលួយ និងការធ្វើឲ្យបាត់បង់នូវសីលធម៌ពីសំណាក់មន្ត្រីរដ្ឋាភិបាល។ មាត្រដ្ឋាន និងទំហំដ៏មហិមានៃកំណែទម្រង់រដ្ឋបាលនេះតម្រូវឲ្យបន្តការប្រតិបត្តិជាមួយនឹងការសម្រេចចិត្តដ៏ខ្ពស់ សិក្សា និងអនុវត្តដំណាលគ្នា ការសាកល្បង និងគូសវាសបទពិសោធន៍ពីគំរូនៃការគ្រប់គ្រងឲ្យបានច្បាស់លាស់។ ការិយាល័យរដ្ឋបាលរបស់រដ្ឋាភិបាលត្រូវការការព្យាយាមក្នុងការកែលំអឡើងវិញ កំណែទម្រង់ដោយខ្លួនឯងដើម្បីទទួលបាននូវគោលដៅមួយក្នុងការកសាងរដ្ឋបាលបែបលិទ្ធិប្រជាធិបតេយ្យ និងឈានទៅរកទំនើបកម្មដោយសន្សឹមៗ ទទួលស្គាល់សិទ្ធិ ប្រជាជនជាធំ ពង្រឹងការអនុវត្តច្បាប់ ក្នុងរបបសង្គមនិយមបែបសេដ្ឋកិច្ចទីផ្សារ។

និចលភាពនៃមជ្ឈការ និងរបៀបរបបការិយាល័យធិបតេយ្យបានមានឥទ្ធិពលគ្របដណ្តប់យ៉ាងខ្លាំងក្លាទៅលើរចនាបថនៃការគិតនិងបែបផែនធ្វើការរបស់មន្ត្រី និងអ្នកបំរើការស៊ីវិលជាច្រើន ក្នុងខណៈដែលកំណែទម្រង់ត្រូវបានគេធ្វើឡើងក្នុងល័ក្ខខណ្ឌមួយដែលគ្មានបទពិសោធន៍ ចំណេះដឹងនិងសមត្ថភាពនៅមានកំណត់នៅឡើយពាក់ព័ន្ធទៅនឹងយន្តការសេដ្ឋកិច្ចបែបថ្មីនេះ។ នេះជាការប្រឈមមុខនឹងតម្រូវការការកសាងលទ្ធិប្រជាធិបតេយ្យ និងប្រព័ន្ធរដ្ឋបាលសាធារណៈបែបទំនើប។

បុគ្គលិកការងារក្នុង The One Stop Shop ត្រូវបានគេចាត់មកពីនាយកដ្ឋាននានាដែលមានប្រព័ន្ធគ្រប់គ្រងបុគ្គលិកខុសៗគ្នា។ ដូចនេះជាការពិបាកណាស់ក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យរាល់ការងាររបស់ពួកគាត់ និងធានាថាបានទទួលអត្ថប្រយោជន៍ដូចៗគ្នាក្នុងពេលធ្វើការសម្រាប់ The One Stop Shop។ ផ្ទុយទៅវិញបុគ្គលិកមិនត្រូវបានគេបណ្តុះបណ្តាល ជាប្រចាំដើម្បីបំពេញសមត្ថភាពបំពេញការងាររបស់ពួកគេទេ ហេតុដូច្នេះ

ពេលខ្លះមន្ត្រីនៅក្នុងនាយកដ្ឋាននេះមិនអាចផ្តល់ការពន្យល់ច្បាស់លាស់ណាមួយដល់ប្រជាពលរដ្ឋពីបញ្ហាពន្យាពេល និងបញ្ហានានាដែលទាក់ទងដទៃទៀត។

ការត្រួតពិនិត្យពីការវិវត្តនៃឯកសារទូទាត់មិនត្រូវបានរួមបញ្ចូលទៅក្នុងប្រព័ន្ធប្រើប្រាស់ដោយកុំព្យូទ័រនោះទេ។ ISO9001-2000 បានធ្វើការពិនិត្យឡើងវិញពីការងារដំណើរការបន្តរបស់រដ្ឋបាលសាធារណៈនេះ ហើយគេប្រើអេក្រង់របស់កម្មវិធីប្រើប្រាស់ដោយប្រព័ន្ធកុំព្យូទ័រដើម្បីស្វែងរកភាពមិនសុក្រិតជាមួយនឹងប្រព័ន្ធដែលមិនត្រូវបានបង្ហាញជាសាធារណៈ។ ដើមទុនវិនិយោគសម្រាប់មជ្ឈមណ្ឌល និងបរិក្ខាសម្រាប់ផ្នែកនេះក៏មិនគ្រប់គ្រាន់។

### ឆ- ផ្តោតទៅលើនិរន្តរភាព

សម្រាប់បណ្តាទីក្រុងសាកល្បងណាដែលមានបំណងអនុវត្តតាមការអនុវត្តល្អនេះ គួរយកចិត្តទុកដាក់លើកិច្ចការដូចខាងក្រោម:

- ការប្រើប្រាស់ One stop shop និង The e-portal អាចមានប្រសិទ្ធភាពអតិបរមា និងមាននិរន្តរភាពលុះត្រាតែគ្រប់ប្រភេទសេវាទាំងអស់ជាតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។ដូចនេះទីក្រុងសាកល្បងគួរតែអភិវឌ្ឍន៍អត្ថន័យដើម្បីកំណត់ពីសេវាអ្វីដែលប្រជាពលរដ្ឋត្រូវការបំផុត ព្រមទាំងទទួលបានមុខងារទាំងនោះបន្ថែមពីថ្នាក់លើនៃរដ្ឋាភិបាលដោយសន្សឹមៗ។

- ការផ្តល់សេវាកាន់តែច្រើននៅកំរិតនេះ ការខិតចូលទៅរកការត្រួតពិនិត្យ និងការធ្វេសប្រហែសទៅលើគំនិតនេះអាចក្លាយជាបន្ទុកកាន់តែធ្ងន់សម្រាប់ការគ្រប់គ្រងរបស់ក្រុង។ ដូចនេះកត្តាដែលសំខាន់សំដៅលើយន្តការដូចជាការធ្វើសវនកម្មសង្គម, បើកវេទិកាជាប្រចាំ និងដាក់ប្រព័ន្ធពាក្យបណ្តឹងផ្សេងៗនៅកន្លែងមួយដែលអាចរក្សាការពារបាន និងបង្ហាញពីការខកខានមិនទាន់បានចាត់ការទៅលើឯកសារណាមួយព្រមទាំងមានការដាក់ទោសដល់មន្ត្រីនិងផ្នែកដែលពាក់ពន្ធ័ទៀតផង។

- វាស្រដៀងនឹងការអនុវត្តល្អពីរដ្ឋាភិបាលអេឡិចត្រូនិច ក្នុងក្រុងយូកយ៉ាកាតា ដែលត្រូវតែមានការជួសជុលថែទាំ និងធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធប្រើប្រាស់កុំព្យូទ័រ។ ដូចនេះទីក្រុងសាកល្បងគួរតែចាត់ចែងទុកថវិកាមួយចំណែកសម្រាប់បំរើគោលបំណងនេះ និងផ្តល់វគ្គបណ្តុះបណ្តាលសំខាន់ៗដល់មន្ត្រីពាក់ព័ន្ធក៏ដូចជា លើកទឹកចិត្តដល់ការយល់ដឹងរបស់សាធារណៈជនពីការប្រើប្រាស់ប្រព័ន្ធថ្មីនេះ។

### ៤-២-៥ ការពង្រឹងរដ្ឋបាលថ្នាក់មូលដ្ឋានដោយខ្លួនឯង: ចំណូល និងថវិកាក្នុងខេត្តបាត់ដំបង ប្រទេសកម្ពុជា

ទីក្រុងបាត់ដំបងស្ថិតនៅចំកណ្តាលនៃខេត្តបាត់ដំបង ដែលមានចំងាយប្រហែលជា៣១០គីឡូម៉ែតពីរាជធានីភ្នំពេញ ហើយស្ថិតនៅភាគខាងលិចនៃប្រទេស។ ទីក្រុងនេះគ្របដណ្តប់ដោយដីទំហំ១១,៥៤៤ហិកតា និងមានប្រជាជនសរុបចំនួន ១៥១,៦៥៦នាក់ (ឆ្នាំ ២០០៨)។ ជាមួយនឹងចំនួនប្រជាជនយ៉ាងច្រើន និងមានទីតាំងនៅចំកណ្តាលខេត្តបាត់ដំបងដូចនេះហើយទើបធ្វើទីក្រុងឈានទៅរកសម័យនគរូបនីយកម្មយ៉ាងរហ័ស និងក្លាយទៅជាទីប្រជុំជនមួយយ៉ាងធំដែលអាចផ្តល់ការស្នាក់នៅ ដល់បណ្តាអ្នកស្នាក់អាស្រ័យដើម្បីបន្តចំណេះដឹង ទទួលសេវាសុខភាព វប្បធម៌ និងសេវាសេដ្ឋកិច្ច ដែលពួកគេមកពីបណ្តាខេត្តជិតខាងទៀតផង។ ក្រោមច្បាប់រៀបចំអង្គការ ទីក្រុងនេះត្រូវបានគ្រប់គ្រងដោយសមាជិកក្រុមប្រឹក្សាចំនួន១៥នាក់ (ស្ត្រីម្នាក់) និង គណៈអភិបាលក្រុងចំនួន៥នាក់ទៀត។ អ្នកបំរើការងារស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យាចំនួន៧៨នាក់ (ស្ត្រី២០នាក់) ដែលស្ថិតក្រោមការត្រួតត្រាដោយផ្ទាល់ពីរដ្ឋបាលក្រុង។

#### ក- ការបរិយាយនិងដើមហេតុឲ្យកើតមានការអនុវត្តល្អច្រកចេញចូលតែមួយ

កម្មវិធីសាកល្បងដែលមានឈ្មោះថាច្រកចេញចូលតែមួយត្រូវបានផ្តួចផ្តើម និងបង្កើតឡើងដោយអនុក្រិត្យលេខ៤៧ ចុះថ្ងៃទី១១ មិថុនា ២០០៣ និងបានដាក់ឲ្យអនុវត្តសាកល្បងក្នុងក្រុងបាត់ដំបង និងក្រុងសៀមរាប(ដែលពីមុនគេហៅថាស្រុក) ក្នុងឆ្នាំ២០០៥។ សារៈសំខាន់ចំបងនៃកម្មវិធីសាកល្បងនេះគេធ្វើឡើងដើម្បីអភិវឌ្ឍន៍លើ:

- ក្របខ័ណ្ឌច្បាប់សំខាន់លើប្រព័ន្ធចំណូលសម្រាប់គម្រោងសាកល្បងក្នុងស្រុកប្រជុំជន និងទទួលបានបទពិសោធន៍ និងមេរៀនត្រលប់សម្រាប់កំណែទម្រង់វិមជ្ឈការក្នុងកំរិតនេះ

- គោលការណ៍ច្បាប់ថវិកាដែលមានស្រាប់ សម្រាប់ទីក្រុងសាកល្បងនេះផ្តោតទៅលើតួនាទីមុខងារល្អៗ និងប្រព័ន្ធគម្រោងថវិកាប្រកបដោយប្រសិទ្ធភាពការប្រតិបត្តិ ការត្រួតពិនិត្យតាមដាន ក្នុងមូលដ្ឋាន។

- សមត្ថភាព និងការផ្លាស់ប្តូរឥរិយាបថរបស់ថ្នាក់រដ្ឋបាលកំរិតទី៣ដើម្បីមានភាពខិនលំទោនជាងមុន។ ការគ្រប់គ្រង និងការប្រើប្រាស់ច្បាប់ថ្មីមានភាពសកម្មសម្រាប់អភិបាលកិច្ចល្អ ការចូលរួមពីប្រជាជនក្នុងនាមជាគំរូលទ្ធិប្រជាធិបតេយ្យថ្នាក់មូលដ្ឋានក្នុងប្រទេសកម្ពុជា និងការខិតចូលទៅកាន់តែជិតសាធារណជន ព្រមជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកដើម្បីផ្តល់ព័ត៌មានពីរដ្ឋបាលក្រុង។

ការិយាល័យច្រកចេញចូលតែមួយ (OWSO) ទទួលខុសត្រូវលើកិច្ចការរដ្ឋបាល និងការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ។ ការិយាល័យនេះមានមន្ត្រីនៅជួរមុខ (៣-៦នាក់) ដែលជាអ្នកទទួលខុសត្រូវលើការបំរើសេវាដល់អតិថិជន និងមន្ត្រីនៅជួរក្រោយ (៥-១០នាក់) ជាអ្នកទទួលខុសត្រូវសម្រាប់រៀបចំ និងដំណើរការការងារតាមតម្រូវការរបស់អតិថិជន។ ទីក្រុងផ្តល់នូវសេវាដូចជាៈ

- វប្បធម៌ និងវិចិត្រសិល្បៈ (សម្រាប់ផ្តល់នូវអាជ្ញាប័ណ្ណដល់ជាងថតរូបផ្សេងៗ ឬហាងជួលថតវីដេអូជាដើម)

- ទេសចរណ៍ (ក្នុងការផ្តល់នូវអាជ្ញាប័ណ្ណដល់បណ្តាផ្ទះសំណាក់ដែលមានគ្រែ៥ និងភោជនីយដ្ឋានត្រឹម៥០កៅអី)

- គមនាគមន៍ (ការចុះបញ្ជីម៉ូតូនិងយានជំនិះផ្សេងៗ )

- វិស័យឧស្សាហកម្មរ៉ែ និងថាមពល (ក្នុងការចុះបញ្ជីកាន់កាប់លើហាងសិប្បកម្ម និងមុខជំនួញក្នុងវិស័យឧស្សាហកម្ម)
- ពាណិជ្ជកម្ម (ការចុះបញ្ជីពាណិជ្ជកម្មខ្នាតតូច)
- អាជ្ញាប័ណ្ណសំណង់ សម្រាប់ផ្ទះស្នាក់នៅក្នុងទំហំមិនលើសពី៥០០ម៉ែត្រការេ

រហូតមកដល់ឆ្នាំ២០០៩ OWSO ក្នុងទីក្រុងបាត់ដំបងមានលទ្ធភាពផ្ដល់នូវសេវាប្រហែល៩៨ប្រភេទខុសៗគ្នាដែលពាក់ព័ន្ធជាមួយវិស័យនានាខាងលើ ក្នុងខណៈដែលបច្ចុប្បន្ននេះក្នុងជួរស្ថាប័នក្រសួងកំពុងស្ថិតក្នុងដំណើរការពិនិត្យឡើងវិញ និងផ្ដល់មុខងារបន្ថែមមកដល់គម្រោងនេះផងដែរ។

### ខ- ការិយាល័យប្រជាពលរដ្ឋ

ដើម្បីជាការលើកទឹកចិត្តដល់អភិបាលកិច្ចល្អក្នុងការអនុវត្តOWSO ទីក្រុងបានបង្កើត **ការិយាល័យប្រជាពលរដ្ឋ** ដែលមានសិទ្ធិក្នុងការទទួលពាក្យត្អូញត្អែរ និងផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ អ្នកជំនួញ អ្នកផ្តល់សេវា សហគ្រាសតូចៗ និង អង្គការក្រៅរដ្ឋាភិបាល ក្នុងករណីណាដែលមានភាពមិនត្រឹមត្រូវ ឬកំហុសកើតឡើងដោយចេតនាពីសំណាក់មន្ត្រី/បុគ្គលិកដែលធ្វើការងារក្នុងរដ្ឋបាលក្រុង/ស្រុក។

**ការិយាល័យប្រជាពលរដ្ឋ** គឺជាការិយាល័យអព្យាក្រឹត្យសម្រាប់ទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋអំពីកិច្ចការរដ្ឋបាល ហើយមានតួនាទីជាអ្នករៀបចំទុកដាក់ពាក្យបណ្តឹងទាំងអស់នោះ ពិនិត្យរាល់ការព្រួយបារម្ភណ៍របស់ប្រជាពលរដ្ឋ កសាងទំនាក់ទំនងល្អជាមួយអ្នកជំនួញ សង្គមស៊ីវិល និងរដ្ឋបាល។ ប្រធានការិយាល័យត្រូវបានបោះឆ្នោតដោយគណៈកម្មការមួយ ដែលគាត់អាចជ្រើសរើសយកអ្នកណាដែលមានប្រជាប្រិយភាព និងគួរឲ្យគោរព សុចរិត និងមានកេរ្តិ៍ឈ្មោះល្អពីក្នុងសហគមន៍របស់គាត់។ គាត់ត្រូវតែមិនមែនជាបុគ្គលណាម្នាក់ដែលស្ថិតក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់គណៈបក្សនយោបាយណាមួយ ហើយជាមនុស្សដែលមានចំណេះដឹង និងបទពិសោធន៍ល្អ មានការយោគយល់ចេះអាធ្យាស្រ័យ ជាអ្នកមានសុភវិនិច្ឆ័យក្នុងរដ្ឋបាលក្រុង/ស្រុកទៀតផង។

ប្រធានត្រូវទទួលបានការបោះឆ្នោតដោយគណៈកម្មការបោះឆ្នោតមូលដ្ឋាន ដែលរួមមាន អភិបាលក្រុង/ស្រុក សមាជិកក្រុមប្រឹក្សាក្រុង/ស្រុកទាំងអស់ អ្នកតំណាងមកពីក្រុមអ្នកជំនួញ៣នាក់ អ្នកតំណាងមកពីអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល៣នាក់។

គោលបំណងសំខាន់ក្នុងការបង្កើត **ការិយាល័យប្រជាពលរដ្ឋ** គឺដើម្បីៈ

- ធ្វើឲ្យរដ្ឋបាលកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព កាត់បន្ថយអំពើពុករលួយ កាន់តែទទួលបានការជឿជាក់ និងពេញចិត្តពីសំណាក់ប្រជាពលរដ្ឋលើរដ្ឋបាលនេះ។
- បង្កើនការចូលរួមនឹងផ្តល់ឱកាសដល់ប្រជាពលរដ្ឋ ដើម្បីឲ្យសំលេងគាត់បានលឺដល់ថ្នាក់គ្រប់គ្រង

- ផ្តល់ឲ្យប្រជាពលរដ្ឋនូវអ្នកសម្របសម្រួលអព្យាក្រឹត្យមួយដែលអាចជួយគាត់ដើម្បីដោះស្រាយពាក្យបណ្តឹង និងទំនាស់ជាមួយថ្នាក់គ្រប់គ្រង

**គ- ការវាយតំលៃនៃការអនុវត្តល្អ**

សេវានានាក្នុង OWSO ដែលមាននៅក្នុងទីក្រុងបាត់ដំបងត្រូវបានគេសំគាល់ឃើញថាមានភាពខុសគ្នាពីប្រព័ន្ធចាស់ ហើយលក្ខណៈខុសគ្នាមានដូចជាៈ (១) ថ្លៃឈ្នួលសម្រាប់សេវាចម្រុះនៅការិយាល័យនេះ ត្រូវបានដាក់បង្ហាញឲ្យឃើញ(ផ្សព្វផ្សាយឲ្យមើលនៅការិយាល័យផ្ទាល់) និង (២) សេវាត្រូវបានផ្តល់ឲ្យទាន់ពេលវេលា និងសុក្រិត្យ។ តាមរយៈការអនុវត្តនូវការផ្តល់ប្រភេទសេវាទាំងនេះ ទីក្រុងមានលទ្ធភាពប្រមូលបានប្រភពចំណូលប្រចាំឆ្នាំផ្ទាល់ខ្លួនផងដែរ។

ការសាកល្បងទៅលើ OWSO និង **ការិយាល័យប្រជាពលរដ្ឋ**មិនមែនជាឧបករណ៍សម្រាប់ចាក់ចូលទៅជ្រៅ និងគ្របដណ្តប់លើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ D&D នោះទេ ប៉ុន្តែវាជាការចូលរួមចំណែកមួយក្នុងការគាំទ្រដល់រដ្ឋាភិបាលដើម្បីធ្វើឲ្យការផ្តល់សេវាមានគុណភាពកាន់តែប្រសើរឡើង ព្រមទាំងនាំយកសេវាកម្មទាំងនេះទៅកាន់តែជិតប្រជាជន។ នេះជាការលើកទឹកចិត្តដល់គោលការណ៍អភិបាលកិច្ចល្អជាច្រើនយ៉ាងដូចជា តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងដាក់រង្វាស់ត្រឹមត្រូវដើម្បីប្រឆាំងនឹងអំពើពុករលួយ ព្រមជាមួយនឹងការដាក់ទោសទណ្ឌផងដែរ។ ខាងក្រោមនេះជាការសង្ខេបពីលទ្ធផលនៃអនុវត្តសាកល្បងៈ

- ការបង្កើតរចនាសម្ព័ន្ធគាំទ្រលើការិយាល័យច្រកចេញចូលតែមួយបានផ្តល់ ឲ្យទីក្រុងបាត់ដំបងទទួលបានសិទ្ធិតាមផ្លូវច្បាប់ក្នុងការសម្របសម្រួលជាមួយផ្នែកពាក់ព័ន្ធនានាក្នុងការផ្តល់សេវាសាធារណៈនិងនាំយកនូវអំណាចតាមមុខងារនិមួយៗរបស់ក្រសួងពាក់ព័ន្ធផងដែរ។

- ការបង្កើតការិយាល័យប្រជាជនគឺមានប្រយោជន៍ណាស់។ ការិយាល័យនេះមិនត្រឹមតែដើរតួនាទីជាអាជ្ញាកណ្តាល ក្នុងការដោះស្រាយវិវាទរវាងប្រជាពលរដ្ឋ និង រដ្ឋបាលក្រុងប៉ុណ្ណោះទេ ពោលគឺការិយាល័យនេះក៏បានជួយ

ក្នុងការធ្វើឲ្យគុណភាព តម្លាភាព និងគណនេយ្យភាពកាន់តែប្រសើរឡើង ព្រមទាំងលើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ និងធ្វើឲ្យប្រជាពលរដ្ឋមានការជឿជាក់លើការផ្តល់សេវានានារបស់សាលាក្រុងផងដែរ។

- ការបង្កើតនូវ OWSO ផ្តល់នូវឱកាសដ៏ល្អសម្រាប់ប្រជាពលរដ្ឋដើម្បីទទួលបានសេវាសាធារណៈនានាដែលបានមកពីរដ្ឋបាលក្រុងជាមួយនឹងប្រសិទ្ធភាព និងតម្លាភាពកាន់តែប្រសើរច្រើនជាងមុន។
- មានក្រុមប្រឹក្សាក្រុងដើម្បីកែលំអគម្រោងថវិកាប្រចាំឆ្នាំ និងត្រួតពិនិត្យតាមដានការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ នេះគឺជាយន្តការមួយប្រកបដោយប្រសិទ្ធភាពសម្រាប់ពិនិត្យ/តុល្យភាពនៃការប្រើប្រាស់ធនធានសាធារណៈ
- តាមរយៈ OWSO ទីក្រុងបាត់ដំបងមានលទ្ធភាពក្នុងការបង្កើនចំណូលរបស់ខ្លួនជិត៨ដងក្នុងឆ្នាំ២០០៩ ពោលគឺពី២៧លានរៀលក្នុងឆ្នាំ២០០៥ កើនដល់២០៥លានរៀល (ឬប្រហែល៥០,០០០ដុល្លារអាមេរិក) ក្នុងឆ្នាំ២០០៩ នៅខណៈដែលគោលដៅរដ្ឋាភិបាលដាក់ចេញសម្រាប់ការិយាល័យនេះមានត្រឹមតែ៨៧លានរៀលប៉ុណ្ណោះ។ នេះជាសមិទ្ធផលសម្រេចមួយលើប្រភពចំណូល ហើយនេះក៏ជាភស្តុតាងមួយយ៉ាងច្បាស់លាស់សម្រាប់រដ្ឋាភិបាលថ្នាក់ជាតិក្នុងការធ្វើកំណែទម្រង់បន្ថែមទៀតលើ D&D។

ដោយយោងលើលទ្ធផលវិជ្ជមាននៃគំរូនេះ រដ្ឋាភិបាលនៃប្រទេសកម្ពុជាបានសម្រេចពង្រីកគំរូនេះទៅក្នុងការអនុវត្តលើ២២ក្រុង/ស្រុកក្នុង៤ឆ្នាំបន្ទាប់ទៀត។ ការពង្រីកគំរូនេះត្រូវអនុវត្តដោយគណៈកម្មការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ NCDD ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ ជាមួយនឹងការគាំទ្រហិរញ្ញវត្ថុដោយធនាគារពិភពលោកសម្រាប់គម្រោងអភិបាលកិច្ចល្អ (DfGG)។

### ឃ- បញ្ហាប្រឈម និងកត្តានិរន្តរភាព

គោលដៅចំបងនៃOWSO ក្នុងនាមជាកម្មវិធីសាកល្បងមួយសម្រាប់ការផ្ទេរអំណាចមុខងារសេវាសាធារណៈពីថ្នាក់ក្រសួងទៅថ្នាក់ក្រោមជាតិ។ តាំងពីយូរមកហើយ មានក្រសួង

ចំនួន៦ដែលបានផ្ទេរអំណាចមុខងារឲ្យទៅOWSO ហើយក្រសួងទាំងនោះមានដូចជា ក្រសួងគ្រប់គ្រងដែនដីនគរូបនីយកម្ម ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងទេសចរណ៍។ បទពិសោធន៍បានមក ពីការសាកល្បងក្នុងទីក្រុងបាត់ដំបងបញ្ជាក់ថា បណ្តាក្រសួងដែលពាក់ព័ន្ធមានភាព ទើសទាល់ក្នុងការផ្ទេរមុខងារពេញលេញរបស់ខ្លួនទៅឲ្យថ្នាក់ក្រោមជាតិ ។

ពេលខ្លះក្រសួងផ្ទេរមុខងារណាដែលជាមុខងារបន្ទាប់បន្សំ ឬជាមុខងារផ្សេងៗដែល លើសតម្រូវការទៅឲ្យOWSOថ្នាក់ស្រុក ដូចជាដំណើរការនៃការចេញអាជ្ញាប័ណ្ណទៅឲ្យ ផ្ទះសំណាក់និងភោជនីយដ្ឋានតូចៗដែលមុខងារទាំងនេះមិនមែនជាតម្រូវការសាធារណៈនៅ ក្នុងក្រុង/ស្រុកឡើយ។

មន្ត្រីនិងបុគ្គលិកដែលត្រូវបានជ្រើសរើស និងចាត់ចែងឲ្យចុះទៅធ្វើការក្នុង ការិយាល័យOWSO ជាមន្ត្រីដែលមានជំនាញបច្ចេកទេសមិនសមស្របទៅតាមមុខងារ និមួយៗដែលថ្នាក់លើបានផ្ទេរមកឲ្យ។ ស្របពេលជាមួយគ្នានេះដែរ ក្រសួងពាក់ព័ន្ធនានា មិនផ្តល់ការពង្រឹងសមត្ថភាពគ្រប់គ្រាន់ដល់មន្ត្រីរបស់ខ្លួនដែលបានចាត់ឲ្យមកធ្វើការក្នុង OWSO ឡើយ។ ផ្ទុយទៅវិញ អ្នកដែលមានសមត្ថភាព និងជំនាញពេញលេញនោះមិនចង់ ធ្វើការក្នុង OWSOទេព្រោះថាប្រាក់លើកទឹកចិត្ត និងប្រាក់ខែមានកំរិតទាប។

ការិយាល័យOWSO ត្រូវបានរៀបចំឲ្យមានលក្ខណៈរាក់ទាក់ទទួលភ្ញៀវ ដែលបង្កឲ្យ មានភាពងាយស្រួលដល់ប្រជាពលរដ្ឋ ហើយពួកគាត់ត្រូវបានគេទទួលស្វាគមន៍ដោយ រាក់ទាក់និងគួរសម។ បន្ថែមពីនេះមន្ត្រីត្រូវចាំបាច់យល់ដឹងពីបច្ចេកទេស និងគោលការណ៍ ក្នុងការផ្តល់សេវា។ ការអនុវត្តសាកល្បងបានបង្ហាញថាបញ្ហាសមត្ថភាពទាំងពីរជំនាញ ខាងលើនៅមានការខ្វះខាតនិងជាបញ្ហាប្រឈមនៅឡើយ។

# ជំពូកទី៣

# ទស្សនទានស្តីពីសេវាកម្ម សាធារណៈទីក្រុងដោយផ្តោតលើ បញ្ហាបរិស្ថានទីប្រជុំជន

## -ទស្សនទាននិងការអនុវត្តន៍ល្អនានា-

ដោយលោកបណ្ឌិត Paul Chamniern< Ma. Zenia M. Rodriguez, and Professor Edmund Tayao

# ជំពូកទី៣

# ប្រធានបទទី៥៖ សេវាកម្មសាធារណៈទីក្រុងដោយផ្តោតលើបញ្ហាបរិស្ថានទីប្រជុំជន

មាតិកា


៥-១ ធាតុនៃការអភិវឌ្ឍទីក្រុង

៥-១-១ បញ្ហាបរិស្ថានទីក្រុងនៅអាស៊ីអាគ្នេយ៍

៥-១-២ យុទ្ធសាស្ត្រទាំង១០ សម្រាប់ការគ្រប់គ្រងការអភិវឌ្ឍន៍បរិស្ថានទីក្រុង

៥-១-៣ ប្រព័ន្ធគ្រប់គ្រងនៃបរិស្ថានទីក្រុង

៥-១-៤ អភិក្រមចំរុះឈានទៅដោះស្រាយបញ្ហាបរិស្ថានទីប្រជុំជន

៥-២ ការអភិវឌ្ឍល្អសម្រាប់បរិស្ថានទីក្រុង

៥-២-១ គម្រោងសង្គ្រោះបរិស្ថានម៉ារីគីណា (ទីក្រុងMarikina, ហ្វីលីពីន)

៥-២-២ ក្រុមប្រឹក្សាការសម្របសម្រួលគ្រោះមហន្តរាយទីក្រុងOLONGAPO (ទីក្រុងOlongap, ហ្វីលីពីន)

៥-២-៣ ការគ្រប់គ្រងតំបន់ដីសើមសម្រាប់កែលំអទឹកកខ្វក់របស់ទីក្រុងឧដុងថានី ប្រទេសថៃ

៥-២-៤ ទីក្រុងដែលមានជាតិកាបូនទាប (មួងក្លាងMuangklang ប្រទេលថៃ)

# ៥ ប្រធានបទទី៥ - សមាសធាតុនៃការរៀបចំបរិស្ថានទីប្រជុំជន

## ៥.១ ធាតុនៃការអភិវឌ្ឍទីក្រុង

### ៥.១.១ បញ្ហាបរិស្ថានទីក្រុងនៅអាស៊ីអាគ្នេយ៍

ក្នុងសតវត្សទី២១ គេឃើញមានការរីកចម្រើននៃទីក្រុងទំនើបៗនិងធំៗដោយជាងពាក់កណ្តាលនៃប្រជាជនទូទាំងពិភពលោកបច្ចុប្បន្ននេះកំពុងរស់នៅតំបន់ទីក្រុង។ ទន្ទឹមនឹងសកលភាវូបនីយកម្ម ការកើនឡើងចំនួនប្រជាជន កំណើនសេដ្ឋកិច្ចឆាប់រហ័ស និងការរីកចម្រើនផ្នែកបច្ចេកវិទ្យា បាននឹងកំពុងធ្វើឲ្យមានបញ្ហាបរិស្ថានច្រើនសណ្ឋាន ជាពិសេសភាគច្រើនគឺនៅក្នុងតំបន់នគរូបនីយកម្មក្នុងទ្វីបអាស៊ី។ បញ្ហាទាំងនេះបានជះឥទ្ធិពលដោយផ្ទាល់និងយ៉ាងធ្ងន់ធ្ងរដល់អាយុជីវិតមនុស្ស។ នគរូបនីយកម្មដែលមានលក្ខណៈធំទូលាយនិងឆាប់រហ័សប៉ុន្តែគ្មានលំនឹងផ្នែកអភិវឌ្ឍន៍ដែលនាំឲ្យមានបញ្ហាផ្នែកបរិស្ថានដូចជា ការបំពុលទឹក ខ្យល់ និងសំលេង សំនល់រឹងនិងមានគ្រោះថ្នាក់ ការកកស្ទះចរាចរណ៍ និងការធ្វើឲ្យមានឡើងនូវតំបន់អណាធិបតេយ្យ គឺគ្រាន់តែជាលទ្ធផលរូបសាស្ត្រខ្លះៗប៉ុណ្ណោះ។ បញ្ហាផ្នែកសង្គមនិងវប្បធម៌គឺរឹតតែសំខាន់។

សឹងតែគ្រប់ទីក្រុងក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ បញ្ហាបរិស្ថានក្នុងទីប្រជុំជនបានក្លាយជាមានលក្ខណៈធ្ងន់ធ្ងរនិងហួសឆ្ងាយពីសមត្ថភាពនៃរដ្ឋាភិបាលមូលដ្ឋានភាគច្រើន ក្នុងការដោះស្រាយដោយខ្លួនឯងនិងទាន់ពេលវេលា ហើយអភិបាលកិច្ចល្អតាមមូលដ្ឋានបានក្លាយជាគោលដៅមួយក្នុងចំណោមគោលដៅដែលប្រកបដោយឧបសគ្គសម្រាប់ដៃគូអភិវឌ្ឍន៍ទីក្រុងនិងប្រជាពលរដ្ឋ។

សាលាក្រុងឬរដ្ឋាភិបាលមូលដ្ឋានគឺជាភ្នាក់ងាររដ្ឋបាលមូលដ្ឋានដែលទទួលខុសត្រូវដោយផ្ទាល់នូវការអភិវឌ្ឍ ការផ្តល់និងការថែរក្សានូវអត្ថប្រយោជន៍សាធារណៈ ហេដ្ឋារចនា-សម្ព័ន្ធ និងសេវាមូលដ្ឋានដល់ប្រជាជនប្រកបដោយគុណភាពល្អ ធ្វើឲ្យពួកគេអាចរស់ក្នុង

បរិស្ថានប្រកបដោយផាសុខភាពនិងទីបញ្ចប់សម្រេចបានការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ គ្រប់សាលាក្រុងឬរដ្ឋាភិបាលមូលដ្ឋានគឺជានាដការចម្បងនិងអ្នកសម្របសម្រួលសំខាន់ ជាមួយនិងភ្នាក់ងារផ្សេងៗទៀតក្នុងការដោះស្រាយបញ្ហាបរិស្ថាននិងការអភិវឌ្ឍ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមូលដ្ឋានភាគច្រើនជួបប្រទះភាពមានកំហិតនិងឧបសគ្គមួយចំនួនក្នុងការសម្រេចបាននូវគោលដៅទាំងនេះ ដោយមូលហេតុដូចជា៖

- ភាពខ្វះខាតនូវទសសន្សវិស័យយូរអង្វែងនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ពីអ្នកធ្វើសេចក្តីសម្រេចនៃរដ្ឋបាលមូលដ្ឋានក្នុងការសម្រេចបាននូវគោលដៅទីក្រុងដែលមាននិរន្តភាព
- សមត្ថភាពសម្របសម្រួលនិងប្រសិទ្ធិភាពនៃរដ្ឋបាលមូលដ្ឋានជាមួយនឹងភ្នាក់ងារនិងដៃគូដទៃដែលស្ថិតក្នុងនិងក្រៅដែនសមត្ថកិច្ចខ្លួនគឺនៅមានកំណត់
- អភិក្រមអភិវឌ្ឍន៍តាមបែបភាពជាដៃគូ ជាទូទៅមិនមានការរួមបញ្ចូលគ្នាជាមួយដំណើរការនៃការអភិវឌ្ឍទីក្រុងទេ
- ចំណេះដឹងបច្ចេកទេសនិងសមត្ថភាពដឹកនាំខាងផ្នែករដ្ឋបាលមូលដ្ឋានគឺនៅមានកម្រិត
- ព័ត៌មាននិងទិន្នន័យសំខាន់ពីស្ថានភាពទូទៅនៅថ្នាក់មូលដ្ឋានគឺមិនមានភាពគ្រប់គ្រាន់ក្នុងការគាំទ្រដល់គម្រោងអភិវឌ្ឍន៍ប្រកបដោយស្ថេរភាព
- វិធានការការរៀបចំផែនការនិងការអភិវឌ្ឍន៍ ដូចជាគម្រោងការអភិវឌ្ឍន៍មូលដ្ឋាននិងគម្រោងការការប្រើប្រាស់ដីប្រកបដោយភាពឆ្លាតវៃ គឺមិនមានការទទួលស្គាល់ពេញលេញនិងប្រតិបត្តិដោយមានប្រសិទ្ធិភាព។

ដើម្បីដោះស្រាយភាពមានកំហិតនិងកម្រិតនៃរដ្ឋបាលមូលដ្ឋានភាគច្រើន យុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថានទីក្រុងចំនួន១០ខាងក្រោមនេះត្រូវបានស្នើដូចតទៅ៖

### ៥.១.២ យុទ្ធសាស្ត្រទាំង១០ សម្រាប់ការគ្រប់គ្រងការអភិវឌ្ឍបរិស្ថានទីក្រុង

យុទ្ធសាស្ត្រទាំង១០ខាងក្រោមនេះគឺជាសេចក្តីណែនាំដើម្បីទទួលបាននូវការគ្រប់គ្រងការអភិវឌ្ឍបរិស្ថានទីក្រុងមួយប្រកបដោយប្រសិទ្ធភាព។ យុទ្ធសាស្ត្រដែលបានស្នើទាំងនេះ

មិនគួរអនុវត្តដោយឡែកៗពីគ្នានោះទេ ផ្ទុយទៅវិញសាលាក្រុងគួរគិតគូរនិងរួមបញ្ចូលគោលការណ៍ទាំងនេះទៅក្នុងដំណើរការនៃសកម្មភាពធ្វើផែនការនិងការអភិវឌ្ឍ។

១) ភាពសម្រេចដោយខ្លួនឯង

ការគ្រប់គ្រងការអភិវឌ្ឍបរិស្ថានទីក្រុង គឺជាការទទួលខុសត្រូវចំបងមួយរបស់សាលាក្រុង។ បញ្ហាពីថ្នាក់លើ ឬការគាំទ្រពីរដ្ឋាភិបាលកណ្ដាលគឺមិនគ្រប់គ្រាន់ទេ។ សាលាក្រុងគួរគិតគូរនិងចាប់ផ្ដើមប្រកបដោយភាពច្នៃប្រឌិតដើម្បីដោះស្រាយតម្រូវការនិងបញ្ហា។

២) ឯករាជភាព

ការគ្រប់គ្រងការអភិវឌ្ឍបរិស្ថានទីក្រុង គឺជាការទទួលខុសត្រូវរួមនិងទាមទារឲ្យមានការសហការគ្នាពីសំណាក់បណ្ដារដ្ឋបាលមូលដ្ឋានពាក់ពន្ធ័ទាំងឡាយ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលកណ្ដាលគួរតែជាប្រភពនៃជំនាញការនិងហិរញ្ញវត្ថុមួយចំនួន ប៉ុន្តែមិនមែនជាអ្នកផ្ដល់សេវានោះទេ។

៣) ការអភិវឌ្ឍសមត្ថភាព

បញ្ហាបរិស្ថានបានក្លាយជាមានលក្ខណៈលំបាកឡើង ស្មុគស្មាញឡើង និងធ្ងន់ធ្ងរឡើង។ ហេតុនេះ ដើម្បីឲ្យមានការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព ការលើកកម្ពស់សមត្ថភាពនិងឱកាសបណ្ដុះបណ្ដាលជាលំដាប់សម្រាប់បុគ្គលិកនិងអ្នកសម្រេចចិត្តនៃអាជ្ញាធរក្រុងគួរតែត្រូវបានគាំទ្រនិងពង្រឹងបន្ថែម។

៤) ការប្រមូលទិន្នន័យ

ការផ្គត់ផ្គង់សេវាកម្មក្នុងស្រុកប្រកបដោយប្រសិទ្ធភាព គឺមិនអាចទៅរួចទេប្រសិនបើមិនមានព័ត៌មានចាំបាច់ពីស្ថានភាពបច្ចុប្បន្ននិងមូលហេតុនៃបញ្ហា។ ឯកសារគួរតែត្រូវបានវិភាគនិងកែលម្អទៅតាមព័ត៌មានថ្មីជាបន្តបន្ទាប់។

៥) ភាពជាដៃគូនៃអ្នកពាក់ពន្ធ័

វាគឺជារឿងសមគួរក្នុងការប្រើប្រាស់វិធីសាស្ត្រផ្សេងៗពីគ្នាដើម្បីជំរុញការគាំទ្រនិងការចូលរួមពីសំណាក់ស្ថាប័នក្នុងស្រុកដែលមានស្រាប់ដូចជាវិស័យពាណិជ្ជកម្ម ក្រុមសប្បុរសធម៌ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីជួយនិងគាំទ្រក្នុងការដោះស្រាយបញ្ហា។

៦) ការទំនាក់ទំនង

ដើម្បីដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព សំខាន់បំផុតនោះគឺការផ្សព្វផ្សាយព័ត៌មានដល់អ្នកចូលរួមទាំងអស់។ ប្រព័ន្ធផ្សព្វផ្សាយជាច្រើនត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់និងដោយសេរីដើម្បីជាមធ្យោបាយទំនាក់ទំនងរវាងសាលាក្រុងនិងក្រុមអ្នកពាក់ព័ន្ធនានា។

៧) ផ្តល់សិទ្ធិអំណាចដល់សហាគមន៍មូលដ្ឋាន

វិធានការដ៏ល្អមួយសម្រាប់ការគ្រប់គ្រងបរិស្ថានគឺការបង្កើតឲ្យមានអង្គការសហាគមន៍មូលដ្ឋានមួយដែលរឹងមាំដើម្បីដោះស្រាយបញ្ហាក្នុងស្រុក។ សាលាក្រុងអាចគាំទ្រក្រុមសហាគមន៍ទាំងនេះដោយការអប់រំសហាគមន៍ បណ្តុះបណ្តាលចំណេះដឹង និងផ្តល់ធនធានហិរញ្ញវត្ថុដែលចាំបាច់។

៨) ការសម្របសម្រួល និង សមាហរណ៍កម្ម

ការកៀរគរធនធានបានត្រឹមត្រូវល្អ ការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័ និងការធ្វើឲ្យប្រសើរឡើងនៃសហាគមន៍ សាលាក្រុងដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលភាគីជាប់ពាក់ព័ន្ធមិនត្រឹមតែក្នុងផ្នែកធ្វើផែនការប៉ុណ្ណោះទេ តែក៏ជួយសម្របសម្រួលក្នុងផ្នែកប្រតិបត្តិការផងដែរ។ សេវាបរិស្ថាននិងហេដ្ឋារចនាសម្ព័នភាគច្រើនគឺមានលក្ខណៈឯករាជ្យរីឯការរួមបញ្ចូលគ្នានៃអ្នកផ្គត់ផ្គង់និងផ្តល់សេវាក្នុងតំបន់គឺជាកិច្ចការមួយក្នុងចំណោមកិច្ចការសំខាន់ៗរបស់សាលាក្រុង។

៩) កែសម្រួល និង តាមដាន

សាលាក្រុងត្រូវធ្វើការកំណត់ឲ្យច្បាស់នូវគោលដៅបរិស្ថាន និងធ្វើការយ៉ាងជាប់លាប់តាមដំណើរការនៃការប្រតិបត្តិគម្រោងការគ្រប់គ្រងបរិស្ថាន។ ជារឿយៗការវាយតម្លៃនៃសមិទ្ធផលត្រូវធ្វើឡើងដើម្បីសកម្មភាពអនាគត។

១០) ក្របខ័ណ្ឌច្បាប់ និងការអនុវត្ត

សាលាក្រុងត្រូវតែមានការគាំទ្រផ្នែកវិធានការតាមច្បាប់ឲ្យច្បាស់លាស់ដែលអាចប្រព្រឹត្តិទៅបានសម្រាប់គោលនយោបាយបរិស្ថានក្នុងស្រុក។ វិធានឬលក្ខន្តិកៈសំខាន់ៗ គួរតែអនុម័តដោយក្រុមប្រឹក្សាអាជ្ញាធរក្រុង និងត្រូវដាក់ឲ្យអនុវត្តតាមយ៉ាងតឹងរឹង។

### ៥.១.៣ ប្រព័ន្ធគ្រប់គ្រងនៃបរិស្ថានទីក្រុង

យុទ្ធសាស្រ្តការគ្រប់គ្រងបរិស្ថានទាំង១០គឺជាគោលការណ៍ណែនាំការប្រតិបត្តិដែលត្រូវការការគាំទ្រនិងដឹកនាំដោយប្រព័ន្ធគ្រប់គ្រងដែលល្អមួយ។ ប្រព័ន្ធគ្រប់គ្រងបរិស្ថានទីក្រុងដែលល្អមួយគួរតែមានចរិកលក្ខណៈដូចខាងក្រោម៖

- ជាប្រព័ន្ធមួយដែលអាចយល់និងទទួលស្គាល់ជាទូទៅ
- ជាប្រព័ន្ធមួយដែលឆ្លើយតបយ៉ាងល្អទៅនឹងគោលនយោបាយដែលបានលើកឡើង
- ជាប្រព័ន្ធមួយដែលផ្តោតទៅលើវិធានការការពារជាជាងការព្យាបាល
- ជាប្រព័ន្ធមួយដែលមានភាពបត់បែនទៅតាមស្ថានភាពបច្ចុប្បន្ន។

**ធាតុទាំង៩នៃប្រព័ន្ធគ្រប់គ្រងបរិស្ថានទីក្រុង៖**

| | |
|---|---|
| ១) គោលនយោបាយបរិស្ថានទីក្រុង<br>មគ្គុទេសន៍អាជ្ញាធរក្រុងគួរអភិវឌ្ឍគោលនយោបាយពួកគេដោយមានគោលដៅច្បាស់លាស់ដែលត្រូវបានយល់ព្រមពីក្រុមប្រឹក្សាអាជ្ញាធរក្រុងនិងទទួលយក | ២) រចនាសម្ព័ន្ធអង្គការ បុគ្គលិក និងធនធានហិរញ្ញវត្ថុ<br>សាលាក្រុងត្រូវរៀបចំខ្លួនឲ្យជាមជ្ឈមណ្ឌលដើម្បីសម្របសម្រួលសកម្មភាពគ្រប់បែបយ៉ាងដែលមានបំណងចង់បង្កើតបរិស្ថានទីក្រុងមួយដែល |

| | |
|---|---|
| ដោយបុគ្គលិកអាជ្ញាធរក្រុង។ | មានផាសុខភាពនិងគួរជាទីពេញចិត្ត។ ដើម្បីសម្រេចបំណងនេះ ការអភិវឌ្ឍនិងប្រើប្រាស់បុគ្គលិក ទុននិងហិរញ្ញវត្ថុផ្ទាល់ខ្លួនរបស់សាលាក្រុងជាកត្តាសំខាន់ណាស់។ |
| ៣) គម្រោងសកម្មភាពបរិស្ថាន<br>គម្រោងសកម្មភាពគឺការសំដែងចេញយ៉ាងច្បាស់លាស់នៃគោលនយោបាយដែលបានដាក់ចេញនិងស្របតាមរចនាសម្ព័ន្ធរដ្ឋបាល ថវិកា និងធនធានមនុស្សដែលមាន។ ដំណើរការធ្វើផែនការត្រូវចាប់ផ្តើមពីតម្រូវការនៃសហគមន៍ និងរួមបញ្ចូលសហគមន៍ក្នុងការសម្រេចចិត្ត។ គម្រោងសកម្មភាពរដ្ឋាភិបាលក្នុងស្រុកគួរតែត្រូវរចនាឡើងនិងស្របតាមគម្រោងអភិវឌ្ឍន៍ជាតិនិងខេត្ត។ | ៤) វិធានការតាមច្បាប់<br>ច្បាប់ វិធាន បទបញ្ញត្តិ និងលក្ខន្តិកៈ គឺសុទ្ធតែជាវិធានការសំខាន់ក្នុងការបង្គាប់ការដាក់ឲ្យប្រតិបត្តិគោលនយោបាយដែលបានដាក់ចេញនិងគម្រោងសកម្មភាពដែលបានយល់ស្រប ហើយក៏មានសារៈសំខាន់ក្នុងការធ្វើឲ្យដំណើរការការប្រមូលថ្លៃសេវាកម្ម ស្វែងរកនិងបញ្ឈប់អ្នករំលោភបទបញ្ញត្តិបរិស្ថាន។ |

### ៥.១.៤ អភិក្រមចំរុះឈានទៅដំណោះស្រាយបញ្ហាបរិស្ថានទីប្រជុំជន

ការធ្វើឲ្យទីក្រុងមួយមានលក្ខណៈសមគួរសម្រាប់ការរស់នៅនិងមាននិរន្តរភាពគឺជាគោលដៅចុងក្រោយនៃអ្នករដ្ឋការគ្រប់ទីក្រុងទាំងអស់។ គោលដៅនេះគួរតែស្តែងចេញតាមរយៈកម្មវត្ថុទាំងរយៈពេលវែងនិងខ្លីក្នុងដំណើរការធ្វើផែនការនិងអភិវឌ្ឍន៍នៃសកម្មភាពក្នុងគម្រោងអភិវឌ្ឍន៍។ ទោះជាយ៉ាងណាក៏ដោយ ទីក្រុងដែលសមនឹងរស់នៅនិងមាននិរន្តរភាពគួរបញ្ចូលធាតុសំខាន់៣ គឺសុខមាលភាពរបស់មនុស្ស សន្តិសុខសង្គម និង

មានបរិស្ថានដែលសមនឹងរស់នៅ។ ធាតុទាំងបីនេះគួរត្រូវផ្អែកលើគោលជំហារពីរគឺចំណេះដឹង និងអភិបាលកិច្ចល្អ។

បញ្ហាបរិស្ថានទីក្រុងអាចបែងចែកចេញជាពីរបៀបវារៈ២ គឺរបៀបវារៈពណ៌ត្នោត និង ពណ៌បៃតង។

របៀបវារៈពណ៌ត្នោតមានៈ

១. កាគ្រប់គ្រងការបំពុលទឹក

២. ការបង្ហូរទឹកល្វ

៣. ការគ្រប់គ្រងសំណល់រឹង

៤. ការគ្រប់គ្រងសំណល់គ្រោះថ្នាក់

៥. ការគ្រប់គ្រងការបំពុលខ្យល់

៦. សុខភាពបរិស្ថាន

បញ្ហារបៀបវារៈពណ៌ត្នោតភាគច្រើនគឺត្រូវការឲ្យដោះស្រាយភ្លាមៗឬក៏ក្នុងរយៈពេលខ្លីដោយអនុវត្តបច្ចេកទេសដែលស្គាល់និងដោយវិធីគ្រប់គ្រងសាមញ្ញៗ។ ទោះជាយ៉ាងណារបៀបវារៈទាំងនេះនៅតែជាបញ្ហាសំខាន់សម្រាប់ទីក្រុងភាគច្រើននៃទីក្រុងប្រទេសកំពុងអភិវឌ្ឍ។

របៀបវារៈពណ៌បៃតងមានៈ

១. ការដឹកជញ្ជូននិងចរាចរ

២. ការធ្វើឲ្យទីក្រុងមានពណ៌បៃតង

៣. បរិស្ថានដែលបានកសាង (ដូចជា ហេដ្ឋារចនាសម្ព័ន្ធ និងទេសភាព)

៤. ការកែលម្អសំណង់អនាធិបតេយ្យ

៥. ការរៀបចំផែនការសម្រាប់ការប្រើប្រាស់ដី

៦. ការគ្រប់គ្រងធនធានធម្មជាតិ

៧. ការគ្រប់គ្រងថាមពលនិងបរិស្ថានសិប្បនិមិត្រ

របៀបវារៈពណ៌បៃតងគឺមានលក្ខណៈស្មុគស្មាញនិងទាមទារឲ្យមានការប្តេជ្ញាក្នុងការគិតបែបវែងឆ្ងាយជាមួយនឹងការយល់ស៊ីជម្រៅអំពីបុព្វហេតុនៃបញ្ហាបរិស្ថានក្នុង″ របៀបវារៈពណ៌ត្នោត″ ។ ម៉្យាងវិញទៀត ប្រសិនបើរបៀបវារៈពណ៌បៃតងត្រូវបានគ្រោងនិងប្រតិបត្តិ បញ្ហាពតិត្នោត នឹងកើតឡើងតិចតួច។

បញ្ហាដែលបានលើកឡើងទាំងអស់មានទំនាក់ទំនងគ្នានិងបំពេញគ្នាទៅវិញទៅមក ហេតុនេះ សាលាក្រុងត្រូវដោះស្រាយបញ្ហាតាមលក្ខណៈប្រព័ន្ធនិងស្វែងរកចំណុចទាក់ទងគ្នាពីបញ្ហាមួយទៅបញ្ហាមួយ ទាំងក្នុងរយៈពេលវែងនិងខ្លី។ របៀបវារៈទាំងពណ៌ត្នោតនិងបៃតងមិនគួរត្រូវដោះស្រាយដោយដាច់ពីគ្នានោះទេ។ ភាពជាប់ពាក់ព័ន្ធគ្នាគឺមានរវាងនិងក្នុងចំណោមបញ្ហាទាំងឡាយ ។ ការចាត់ថ្នាក់នៃបញ្ហាទាំងនេះត្រូវបានធ្វើឡើងដោយការគ្រប់គ្រងប្រកបដោយភាពប៉ិនប្រសប់និងមានឯកទេសខ្ពស់។ យ៉ាងណាក៏ដោយ ក្នុងដំណើរការគ្រោងការនិងអភិវឌ្ឍន៍ វាមានសារៈសំខាន់ណាស់សម្រាប់សាលាក្រុងនិងសហគមន៍ក្នុងការគិតគូរយ៉ាងល្អិតល្អន់និងដោយឥតលំអៀង ជាមួយនឹងទស្សនធំទូលាយជាងមុននិងក្នុងផ្លូវរួមមួយ។ បច្ចុប្បន្ននេះ របៀបវារៈការប្រែប្រួលអាកាសធាតុបានគ្រប់ដណ្តប់លើវិសាលភាពនៃសកម្មភាពអភិវឌ្ឍន៍ដែលជាពិសេសពាក់ព័ន្ធនឹងដំណើរការការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការផ្គត់ផ្គង់សេវាកម្មសាធារណៈ ដែលតាមរយៈអ្វីទាំងនេះធ្វើឲ្យការពឹងផ្អែកគ្នាទៅវិញទៅមកក៏ដូចជាផលប៉ះពាល់នៃបញ្ហា″ពណ៌ត្នោត″ និង″ពណ៌បៃតង″ កាន់តែមានសារៈសំខាន់ថែមទៀត។

ការអនុវត្តល្អទាំង៩សម្រាប់បរិស្ថានទីក្រុងដែលត្រូវបានប្រមូលនិងបង្ហាញក្នុងផ្នែកខាងក្រោយគឺគ្រាន់តែជាបទពិសោធន៍ខ្លះៗពីដីកានិងសកម្មភាពផ្សេងៗនៃទីក្រុងមួយចំនួនក្នុងតំបន់ដែលត្រូវបានជ្រើសរើសសម្រាប់ភ្នាក់ងារផ្លាស់ប្តូរដើម្បីចែករំលែកនិងធ្វើការសិក្សា។ គេគួរតែធ្វើការប្រៀបធៀបការអនុវត្តមួយជាមួយការអនុវត្តមួយទៀតដើម្បី

កំណាត់ពីទំនាក់ទំនងនិងឥទ្ធិពល។ ជាមួយគ្នាផងដែរ គេក៏គួរតែញែកបញ្ហាបរិស្ថានចេញពីបញ្ហាដទៃទៀតដូចជាការគ្រប់គ្រងល្អជាដើម។ ទីបំផុត បរិស្ថានទីក្រុងដែលមានផាសុខភាព និងការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធិភាព គួរតែពឹងផ្អែកទៅលើស្ថាប័នអភិបាលកិច្ចមូលដ្ឋានដែលអាចធ្វើបាន ព្រមទាំងដៃគូនិងការចូលរួមពីប្រជាពលរដ្ឋ។

## ៥.២ ការអភិវឌ្ឍល្អសម្រាប់បរិស្ថានទីក្រុង

### ៥.២.១ គម្រោងសង្គ្រោះបរិស្ថានម៉ារីគីណា (ទីក្រុងMarikina, ហ្វីលីពីន)

ទីក្រុងម៉ារីគីណា (Marikina) ផ្តោតទៅលើគម្រោងកែច្នៃជាថ្មីតាមរបៀបបញ្ចូលថ្មីដែលលើកកម្ពស់វប្បធម៌នៃគោលការណ៍ក្នុងចំណោមយុវជនតាមរយៈការគ្រប់គ្រងសំណល់រឹងនៃបរិស្ថានវិទ្យា។

កម្មវិធីនេះរួមបញ្ចូលធាតុសំខាន់ៗដូចខាងក្រោម៖

- ការគ្រប់គ្រងសំណល់នៅនឹងកន្លែង
  កម្មវិធីនេះទាមទារឲ្យសិស្សានុសិស្សនាំយកសំរាមដែលអាចកែច្នៃជាថ្មីបានពីផ្ទះរបស់ពួកគេមកសាលាក្នុងថ្ងៃបរិស្ថាន ជាថ្ងៃដែលសម្រាមនឹងត្រូវថ្លឹងនិងវាយតម្លៃដាក់ចូលក្នុងបញ្ជីសង្គ្រោះបរិស្ថានរបស់ពួកគេ។
- ផ្តល់សិទ្ធិអំណាចដល់សិស្សបឋមសិក្សាក្នុងការគ្រប់គ្រងសំណល់រឹងបរិស្ថាន
  សិស្សបឋមសិក្សានៅសាលារៀនសាធារណៈទីក្រុងម៉ារីគីណា ត្រូវបានផ្តល់ឲ្យនូវឱកាសដើម្បីរួមចំនែកនិងបង្កើតឥទ្ធិពលដែលមានអត្ថន័យទៅដល់យុវជនតំណាលគ្នាក្នុងការប្រតិបត្តិវិធីក្នុងការគ្រប់គ្រងសំណល់រឹងបរិស្ថានដោយទាញយកមកនូវសម្ភារៈដែលអាចធ្វើការកែច្នៃបានពីសំណល់ក្រុមគ្រួសារ។

- ការលើកកម្ពស់នៃប្រយោជន៍សេដ្ឋកិច្ចបានពីរបស់ដែលអាចកែច្នៃជាថ្មីបាន
- សិស្សនឹងទទួលបានពិន្ទុសម្រាប់សម្ភារៈដែលពួកគេបានយកទៅសាលា។
  សម្រាមដែលអាចកែច្នៃឡើងវិញបានត្រូវបានវាយតម្លៃទៅតាមតម្លៃទីផ្សារ ដូចជា PhP1.00 = 1 point ។ ពិន្ទុដែលទទួលបានផ្តល់សិទ្ធិដល់សិស្សក្នុងការជាវនៅក្នុងរថយន្តអ្នកសង្គ្រោះបរិស្ថានដែលមានដឹកជញ្ជូនសម្ភារៈសិក្សាដូចជាវចនានុក្រម

សៀវភៅ សម្ភារៈសាលានិងគ្រឿងក្មេងលេងមានលក្ខណៈអប់រំ និងទំនិញចាំបាច់ដូចជាស្ករ ម៉ៅ្យសូកូឡា និងអង្ករ។

- គម្រោងលើកទឹកចិត្តតាមរយៈបញ្ជីអ្នកសង្គ្រោះបរិស្ថាន
  សៀវភៅបញ្ជីEco-passbookនឹងបោះពុម្ពដល់សិស្សម្នាក់ៗនៅដើមឆ្នាំ។ ពិន្ទុដែលបានពីការនាំយកសំណល់អាចកែច្នៃបានមកសាលារបស់សិស្សនិមួយៗនឹងត្រូវកត់ត្រាក្នុងសៀវភៅបញ្ជីនេះ។ អ្នកសង្គ្រោះបរិស្ថានដែលប្រាថ្នាចង់ជាវទំនិញក្នុងរថយន្តសង្គ្រោះបរិស្ថានគ្រាន់តែត្រូវបង្ហាញសៀវភៅនេះដែលវាផ្តល់សិទ្ធិឲ្យពួកគេផ្លាស់ប្តូរពិន្ទុរបស់ពួកគេជាមួយនឹងទំនិញណាមួយ។

- ការប្រើប្រាស់រថយន្តសង្គ្រោះបរិស្ថាន
- រថយន្តសង្គ្រោះបរិស្ថានឬក៏ហាងចល័តជាបរិក្ខាររដ្ឋាភិបាលទីក្រុងដែលផ្ទុកសម្ភារះអប់រំដូចជាវចនានុក្រម សៀវភៅរឿង សម្ភារៈសិក្សា និង គ្រឿងក្មេងលេងមានលក្ខណៈអប់រំ និងទំនិញចាំបាច់ដូចជាស្ករ ម្សៅ្យសូកូឡា និងអង្ករជាដើម។ ទំនិញទាំងនេះអាចផ្លាស់ប្តូរបានជាមួយនឹងពិន្ទុដែលសន្សំដោយសិស្សពីសំណល់អាចកែច្នៃបានដែលពួកគេយកទៅសាលា។

**កត្តាជោគជ័យ**

- ដោយផ្អែកលើការគ្រប់គ្រងសំណល់នៅនឹងកន្លែង កម្មវីធីសង្គ្រោះបរិស្ថាននេះបាននាំមកនូវវប្បធម៌ទំនួលខុសត្រូវនៃសហគមន៍ និងការយល់ដឹងពីសារៈសំខាន់នៃការសន្សំ។ កម្មវិធីនេះលើកស្ទួយការយល់ដឹងរបស់សហគមន៍ ហេតុដូចនេះលើកកម្ពស់ការបែងចែកសំរាមនិងការអនុវត្តកំណៃច្នៃឡើងវិញនៅតាមគេហដ្ឋាន។ ឪពុកម្តាយរបស់សិស្សានុសិស្សបានចូលរួមជាទៀងទាត់ជាមួយលោកគ្រូអ្នកគ្រូនិងអង្គភាពរដ្ឋាភិបាលក្រុង។ នេះគឺមានសារៈសំខាន់ណាស់ក្នុងការជំនះភាពស្ទាក់ស្ទើរនៃអ្នកត្រូវរួមចំណែកជាពិសេសឪពុកម្តាយ ដើម្បីទៅចូលរួមក្នុងកម្មវិធីនេះពីព្រោះជំនួសឲ្យការចំណាយ កម្មវិធីនេះបានជួយចេញថ្លៃលើសម្ភារៈសិក្សាដែលពួកគេត្រូវបានអនុញ្ញាតឲ្យប្រើពិន្ទុនោះ។ ជាលទ្ធផល កម្មវិធីនេះបង្កើតការជះឥទ្ធិពលផ្នែកសេដ្ឋកិច្ចហើយដោយរបៀបនេះ ហើយដែលការកែច្នៃឡើងវិញគឺមានផលប្រយោជន៍។

- ចាប់តាំងពីកម្មវិធីនេះបានបង្កើតឡើងមក ចំណូលពីសម្ភារៈដែលអាចកែច្នៃបាន បានកើនដល់ P1.3 million. ហើយបានជួយបន្ធូរបន្ថយភាពពឹងផ្អែកនៃទីក្រុងទៅលើការបែងចែកប្រាក់ចំណូលផ្ទៃក្នុង។ លើសពីនេះទៅទៀត ចំណាយរបស់រដ្ឋាភិបាលក្រុងក្នុងការទុកដាក់សំណល់រឹងក៏បានកាត់បន្ថយ។ វាបានផ្តល់ឲ្យហាងវត្ថុសំណល់នូវអតិថិជនជាទៀងទាត់ ដែលនេះកត្តាជំរុញសកម្មភាពសេដ្ឋកិច្ចមួយចំណែកផងដែរ។ ចំពោះទស្សនៈមាតាបិតា អ្នកសង្គ្រោះបរិស្ថានផ្តល់នូវអត្ថប្រយោជន៍មួយថែមទៀតៈ វាជួយចេញជាជំនួយនូវថ្លៃចំណាយទៅលើសម្ភារៈសិក្សាតាមរយៈការសន្សំផ្ទាល់ខ្លួន ឬតាមរយៈពិន្ទុដែលរកបានដោយសិស្ស។
- ការិយាល័យគ្រប់គ្រងសំណល់ប្រកបដោយសមត្ថភាពរបស់រដ្ឋាភិបាលទីក្រុង ដោយប្រតិបត្តិតាមប្រព័ន្ធការគ្រប់គ្រង់សំណល់ប្រកបដោយសមត្ថភាពនិងប្រសិទ្ធភាពដោយមានមូលដ្ឋាននៅសាលា កម្មវិធីនេះបានផ្តល់ភាពបត់បែនធំជាងមុនក្នុងការទទួលយកយុទ្ធសាស្ត្រដើម្បីកាត់បន្ថយនិងកែច្នៃសំណល់។ ដោយកម្មវិធីនេះតម្រូវឲ្យមានប្រតិបត្តិការនិងការងារស្មៀនជាច្រើនសម្រាប់ការប្រមូលឯកសារ វាបានបង្កើតការងារបន្ថែមដល់ការិយាល័យ។ ទោះជាយ៉ាងណាក៏ដោយ ការិយាល័យគ្រប់គ្រងសំណល់ គិតថាវាសមគួរណាស់ក្នុងការប្រតិបត្តិការយុទ្ធសាស្ត្រនៃកម្មវិធីនេះព្រោះវាអនុញ្ញាត្តិឲ្យការិយាល័យសម្រេចបានគោលដៅនៃការបង្វែរសំណល់២៥% ឬក៏លើសពីនេះទៅទៀត។

- កម្មវិធីនេះក៏បានផ្តល់ការបង្ការបន្ថែមទៅលើសុខភាពនិងបរិស្ថានរបស់សហគមន៍។ បរិមាណគួរឲ្យកត់សម្គាល់មួយនៃសំណល់ដែលត្រូវបានបង្វែរចេញពីទីលានចាក់សំរាមបានជួយឲ្យបរិយាកាសនិងដីមានការប្រសើរឡើង។ ដូចគ្នាដែរ ចំនួនដងដែលឡានសំរាមត្រូវយកសំរាមទៅចាក់ចោលត្រូវបានកាត់បន្ថយ បានធ្វើឲ្យការកកស្ទះចរាចរមានការប្រសើរឡើង ការបំពុលខ្យល់មានការថយចុះ ព្រមជាមួយនឹងការរក្សាថាមពលទៀតផង។
- កម្មវិធីនេះបានក្លាយទៅជាវិថីដែលប្រជាជនទទួលបានអារម្មណ៍ពីវត្តមាននៃរដ្ឋាភិបាលក្រុង។ វាក៏បង្ហាញផងដែរនូវឆន្ទៈនយោបាយដ៏រឹងមាំនៃរដ្ឋាភិបាលក្រុងក្នុងការប្រតិបត្តិកម្មវិធីដែលក្លាហាននិងមានគំនិតច្នៃប្រឌិតក្នុងគោលបំណងទទួលបាន

ការយល់ព្រមទាំងស្រុងតាមច្បាប់។ ដោយសារតែកម្មវិធីដែលប្រកបដោយការច្នៃប្រឌិតថ្មីហើយប្លែកក្នុងការបោះជំហានទៅកាន់ភាពយល់ដឹងខាងផ្នែកបរិស្ថាន វាបានក្លាយជាគម្រូប្រៀបធៀបសម្រាប់អង្គភាពរដ្ឋាភិបាលមូលដ្ឋានផ្សេងទៀតក្នុងការអភិវឌ្ឍកម្មវិធីរបស់ពួកគេផ្ទាល់ ជាពិសេសក្នុងកំឡុងទស្សនកិច្ចសិក្សារបស់ពួកគេ។

- ការទំនុកបម្រុងផ្នែកហិរញ្ញវត្ថុពីអ្នកវិភាគទានអន្តរជាតិនិងពីវិស័យឯកជន
- នៅពេលដំបូងនៃកម្មវិធី ភាពជាដៃគូបរិស្ថានUNDP/Africa-Asiaបានឧបត្ថម្ភការផលិតសៀវភៅបញ្ជីសម្រាប់កូនសិស្ស។ វិស័យពាណិជ្ជកម្មក៏បានជួយដល់ការធ្វើឲ្យមាននូវឧបករណ៍គ្រប់គ្រាន់សម្រាប់អូសទាញសម្ភារៈអាចកែច្នៃបានផងដែរ។

**ឧបសគ្គចម្បង និងការលំបាក**

- ភាពជាអ្នកដឹកនាំនៃរដ្ឋាភិបាលក្រុងគួរតែបន្តជាលំដាប់ៗលើការប្រតិបត្តិនិងជៀសវាងការរួញតូចទៅៗនៃផលប្រយោជន៍ដែលអាចមានក្នុងកម្មវិធីនេះដោយសារតែអាកប្បកិរិយាចូលរួមមិនបានយូរអង្វែង។ ប្រសិនបើធ្វើបានបែបនេះ អ្នកចូលរួមដែលបានកំណត់ទុកនៃកម្មវិធីនេះនឹងរក្សាទំនុកចិត្តរបស់គេក្នុងរដ្ឋាភិបាលនិងការពាក់ព័ន្ធដ៏សកម្មថែមទៀត។

- គ្មាននិរន្តភាពពីការចូលរួមរបស់សិស្សវិទ្យាល័យ
- តម្រូវការការងារការិយាល័យដ៏ច្រើន ដូចជា ការកត់ត្រា ការគណនាលេខ ការត្រួតពិនិត្យ ។ល។

**ការចម្លងតាមនៃគំរូម៉ូដែល**

ដោយសារតែភាពសាមញ្ញនិងភាពជោគជ័យជាបន្តបន្ទាប់របស់កម្មវិធីនេះ វាត្រូវបានចម្លងតាមនិងអនុវត្តដោយតំបន់ដទៃ តាមរយៈការបណ្តើមគំនិតដោយឯកជនឬរដ្ឋ។ នេះនឹងជួយនិងជំរុញក្រុមរដ្ឋាភិបាលមូលដ្ឋានដទៃទៀតឲ្យស្វែងរកផ្លូវសម្រាប់សម្រេចគោលដៅការកាត់បន្ថយសំណល់និងការបង្វែរសំណល់ក្នុងរយៈពេលខ្លី។

### ៥.២.២ ក្រុមប្រឹក្សាការសម្របសម្រួលគ្រោះមន្តរាយទីក្រុងOLONGAPO

(ទីក្រុងOlongap, ហ្វីលីពីន)

រដ្ឋបាលមូលដ្ឋានបានផ្តោតទៅលើការបង្កើត ក្រុមប្រឹក្សាការសម្របសម្រួលគ្រោះមហន្តរាយ(CDCC) ទីក្រុងOLONGAPO ដែលមានមុខងារដូចខាងក្រោមៈ

១) ជាក្រុមត្រួតពិនិត្យ សម្របសម្រួលនិងសម្រេចចិត្តលើគោលនយោបាយដែលខ្ពស់បំផុតសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយនៅកម្រិតមូលដ្ឋាន

២) ផ្តល់យោបល់ដល់ចៅហ្វាយក្រុងអំពីការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយក្នុងតំបន់និងគម្រោងការគ្រប់គ្រង

៣) ផ្តល់យោបល់ដល់ចៅហ្វាយក្រុងអំពីការប្រកាសពីស្ថានការនៃគ្រោះមហន្តរាយ (Sate of Calamity) និងបញ្ចេញមូលនិធិសម្រាប់គ្រោះមហន្តរាយ (Calamity Fund) ដើម្បីគាំទ្រដល់សកម្មភាពក្នុងគ្រាអាសន្ននិងបន្ទាន់។

ទីក្រុងអូឡុងហ្គាប៉ូ Olongapo តែងតែមើលឃើញភាពចាំបាច់នៃផ្នែករបស់ខ្លួនដើម្បី "រៀបចំ, ការពារ, ឆ្លើយតប, និងងើបឡើងវិញពីគ្រោះមហន្តរាយ" (DMO) ។ ទាំងនេះនៅទីបំផុតក្លាយជាបេសកកម្មបន្ទាប់ពីការបង្កើតការិយាល័យគ្រប់គ្រងគ្រោះមន្តរាយមួយជាអចិន្ត្រៃយ៍សម្រាប់ពង្រឹងវត្តមានCDCC ។ ការបង្កើតDMO អាចទៅរួចតាមរយៈសេចក្តីសម្រេចដោយក្រុមប្រឹក្សាក្រុង លេខ៥៩, អនុក្រមនៃឆ្នាំ២០០២។

DMOត្រូវបានបង្កើតឡើងជាផ្នែកប្រតិបត្តិការនិងលេខានៃ Olongapo CDCC។ DMO មានការទទួលខុសត្រូវចម្បងក្នុងការសម្របសម្រួលសកម្មភាពនិងមុខងារនៃភ្នាក់ងាររដ្ឋាភិបាលសំខាន់ៗ ស្ថាប័នឯកជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការនៃពលរដ្ឋសម្រាប់ការការពារនិងការថែរក្សានៃជីវិតនិងភាពក្រីក្រក្នុងកំឡុងពេលមានគ្រោះមហន្តរាយនិងអាសន្ន។ វាក៏បំពេញតួនាទីដូចខាងក្រោមដែរៈ

១. សម្របសម្រួលប្រតិបត្តិការCDCCជាមួយនឹងភ្នាក់ងាររដ្ឋាភិបាលក្នុងស្រុក ក្រុមប្រឹក្សាសម្របសម្រួលគ្រោះមហន្តរាយbarangay (BDCCs) និងភ្នាក់ងារទំនុកបម្រុងដទៃទៀត និងអង្គការក្រៅរដ្ឋាភិបាល។

២. បង្កើតនិងសម្របសម្រួលកម្មវិធីសម្រាប់ព័ត៌មាន ការអប់រំនិងការហ្វឹកហាត់សម្រាប់អនុប្រជាក្នុងស្រុក អ្នកធ្វើការស្ម័គ្រចិត្ត ។ល។

៣. បង្កើតផែនការនិងគោលនយោបាយសម្រាប់ការការពារនិងអភិរក្សសុខមាលភាពនៃអនុប្រជាក្នុងស្រុកនៅពេលដែលមានគ្រោះនិងពេលណាផ្សេងដែលមានអាសន្ន។

៤. ប្រតិបត្តិច្បាប់ គម្រោងការនិងកម្មវិធីដែលជាប់ពាក់ព័ន្ធនឹងការទប់ស្កាត់គ្រោះថ្នាក់មហន្តរាយ ការប្រុងប្រៀបជាមុន ការសម្រាលផលប៉ះពាល់ ការឆ្លើយតបនិងការស្តារបនាឡើងវិញ។

៥. ផ្តល់នូវសេវាកម្មដែលប្រកបដោយប្រសិទ្ធភាពនិងគុណភាពល្អព្រមទាំងមានភាពសន្សំសំចៃទៅក្រុមជនរងគ្រោះនិងអ្នកអាចជាជនរងគ្រោះនៃគ្រោះមហន្តរាយទាំងក្នុងនិងក្រៅដែនសមត្ថកិច្ច (AOR).

៦. ត្រួតពិនិត្យនិងគ្រប់គ្រងដំណើរការប្រតិបត្តិការការងារប្រចាំឆ្នាំនៃក្រុមប្រឹក្សាសម្របសម្រួលគ្រោះមហន្តរាយនិងផែនការហិរញ្ញវត្ថុ។

លក្ខណៈបង្កើតថ្មីនៃCDCC/DMOមានដូចជា៖

១. ដំណោះស្រាយប្រកបដោយយុទ្ធសាស្រ្តនិងមានលក្ខណៈល្អិតល្អន់សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយដោយការបន្ធូរ ការរៀបចំទុកជាមុន ការឆ្លើយតបនិងបុននីតិសម្បទាន

២. ក្រុមរុករកនិងសង្គ្រោះអគ្គីភ័យទីក្រុងអូឡុងហ្គាប៉ូ Olongapo ដ៏សកម្ម

៣. សេវាឯកទេសគ្រោះមហន្តរាយ

៤. ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយដែលមានមូលដ្ឋានក្នុងសហគមន៍

<u>កត្តាជោគជ័យ</u>

- *ស្មារតីនៃការស្ម័គ្រចិត្ត*

  ក្នុងចំណោមកត្តាជោគជ័យដែលគួរឲ្យកត់សម្គាល់ជាងគេក្នុងការទទួលបានការទទួលស្គាល់និងជោគជ័យ គឺស្មារតីនៃការស្ម័គ្រចិត្ត តាំងពីថ្នាក់ដឹកនាំទីក្រុងរហូតដល់ប្រជាពលរដ្ឋ។ ក៏ដោយសារតែស្មារតីស្ម័គ្រចិត្តនេះហើយដែលបានសង្គ្រោះទីក្រុងនេះ

ពីការត្រាំត្រែងក្នុងសេចក្តីលំបាកទាំងផ្នែករាងកាយនិងថវិកាដែលបណ្តាលមកពីគ្រោះមហន្តរាយក្នុងទសវត្សរ៍១៩៩០។ CDCC/DMO ត្រូវបានបង្កើតឡើងដើម្បីបម្រើដល់ប្រជាពលរដ្ឋនៃក្រុងអូឡុងហ្គាប៉ូ Olongapo ហើយវាក៏ជាកត្តាគន្លឹះក្នុងការទទួលបានភាពជោគជ័យនៃវត្តមានរបស់វាផងដែរ។ ចលនាការស្ម័គ្រចិត្តមានភាពរីកចម្រើនក្នុងចំណោមប្រជាជនទីក្រុង។ ការប្តេជ្ញាពីប្រជាជនក្នុងការគាំទ្រ CDCC/DMO គឺជាសមិទ្ធិផលមួយទៅហើយ។

- *មគ្គុទេសភាពដែលមានភាពរីកចម្រើន*
  ទីក្រុងអូឡុងហ្គាប៉ូ Olongapo មានលទ្ធភាពអាចបង្កើតប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយដែលមានប្រសិទ្ធភាពស្របជាមួយនឹងផលប្រយោជន៍ជាសាធារណៈនៃសមាសភាពរបស់វា។ CDCC/DMOទទួលបានការគាំទ្រគួរឲ្យកត់សម្គាល់ផ្នែកនយោបាយ ហិរញ្ញវត្ថុនិងរដ្ឋបាលទីក្រុង ជាមួយនឹងអំណះអំណាងពិសេសពីសំណាក់ការិយាល័យលោកអភិបាលក្រុងផងដែរ។ លើសពីនេះទៅទៀត ទោះបីជាទទួលបានការកោតសសើររួចទៅហើយក៏ថ្នាក់ដឹកនាំរដ្ឋាភិបាលក្នុងស្រុកនៅតែជំរុញឲ្យមានការខិតខំប្រឹងប្រែងកែលម្អតទៅទៀតដើម្បីទទួលបានភាពល្អប្រសើរក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ។
- ទំនាក់ទំនងនិងភាពជាដៃគូនៃភ្នាក់ងាររដ្ឋាភិបាលនិងវិស័យឯកជន—CDCC/DMO បានប្រើប្រាស់ទំនាក់ទំនងដ៏ធំទូលាយរបស់ខ្លួនក្នុងរដ្ឋាភិបាលក្នុងស្រុកក៏ដូចជាក្នុងវិស័យឯកជននិងភ្នាក់ងារជាតិដទៃទៀតដើម្បីលើកស្ទួយនិងអនុវត្តកម្មវិធីនិងសកម្មភាពរបស់ខ្លួន។
- វិភាគទាននិងការបរិច្ចាគពីក្រុមឯកជន។ វិភាគទានជាសម្ភារៈដែលបានមកពីក្រុមទាំងនេះមិនអាចមើលរំលងបានទេ។ ប្រសិនបើគ្មានការបរិច្ចាគទាំងនេះទេ CDCC/DMO ទំនងជាមិនអាចដំណើរការល្អនិងរហ័សយ៉ាងនេះទេ។ ក្នុងពេលយូរអង្វែង CDCCមានភាពជឿជាក់ក្នុងការទ្រទ្រង់ប្រតិបត្តិការគ្រប់គ្រងគ្រោះមហន្តរាយដោយសារតែសម្ភារៈនិងបរិក្ខាទំនើបៗរបស់ខ្លួន។

## ឧបសគ្គចម្បងនិងការលំបាក

១. ការអត់ធន

យុទ្ធនាការអប់រំនិងផ្តល់ព័ត៌មាននៃCDCCគឺមានភាពលំបាកក្នុងស្ថានភាពគ្រប់យ៉ាង ហើយក្រុមការងារក៏ធ្វើការងារក្នុងកំហិតដែលប្រជាជនមួយចំនួនពុំព្រមសហការនិងមិនចង់ដឹងចង់លឺពីសេចក្តីសំខាន់នៃការខិតខំប្រឹងប្រែងរបស់CDCC។ ប៉ុន្តែដោយសារតែឧបសគ្គទាំងនេះហើយធ្វើឲ្យCDCCកាន់តែខិតខំប្រឹងប្រែងបន្តគំនិតរបស់ខ្លួនពីព្រោះខ្លួនយល់ថាទង្វើនេះគឺធ្វើឡើងដើម្បីផលប្រយោជន៍ទូទៅនៃប្រជាជនទីក្រុងទាំងមូល។

២. សហាគមន៍ឥតរបៀប

ពីដំបូងទីក្រុងOlongapoបានជួបជាមួយនឹងបញ្ហាក្នុងការរៀបចំសហាគមន៍របស់ខ្លួនឲ្យធ្វើការជាមួយគ្នាដើម្បីគោលដៅរួមមួយគឺឈានទៅរកឧត្តមភាព។ អភិបាលក្រុងនៃOlongapoជាបន្តបន្ទាប់បានខិតខំប្រឹងប្រែងក្នុងការរៀបចំអង្គភាពរដ្ឋាភិបាលក្នុងស្រុកដោយកំណត់តួនាទីនិងបែងចែកទំនួលខុសត្រូវទៅឲ្យសមាជិក--ពីអ្នកបើកបររថយន្តដល់សំអាតថ្នល់។ ទីក្រុងOlongapoបានជំនះរាល់ការលំបាកក្នុងការរៀបចំទីក្រុង។ ជាលទ្ធផលវាមានភាពស្រួលជាងនេះក្នុងការអំពាវនាវឲ្យចូលរួមក្នុងការប្រជុំ។

៣. កំហិតហិរញ្ញវត្ថុ

DMOមិនបានទទួលការអនុញ្ញាត្តិពីDBMក្នុងការតម្លើងខ្លួនទៅជានាយកដ្ឋានឯករាជ្យមួយនៃរដ្ឋាភិបាលក្រុងទេ។ ហេតុនេះ ត្រូវតែរកមធ្យោបាយសម្រាប់ទ្រទ្រង់ដល់ការប្រតិបត្តិការរបស់ខ្លួននិងកម្មវិធីពង្រឹងសមត្ថភាពសម្រាប់បុគ្គលិក។ DMOគឺជាគោលដៅរួមមួយនៃសមាជិកCDCC ទាំងអស់ក្នុងការសម្រេចចិត្តដ៏មាំមួនក្នុងការបង្កើតDMOដែលជួយពួកគេក្នុងការដោះស្រាយបញ្ហានេះ។ ចំណែក៥%នៃមូលនិធិគ្រោះមហន្តរាយក្នុងស្រុកត្រូវប្រើប្រាស់ទៅលើការចំណាយក្នុងDMO។

**៤. ការទទួលបាននៃបរិក្ខារនិងឧបករណ៍**

ក្នុងកំឡុងដំណាក់កាលដំបូងនៃការបង្កើតក្រុមឆ្លើយតបនឹងភាពអាសន្នចម្បងរបស់ DMO ពួកគេមានការលំបាកក្នុងការអនុវត្តសកម្មភាពនានាដែលទាក់ទងទៅនឹងគ្រោះមហន្តរាយដោយមូលហេតុធនធានមានកំណត់។ ប៉ុន្តែដោយសារតែការប្តេជ្ញាចិត្តបន្តនិងកែលម្អកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយទីក្រុង អភិបាលដែលកំពុងកាន់តំណែងបានបន្តបង្កើតសហប្រតិបត្តិការនិងទំនាក់ទំនងជាមួយនឹងភ្នាក់ងារផ្សេងៗដែលទំនងជាអាចបរិច្ចាគធនធានរបស់ពួកគេក្នុងទម្រង់ជាបរិក្ខារនិងឧបករណ៍។

៥. លក្ខណៈភូមិសាស្ត្រនៃដី

ឧបសគ្គធំមួយទៀតគឺលក្ខណៈភូមិសាស្ត្រដីនៃទីក្រុងអូឡុងហ្គាប៉ូ Olongapo។ មានតែ ១២% នៃផ្ទៃដីនេះប៉ុណ្ណោះដែលកកកុញទៅដោយប្រជាជនទីក្រុង។ វាមានការលំបាកជ្រៀតចូលទៅក្នុងតំបន់ភ្នំនិងធ្វើឲ្យវាងាយស្រួលសម្រាប់ការរស់នៅ។ ហេតុនេះហើយនៅពេលដែលមានគ្រោះមហន្តរាយចំកន្លែងដែលណែនតាន់តាប់នៃទីក្រុងអូឡុងហ្គាប៉ូ Olongapo ផលប៉ះពាល់នឹងមានលក្ខណៈធំហើយជះឥទ្ធិពលខ្លាំងទៅលើប្រជាជនជាច្រើន។ ដើម្បីដោះស្រាយបញ្ហានេះអភិបាលក្រុងបច្ចុប្បន្ននេះកំពុងរៀបចំផែនការស្វែងរកកន្លែងតាំងទីលំនៅថ្មី។ ផ្តើមចេញពីនេះ ក៏មានបណ្តាញផ្លូវនឹងត្រូវបានរៀបចំពីទីក្រុងរណបទៅក្នុងជ្រលងភ្នំដែលជាទីអាចបង្កើតសហគមន៍មួយទៀតបាន។ អភិបាលក្រុងបាននិយាយថាការបែងចែកតំបន់ត្រឹមត្រូវគឺជាដំណោះស្រាយគន្លិះមួយសម្រាប់ប្រជាជនដែលរស់នៅតំបន់ដែលងាយរងគ្រោះដោយគ្រោះមហន្តរាយឬដោយការបាក់ស្រុតដីដោយពួកគេនឹងត្រូវបានផ្លាស់ទៅកន្លែងដែលមានសុវត្ថិភាពជាង។

## ការធ្វើតាមនៃគំរូម៉ូដែល

កម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយទីក្រុងអូឡុងហ្គាប៉ូ Olongapo អាចធ្វើតាមបានដោយសារគ្រោះមហន្តរាយមិនមានគាំទ្រទៅលើជាតិ អាយុ ជំនឿសាសនា ឋានៈក្នុងសង្គមឬក៏សម្ព័ន្ធមិត្តនយោបាយណាមួយទេ។ នៅពេលដែលគ្រោះមហន្តរាយកើតឡើង ផលប៉ះពាល់នឹងកើតមានដល់គ្រប់គ្នារស់នៅតំបន់នោះ តំបន់ជិតខាង ហើយនិងតំបន់ដទៃទៀតដែលពឹងផ្អែកលើធនធានសេដ្ឋកិច្ចពីតំបន់នោះ។

ប្រសិនបើមានការប្តេជ្ញាចិត្ត សមាគមន៍រដ្ឋបាលមូលដ្ឋានណាក៏ដោយក៏អាចបង្កើតការិយាល័យការគ្រប់គ្រងគ្រោះមហន្តរាយដែលមានសេវាកម្រិតខ្ពស់ដូចការិយាល័យនេះដែរ។ ក្នុងការធ្វើតាម សមាគមន៍រដ្ឋបាលមូលដ្ឋានគួរតែខិតខំឈានឲ្យដល់គោលដៅរួមនៃការសម្រេចបានការបាត់បង់ជីវិតក្នុងកម្រិតសូន្យក្នុងពេលមានគ្រោះនិងធានាថាអ្នកជាប់ពាក់ព័ន្ធអនុវត្តមុខងាររបស់ខ្លួនក្នុងការរក្សាដំណើរការឲ្យទៅតាមផែនការសកម្មភាពដែលបានគ្រោងពីខាងដើម។ គំរូម៉ូដែលនោះមានសមាសភាពនៃអ្នកពាក់ព័ន្ធដ៏សាមញ្ញ និងការពឹងពាក់គ្នាទៅវិញទៅមកនៃតួនាទីហើយវានឹងជោគជ័យប្រសិនបើមុខងារទាំងអស់ត្រូវបានបំពេញប្រកបដោយការទទួលខុសត្រូវ។

ជាងនេះទៅទៀត ក្រុមកំលាំងឆ្លើយតបនៃការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយដែលអនុវត្តតាមគួរតែសមរម្យនិងមានសមត្ថភាពក្នុងការប្រឈមមុខនឹងឧបសគ្គមួយចំនួនក្នុងពេលគ្រោះមហន្តរាយជិតមកដល់។

ទោះជាយ៉ាងណាក៏ដោយ សមត្ថភាព ឧបករណ៍ និងធនធានដែលមានគឺនៅមានកំណត់បើប្រៀបធៀបទៅនឹងស្ថានភាពគ្រោះថ្នាក់នៃគ្រោះមហន្តរាយជាទូទៅនៃប្រទេសហ្វីលីពីន។ ជាឧទាហរណ៍ លោកអភិបាលក្រុង ជដានGordonបានលើកឡើងពី "ប្រតិបត្តិការជំនួយតាមបែបហ្វីលីពីន" មួយក្នុងការឆ្លើយតបទៅនឹងការវាយប្រហារដោយគ្រោះមហន្តរាយទៅលើខេត្តមួយចំនួនជាមួយនឹងជំនួយដែលមានក្នុងដៃស្រាប់។ ប្រតិបត្តិការCDCCអាចយកធ្វើជាគំរូល្អមួយបានប៉ុន្តែវាខ្វះឧទាហរណ៍ជាក់លាក់ដែលថាយុទ្ធសាស្ត្រទាំងនេះអាចសក្តិសមទៅនឹងអង្គភាពរដ្ឋាភិបាលឬក្រុងដទៃទៀតជាពិសេសនៅក្រៅប្រទេស។ ការលំបាកនៃការចម្លងតាមកម្មវិធីរបស់ទីក្រុង Olongapo CDCC គឺស្ថិតលើការបង្កើតឲ្យមានផែនការឆ្លើយតបនឹងភាពអាសន្ននិងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយដែលមានគោលបំណងដោះស្រាយតម្រូវការនៃបណ្តាសមាគមន៍រដ្ឋបាលមូលដ្ឋាននានា។

### ៥.២.៣ ការគ្រប់គ្រងតំបន់ដីសើមសម្រាប់កែលំអរទឹកកខ្វក់របស់ទីក្រុងឧដុងថានី ប្រទេសថៃ

#### សេចក្តីសង្ខេប

ឆ្លើយតបទៅនឹងការកើនឡើងចំនួនប្រជាជននិង នគរូបនីយកម្មភាពយ៉ាងឆាប់រហ័ស នាំឲ្យមានការកើនឡើងនៃទឹកសំអុយនិងការបំពុល សាលាក្រុងឧដុងថានីUdonthani បានផ្តួចផ្តើមគំនិតធ្វើប្រព័ន្ធប្រព្រឹត្តិកម្មទឹកសំអុយដោយប្រែក្លាយផ្លូវទឹកដែលមានស្រាប់ គឺពីលូទឹកសំអុយទៅជាប្រព័ន្ធប្រព្រឹត្តិកម្មធម្មជាតិ (ដីភក់សិប្បនិមត្តិ constructed wetland) ។ គំរូម៉ូដែលនៃការអនុវត្តល្អនេះត្រូវបានធ្វើឡើងជាប្រព័ន្ធបំពេញបន្ថែមទៅនឹងប្រព្រឹត្តិកម្មទឹកសំអុយរបស់ក្រុង។ ឧដុងថានីUdonthani មានបន្ទុកខាងផ្នែកទឹកសំអុយពី៤៧,៨២៨គ្រួសារ ផ្សារចំនួន១១ និងរោងចក្រឧស្សាហកម្មចំនួន៤០០ដែលបញ្ចេញសំនល់គិតសរុបគឺ៥០,០០០ម៉ែតគីបក្នុងមួយថ្ងៃ។ ឧដុងថានីUdonthani មានលទ្ធភាពអាចកាត់បន្ថយសមាសធាតុសរីរាង្គ អាសូតហ្វូសហ្វ័រ លោហៈធាតុ និងមេរោគពីក្នុងទឹក ស្របពេលជាមួយគ្នាដែរបង្កើតជាទីផ្លាលំហែកម្សាន្តសម្រាប់ប្រជាជននៅតាមដងទន្លេ។

ផលប្រយោជន៍នៃគម្រូការអនុវត្តល្អគឺអាចពន្យល់បានដោយខ្លួនឯង៖

- វាងាយស្រួលក្នុងការតំឡើងនិងអាចប្រែប្រួលទៅតាមស្ថានភាពបរិស្ថាននិងគោលបំណង។
- វាមានភាពសន្សំសំចៃដោយសារតែសមត្ថភាពធម្មជាតិរបស់វាក្នុងការសំអាតទឹកបានមានប្រសិទ្ធិភាព តៃមានតម្លៃល្មម តម្លៃថៃទាំទាប និងភាពពឹងផ្អែកផ្នែកបច្ចេកវិទ្យាក៏ទាប។
- វាមានស្ថេរភាពដោយការប្រើប្រាស់ធនធានធម្មជាតិដើម្បីសំអាតទឹកលូទីក្រុងនិងកាត់បន្ថយការបំពុល។
- ការប្រែក្លាយទៅជាដីភក់សិប្បនិមិត្ត ទីធ្លាសាធារណៈមួយជាមួយនឹងទេសភាពគួរឲ្យរីករាយ (សួនច្បារ ទីធ្លាបៃតង) និង ទីធ្លាកម្សាន្តសម្រាប់ប្រជាជនត្រូវបានបង្កើត។

រោងចក្រប្រព្រឹត្តិកម្មទឹកក្នុងព្រែក Huay Mak Khaeng គឺជាការខិតខំប្រឹងប្រែងរួមមួយរវាងសាលាក្រុងឧដុងថានីUdonthani មហាវិទ្យាល័យវិស្វករ និងមហាវិទ្យាល័យស្ថាបត្យកម្មនៃសកលវិទ្យាល័យកនកែនKhon Kaen ដែលត្រូវបានដាក់ឲ្យធ្វើកិច្ចការស្ទង់មតិមហាជនសិក្សាស្រាវជ្រាវ និងរៀបចំគម្រោងសាងសង់ ក្រោមការត្រួតពិនិត្យ/សម្របសម្រួលនៃអង្គភាពកិច្ចការអនាម័យនៃទីក្រុង។ កិច្ចការនេះក៏ជាការរួមចំនែកជាមួយការិយាល័យសុខមាលភាពសង្គមដែលបានសម្របសម្រួលការខិតខំប្រឹងប្រែងរបស់ខ្លួនជាមួយនឹងសហគមន៍ក្នុងស្រុក និងការិយាល័យសុខភាពសាធារណៈនិងបរិស្ថាន ដែលជាអ្នកត្រួតពិនិត្យសុខភាពនិងគុណភាពបរិស្ថានក្នុងទីប្រជុំជន។

## ប្រវត្តិនិងវត្ថុបំណង

សាលាក្រុងឧដុងថានីUdonthani ស្ថិតក្នុងខេត្តឧដុងថានីUdonthani ដែលត្រូវបានគេចាត់ទុកថាជាចំណុចកណ្តាលនៃប្រទេសថៃភាគខាងឥសាន(ខាងជើងឈានខាងកើត)។ យោងតាមទិន្នន័យស្ថិតិក្នុងឆ្នាំ២០១០ខែមករា ឧដុងថានីUdonthani មានអ្នករស់នៅ ១៩១,៦៥៣នាក់ក្នុងសហគមន៍ចំនួន១០០។ ប្រព័ន្ធគមនាគមន៍រួមមានអាកាស ផ្លូវដែកនិងមហាវិថីនានាជាដើម។ ក្រុងនេះមានព្រែកពីរះ គឺព្រែកហួម៉ាកខែងHuay Mak Khaeng និងហួម៉ុងHuay Mung ។ ព្រែកទាំងពីរនេះបម្រើជាច្រកបង្ហូរទឹកចេញតាមបែបធម្មជាតិ។ មានអាងទឹកពីរសម្រាប់ផលិតទឹកដែលអាចប្រើប្រាស់បានះ នងប្រាចាក់សុប៉ាខនNong Prajak Silpakom និង នងសីមNong Sim ។

ជាមួយនឹងប្រាក់ចំណូលចំនួនមួយពាន់លានបាតក្នុងមួយឆ្នាំ ឧដុងថានីUdonthani គឺជាក្រុងជាប់លំដាប់ទី៣ខាងផ្នែកកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេក្នុងប្រទេសថៃភាគឥសាន(ខាងជើងឈៀងខាងកើត)។ យោងតាមគណៈកម្មការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចជាតិ ឧដុងថានីមានសក្តានុពលក្លាយជាអ្នកផ្តល់សេវាដ៏សំខាន់មួយនៃអនុតំបន់មេគង្គ(GMS)។ វាអាចបម្រើជាមជ្ឈមណ្ឌលពាណិជ្ជកម្មនិងហិរញ្ញវត្ថុតភ្ជាប់ជាមួយប្រទេសឡាវ ចិន និងវៀតណាម។ វាក៏អាចក្លាយជាបណ្តាញអាកាសយាចរណ៍មានលក្ខណៈនាំចេញតភ្ជាប់ទៅតំបន់ឥណ្ឌូចិនផងដែរ។

ភាពជោគជ័យនៃការតម្លើងប្រព័ន្ធប្រព្រឹត្តិកម្មទឹកសំអុយជាមួយនឹងអនុផលរបស់វាដែលបាននាំឲ្យមានការស្តាបនាឡើងវិញនៃផ្លូវទឹកទីក្រុងបានធ្វើឲ្យឧដុងថានីUdonthani ក្លាយជាទីក្រុងគម្រូមួយក្នុងចំណោមទីក្រុងដែលមាននិរន្តរភាពខាងអភិវឌ្ឍន៍ក្នុងប្រទេសនិងក្នុងតំបន់។

ក- ធាតុការបង្កើតថ្មី

ដីភក់សិប្បនិមិត្រដែលចម្លងតាមប្រព័ន្ធបរិស្ថានវិទ្យាអាចប្រើប្រាស់ដាច់តែឯងក៏បានឬក៏ប្រើប្រាស់ជាមួយប្រព័ន្ធដទៃទៀតដើម្បីកែលម្អគុណភាពទឹក។ ដីភក់សិប្បនិមិត្រគឺជាប្រព័ន្ធបន្ថែមធៀបនឹងប្រព័ន្ធប្រព្រឹត្តិកម្មទឹកសំអុយរបស់ក្រុងក្នុងការដោះស្រាយជាមួយនឹងបន្ទុកដែលប្រែប្រួល គុណភាពដែលការហូរចូលនៃទឹកសំអុយ និងការផ្លាស់ប្តូរជាមួយធាតុអាកាស។

- ក្រុងស្វ័យតមួយនេះបាននាំចូលមកនូវបច្ចេកទេសប្រព្រឹត្តិកម្មដែលសក្តិសមនិងមានលក្ខណៈថ្មីក្នុងការកាត់បន្ថយថ្លៃដោយស្រះបីប្រភេទ៖
- ស្រះទឹករាក់(ស្រះចំនួនមួយ) គឺត្រូវដាំនូវស្មៅទឹក ដើម្បីកាត់បន្ថយល្បឿនទឹកហូរនិងកម្ចាត់ចោលនូវរូបធាតុសរីរាង្គក្នុងទឹក។ សមាសធាតុប្រូតេអ៊ីនត្រូវបានប្រែក្លាយទៅជាអាម៉ូញ៉ាក់។
- ស្រះទឹកជ្រៅត្រូវបានដាំជាមួយនឹងឈូកនិងរុក្ខជាតិក្រោមទឹកដើម្បីប្រែក្លាយអាម៉ូញ៉ាក់ ក្នុងស្រះទឹករាក់ទៅជានីត្រាត (ក្នុងប្រតិកម្មមួយដែលគេហៅថានីត្រាតកម្ម)
- ស្រះទឹករាក់(ស្រះចំនួនពីរ) ត្រូវបានដាំជាមួយនឹងស្មៅ ដើម្បីប្រែក្លាយនីត្រាតទៅជាអាសូត (ប្រតិកម្មបំបែកនីត្រាតកម្ម) និងបំបែកចូលទៅក្នុងខ្យល់។ ការបញ្ចេញក្នុងវគ្គនេះគឺត្រូវបានប្រើប្រាស់ក្នុងគោលដៅនេសាទ។

ថ្លៃចំណាយទៅលើការប្រតិបត្តិគឺមានចំនួនទាបគួរសម ចំណែកឯផលប្រយោជន៍វិញគឺគួរឲ្យពេញចិត្ត៖

- ការយកតំបន់ដីភក់សិប្បនិមិត្រធ្វើជាប្រព័ន្ធប្រព្រឹត្តិកម្មទឹកសំអុយគឺជាការផ្តួចផ្តើមមួយដែលប្រើប្រាស់រុក្ខជាតិធម្មជាតិដែលមានគុណភាពដើម្បីកែលម្អគុណភាពទឹកសំអុយ។ ប្រតិបត្តិការរបស់វាគឺពឹងផ្អែកទៅលើសក្តានុពលនៃប្រព័ន្ធអេកូឡូស៊ីក្នុងទឹកជាមួយនឹងសមត្ថភាពផ្ទុកដែលអាស្រ័យទៅតាមបរិមាណបន្ទុក។ វាចំណាយអស់តិចប៉ុន្តែមានប្រសិទ្ធភាព។

- ប្រជាជនអាចរីករាយជាមួយទីធ្លាមានពណ៌បៃតងដែលមានច្រើនជាងមុននិងសួនដែលធំជាងមុន។ ដោយដាក់ដាំដើមរុក្ខជាតិក្នុងទឹកនៅតាមដងព្រែកទាំងសងខាងនិងនៅក្នុងទឹកធ្វើឲ្យមានទីធ្លាសួនច្រើនជាងមុន។ ប្រជាជនអាចប្រើប្រាស់ទីធ្លាដែលអភិវឌ្ឍនេះសម្រាប់សកម្មភាពសម្រាកកម្សាន្ត។

- ដីភក់សិប្បនិមិត្រគឺជាប្រព័ន្ធបន្ថែមមួយទៅលើប្រព្រឹត្តិកម្មទឹកសំអុយរបស់ក្រុងដើម្បីធ្វើឲ្យប្រព្រឹត្តិកម្មនៃក្រុងមានប្រសិទ្ធភាពជាងមុន។ បន្ទុកគឺបានមកពីក្រុមគ្រួសារចំនួន៤៧,៨២៨ ទីផ្សារចំនួន១១ និងរោងចក្រឧស្សាហកម្មចំនួន៤០០ដែលបញ្ចេញសំណល់ជាសរុប៥០,០០០ម៉ែត្រគូបក្នុងមួយថ្ងៃ។ ដីភក់សិប្បនិមិត្រអាចជួយកាត់បន្ថយសមាសធាតុសរីរាង្គ អាសូត ផូសស្វ័រ ធាតុលោហ:និងមេរោគ។

### ខ. ការចូលរួមនិងសកម្មភាព

អ្នកតាំងទីលំនៅតាមដងព្រែកទាំងសងខាងបានចូលរួមក្នុងការប្រកាសជាសាធារណៈដែលធ្វើឡើងនៅមុនពេលការការចាប់កំណើតនៃគម្រោងការនេះ។ បច្ចុប្បន្ននេះ ពួកគេគឺជាអ្នកជួយថែរក្សានិងទទួលផលប្រយោជន៍នៃតំបន់ជិតខាងនៃព្រែកទាំងនេះសម្រាប់គោលបំណងលំហែកម្សាន្ត។ អ្នកតាំងទីលំនៅផ្សេងទៀតនៃឧដុងថានីUdonthani ជួយដោយមិនបោះ ចាក់ ឬបញ្ចេញសម្រាមឬក៏ទឹកសំអុយចូលទៅក្នុងព្រែក។ ពួកគេក៏ទទួលផលប្រយោជន៍ពីសួនថ្មីដែលជាទីកន្លែងសម្រាប់សកម្មភាពកម្សាន្តដូចជារត់កីឡានិងជិះកង់ជាដើម។ ពួកគេក៏មកកាន់សួនទាំងនេះម្តងម្កាលសម្រាប់សកម្មភាពសង្គមវប្បធម៌ ដូចជាបុណ្យLoy Kratong ឬការសម្តែងសិល្បៈនិងចំរៀង។ ផលប្រយោជន៍ដែលមានលើសពីអ្វីដែលគ្រោងទុកដំបូងគឺសម្បូរបែបណាស់។

**ប្រតិបត្តិការជាក់ស្តែងនៃគម្រូនេះមានដូចខាងក្រោម៖**

- មុនពេលបញ្ចេញចោលទឹកពីតំបន់ទីក្រុងចូលក្នុងព្រែក វាបានរងប្រព្រឹត្តកម្មមួយចំនួនដោយដីភក់សិប្បនិមិត្រ តាមរយៈការប្រើប្រាស់រុក្ខជាតិក្នុងទឹកដូចជាស្មៅទឹក។ សមាសភាពបុរេប្រព្រឹត្តិកម្មនេះក៏បម្រើដល់ការគោលបំណងលម្អផងដែរ។ កំលាំងទាញនៃទឹកធ្លាក់ត្រូវបានដាក់បន្ថែមដើម្បីបញ្ចូលអុកស៊ីសែនទៅក្នុងទឹកនិងធ្វើឲ្យទេសភាពស្រស់ស្អាត។
- សមត្ថភាពនៃប្រព័ន្ធធម្មជាតិសម្រាប់ប្រព្រឹត្តកម្មទឹកគឺមានកំណត់។ ដើម្បីដោះស្រាយបញ្ហានេះ លំហូរព្រែកនិងសួនជលជាតិត្រូវបានបែងចែក។ វាក៏បានរៀបចំដើម្បីការពារទឹកជន់នៅក្នុងរដូវភ្លៀងផងដែរ។

**គ. និរន្តរភាពនិងការចម្លងតាម**

តំបន់ដីភក់ដែលត្រូវបានស្ថាបនាឡើងនេះចម្លងតាមប្រព័ន្ធធម្មជាតិដោយប្រើប្រាស់រុក្ខជាតិជលជាតិក្នុងស្រុកដើម្បីស្រូបយកសារធាតុគីមី ស្របពេលជាមួយគ្នាគ្រោងការណ៍ជលវិទ្យាមួយដែលរៀបចំបានយ៉ាងល្អធានាបាននូវចរន្តទឹក។ រុក្ខជាតិជលជាតិច្រើនប្រភេទមិនត្រឹមតែជួយស្រូបយកសារធាតុលោហៈធ្ងន់និងសមាសធាតុសរីរាង្គប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគាំទ្រដល់ប្រព័ន្ធធំជាងនេះឲ្យមាននិរន្តរភាពនិងមានភាពឆាប់ត្រឡប់មកសភាពដើម។

មិនត្រឹមតែជាប្រព័ន្ធប្រព្រឹត្តកម្មទឹកប៉ុណ្ណោះទេ ព្រែកនិងផ្លូវទឹកទាំងនោះជួយបង្កើនតំបន់ពណ៌បៃតងនិងលម្អទេសភាពទីក្រុងទៀតផង។ ពួកគេអាចត្រូវបានប្រើជាទីកន្លែងលំហែកម្សាន្តនិងកន្លែងលំហាត់ប្រាណសម្រាប់ប្រជាជនទីក្រុង។

ប្រព័ន្ធនេះទាមទារឲ្យមានចំណាយថែរក្សាតិចតួចព្រោះមិនមានឧបករណ៍ស្មុគស្មាញអ្វីត្រូវប្រើ។ មិនមានការតម្រូវណាមួយសម្រាប់ការជួយឬក៏ជួសជុល។ អ្វីដែលតម្រូវឲ្យមានគឺមានតែការរក្សាបរិមាណប្រសើរបំផុតនិងភាពផ្សេងៗគ្នានៃរុក្ខជាតិនិងការពារការជាប់គាំងខាងក្នុង។ គម្រូនេះគឺមានលក្ខណៈនិរន្តរភាពនិងអាចត្រូវបានអនុវត្តតាមក្នុងកម្រិតធំក្នុងពេលអនាគត។

ការចម្លងតាមនៃប្រព័ន្ធនេះនៅទីក្រុងផ្សេងៗគឺមិនមែនជាកិច្ចការអ្វីធំដុំនោះទេប្រសិនបើក្រុមគ្រប់គ្រងនៅទីក្រុងអាចកំណត់បាននូវកន្លែងដែលមានការបំពុលទឹកនិងកន្លែងដែលមានសក្តានុពលក្នុងការស្ថាបនាប្រព័ន្ធប្រព្រឹត្តិកម្មដីភក់សម្រាប់ធ្វើប្រតិបត្តិការ។ មានការ

ទាមទារឲ្យមានការពិគ្រោះយោបល់និងការចូលរួមពីសហគមន៍មុនពេល កំឡុងពេលនិងក្រោយពេលសំណង់ ទោះបីជាការវិនិយោគនិងការថែរក្សាប្រព័ន្ធនេះមិនថ្លៃក៏ដោយ។

### ៥.២.៤ ទីក្រុងដែលមានជាតិកាបូនទាប (មួងក្លាងMuangklang ប្រទេសថៃ)

សេចក្តីសង្ខេប

ជាមួយនឹងថវិកាត្រឹមតែ១០០០អឺរ៉ូ អភិបាលក្រុងមួងក្លាង Muangklang បានផ្តើមធ្វើកម្មវិធីគ្រប់គ្រងសំណល់រឹងមួយដែលនាំមកនូវការកើនឡើងគួរឲ្យកត់សម្គាល់នៃល័ក្ខខ័ណ្ឌក្នុងការរស់នៅនៃប្រជាជនក្នុងស្រុកនិងបានប្រែក្លាយទីក្រុងនេះទៅជាទីក្រុងដែលមានបរិស្ថានដែលគួរឲ្យចង់រស់នៅ។

របៀបបញ្ចូលថ្មីដូចខាងក្រោមត្រូវបានអនុវត្តៈ

- ការគ្រប់គ្រងសំណល់រឹងមួយត្រូវបានបង្កើតឡើង។ ជំនួសឲ្យការសាងសង់អាគារមួយដែលពេញលេញជាមួយនឹងឡដុតសម្រាមដ៏ស្មុគស្មាញ ដែលមានខ្សែពានបញ្ជូនសម្រាមនៅទីវាលខាងក្រៅដ៏សាមញ្ញមួយត្រូវបានយកមកប្រើប្រាស់។ សំណល់សរីរាង្គដែលអាចបែងចែកបានត្រូវបានយកមកផលិតកំប៉ុស្ត។ តាមរយៈវិធីនេះបរិមាណជាច្រើននៃសម្រាមដែលត្រូវបោះចោលប្រចាំថ្ងៃត្រូវបានកាត់បន្ថយ។
- លំនាំចូលនៃយានឧស្ម័នធម្មជាតិ (NGV)។ រថយន្តក្រុងដែលមានរូបរាងស្រដៀងនឹងរថអគ្គីសនីបានជំរុញប្រជាជនឲ្យប្រើប្រាស់គមនាគមន៍សាធារណៈក្នុងក្រុងជាជាងការប្រើប្រាស់រថយន្តផ្ទាល់ខ្លួន។ វិធីនេះជាទូទៅអាចជួយកាត់បន្ថយនូវការបញ្ចេញផ្សែង ពុលបានយ៉ាងមានប្រសិទ្ធភាព។
- ការកែលម្អគុណភាពទឹក
    - ក្នុងទីផ្សារក្រុង បន្លែនិងផ្លែឈើដែលត្រូវបានបោះចោលត្រូវបានប្រមូលដើម្បីផលិត E.M. (សរីរាង្គមីក្រូដែលមានប្រសិទ្ធភាព)ខាប់។ ក្រោយមកសារធាតុរាវខាប់នេះត្រូវបានគេយកមកកែលម្អគុណភាពទឹកនៃទឹកទន្លេដោយដាក់បញ្ចូលវាចូលទៅក្នុងលូទឹកស្អុយនៅកន្លែងផ្សេងៗគ្នា។ សល់

ពីនេះវាអាចយកទៅធ្វើជាចំណីសត្វនៅក្នុងកសិដ្ឋាន។ អាចម៍របស់ពួកវានឹងត្រូវប្រមូលនិងដាក់លក់។

- សាលាក្រុងក៏បានណែនាំឲ្យតម្លើងតម្រងប្រេងនិងខ្លាញ់ នៅតាមផ្ទះនិងហាងដែលស្ថិតតាមដងទន្លេនិងនៅក្នុងទីក្រុង។ តម្រងប្រេងនិងខ្លាញ់ នឹងកាត់បន្ថយបន្ទុកសារធាតុសរីរាង្គក្នុងទឹកទន្លេ ដូចនេះនាំឲ្យមានការកែលំអគុណភាពទឹកជាទូទៅនៃទឹកទន្លេ។ សារធាតុខ្លាញ់ដែលបានប្រមូលត្រូវបានប្រែក្លាយទៅជាដុំឥន្ធនៈ ដែលប្រើជាជំនួយក្នុងទីសត្តឃាត និងកាត់បន្ថយការប្រើប្រាស់អុស។

សកម្មភាពទាំងនេះច្រើនតែត្រូវបានឧបត្ថម្ភដោយថវិកាប្រចាំឆ្នាំដោយរដ្ឋាភិបាលមូលដ្ឋាន និងវិភាគទានមួយចំនួន (ហិរញ្ញវត្ថុនិងសម្ភារះ) ពីក្រុមហ៊ុនឯកជនដូចជាក្រុមហ៊ុននិងតំបន់ជិតខាងដូចជាខេត្តរ៉ាក់យ៉ង ដែលបានគាំទ្រការតម្លើងតម្រងប្រេងនិងខ្លាញ់ ក្នុងផ្ទះសម្រាប់សាលាក្រុងមួងក្លាង Muangklang។

## ប្រវត្តិនិងវត្ថុបំណង

ស្ថិតនៅចំងាយ២៦៩គីឡូម៉ែត្រពីទីផ្លូវហាយវេភាគខាងលិចនៃទីក្រុងបាងកក សាលាក្រុងមួងក្លាង Muangklang មានប្រជាជនចំនួន១៧,១៩៧ឬ ក្រុមគ្រួសារចំនួន៣,៣០៩។ ជាសរុបវាមានសហគមន៍ចំនួន១៣ និងគ្របដណ្តប់ទៅលើផ្ទៃដី១៤.៥គីឡូម៉ែត្រការ៉េ។ គោលបំណងនៃអភិបាលសាលាក្រុងគឺអភិវឌ្ឍក្រុងមួយដែលមានលក្ខណៈនិរន្តរភាពផ្នែកបរិស្ថាន ភាពអាចរស់នៅបានរួមទាំងផ្នែកសេដ្ឋកិច្ច និងភាពចូលរួមពីសង្គម។ វិធីរបស់អភិបាលក្រុងគឺការប្រើប្រាស់ធនធាននិងសក្តានុពលដែលមានស្រាប់ និងការកាត់បន្ថយការយឺតយាវផ្នែកការងារការិយាល័យតាមដែលអាចធ្វើទៅបាន។ តាមការពិត លោកអភិបាលក្រុងចង់កែប្រែមធ្យោបាយប្រើប្រាស់របស់ប្រជាជនដើម្បីឲ្យពួកគេមានផលិតភាពខ្ពស់និងអាចបំពេញតម្រូវការខ្លួនឯងបាន។

អ្នករស់នៅក្នុង មួងក្លាង Muangklangបានទទួលផលប្រយោជន៍ពីការកែប្រែគុណភាពនៃទន្លេ គមនាគមន៍សាធារណៈ និងភាពសម្បូរបែបនៃបន្លែសរីរាង្គក្នុងស្រុក ជី និងជីកំប៉ុសព្រមជាមួយនឹងការកើនឡើងនៃតំបន់មានពណ៌បៃតងក្នុងក្រុង។ អាជ្ញាធរក្នុងស្រុកជាច្រើនក្នុង

ប្រទេសថៃបានធ្វើទស្សនកិច្ចទៅសាលាក្រុងម្វងក្លាង Muangklang ដើម្បីសិក្សាថាតើការអនុវត្តល្អត្រូវបានប្រតិបត្តិការយ៉ាងដូចម្តេច។

ឃ. ធាតុការបង្កើតថ្មី

ក្រុងម្វងក្លាង បានបង្កើតគម្រោងការគ្រប់គ្រងសំណល់រឹងមួយដែលមានទឹកប្រាក់ចំនួនតែ១០០០អ៊ីរ៉ូប៉ុណ្ណោះ។ មានការបង្កើតថ្មីមួយចំនួនក្នុងការធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងសំណល់រឹងដូចខាងក្រោមៈ

១. ការគ្រប់គ្រងសំណល់រឹង។ ជំនួសឲ្យការសាងសង់អាគារទាំងមូលដែលផ្ទុកដោយឡដុតសម្រាមដ៏ស្មុគស្មាញ ជាការប្រើដោយខ្សែពានបញ្ជូនសម្រាមនៅទីវាលខាងក្រៅដ៏សាមញ្ញមួយ។ សំណល់ដែលប្រមូលបានជាប្រចាំថ្ងៃត្រូវបានដាក់ទៅលើ ខ្សែពានបញ្ជូនសម្រាមនៅទីវាលខាងក្រៅ ដែលនៅទីនេះកម្មករនឹងរើសវត្ថុដែលអាចកែច្នៃបាន។ សំណល់សរីរាង្គដែលអាចបំបែកបានក៏ត្រូវបានគេយកមកធ្វើកំប៉ុសកម្ម។ នេះជាវិធីកាត់បន្ថយសម្រាមបានយ៉ាងច្រើនជាងធម្មតាដែលត្រូវយកទៅបោះចោលនៅកន្លែងចាក់សម្រាម។

២. ការកែលម្អគុណភាពទឹក។ ក្នុងទីផ្សារក្រុង បន្លែផ្លែឈើដែលត្រូវបានគេបោះចោលត្រូវបានប្រមូលនិងផលិតទៅជា E.M. (Effective Micro organism)ខាប់ដែលត្រូវបានគេប្រើប្រាស់ដើម្បីកែលម្អគុណភាពទឹកក្នុងទន្លេដោយបន្ថែមវាបន្តិចចូលទៅក្នុងលូទឹកស្អុយត្រង់កន្លែងខុសៗគ្នា។ ហើយចំណែកនៅសល់គឺប្រើសម្រាប់ផ្តល់ចំណីទៅឲ្យសត្វដូចជាពពែ ជ្រូក ទា ទន្សាយ ធៀបដូចជន្លេនក្នុងការដ្ឋានក្រុង។ អាចម៍របស់ពួកគេនឹងត្រូវបានប្រមូលនិងដាក់លក់។

៣. តម្រងប្រេងនិងខ្លាញ់នៅពេលដំបូង សាលាក្រុងបានណែនាំនិងផ្តល់ តម្រងប្រេងនិងខ្លាញ់ដើម្បីតម្លើងនៅតាមផ្ទះនិងនៅតាមដងទន្លេនិងក្នុងទីក្រុង។ បច្ចុប្បន្ននេះ ការអនុវត្តបែបនេះត្រូវបានដាក់ឲ្យប្រតិបត្តិដោយច្បាប់របស់ក្រុង។
តម្រងប្រេងនិងខ្លាញ់កាត់បន្ថយបន្ទុកសារធាតុសរីរាង្គនៃទន្លេ ហេតុនេះវាជួយកែលម្អយ៉ាងប្រសើរទៅលើគុណភាពទូទៅក្នុងទន្លេ។ សារធាតុខ្លាញ់ដែលប្រមូលបានគឺនឹង

ប្រែក្លាយទៅជាដុំឥន្ធនៈ (Fuel Bars) ដែលបម្រើជាឥន្ធនៈបន្ថែមក្នុងទីសត្តឃាត ហើយនិងកាត់បន្ថយការប្រើប្រាស់ធ្យូងថ្ម។

៤. គមនាគមន៍សាធារណៈ

រថយន្តសាធារណៈដែលស្រដៀងគ្នានឹងរថអគ្គីសនី ប្រើប្រាស់ថាមពល NGV ត្រូវបានណែនាំឲ្យទៅដឹកជញ្ជូនក្មេងសាលាមនុស្សចាស់និងអ្នកឯទៀតទៅសាលារៀននិងទៅអាគារកីឡាក្រុងជំនួសឲ្យការប្រើប្រាស់រថយន្តឯកជន។ ទាំងនេះគឺជាកត្តានឹងកាត់បន្ថយឥន្ធនៈកម្មនិងឧស្ម័នកាបោន ក្នុងទីក្រុង។

គំនិងផ្តួចផ្តើមថ្មីដែលត្រូវបានណែនាំក្នុងកម្មវិធីនេះបានផ្តល់អត្ថប្រយោជន៍ដូចខាងក្រោមទៅដល់សហគមន៍ក្នុងស្រុកនិងសាលាក្រុងខ្លួនផ្ទាល់។

ការគ្រប់គ្រងសំណល់រឹងបានកាត់បន្ថយសំណល់ដែលជាលទ្ធផលពីការកែច្នៃជាថ្មីនិងការប្រើប្រាស់ឡើងវិញ ហេតុនេះវាបានកាត់បន្ថយជើងធ្វើដំណើរនៃរថយន្តដឹកសម្រាមក្នុងការដឹកជញ្ជូនសម្រាមទៅកន្លែងចាក់សម្រាម។ ដូចនេះ សាលាក្រុងបានសន្សំយ៉ាងច្រើនលើការចំណាយប្រេងសាំងនិងកន្លែងចាក់សម្រាមអាចប្រើប្រាស់បានយូរជាងមុន។

ជីកំប៉ុសក៏កំពុងតែរកបានចំណូលហើយវាសន្សំសំចៃថែមទៀតសម្រាប់ក្រុង។ ឧស្ម័នមេតានដែលបានមកពីពេលធ្វើកំប៉ុសកម្មជំនួសឲ្យធនធានឥន្ធនៈធម្មតានៅក្នុងទីសត្តឃាតក្នុងក្រុង។ ជីកំប៉ុសនិងសារធាតុរាវE.M.គឺមានតម្រូវការខ្ពស់ពីសំណាក់អ្នកដាំផ្លែឈើ។

- គុណភាពទឹកទន្លេមានការប្រសើរឡើងគួរឲ្យកត់សម្គាល់។ សារធាតុរាវE.M. ខាប់ត្រូវបានដាក់ក្នុងទឹកលូក្រុងនៅត្រូវទីកន្លែងផ្សេងៗគ្នាដែលនេះធ្វើឲ្យទឹកត្រូវបានសំអាតជូនកាលមុនពេលវាហូរចូលទន្លេទៀត។
- គុណភាពខ្យល់បានប្រសើរឡើង។ ការកាត់បន្ថយរថយន្តឯកជននៅលើផ្លូវចង្អៀតនៃម្វូងក្លាង Muangklangមានន័យថានឹងកាត់បន្ថយការស្ទះចរាចរកាត់បន្ថយពេលវេលាធ្វើដំណើរ និងកាត់បន្ថយការបញ្ចេញសំណល់ពីបំពង់បញ្ចេញផ្សេង។

- ការដាំដើមឈើក្នុងតំបន់ដែលត្រូវបោះបង់ចោលត្រូវបានកើនឡើង ព្រមទាំងតំបន់បៃតងនៃទីក្រុងផងដែរ។ ទីក្រុងនេះក៏បានណែនាំជាកសិកម្មទីក្រុង ដូចនេះប្រជាជនអាចដាំបន្លែសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ។ កសិដ្ឋានសរីរាង្គកំពុងតែត្រូវបានគេណែនាំ និងលើកកម្ពស់ទៅកាន់កសិករក្នុងស្រុក។

**ង- ការពាក់ព័ន្ធនិងសកម្មភាព**

សកម្មភាពទាំងនេះត្រូវបានទទួលយកបានយ៉ាងល្អនៅក្នុងសហគមន៍។ ជាមួយនឹងផលប្រយោជន៍ភ្លាមៗនិងប្រកបដោយប្រសិទ្ធភាព ប្រជាជនមានការត្រៀមលក្ខណៈច្រើនជាងមុនដើម្បីធ្វើការជាមួយនឹងរដ្ឋាភិបាលក្រុងក្នុងការអនុវត្តសកម្មភាពដែលជាផ្នែកមួយនៃគម្រូការអនុវត្តល្អ។ អ្នកលក់តាមផ្សារមានសេចក្តីសោមនស្សក្នុងការប្រមូលនិងបែងចែកបន្លែនិងផ្លែឈើដែលត្រូវបានបោះចោល ជាសំណាងមកវិញ ពួកគេមានសារធាតុរាវE.M. កំប៉ុសនិងបរិស្ថាននិងផ្សារប្រកបដោយអនាម័យ។ តាមរយៈទំនប់សម្រាមសាលា ការគ្រប់គ្រងសាលាតម្លើងថ្លៃនៃអត្រាប្តូរព្រោះរាល់សំណល់អាចកែច្នៃបានដែលត្រូវបានប្រមូលមួយគីឡូក្រាមមានតម្លៃស្មើនឹង១បាតសម្រាប់សកម្មភាពអភិវឌ្ឍន៍សាលា។ ដូចគ្នាដែរ ម្ចាស់ផ្ទះ បានកំពុងប្រើប្រាស់Grease Trapsក្នុងផ្ទះរបស់ពួកគេកាន់តែច្រើនឡើងៗ។

លោកអភិបាលក្រុងស៊ុមចៃ ចារីយ៉ាចារឹន Somchai Chariyacharoen បម្រើការងារនៅសាលាក្រុងក្លាងKlang ចំនួនបីអាណត្តិហើយ។ ជោគជ័យការបោះឆ្នោតលើកចុងក្រោយនេះរបស់លោកដោយគ្មានបេក្ខជនប្រកួតប្រជែងណាបានបញ្ជាក់ពីការអភិវឌ្ឍសេដ្ឋកិច្ចនិងបរិស្ថានដោយមានតុល្យភាពនិងរួមបញ្ចូលគ្នា និងការចូលរួមពីប្រជាពលរដ្ឋ គឺជាកត្តាគន្លិះនៃការជោគជ័យ។ អាណត្តិថ្មីនេះអនុញ្ញាតិឲ្យគាត់ណែនាំគំនិតថ្មីៗនិងសកម្មភាពក្នុងការកែលម្អអ្វីដែលមាននិងស្វែងរកអ្វីៗថ្មីទៀតដូចជា កសិកម្មទីក្រុង ជីវៈចំរុះទីក្រុង សុខភាពនិងបរិស្ថាន ការប្រែប្រួលអាកាសធាតុក្នុងបរិបទវប្បធមិទីក្រុង។

**ច- និរន្តរភាព និងការអនុវត្ត**

កត្តាខាងក្រោមនេះធានាដល់ការគាំទ្រនៃកម្មវិធីនេះ៖

- **ភាពអាចពឹងផ្អែកលើខ្លួនឯងបាន។** គម្រូប្រតិបត្តិការនេះគឺហាក់បីដូចជាមានទំហំតូចបន្តិច ដែលការគ្រប់គ្រងសំណល់រឹងនេះមានប្រសិទ្ធភាពចំពោះតែទីក្រុងណាដែលមានប្រជាជនមិនលើសពី២០,០០០នាក់។ ទោះបីធ្វើការដោយឯករាជ្យ ក្រុមគ្រប់គ្រងសំណល់ខ្សែក្រវ៉ាត់ដឹកនាំ នៅតែស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងជិតដិតពីអភិបាលក្រុង។ ការលក់អនុផលនៃប្រតិបត្តិការដូចជាជីកំប៉ុស សារធាតុរាវEM សម្ភារៈអាចកែច្នៃបាន និងបន្លែសរីរាង្គដែលត្រូវបានដាំក្នុងស្រុក ក្រុមនេះរកបានចំណូលគ្រាន់បើសម្រាប់ថ្លៃដើមនៃការធ្វើប្រតិបត្តិការនិងគ្រឿងលើកទឹកចិត្តកម្មករ។ ក្នុងឋានៈជាមជ្ឈមណ្ឌលសិក្សាអំពីបរិស្ថានទីក្រុង១ក្នុងចំណោម៥នៃតំបន់ klang ក៏បានថែរក្សាសកម្មភាពសិក្សាតាមរយៈការបរិច្ចាគថ្លៃចូលដែលបានប្រមូលពីក្រុមអ្នកដែលមកទស្សនានៅប្រទេសថៃ។
- **ការអប់រំសម្រាប់អ្នកជំនាន់ក្រោយ។** កម្មវិធីការកែប្រែសម្រាមត្រូវបានគេពង្រីកទៅដល់សាលាច្រើន។ ការគ្រប់គ្រងសំណល់រឹងគឺមិនត្រឹមតែត្រូវបានបង្រៀននោះទេ សិស្សនៅត្រូវបានលើកទឹកចិត្តឲ្យអនុវត្តជាប្រចាំនៅឯផ្ទះ។ កត្តានេះធ្វើឲ្យពួកគេមើលឃើញផ្ទាល់នូវលទ្ធផលល្អដែលមានការកាត់បន្ថយសម្រាមនិងផលប្រយោជន៍នៃការកើនឡើងនៃប្រាក់ចំណូល។ អ្នកហ្វឹកហាត់ស្ម័គ្រចិត្តដែលមកពីសាលាក្រុងដើរជុំវិញសាលារៀនដើម្បីអប់រំនិងលើកទឹកចិត្តសិស្សានុសិស្សឲ្យអនុវត្តការគ្រប់គ្រងសំណល់រឹង។

- **ទំនាក់ទំនងសាធារណៈ និងគមនាគមន៍។** អភិបាលក្រុងបានទាញភ្ជាប់គ្រឿងផ្សាយព័ត៌មានឲ្យផ្សព្វផ្សាយពីគម្រូការអនុវត្តល្អ។ លោកបានប្រាស្រ័យទាក់ទងជាទៀងទាត់ជាមួយប្រជាជនតាមរយៈវិទ្យុFMក្នុងស្រុក។ ព័ត៌មាននិងទិន្នន័យដែលមានគុណភាពខ្ពស់នៃគេហទំព័ររបស់សាលាក្រុង (muangklang.com) បានក្លាយជាកន្លែងសម្រាប់ចែករំលែកនិងរៀនសូត្រដែលទទួលប្រជាប្រិយភាពកាន់តែច្រើនឡើងៗ។

ថ្មីៗនេះ សាលាក្រុងក្លាងKlangបានក្លាយជាមជ្ឈមណ្ឌលល្បីមួយសម្រាប់សិក្សារៀនសូត្រអំពីការអនុវត្តល្អៗមួយចំនួន ជាពិសេសគឺទៅលើបញ្ហាការគ្រប់គ្រងបរិស្ថានទីក្រុង។

ប្រជាជនមួយចំនួនធំ ភ្នាក់ងាររដ្ឋាភិបាលកណ្តាលនិងក្នុងស្រុក អង្គការក្រៅរដ្ឋាភិបាលនិងសហាគមន៍បានធ្វើទស្សនកិច្ចនិងមើលឃើញពីការអនុវត្តល្អនៃក្លាងKlang ប៉ុន្តែមានតិចតួចណាស់ដែលអាចអនុវត្តតាមបាន។ មានកត្តាមូលដ្ឋានមួយចំនួនជួយឲ្យក្លាងKlangទទួលបានជោគជ័យ តែមិនបានលើកឡើង។ នេះគឺជាកត្តាមួយចំនួនដែលអ្នកអនុវត្តល្អគួរតែយកមកគិតពិចារណា៖

- បច្ចេកវិទ្យានិងមធ្យោបាយត្រឹមត្រូវ។ បច្ចេកវិទ្យាប្រហែលជាក្លាយជាភាពមានកម្រិតខាងបច្ចេកវិទ្យានិងបន្ទុកហិរញ្ញវត្ថុសម្រាប់រដ្ឋាភិបាលក្នុងស្រុក។ បច្ចេកវិទ្យាឬមធ្យោបាយសមរម្យគួរតែមិនបំផ្លាញប្រព័ន្ធអេកូឡូស៊ីទេ។ ផ្ទុយទៅវិញវាគួរតែអភិរក្សនិងការពារអេកូឡូស៊ី។ ដូចដែលបានរៀបរាប់រួចក្លាងKlangបានប្រើប្រាស់សំណល់សរីរាង្គទាំងអស់ដើម្បីផលិតជីសម្រាប់ផលិតកម្មកសិកម្ម ចំណីអាហារសត្វ និងសម្រាប់សម្អាតទន្លេ។ **ខ្សែពានបញ្ជូនសម្រាម** ដ៏សាមញ្ញមួយប្រើសម្រាប់ញែកសំណល់។

- គ្រឿងលើកទឹកចិត្តដ៏ត្រឹមត្រូវ។ ការអនុវត្តល្អគឺជាលទ្ធផលនៃការជំរុញទឹកចិត្តនិងគ្រឿងលើកទឹកចិត្តដ៏ត្រឹមត្រូវ។ ក្លាងKlangមានក្រុមល្អមួយជាមួយនិងការជំរុញទឹកចិត្តត្រឹមត្រូវនិងគោលបំណងល្អដើម្បីធ្វើឲ្យក្លាងKlangក្លាយជាទីក្រុងដែលសមនឹងរស់នៅ។ គ្រឿងលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចនិងផ្នែកស្មារតីត្រូវបានលើកឡើង ហើយវាបានជំរុញទឹកចិត្តដល់បុគ្គលិកសាលាក្រុងអ្នកលក់ដូរ និងសមាជិកសហាគមន៍។ ការកាត់បន្ថយថ្លៃនិងការបង្កើតចំណូលនៃសកម្មភាពអភិវឌ្ឍន៍ទាំងអស់គឺជាគ្រឿងលើកទឹកចិត្តដែលអាចសម្រេចបាន។

# ជំពូកទី៣

# ប្រធានបទ៖ ការគ្រប់គ្រងសារពើពន្ធ

**-ទស្សនទាននិងការអនុវត្តល្អនានា-**

ដោយលោក ហ្គីលប៊ិត ឡានតូ និង លោកអានតូនីញ៉ូ អារីឡា

# ជំពូកទី៣

# ប្រធានបទទី៦៖ ការគ្រប់គ្រងសារពើពន្ធ

## មាតិកា


៦-១ តួនាទីនៃរដ្ឋាភិបាលក្នុងការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក៖ គំនិតសំខាន់

៦-១-១ វិមជ្ឈការនិងការដើរតួដ៏សកម្ម នៃរដ្ឋាភិបាលមូលដ្ឋាន ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចមូលដ្ឋាន

៦-១-២ ការលើកទឹកចិត្ត វិស័យសេដ្ឋកិច្ច និងវិស័យនយោបាយ សម្រាប់ការផ្តួចផ្តើមអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក

៦-១-៣ បង្កើតឲ្យមានសេចក្តីផ្តើមគំនិតអភិវឌ្ឍមូលដ្ឋាននៅក្នុងផែនការអភិវឌ្ឍតំបន់និងជាតិ

៦-១-៤ ផ្សារភ្ជាប់អ្នករួមចំណែកក្នុងស្រុកតាមរយៈមធ្យោបាយរួមចំណែក (កសិករ អ្នកនេសាទ អ្នកលក់ដូរនៅផ្សារ ពាណិជ្ជករឬសហគ្រិនក្នុងស្រុក និងសង្គមស៊ីវិល)

៦-១-៥ ភាពជាដៃគូឯកជន-សាធារណៈសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន

៦-២ គ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុកនិងការជំរុញការវិនិយោគ ក្នុងប្រទេសប្រាំនៅអាស៊ីអាគ្នេយ៍

៦-២-១ គម្រោងសមុទ្រវិប្បកម្ម Tubigon ៖ គ្រប់គ្រងសេដ្ឋកិច្ចនិងបរិស្ថានក្នុងស្រុក

៦-២-២ រៀបចំអ្នកលក់ដូរតាមដងផ្លូវនៅក្នុងទីក្រុងសូឡូ - យុទ្ធសាស្រ្តអភិវឌ្ឍន៍ទីក្រុង

៦-២-៣ វិនិយោគសារជាថ្មីលើក្រុងភូកេតចាស់៖ ទេសចរណ៍វប្បធម៌ជា យុទ្ធសាស្រ្តអភិវឌ្ឍន៍

## ៦ ប្រធានបទទី៤ - ការគ្រប់គ្រងសារពើពន្ធ

### ៦-១ តួនាទីនៃរដ្ឋាភិបាលក្នុងការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក៖ គំនិតសំខាន់

ជំពូកនេះផ្តល់នូវវិធាននៃគោលគំនិតសម្រាប់ខ្លឹមសារសំខាន់អំពីការលើកទឹកចិត្តការគ្រប់គ្រងនិងការវិនិយោគ។ វាសង្កត់ធ្ងន់ទៅលើតួនាទីសំខាន់ៗដែលរដ្ឋាភិបាលក្នុងស្រុកអាចដើរតួក្នុងការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក។ គោលគំនិតទាំងនោះមានដូចជា៖

១.ការកើនឡើងនៃការដើរតួ របស់រដ្ឋាភិបាលមូលដ្ឋានក្នុងបរិបទការចែករំលែកអំណាចពីថ្នាក់ខ្ពស់មកថ្នាក់ទាបវិមជ្ឈការ។

២.ការលើកទឹកចិត្តដល់វិស័យសេដ្ឋកិច្ច និងនយោបាយដើម្បីការចាប់ផ្តើមអភិវឌ្ឍវិស័យសេដ្ឋកិច្ចមូលដ្ឋាន។

៣.បង្កើតការចាប់ផ្តើមអភិវឌ្ឍមូលដ្ឋាន លើគម្រោងអភិវឌ្ឍសាសនាក្នុងតំបន់ឬជាតិទាំងមូល។

៤. គ្រប់គ្រងអ្នករួមចំណែកដោយការចូលរួម។

៥. ភាពជាដៃគូនៃវិស័យឯកជនដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន។

#### ៦-១-១ វិមជ្ឈការនិងការដើរតួដ៏សកម្ម នៃរដ្ឋាភិបាលមូលដ្ឋាន ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចមូលដ្ឋាន

វិមជ្ឈការត្រូវបានអនុវត្តដោយប្រទេសកំពុងអភិវឌ្ឍមួយចំនួនដើម្បីនាំមកនូវភាពអាចទទួលខុសត្រូវបាននិងអភិបាលកិច្ចដែលល្អប្រសើរជាងមុន ហើយការផ្តល់នូវសេវាកម្មនិងផលិតផលសាធារណៈមកកាន់តំបន់មូលដ្ឋានឲ្យបានល្អជាងមុនផងដែរ។ ទំនួលខុសត្រូវលើការអភិវឌ្ឍតាមតំបន់ និងការនាំយកផលិតផល និងសេវាកម្មមូលដ្ឋានសាធារណៈបានផ្ទេរពី

រដ្ឋាភិបាលកណ្តាលមកកាន់រដ្ឋាភិបាលថ្នាក់ក្រោមជាតិដែលត្រូវបានគេហៅជាទូទៅថា រដ្ឋបាលមូលដ្ឋាន។

តាមរយៈគំនិតដែលចូលទៅជិតប្រជាពលរដ្ឋតាមគោលការណ៍ជាកន្លែងដែលអាចឆ្លើយតបនឹងការពេញចិត្តរបស់ប្រជាជនតាមរយៈផលិតផលរដ្ឋ រដ្ឋបាលមូលដ្ឋានទទួលនឹងស្ថិតនៅចំណុចប្រសើរក្នុងការវាយតម្លៃទៅលើការស្ម័គ្រចិត្តចំណាយនិងក្នុងការកំណត់សេវាឲ្យត្រូវនឹងប្រជាជន។ ក្នុងប្រទេសដែលធ្វើវិមជ្ឈការខ្លះ រដ្ឋបាលមូលដ្ឋានកំពុងដឹកនាំការរៀបចំវិធានការច្នៃប្រឌិតថ្មីៗ ដើម្បីអោយការចំណាយរបស់រដ្ឋកាន់តែមានប្រសិទ្ធភាព។ ឧទាហរណ៍ នៅប្រទេសអេស្ប៉ាញ កម្មវិធីសម្រាប់សាកល្បងតាមតំបន់ខ្លះដែលផ្តោតលើការចំណាយផ្នែកឱសថ និងការកាត់បន្ថយតារាងការរង់ចាំសេវាពីមន្ទីរពេទ្យសាធារណៈ ហើយកម្មវិធីនេះបានបង្ហាញពីលទ្ធផលដែលនឹងទទួលបានជោគជ័យ។

ប្រទេស៥នៅអាស៊ីអាគ្នេយ៍ក្នុងគម្រោងនេះ ស្ថិតក្នុងស្ថានភាពផ្សេងគ្នានៃការធ្វើវិមជ្ឈការ ប៉ុន្តែមានបំណងប្រាថ្នាធំរួមមួយគឺកែលម្អសុខមាលភាពនៃសហគមន៍មូលដ្ឋានរបស់គេរៀងខ្លួនតាមរយៈការផ្តល់នូវភាពប្រសើរជាងមុននូវសេវានិងតម្លាភាពក្នុងទំនួលខុសត្រូវរដ្ឋបាលមូលដ្ឋាន។

ក្នុងប្រទេសហ្វីលីពីន ក្នុងឆ្នាំ១៩៩១ ក្រុមរដ្ឋបាលមូលដ្ឋានបានផ្តល់អង្គភាពរដ្ឋាភិបាលមូលដ្ឋាននូវទំនួលខុសត្រូវក្នុងការនាំយកសេវាក្នុងតំបន់និងមូលដ្ឋានសាធារណៈ និងលើកកម្ពស់ប្រាក់ចំណូលមូលដ្ឋានឬប្រាក់ចំណូលដែលរកបានដោយខ្លួនឯងសម្រាប់ផ្គត់ផ្គង់ចំណាយលើកិច្ចការខ្លួន។ ការធ្វើវិមជ្ឈការនិងប្រតិភូកម្មនៃអំណាចនិងអាជ្ញាធរពីរដ្ឋាភិបាលកណ្តាលមករដ្ឋាភិបាលមូលដ្ឋានបានបង្កើតឱកាសជាច្រើនសម្រាប់ការអភិវឌ្ឍខ្លួនឯងតាមកម្រិតមូលដ្ឋានដែលមានការខុសគ្នាពីអំឡុងពេលវេលាមុនការប្រកាសច្បាប់វិមជ្ឈការនៅពេលរដ្ឋាភិបាលកណ្តាលឬថ្នាក់ជាតិ បានបញ្ចូលការគ្រប់គ្រងស្ទើរតែគ្រប់ផ្នែកនៃរដ្ឋបាលមូលដ្ឋាននិងអភិបាលកិច្ច។

ថ្វីបើប្រទេសទាំង៥មានការខុសគ្នាលើទីតាំងភូមិសាស្ត្រ វប្បធម៌ នយោបាយ និងការអភិវឌ្ឍវិទ្យាសាស្ត្រសង្គមសេដ្ឋកិច្ច តែកំណែទម្រង់លើវិមជ្ឈការ និងការគ្រប់គ្រងតាមតំបន់ ហាក់បីដូចជាសមហេតុផលដូចគ្នា៖ “*កាត់បន្ថយការមិនពេញចិត្តលើប្រព័ន្ធ*

*គ្រប់គ្រងមជ្ឈការ និងការនាំយកសំលេងរបស់ប្រជាជនទៅក្នុងដំណើរការអភិបាលកិច្ច ក្នុងបំណងលើកស្ទួយការឆ្លើយតប និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាលនិងមន្ត្រី ក្នុងការបំពេញតួនាទីរបស់ពួកគេ។* គោលដៅសំខាន់ៗក្នុងកំណែទំរង់វិមជ្ឈការមាន ដូចតទៅ៖

- បង្កើតអោយមានវប្បធម៌នៃលទ្ធិប្រជាធិបតេយ្យដែលមានការចូលរួម ពីមូលដ្ឋាន មានការទទួលខុសត្រូវលើប្រជាជន
- កែលម្អសេវាសាធារណៈ និង ហេដ្ឋារចនាសម្ព័ន្ធ
- នាំយកមកនូវការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច
- រួមចំណែកការកាត់បន្ថយភាពក្រីក្រ

យោងតាមបទពិសោធន៍របស់ប្រទេសទាំង៥នៃអាស៊ីអាគ្នេយ៍ ការធ្វើវិមជ្ឈការបាន រួមចំណែកដូចខាងក្រោម៖

- ការកែលម្អចំណែកធនធានក្នុងតំបន់
- ការទទួលខុសត្រូវកាន់តែប្រសើរជាងមុន ពីសំណាក់សមាសភាគ រដ្ឋាភិបាល
- ជាឱកាសដ៏ប្រសើរ ក្នុងការលើកស្ទួយការចូលរួមក្នុងរដ្ឋបាលនិង អភិបាលកិច្ចមូលដ្ឋាន
- ណែនាំអោយមានការផ្តើមគំនិតអភិវឌ្ឍក្នុងតំបន់ ដែលជាសក្តានុភាព ក្នុងការផ្តល់ការងារ និង ឱកាសធ្វើជំនួញសម្រាប់សមាសភាគ
- ការនាំយកសេវាកម្មនិងផលិតផលសាធារណៈឲ្យកាន់តែប្រសើរឡើង ទៅកាន់សមាសភាគផ្សេងៗ។

ជាទូទៅ រដ្ឋាភិបាលក្នុងស្រុកនាពេលបច្ចុប្បន្ននេះកាន់តែយល់ច្បាស់ពីការដើរតួដ៏ សំខាន់របស់ពួកគេក្នុងការធានាអោយមានសុខមាលភាពផ្នែកសេដ្ឋកិច្ចនៃសមាសភាគ និង ក្នុងការផ្តល់នូវបរិស្ថានមួយដែលជំរុញអោយមានការអភិវឌ្ឍ និងការរីកចម្រើនក្នុងតំបន់។ ក្នុង ច្បាប់មូលដ្ឋានជាច្រើន ការលើកស្ទួយការវិនិយោគតាមតំបន់និងការផ្តើមគំនិត ដែលបាន បន្ថែមអោយមានទិន្នផលក្នុងស្រុកកើនឡើងជាមួយនឹងការងារ ត្រូវបានឃើញថាជាតួនាទី និងការទទួលខុសត្រូវដ៏សំខាន់របស់រដ្ឋាភិបាលមូលដ្ឋាន។ តួនាទីនេះគឺទទួលបានចំណាត់

ថ្នាក់កំពូល ក្នុងចំណោមតួនាទីធម្មតារបស់រដ្ឋាភិបាលមូលដ្ឋានក្នុងរដ្ឋបាលមូលដ្ឋាន ដើម្បីធានាអោយមានសុវត្ថិភាព និងសន្តិភាព ដែលដាក់កម្រិតទៅលើសកម្មភាពអាជីវកម្មក្នុងស្រុក និងក្នុងតំបន់តាមប្រពៃណីផ្សេងទៀត។

### ៦-១-២ ការលើកទឹកចិត្ត វិស័យសេដ្ឋកិច្ច និងវិស័យនយោបាយ សម្រាប់ការផ្តួចផ្តើមអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក

ការធ្វើវិមជ្ឈការ បានត្រូវសរសើរដោយសារសក្តានុពលនៃការតម្រង់សេចក្តីត្រូវការនិងផលប្រយោជន៍របស់ប្រជាជនជាមួយនឹងសេចក្តីត្រូវការនិងផលប្រយោជន៍របស់រដ្ឋាភិបាល។ ទ្រឹស្តីនេះគឺចង់បានន័យថារដ្ឋបាលមូលដ្ឋានគឺសក្តិសមបំផុតក្នុងការកំណត់និងរៀបចំអន្តរាគមន៍ដូចជាគម្រោងអភិវឌ្ឍន៍មូលដ្ឋានដែលអាចដោះស្រាយបញ្ហានិងការព្រួយបារម្ភរបស់មូលដ្ឋានក្នុងវិធីមួយដែលមានអត្ថន័យ។ វាអាចបែបនេះបាននៅពេលដែលមន្ត្រីមូលដ្ឋានមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋមូលដ្ឋានពេញលេញ មានការឆ្លើយតបលឿនទៅនឹងតម្រូវការនិងសេចក្តីប្រាថ្នារបស់មូលដ្ឋាន និងមានធនធាននិងជំនាញការរដ្ឋបាលដើម្បីដោះស្រាយបញ្ហាអភិវឌ្ឍន៍មូលដ្ឋាន។ ដំណើរការក្នុងការបោះឆ្នោតដែលយុត្តិធម៌និងមានតម្លាភាពជួយធានាដល់ការទទួលខុសត្រូវនិងភាពដែលអាចឆ្លើយតបបានឆាប់រហ័សដល់សេចក្តីត្រូវការនិងសេចក្តីប្រាថ្នារបស់មូលដ្ឋាន។ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការត្រួតពិនិត្យនិងអភិបាលកិច្ចក៏ផ្តល់នូវការលើកទឹកចិត្តដល់អាកប្បកិរិយាដែលទទួលខុសត្រូវរបស់មន្ត្រីមូលដ្ឋានដែរ។

ចាប់តាំងពីមន្ត្រីមូលដ្ឋានអាចត្រូវបានកត់សំគាល់យ៉ាងងាយស្រួលពីអ្នកបោះឆ្នោតនិងអ្នកជាប់ពន្ធ ពួកគេត្រូវបានរំពឹងថានឹងមានការទទួលខុសត្រូវច្រើនជាងមុន ជាពិសេសបើចំណាយលើការផ្គត់ផ្គង់សេវាសាធារណៈនោះទទួលបន្ទុកដោយថ្នាក់មូលដ្ឋាន។

យន្តការដែលរដ្ឋាភិបាលមូលដ្ឋានមានបំណងលើកស្ទួយសុខមាលភាពមូលដ្ឋានគឺជារូបមន្តនិងសកម្មភាពនៃការផ្តើមអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដែលពុំត្រូវបានចាប់ផ្តើមទេប្រសិនបើគ្មានការផ្តួចផ្តើមនិងការគាំទ្ររបស់រដ្ឋាភិបាលមូលដ្ឋាន។ ការផ្តើមគំនិតអភិវឌ្ឍមូលដ្ឋានក្នុងទម្រង់មួយគឺការសហគ្រាសសេដ្ឋកិច្ចមូលដ្ឋាន ប្រហែលជាកំលាំងជំរុញមួយអោយមាន

ការអភិវឌ្ឍមូលដ្ឋាន ដែលនឹងអាចជួយលើកទឹកចិត្តឲ្យមានការវិនិយោគពីសំណាក់វិស័យឯកជនក្នុងតំបន់ដែលពួកគេចង់ដាក់ទុនបាន។

អំណះអំណាងដើម្បីការណែនាំនិងការអភិវឌ្ឍនៃសហគ្រាសសេដ្ឋកិច្ចមូលដ្ឋាន គឺសក្តានុពលនៃសហគ្រាសរដ្ឋក្នុងការកែតម្រូវទីផ្សារដែលមិនសូវអំណោយផល ជាទូទៅគេហៅថា "បរាជ័យសេដ្ឋកិច្ចទីផ្សារ" ។ ជាឧទាហរណ៍ អាចមានករណីឯកាធិជន(ផ្តាច់មុខ)ដោយធម្មជាតិ ទីផ្សារមូលធនមិនទាន់មានការអភិវឌ្ឍពេញលេញ និងកត្តាខាងក្រៅ ដែលអនុញ្ញាតឲ្យការលូកដៃចូលក្នុងកិច្ចការសេដ្ឋកិច្ចដោយរដ្ឋាភិបាល។ ទីបីគឺវិនិយោគិនវិស័យឯកជនប្រហែលជាមិនបានលើកទឹកចិត្តឲ្យបណ្តាក់ទុនក្នុងវិស័យឧស្សាហកម្ម ដែលមានផលប្រយោជន៍ដល់វិស័យផ្សេងទៀតដោយគ្មានការចំណាយទៅលើសេវាផ្តល់ឲ្យនោះទេ។

ផ្នែកក្រុមហ៊ុនឯកជន ប្រហែលជាមានការស្ទាក់ស្ទើរក្នុងការដាក់ទុនក្នុងគម្រោងអភិវឌ្ឍមូលដ្ឋាន ព្រោះការរកចំណូលត្រលប់មកវិញក្នុងពេលអនាគតហាក់បីដូចជាមានការប្រថុយប្រថាន។ នេះប្រហែលជាមកពីមូលហេតុដែលប្រភពហិរញ្ញវត្ថុអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដូចជាធនាគារឯកជនមានការលំអៀងខ្លាំង ក្នុងការជួយលើគម្រោងការរយៈពេលខ្លីដែលមានការប្រថុយប្រថានទាបជាងគម្រោងរយៈពេលវែង។

ការផ្តួចផ្តើមអភិវឌ្ឍន៍មូលដ្ឋានឬសហគ្រាសសេដ្ឋកិច្ចមូលដ្ឋានដែលត្រូវបានរៀបចំនិងអនុវត្តយ៉ាងល្អប្រសើរ ដូចជា គម្រោងសមុទ្រវប្បកម្មនៅ Tubigon, Bohol ប្រទេសហ្វីលីពីន; វិធីសាស្រ្តតាមបែបប្រជាជនសម្រាប់ទីក្រុងកាន់តែសមរម្យក្នុងការរស់នៅក្នុងទីក្រុងសូឡូ ប្រទេសឥណ្ឌូនេស៊ី; និងគម្រោងការអភិវឌ្ឍនិងអភិរក្សក្រុងចាស់ភូកេតសម្រាប់ទីក្រុងដ៏មនោរម្យ និងការបង្កើតប្រាក់ចំណូលក្នុងប្រទេសថៃ អាចជួយធ្វើឲ្យរដ្ឋាភិបាលមូលដ្ឋានមានការឆ្លើយតបទៅនឹងតម្រូវការការងារ ធនធានសម្រាប់ការរស់នៅឬអាជីវកម្មជាទៀងទាត់សម្រាប់ជាផលប្រយោជន៍ដល់ប្រជាជន។ គម្រោងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដែលត្រូវបានអនុវត្តយ៉ាងល្អប្រសើររឹតតែបានបង្កើនប្រាក់ចំណូលដែលនឹងកែលម្អឋានៈសារពើពន្ធនៃរដ្ឋាភិបាលមូលដ្ឋាន ធ្វើឲ្យរដ្ឋាភិបាលមូលដ្ឋានអាចផ្តល់សេវាបានច្រើននិងល្អជាមុន។ ឧទាហរណ៍សាលាក្រុងTubigon ថ្មីៗនេះត្រូវបានចាត់ចូលចំណាត់ថ្នាក់លេខមួយដែលពីមុន

ជាប់លេខបួនកាលពីដំណាក់កាលដំបូងនៃគម្រោងដ៏ជោគជ័យរបស់ខ្លួន។ ការកើនឡើងនៃប្រាក់ចំណូលដែលបានពីគម្រោងនេះបានធ្វើឲ្យមានការកើនឡើងនៃចំណូលពន្ធរបស់ក្រុង។

ការអនុវត្តដ៏ជោគជ័យសម្រាប់ការផ្តួចផ្តើមអភិវឌ្ឍន៍មូលដ្ឋានបែបនេះក៏ជាការឆ្លុះបញ្ចាំងឲ្យឃើញពីអ្វីដែលរដ្ឋាភិបាលមូលដ្ឋានអាចធ្វើបាននិងកំពុងតែធ្វើដើម្បីជួយ នូវសុខមាលភាពមូលដ្ឋានឲ្យប្រសើរឡើង។ ភាពចំណេញផ្នែកសេដ្ឋកិច្ចដែលបានពីការអនុវត្តគម្រោងដ៏ជោគជ័យមួយនេះ អាចជាអានុភាពនយោបាយសម្រាប់ឥស្សរជនផ្លូវការដែលទទួលខុសត្រូវលើគម្រោងនេះផ្ទាល់។ គុណប្រយោជន៍ផ្នែកនយោបាយដែលបានពីការជោគជ័យលើគម្រោងមូលដ្ឋានធ្លាក់ទៅលើអ្នកនយោបាយមូលដ្ឋានឬឥស្សរជនផ្លូវការដែលគ្រប់គ្រងឬអនុវត្តគម្រោងនេះ ហើយប្រហែលជាធ្លាក់លើអ្នកមួយចំនួនដែលមិនសូវស្គាល់គម្រោងនេះតែមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងការគ្រប់គ្រងឬការអនុវត្តផងដែរ។

ដូច្នេះ ការបង្កើតឲ្យមានលទ្ធផលដូចជាការងារធ្វើ ការលើកទឹកចិត្តសម្រាប់ការវិនិយោគឯកជននិងការចូលរួម។ល។ ពីការផ្តួចផ្តើមការអភិវឌ្ឍមូលដ្ឋានដែលស៊ីគ្នាទៅនឹងការរំពឹងទុកនិងសេចក្តីប្រាថ្នារបស់ប្រជាជន ផ្តល់ឲ្យនូវផលប្រយោជន៍ខាងផ្នែកនយោបាយយ៉ាងសម្បើមដល់ឥស្សរជនមូលដ្ឋានដែលជាភ្នាក់ងារអនុវត្តគម្រោង។

ទោះជាយ៉ាងណាក៏ដោយ ពាក្យប្រុងប្រយ័ត្នគួរតែត្រូវបានផ្តល់។ សេដ្ឋកិច្ចប្រទេសទាំងប្រាំនៃអាស៊ីអាគ្នេយ៍បានប្រកាន់យកគោលនយោបាយទីផ្សារសេរីក្នុងការធ្វើការស្វែងរកកំណើននិងការអភិវឌ្ឍសេដ្ឋកិច្ច។ រដ្ឋាភិបាលពួកគេបានប្រកាន់យកកំណែទម្រង់ទីផ្សារសេរីយ៉ាងផ្ចិតផ្ចង់ ដូចជាការធ្វើសេរីកម្មពាណិជ្ជកម្ម ការបង្រួបបង្រួមសារពើពន្ធ ការជំរុញនៃសហគ្រាសឯកជន ល។ ពាក់ព័ន្ធនឹងអ្វីដែលបានរៀបរាប់ខាងលើ ភាពមិនស៊ីសង្វាក់គ្នាផ្នែកគោលនយោបាយនឹងកើតមានប្រសិនបើរដ្ឋាភិបាលមូលដ្ឋានបង្កើតនិងអនុវត្តគម្រោងអភិវឌ្ឍមូលដ្ឋានដែលអាចប៉ះពាល់ដល់សហគ្រាសឯកជននិងយុទ្ធសាស្ត្រសេដ្ឋកិច្ចដើរដោយទីផ្សារសេរី។ អ្វីដែលអាចធ្វើបានគឺត្រួតពិនិត្យពីភាពជាដៃគូនៃឯកជននិងសាធារណៈទុកជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដែលស៊ីសង្វាក់ទៅនឹងគោលនយោបាយទីផ្សារសេរីរបស់រដ្ឋាភិបាល។

មួយវិញទៀត មន្ត្រីមូលដ្ឋានត្រូវតែដឹងថារដ្ឋាភិបាលនិងទីផ្សារសេរីអាចបរាជ័យបាន។ វានឹងអាចទទួលបរាជ័យលើទីផ្សារសេរី ក៏ដូចជាការបរាជ័យរបស់រដ្ឋាភិបាលផងដែរ។ គម្រោងដែលរៀបចំមិនបានល្អ ការអនុវត្តគ្មានប្រសិទ្ធភាព ខ្វះសមត្ថភាពគ្រប់គ្រងនិងបច្ចេកទេសឬសឹងតែគ្មាន និងកត្តាផ្សេងៗជាច្រើនទៀតដែលអាចរារាំងដល់ការទទួលបានជោគជ័យសម្រាប់គម្រោងអភិវឌ្ឍន៍មូលដ្ឋាន។ វានឹងល្អសម្រាប់រដ្ឋាភិបាលមូលដ្ឋានសហការជាមួយប្រជាជនមូលដ្ឋាន សង្គមស៊ីវិលនិងវិស័យឯកជនក្នុងការកំណត់ ការរៀបចំនិងអនុវត្តគម្រោង។ ស្មារតីអាស៊ីនៃសហប្រតិបត្តិការនិងការអនុវត្តប្រហែលជាការការពារសំខាន់ចំពោះការបរាជ័យ។

### ៦-១-៣ បង្កើតឲ្យមានសេចក្តីផ្តើមគំនិតអភិវឌ្ឍន៍មូលដ្ឋាននៅក្នុងផែនការអភិវឌ្ឍតំបន់និងជាតិ

វាមានសារៈសំខាន់ក្នុងការធានាថាការផ្តួចផ្តើមគំនិតអភិវឌ្ឍន៍មូលដ្ឋានគឺមានលក្ខណៈជួយទំនុកបម្រុងផែនការអភិវឌ្ឍក្នុងស្រុក។ វាគួរឲ្យកត់សម្គាល់ដែរថាផែនការការអភិវឌ្ឍមូលដ្ឋានមួយគឺបង្ហាញពីសេចក្តីប្រាថ្នានៃសមាជិកមូលដ្ឋាននិងថ្លែងពីគោលបំណងនៃគោលនយោបាយ យុទ្ធសាស្ត្រ និងអន្តរាគមន៍ដែលនឹងត្រូវប្រព្រឹត្តិតាមដោយរដ្ឋាភិបាលមូលដ្ឋានដើម្បីធ្វើឲ្យសម្រេចសេចក្តីប្រាថ្នាទាំងនោះ។

ជាធម្មតារដ្ឋាភិបាលក្នុងស្រុកជាអ្នកធ្វើផែនការអភិវឌ្ឍន៍ក្នុងស្រុក ដែលវាជាឯកសារផ្តល់នូវគោលដៅគម្រោង យុទ្ធសាស្ត្រ គោលនយោបាយ និងវិធានការអភិវឌ្ឍន៍ក្នុងស្រុក។ ផែនការអភិវឌ្ឍន៍ដែលល្អមួយគឺជាប្រយោគមួយនៃទស្សនវិស័យរបស់រដ្ឋាភិបាលមូលដ្ឋានសម្រាប់លើកទឹកចិត្តការវិនិយោគដែលនឹងលើកកម្ពស់ការរីកចម្រើនក្នុងសហគមន៍ក្នុងស្រុក។

ដើម្បីប្រែក្លាយវាជាឯកសារយុទ្ធសាស្ត្រប្រើជាគោលយោបល់សម្រាប់ការចំណាយវិនិយោគជាក់លាក់ដែលនឹងត្រូវបន្តដោយរដ្ឋាភិបាលមូលដ្ឋាន ផែនការរដ្ឋាភិបាលមូលដ្ឋានត្រូវតែបានយល់ស្របពីក្រុមប្រឹក្សាអភិវឌ្ឍន៍ក្នុងស្រុក។ ផែនការអភិវឌ្ឍន៍មូលដ្ឋានមួយនិងកម្មវិធីចំណាយការវិនិយោគសហជីវិនដែលល្អគឺជាឯកសារសំខាន់សម្រាប់គោលនយោបាយជាប់លាប់និងការសម្របសម្រួលគ្រប់ថ្នាក់។ ពួកគេនឹងត្រូវការថវិកាគ្រប់គ្រាន់ដែលសក្តិសមក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍ក្នុងស្រុក។

ភាពជាប់លាប់នៃគោលនយោបាយជាតិទាំងមូលនិងការសម្របសម្រួលមានសារៈសំខាន់សម្រាប់ប្រទេសកំពុងអភិវឌ្ឍក្នុងការស្វែងរកការរីកចម្រើន ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ។ ការនេះបញ្ជាក់ឲ្យឃើញថាផែនការអភិវឌ្ឍក្នុងស្រុកគួរតែរួមបញ្ចូលទៅក្នុងផែនការក្នុងតំបន់ដែលវាជាផ្នែកមួយនៃផែនការអភិវឌ្ឍជាតិ។ នេះមិនបានមានន័យថាផែនការអភិវឌ្ឍធ្វើតាមបញ្ជាពីរដ្ឋាភិបាលកណ្តាលទៅកាន់រដ្ឋាភិបាលមូលដ្ឋានទេ។ ផ្ទុយទៅវិញ ផែនការអភិវឌ្ឍជាតិល្អមួយគឺជាការបង្ហាញឲ្យឃើញពីសេចក្តីប្រាថ្នានិងគោលដៅរួម និងពីប្រជាជនភាគច្រើនដែលរស់នៅក្នុងតំបន់នោះផ្ទាល់តែម្តង។

### ៦-១-៤ ផ្សារភ្ជាប់អ្នកពាក់ព័ន្ធក្នុងស្រុកតាមរយៈមធ្យោបាយរួមចំណែក (កសិករ អ្នកនេសាទ អ្នកលក់ដូរនៅផ្សារ ពាណិជ្ជករឬសហគ្រិនក្នុងស្រុក និងសង្គមស៊ីវិល)

ដោយសារតែការផ្តួចផ្តើមការអភិវឌ្ឍមូលដ្ឋានគឺ "មូលដ្ឋាន" វាសមហេតុផលណាស់ដែលដំណើរការបង្កើតវាត្រូវមានការចូលរួមពីអ្នករួមចំណែកមូលដ្ឋាន។ ភាពជាម្ចាស់នៃអ្នករួមចំណែកមូលដ្ឋាននៃការផ្តួចផ្តើមការអភិវឌ្ឍមូលដ្ឋាននឹងជួយធានាឲ្យមានការគាំទ្រយ៉ាងទូលំ-ទូលាយនិងមាននិរន្តរភាព។ ការប្រើប្រាស់នូវមធ្យោបាយការរួមចំណែកដែលនឹងជាប់ពាក់ព័ន្ធសមាជិកក្នុងស្រុកដូចជាសហគ្រិនក្នុងស្រុក អ្នកប្រើប្រាស់ក្នុងស្រុក អ្នកលក់ដូរនៅផ្សារ អ្នកនេសាទត្រី ក្រុមសង្គមស៊ីវិលនិងអង្គការផ្សេងៗទៀត នឹងជួយកសាងទំនុកចិត្តនិងលើកទឹកចិត្តដល់អ្នករួមចំណែកឲ្យផ្តល់ជាយោបល់និងមធ្យោបាយក្នុងការអនុវត្តផែនការអភិវឌ្ឍក្នុងស្រុកប្រកបដោយស្លេរភាព។ នៅទីបញ្ចប់ មធ្យោបាយរួមចំណែកដែលជាកំលាំងជំរុញកិច្ចសហប្រតិបត្តិការមូលដ្ឋាននិងភាពជាម្ចាស់ នឹងលើកតម្កើងសិនិទ្ធពលសង្គមដែលជួយកសាងសហគមន៍មូលដ្ឋានឲ្យល្អប្រសើរឡើង។ វាក៏ជាឧបករណ៍មួយនៃយុទ្ធសាស្ត្រក្នុងការធានាឲ្យផែនការអភិវឌ្ឍមូលដ្ឋានមានទំនាក់ទំនងជាមួយនឹងគោលដៅនិងវត្ថុបំណងជាតិនិងក្នុងតំបន់។

ឲ្យច្បាស់ជាងនេះទៅទៀត មធ្យោបាយការរួមចំណែកមួយនឹងមានសារៈប្រយោជន៍ក្នុងដំណើរការធ្វើផែនការសម្រាប់ការផ្តួចផ្តើមគំនិតនៃការអភិវឌ្ឍក្នុងស្រុកមុននឹងការប្រតិបត្តិកើតឡើង៖

១. អត្តសញ្ញាណគម្រោង

២. ដំណើរការត្រួតពិនិត្យបរិស្ថានដើម្បីពិនិត្យពីភាពអាចធ្វើបាន

៣. រៀបចំការសិក្សាពីភាពអាចធ្វើបានខាងផ្នែកបច្ចេកវិទ្យា

៤. ស្វែងរកយន្តការហិរញ្ញវត្ថុដែលសមស្របមួយ

៥. ការធ្វើបទបង្ហាញទៅកាន់ក្រុមប្រឹក្សាអភិវឌ្ឍន៍ក្នុងស្រុក

៦. ការប្រតិបត្តិនៃសេចក្តីផ្តួចផ្តើមការអភិវឌ្ឍមូលដ្ឋាន

### ៦-១-៥. ភាពជាដៃគូឯកជន-សាធារណៈសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន

ភាពជាដៃគូនៃឯកជន-សាធារណៈអាចជាយន្តការដ៏មានតម្លៃ សម្រាប់ការធ្វើសង្ហារិម-កម្មធនធានក្នុងស្រុកនិងជំនាញការ ដែលអាចប្រើប្រាស់សម្រាប់សកម្មភាពអភិវឌ្ឍន៍ក្នុងស្រុក ដែលនឹងបម្រើដល់គោលបំណងនិងអត្ថប្រយោជន៍នៃភាគីដែលជាប់ពាក់ព័ន្ធ៖ (ក) សេវាកម្មសម្រាប់សមាជិកនៃរដ្ឋាភិបាលក្នុងស្រុក និង (ខ) កិច្ចការដែលផ្តល់កម្រៃសម្រាប់ដៃគូខាងវិស័យឯកជន។ មានករណីជាច្រើននៃការរួមគ្នានៃកម្មវត្ថុដែលហាក់ដូចជាផ្ទុយពីកម្មវត្ថុរបស់ភាគីរៀងខ្លួន (គឺរដ្ឋាភិបាលនិងវិស័យឯកជន) ក្នុងផ្នែកជាច្រើននៃជីវិតសាធារណៈ ឧទាហរណ៍កន្លែងឈប់សំចតរបស់រថភ្លើង ដែលឧបត្ថម្ភនិងសាងសង់តាមរយៈគម្រោងសាងសង់-ដំណើរការ-ផ្ទេរ។

ភាពជាដៃគូដ៏មានប្រសិទ្ធភាពនៃឯកជន-សាធារណៈ (PPP) ទទួលស្គាល់ពីជំនាញការនៃភាគីនិមួយៗក្នុងការរៀបចំធ្វើសកម្មភាពសម្រាប់កិច្ចការណាមួយ។ ឧទាហរណ៍ រដ្ឋាភិបាលក្នុងស្រុកអាចផ្តល់នូវគោលនយោបាយសំខាន់ៗនិងក្របខ័ណ្ឌនិយតករនិងការធានាខាងនយោបាយនៅពេលដែលដៃគូឯកជននាំមកនូវធនធានហិរញ្ញវត្ថុនិងជំនាញការការគ្រប់គ្រងសម្រាប់គម្រោងដែលបានពិចារណារួច។

តាមការរៀបរាប់ដោយសប្បុរសជនម្នាក់៖ ការបរិច្ចាគនៃរដ្ឋាភិបាលទៅPPPអាចធ្វើឡើងក្នុងទម្រង់ជាការបណ្តាក់ទុនវិនិយោគ ដែលអាចរកបានតាមរយៈចំណូលពន្ធ ការផ្ទេរនៃទ្រព្យសកម្ម ឬការប្តេជ្ញាផ្សេងៗឬការបរិច្ចាគណាដែលគាំទ្រដល់ភាពជាដៃគូ។ រដ្ឋាភិបាលក៏

បានផ្តល់ជាការទទួលខុសត្រូវសង្គម ការយល់ដឹងបរិស្ថាន ចំណេះដឹងក្នុងស្រុក និងសមត្ថភាពក្នុងការបំលាស់ទីការគាំទ្រខាងផ្នែកនយោបាយ។ តួនាទីនៃវិស័យឯកជនក្នុងភាពជាដៃគូគឺប្រើប្រាស់ជំនាញការរបស់ខ្លួនក្នុងពាណិជ្ជកម្ម ការគ្រប់គ្រង ការប្រតិបត្តិនិងការបង្កើតថ្មីដើម្បីដំណើរការអាជីវកម្មដ៏មានប្រសិទ្ធិភាព។ ដៃគូឯកជនអាចបរិច្ចាគវិនិយោគទុនពឹងផ្អែកទៅលើទម្រង់នៃកិច្ចសន្យា។

ការខិតខំប្រឹងប្រែងបង្កើតភាពជាដៃគូដ៏មានប្រសិទ្ធិភាពជាមួយនឹងវិស័យឯកជន ក្នុងសកម្មភាពអភិវឌ្ឍក្នុងស្រុកអាចធ្វើឲ្យប្រសើរឡើងនូវដំណើរការអភិវឌ្ឍក្នុងស្រុក។ រដ្ឋាភិបាលក្នុងស្រុកគួយ៉ាងនឹងមានវត្ថុបំណងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុកដែលកំណត់ទំហំនៃភាពជាដៃគូឯកជន-សាធារណៈ។

ទោះជាយ៉ាងណាក៍ដោយក្នុងយុត្តាធិការខ្លះ មានពាណិជ្ជកម្មតូចៗជាច្រើនបានកម្រិតការធ្វើផែនការអាជីកម្មនិងជំនាញការគ្រប់គ្រង ច្រកចូលទីផ្សារនិងចំណេះដឹងផ្នែកទីផ្សារមានកំរិតទាប និងស្ទើតែទាំងអស់គ្មានដើមទុនសម្រាប់វិនិយោគ។ ប្រហែលជាមានអ្នកមានចំណាប់អារម្មណ៍ឬក៏អ្នកវិនិយោគ ប៉ុន្តែពួកគេខ្វះបទពិសោធន៍និងធនធាន។ ក្នុងស្ថានភាពនេះ ប្រហែលជាគ្មានគ្រឿងលើកទឹកចិត្តណាដើម្បីចាប់ឱកាសធ្វើអជីវកម្ម។ យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុកមួយដែលរួមបញ្ចូលគ្នាធនធាននៃរដ្ឋាភិបាលនិងអ្នកជំនួញឯកជនប្រហែលជាអាចនាំមកនូវធនធានទាំងក្នុងនិងក្រៅសហគមន៍ដើម្បីជំរុញឲ្យមានការរីកចម្រើននិងអភិវឌ្ឍន៍ក្នុងស្រុក។

ស្ថានភាពផ្ទុយមួយតាមរយៈការប្រមើលមើលឃើញនោះគឺរដ្ឋបាលមូលដ្ឋានដែលខ្វះជំនាញការនិងធនធានសម្រាប់គម្រោងឬសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុកមួយ ប៉ុន្តែមានក្រុមសហគ្រាសឯកជនក្នុងស្រុកដែលស្ម័គ្រចិត្តវិនិយោគក្នុងសហគមន៍ក្នុងស្រុក។ តាមរយៈភាពជាដៃគូនៃឯកជន-សាធារណៈ សហគមន៍ក្នុងស្រុកប្រហែលជាអាចទាញយកផលប្រយោជន៍ពីការរួមបញ្ចូលគ្នានូវជំនាញការនិងធនធាននៃរដ្ឋាភិបាលក្នុងស្រុកនិងវិស័យឯកជនក្នុងការអភិវឌ្ឍនិងប្រតិបត្តិនូវការផ្តួចផ្តើមគំនិតអភិវឌ្ឍក្នុងស្រុកនេះ។

មធ្យោបាយភាពជាដៃគូឯកជន-សាធារណៈអាចសម្រេចបានក្នុងយុត្តធិការជាច្រើន។ វាត្រូវបានគេចង្អុលបង្ហាញថាមានសមាគមន៍ពាណិជ្ជកម្មឬក្រុមជំនួញ ការជួញដូរឬ

ឧស្សាហកម្មជាច្រើនក្នុងតំបន់ ជាពិសេសក្នុងតំបន់ទីក្រុងដែលមានការលូតលាស់រហ័ស។ រដ្ឋាភិបាលក្នុងស្រុកអាចប្រើប្រាស់សមាគមន៍ពាណិជ្ជកម្មទាំងនោះឲ្យជួយកំណត់ពីទំហំនិងវិសាលភាពនៃការទទួលខុសត្រូវ និងការប្តេជ្ញាចិត្តនៃដៃគូដែលចុះកិច្ចសន្យាដែលមានរដ្ឋាភិបាលក្នុងស្រុកនិងវិស័យឯកជន អំពីធម្មជាតិនិងកម្មវត្ថុនៃសេចក្តីផ្តួចផ្តើមនៃរដ្ឋាភិបាលមូលដ្ឋាន ភាពអាចសម្រេចបាននៃការផ្តួចផ្តើមដែលបានឆ្លងកាត់ការពិចារណា និងសេចក្តីលំអិតពីភាពជាដៃគូយូរអង្វែង។

## ៦-២ គ្រប់គ្រងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុកនិងការជំរុញការវិនិយោគ ក្នុងប្រទេសទាំងប្រាំនៅអាស៊ីអាគ្នេយ៍

### ៦-២-១ គម្រោងសមុទ្រវិប្បកម្ម Tubigon ៖ គ្រប់គ្រងសេដ្ឋកិច្ចនិងបរិស្ថានក្នុងស្រុក

#### ក- ការពណ៌នានិងសនិទានភាពនៃការអនុវត្តល្អ

សាលាក្រុងនៃ Tubigon (ដែលមានន័យថា "ទឹកន្លែងសម្បូរទឹក") ស្ថិតនៅប៉ែកពាយ័ព្យនៃខេត្ត Bohol ក្នុងតំបន់Visayasកណ្តាលនៃប្រទេសហ្វីលីពីន។ តំបន់នេះមានប្រជាជនចំនួន ៤៤,៤៣៤នាក់ (ជំរឿនឆ្នាំ២០០៧) និងមានផ្ទៃដីសរុប៨១.៨៦៩៦គីឡូម៉ែត្រការ៉េ។ ដោយសារតែទីកន្លែងនៃយុទ្ធសាស្រ្តរបស់តំបន់នេះ សាលាក្រុងមានសក្តានុពលជាមជ្ឈមណ្ឌលសេដ្ឋកិច្ចមួយដោយសារកំពង់ផែដ៏មមាញឹកផ្សារភ្ជាប់ទៅនឹងទីក្រុងសេបូCebu និងខេត្តបូហូលBohol ដែលមានការរីកចម្រើនខ្ពស់។ ក៏មានសក្តានុពលដើម្បីអភិវឌ្ឍជីវភាពធនធានឆ្នេរដែលមាននិរន្តរភាពនិងកម្មវិធីសហគ្រាសធនតូចដោយសារសណ្ឋានឆ្នេរដ៏ធំរបស់ខ្លួនផងដែរ។

ទោះជាយ៉ាងណា ទីក្រុងនេះនៅតែជាក្រុងលំដាប់ថ្នាក់ទីបួននៅឡើយដោយសារតែគ្រួសារមួយភាគធំគឺពឹងផ្អែកទៅលើកសិកម្មនិងនេសាទសម្រាប់ទ្រទ្រង់ជីវភាព។ ប៉ុន្តែផលិតភាពវិស័យកសិកម្មនិងនេសាទត្រូវបានចាត់ទុកថានៅមានកម្រិតទាបនៅឡើយដោយសារឥទ្ធិពលពីកត្តាមួយចំនួន។ កត្តាមួយគឺ សម្ពាធប្រជាជននិងភាពខ្វះខាតឱកាសការងារខាងផ្នែកមិនមែនកសិកម្មនាំឲ្យមានការនេសាទលើសកម្រិត មានលក្ខណ:បំផ្លិចបំផ្លាញនិងគ្មាននិរន្តរភាព។ កត្តាទីពីរគឺ ការបំពុលដោយសកម្មភាពរកប្រាក់ចំណេញដែលមានមូលដ្ឋាន

លើដីគោកបានចាប់ផ្តើមមានផលប៉ះពាល់ទៅលើធនធានឆ្នេរ។ កត្តាចុងក្រោយ ភាពខ្វះខាតនៃគ្រោងបទបញ្ញត្តិក្នុងការដោះស្រាយបញ្ហាការទាញយកធនធានដោយចំហដែលបានធ្វើឲ្យបាត់បង់ជម្រកសត្វតាមឆ្នេរដែលមានសារៈសំខាន់ណាស់សម្រាប់ផលិតផលត្រីឲ្យមាននិរន្តរភាព។

អវត្តមាននៃទិសដៅគោលនយោបាយដែលមានទំនាក់ទំនងនឹងគ្នានិងច្បាស់លាស់ដូចជាភាពខ្វះខាតនៃការយល់ដឹងក្នុងចំណោមសមាជិកសហគមន៍ ភាពមិនអាចរកបាននៃឱកាសការងារនិងសកម្មភាពរកប្រាក់ចំណេញផ្សេងៗ បាននាំឲ្យបរិស្ថានធនធានឆ្នេរមានលក្ខណៈមិនមានស្ថេរភាពជាខ្លាំងដែលហាក់ដូចជារុញច្រានសហគមន៍តាមឆ្នេរឲ្យធ្លាក់ចូលក្នុងភាពក្រីក្រទៅៗ ក្នុងរយៈពេលមធ្យមនិងវែងខាងមុខ។ ហេតុដូច្នេះមានតម្រូវការចាំបាច់មួយក្នុងការឆ្លើយតបទៅនឹងស្ថានភាពទាំងនេះដោយបង្កើតឲ្យមានគម្រូមួយដែលផ្សារភ្ជាប់សមាសភាពសំខាន់ៗទាំងអស់ចូលគ្នាទៅជាអន្តរាគមន៍ដែលពាក់ព័ន្ធនិងមាននិរន្តរភាពតាំងពីការគ្រប់គ្រងធនធានឆ្នេររហូតដល់ការរកប្រាក់ចំណេញឲ្យមាននិរន្តរភាព។

ដើម្បីឆ្លោះទៅកាន់អ្វីដែលបានលើកឡើងខាងលើ គម្រោងនេះត្រូវបានបង្កើតឡើងដោយធាតុសំខាន់ៗបី គឺការជំរុញឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក ការគ្រប់គ្រងនិងការពារបរិស្ថាន និងការបង្កើតឱកាសការងារនិងការចិញ្ចឹមជីវិត។ Tubigonត្រូវបានជ្រើសរើសដោយសារតែតំបន់នេះមានប្រព័ន្ធអេកូឡូស៊ីមួយដែលមានសក្តានុពលឲ្យផលច្រើនដែលទាមទារឲ្យមានការធ្វើសមាហរណកម្មក្នុងការឆ្លើយតបទៅកាន់តម្រូវការផលិតកម្មភ្លាមៗ ប៉ុន្តែក៏ទ្រទ្រង់វាសម្រាប់ការរីកចម្រើនសេដ្ឋកិច្ចក្នុងរយៈពេលវែងផងដែរ។

**ខ- គម្រោងសមុទ្រវិប្បកម្មៈ គម្រូម៉ូដែលនៃការគ្រប់គ្រងសេដ្ឋកិច្ចនិងបរិស្ថាន**

គម្រោងសមុទ្រវប្បកម្មដែលចាប់បដិសន្ធិជាមួយនឹងការគាំទ្រនិងការទំនុកបម្រុងនៃមូលនិធិអភិវឌ្ឍន៍រដ្ឋាភិបាលក្នុងស្រុក (LOGODEF) និង Konrad-Adenauer-Stiftung (KAS) ត្រូវបានបង្កើតឡើងក្នុងបរិបទដែលមានទ្រង់ទ្រាយធំសម្រាប់ការគ្រប់គ្រងធនធានឆ្នេរ(CRM) ក្នុងក្រុង។ CRM គឺជាដំណើរការយ៉ាងទូលាយមួយដែលត្រួតពិនិត្យទៅលើរូបសាស្ត្រនិងសង្គមសាស្ត្រសេដ្ឋកិច្ច និងភាពស្វាហាប់នៃវប្បធម៌ព្រមជាមួយនយោបាយនៃបរិស្ថានឆ្នេរ។

ហេតុនេះ លទ្ធផលរបស់វាគឺជាផែនការដែលរួមបញ្ចូលនិងមានការសម្របសម្រួលគ្នាដើម្បីគ្រប់គ្រងនិងទ្រទ្រង់ធនធានឆ្នេរឲ្យត្រឹមត្រូវនាំឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុកមួយ។ គោលការណ៍CRMទាមទារឲ្យគម្រោងនេះអនុវត្តសកម្មភាពដំបូងដើម្បីធានាថាអ្នកចូលរួមនិងសមាជិកផ្សេងទៀតនៃសមាគមន៍យល់អំពីផលប្រយោជន៍រយៈពេលខ្លីនិងវែងដែលពួកគេអាចទាញយកបាន។ សកម្មភាពទាំងនេះតិចឬច្រើនជាធាតុទីមួយនៃគម្រោងការការពារនិងការគ្រប់គ្រងបរិស្ថាន។ សកម្មភាពមុនគេនៃសកម្មភាពទាំងនេះគឺរៀបចំសេចក្តីពណ៌នាត្រួសៗនៃក្រុងនេះនិងភូមិគោលដៅដែលទាមទារឲ្យមានការប្រមូលទិន្នន័យបឋមនិងទិន្នន័យទីពីរ រួមបញ្ចូលទាំងទិន្នន័យរដ្ឋាភិបាលដែលមានស្រាប់អំពីរបាយការណ៍បរិស្ថាន ឯកសារស្របច្បាប់ ផែនទី រូបភាពផ្កាយរណប និងរូបថតជាដើម។ ជាលទ្ធផល ការវិភាគបច្ចេកទេសត្រូវបានធ្វើឡើងក្នុងតំបន់អេកូឡូស៊ី សេចក្តីពណ៌នាត្រួសៗនៃសង្គម។

ដើម្បីជួយដល់ការប្រមូលទិន្នន័យលំដាប់ទីពីរនេះ ការវាយតម្លៃធនធានឆ្នេរដែលមានការចូលរួមពី(PCRA)ត្រូវបានធ្វើឡើង។ PCRA មានសារៈសំខាន់ពីព្រោះវាបានអនុញ្ញាតឲ្យអ្នកចាប់ត្រីនិងអ្នករួមចំណែកឯទៀតក្នុងសហគមន៍ចូលរួមយ៉ាងសកម្មក្នុងឋានៈជាអ្នកប្រើប្រាស់ធនធាននិងរួមបញ្ចូលចំណេះដឹងក្នុងស្រុកនិងចំណេះដឹងពីអតីតកាលជាមួយនិងជំនាញការនៃអ្នកធ្វើផែនការនិងអ្នកជំនាញនិរន្តរភាពនៃបរិស្ថាន។ ទិន្នន័យបឋមត្រូវបានប្រមូលតាមរយៈការធ្វើបទសម្ភាសន៍ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងសារពើភ័ណ្ឌនៃធនធានឆ្នេរដែលមានដូចជាផ្កាថ្ម ដើមកោងកាង ។ល។ ជាលទ្ធផលគឺមានការយល់ដឹងស៊ីជម្រៅជាងមុនថាតើសហគមន៍អាចទទួលផលប្រយោជន៍ដូចម្តេច សហគមន៍ដែលចូលរួមមានការយល់ដឹងកាន់តែច្បាស់អំពីបរិស្ថានរបស់ពួកគេ ស្ថានភាពបច្ចុប្បន្ននៃធនធានឆ្នេរ និងផ្តល់ឲ្យពួកគេនូវជម្រើសផ្សេងៗក្នុងការការពារធនធានទាំងនោះសម្រាប់អនាគត។ សំខាន់ជាងនេះទៅទៀត វាបានផ្តល់ឲ្យពួកគេនូវភាពជាម្ចាស់នៃផែនការនេះ។ ជាចុងក្រោយ លទ្ធផលចម្បងនៃការប្រមូលទិន្នន័យទាំងនេះនិងសកម្មភាពត្រឹមត្រូវគឺការបង្កើតឲ្យមាននូវផែនទីធនធានក្រុងនិងសហគមន៍ដែលកំណត់នូវបញ្ហាបច្ចុប្បន្ននិងក្នុងសហគមន៍និងអន្តរាគមន៍ដ៏សមរម្យសម្រាប់អនុវត្តដោយអ្នករួមចំណែកដើម្បីដោះស្រាយបញ្ហាទាំងនោះ។

ស្របគ្នាជាមួយPCRA សកម្មភាពមួយចំនួនដូចជាការរៀបចំសហាគមន៍ ការប្រឹក្សាយោបល់ និងការផ្សព្វផ្សាយជាសាធារណៈត្រូវបានចាប់ផ្តើម។ លទ្ធផលនៃសកម្មភាពទាំងនេះបានផ្សព្វផ្សាយតាមរយៈយុទ្ធនាការការអប់រំពត៌មាន(IEC)ជាប្រព័ន្ធដែលជាប់ពាក់ព័ន្ធរដ្ឋាភិបាលក្រុង អង្គការក្រៅរដ្ឋាភិបាលនិង អ្នកចូលរួមPCRAក្នុងការធ្វើឲ្យទូលាយឡើយនូវការយល់ដឹងពីសាធារណៈ។

គម្រោងនេះបន្តដោយផ្តោតសំខាន់ទៅលើការប្រតិបត្តិសមាសធាតុពីរផ្សេងទៀតគឺការចិញ្ចឹមជីវិតនិងការអភិវឌ្ឍមូលដ្ឋាន។ សមាសធាតុការចិញ្ចឹមជីវិតជាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍសមុទ្រវប្បកម្មដែលចាត់ទុកជាការផ្តួចផ្តើមការកសាងសមត្ថភាព។ ផ្នែកខាងយុទ្ធសាស្ត្រនៃការផ្តួចផ្តើមនេះមានដូចតទៅ៖ ក) កសាងនិងកែលម្អសមត្ថភាពស្ថាប័ននៃរដ្ឋាភិបាលក្រុងនៃ Tubigon ខ) លើកកម្ពស់ការយល់ដឹងពីការគ្រប់គ្រងធនធានឆ្នេរ (CRM) ត្រឹមថ្នាក់សហាគមន៍ និង(គ) បង្កើតគម្រោងធ្វើជលវប្បកម្មក្នុងសមុទ្រសម្រាប់សមាជិកផ្សេងៗនៃសមាគមន៍អ្នកនេសាទធ្វើជាធនធានមួយសម្រាប់ចិញ្ចឹមជីវិត។ សមាសធាតុបន្ទាប់បន្សំនៃសមុទ្រវប្បកម្មនៃគម្រោងនេះមាន ក) ការចញ្ចឹមងាវសមុទ្រ ខ) ការចិញ្ចឹមត្រីកញ្ចុះ ត្រីសមុទ្រ ជាលក្ខណៈក្នុងបែរ គ)ការធ្វើវប្បកម្មក្តាមក្នុង និង ឃ)ការចិញ្ចឹមបង្កងក្នុងបែរ។ ទាំងនេះមិនត្រូវបានគេចាត់ទុកជាការឈ្លានពាននៃធនធានឆ្នេរទេហើយជាការពិតទៅវាផ្តលនូវការគាំទ្រនៃលទ្ធភាពចញ្ចឹមជីវិតបែបថ្មី។ ការចិញ្ចឹមងាវសមុទ្រនិងត្រីចំពុះទាមិនបានទាមទារឲ្យមានការផ្តល់ចំណីបន្ថែមទេ។ ការចញ្ចឹមក្នុងទ្រុងគឺជាជម្រើសល្អមួយសម្រាប់ជលវប្បកម្មដែលមានមូលដ្ឋានលើដីនិងមិនមានការពាក់ព័ន្ធទៅនឹងការកាប់បំផ្លាញនៃដើមកោងកាង។ ទីបញ្ចប់ក្តាមក្នុងតំបន់ព្រៃកោងកាងរួមបញ្ចូលរុក្ខសាស្ត្រនិងការប្រើប្រាស់ជលវប្បកម្មនៃប្រព័ន្ធអេកូឡូស៊ីនៃព្រៃកោងកាង។ បច្ចុប្បន្ននេះ គម្រោងនេះផ្តោតសំខាន់ទៅលើការចញ្ចឹមក្នុងទ្រុងនៃត្រីកញ្ចុះនិងការចញ្ចឹមត្រីចំពុះទាជាជម្រើសផ្សេងសម្រាប់ងាវសមុទ្រនិងបង្កងសមុទ្រ។ ជាមួយគ្នានេះដែល ការចញ្ចឹមសត្វក្តាមក្នុងតំបន់ព្រៃកោងកាងត្រូវបានបន្ត។

ជាសង្ខេប គម្រោងនេះត្រូវបានបង្កើតឡើងជាមួយនឹងតុល្យភាពនិងនិរន្តរភាពដែលជាព្រំដែនដ៏សំខាន់។ ធាតុសំខាន់ៗរបស់វាមានដូចខាងក្រោម៖

### ១. ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់

- បង្កើនសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកក្នុងចំណោមអ្នកលក់ត្រី អ្នកផ្គត់ផ្គង់កូនត្រី និងអាហារត្រី
- ការរីកចំរើននិងការធ្វើតាមនៃគំនិតផ្តួចផ្តើមស្រដៀងគ្នាទៅលើសហាគមន៍ឆ្នេរដទៃនិងក្រុងជិតខាង
- ភាពអាចចូលទៅកាន់ផ្សារអាហារសមុទ្រក្នុងស្រុកនិងអន្តរជាតិ។

**២. ការបង្កើតការចិញ្ចឹមជីវិតនិងការងារ**

- ការបែងចែកនៃសម្បទានជាប្រាក់និងឥណទានដើម្បី កំរិត អ្នកនេសាទ
- ឱកាសការងារក្នុងគម្រោងការិយាល័យ
- ការទាមទារកំលាំងពលកម្មក្នុងស្រុកលើសមាសភាពនៃគម្រោងជាក់លាក់

**៤. កាគ្រប់គ្រងនិងការពារបរិស្ថាន**

- ការបង្កើតគោលនយោបាយលើការការពារនិងគ្រប់គ្រងនៃធនធានឆ្នេរសមុទ្រ
- ការអនុម័តក្រមបរិស្ថានក្នុងស្រុកមួយ
- ការបំពេញនៃការវាយតម្លៃធនធានឆ្នេរជាលក្ខណៈចូលរួម
- អត្តសញ្ញាណកម្មនៃតំបន់ឆ្នេរដែលត្រូវការពារ
- ការបង្កើតនៃគ្រោងបទបញ្ញត្តិបរិស្ថានក្រុង
- ការអភិវឌ្ឍនៃផែនការគ្រប់គ្រងធនធានឆ្នេរ

**គ-សម្រេចនូវការអភិវឌ្ឍក្នុងស្រុកតាមរយៈការគ្រប់គ្រងនិងការការពារបរិស្ថាន**

ការផ្លាស់ប្តូរកម្តៅលើភពផែនដីដែលយើងទាំងអស់គ្នាកំពុងជួបប្រទះសព្វថ្ងៃគឺជាលទ្ធផលមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចដែលមិនបានគិតគូរទៅលើផលប៉ះពាល់ដែលសកម្មភាពសេដ្ឋកិច្ចមានទៅលើបរិស្ថាន។ ប៉ុន្តែការអភិវឌ្ឍសេដ្ឋកិច្ចអាចកើតមានដែលឬទេដោយគ្មានការប៉ះពាល់ខ្លាំងទៅលើបរិស្ថាន? គម្រោងសមុទ្រវប្បកម្មនៃTugigon បានបញ្ជាក់ថាមានការទំនាក់ទំនងយ៉ាងរឹងមាំរវាងការអភិវឌ្ឍមូលដ្ឋាននិងការការពារនិងការគ្រប់គ្រងបរិស្ថាន។

អាចនិយាយបានថាគម្រោងសមុទ្រវប្បកម្មបានជួយគូរឲ្យកត់សម្គាល់នូវសេដ្ឋកិច្ច Tubigon ក្នុង កំឡុងទស្សវត្សចុងក្រោយនេះដូចខាងក្រោម៖

- ចំណូលនៃអ្នកនេសាទមួយចំនួនមានប្រភពមកពីច្រើនសណ្ឋានជាងមុន គឺថាសកម្មភាពនេសាទនិងមិនមែននេសាទជាប្រភពចំណូល។ ការនេះបានផ្តល់ចំណូលបន្ថែមសម្រាប់អ្នកនេសាទ ធ្វើឲ្យពួកគេមានលទ្ធភាពសង់ផ្ទះពីស៊ីម៉ង់។ គម្រោងជលវប្បកម្មនៅTubigon នាំមកនូវចំណូលបន្ថែមចំនួន P2លានប៉េសូជារៀងរាល់ឆ្នាំ។ ធនធានផ្សេងនៃចំណូលដែលត្រូវបានបង្កើតត្រូវបានផ្សារភ្ជាប់ដោយផ្ទាល់ទៅការខិតខំប្រឹងប្រែងរបស់សហគមន៍ក្នុងការការពារធនធានឆ្នេរ។
- ការរំពឹងទុកថានឹងមានការធ្លាក់ចុះនៃផលិតផលត្រីមកចំនួនតិចជាងមួយលានតោនមុនដំណាច់ឆ្នាំ២០១០ឬក៏ត្រឹម១០.៥គីឡូក្រាមសម្រាប់សមាជិកម្នាក់ៗនៃប្រជាជនទាំងអស់មិនបានក្លាយជាការពិតឡើយ ដោយសារតែការអន្តរាគមន៍នៃគម្រោងនេះតាមរយៈសមាសភាពបន្ទាប់បន្សំផ្សេងៗ បានជួយធ្វើឲ្យល្អប្រសើរឡើងនូវផលិតផលត្រីគួរឲ្យកត់សម្គាល់។ ជាក់ស្តែង ផលិតផលត្រីនៅចុងឆ្នាំ២០០៩ឬ៨ឆ្នាំក្រោយគម្រោង មានចំនួនសរុប១.៨លានតោនក្នុងមួយខែ ១៣ឬ២១.៦លានតោនក្នុងមួយឆ្នាំ។ ជាមូលដ្ឋានក្នុងម្នាក់ វាមានន័យថា៨៨គីឡូក្រាមក្នុងមួយខែ។ បុននីតិសម្បទានៃធនធានឆ្នេរដូចជាព្រៃកោងកាងស្មៅសមុទ្រ និងថ្មប៉ប្រះទឹកនាំទៅរកផលិតភាពសេដ្ឋកិច្ចប្រកបដោយនិរន្តភាពក្នុងតំបន់ឆ្នេរ។ ជាងនេះទៅទៀត គ្រោងបទបញ្ញត្តិនិងយន្តការ

ដែលបានរឹតបន្តឹងនាំទៅរកការកាត់បន្ថយក្នុងការនេសាទនៅក្នុងទឹកដែលត្រូវបាននេសាទលើសកំណត់ និងការកែលម្អការគ្រប់គ្រងនៃតំបន់អភិរក្ស។ ដូចគ្នានេះដែរ មានការថយចុះយ៉ាងគំហក់នូវការអនុវត្តការនេសាទដោយខុសច្បាប់ និងប្រជាជនបានប្តូរទៅការនេសាទតាមបែបនិរន្តរភាព ស្របពេលជាមួយគ្នាក្លាយទៅជាសមាជិកក្រុម bantaydagat។ ចុងក្រោយគឺសមត្ថភាពរដ្ឋាភិបាលត្រូវបានពង្រឹងដែលអនុញ្ញាត្តិឲ្យវាអាចផ្តល់នូវសេវាកម្មនិងការ ហ្វឹកហាត់ អំពីCRM ដ៏ធំទូលាយសម្រាប់ភូមិផ្សេងៗគ្នា។

- ការបែងចែកប្រាក់ចំណូលនៃសាលាក្រុងនៃTubigonបានលោតពីថ្នាក់ទី៥ក្នុងឆ្នាំ១៩៩៧ទៅថ្នាក់ទី១ក្នុងឆ្នាំ២០០៩ ជាមួយនឹងការកើនឡើងជាប្រចាំឆ្នាំពី PhP៣២.៥លានប៉េសូក្នុងឆ្នាំ១០០៧ ទៅ PhP ៩៣.៣លានប៉េសូក្នុងឆ្នាំ២០០៩។ ការកើនឡើងខ្លាំងយ៉ាងនេះក្នុងចំណូលរបស់ក្រុងគឺជាសញ្ញាមួយប្រាប់ថាសកម្មភាពសេដ្ឋកិច្ចមានការកើនឡើងយ៉ាងខ្លាំង។

- គម្រោងនេះក្លាយជាកាតាលីករក្នុងការរីកចម្រើននៃសកម្មភាពពាណិជ្ជកម្មនិងជំនួញក្នុងតំបន់ក្រុងដែលសម្រួលដោយភាពងាយស្រួលទៅកាន់ទីក្រុងសេបូCebu។ ផលិតផលពីការចិញ្ចឹមត្រីនិងការនេសាទត្រីត្រូវបានជួញដូរក្នុងមជ្ឈមណ្ឌលសំខាន់ៗ ដូចជាមជ្ឈមណ្ឌលជំនួញ Tubigon សម្រាប់ធ្វើការចែងចាយទៅកាន់បណ្តាក្រុងជិត ខាងនិងទៅកាន់ទីក្រុងសេបូ។ ការបើកមជ្ឈមណ្ឌលជំនួញTubigonបានធ្វើឲ្យមានការ កើនឡើងនូវសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់នោះ។ ដូចគ្នាដែរទំនិញពាណិជ្ជកម្មនិង ផលិតផលផ្នែករឹងត្រូវបានដឹកជញ្ជូនពីទីក្រុងសេបូសម្រាប់ការចែកចាយទៅកាន់តំបន់ផ្សេងៗនៃខេត្ត។

វាត្រូវបានគូសបញ្ជាក់ថាសមិទ្ធផលដែលបានលើកឡើងខាងលើនៃគម្រោងនេះ គឺភាគច្រើនមកពីសង្ហារិមកម្មនិងការចូលរួមយ៉ាងសកម្មនៃសមាជិកនៃក្រុមគ្រួសារ ក្នុង

សកម្មភាពCRM ។ អ្នកនេសាទបានក្លាយទៅជាមានជំនឿចិត្តជាងមុនក្នុងការបង្ហាញពីតម្រូវការនិងផលប្រយោជន៍របស់ពួកគេនៅចំពោះមុខអ្នករួមចំណែកដទៃទៀត។ នេះត្រូវបានបញ្ជាក់តាមរយៈការចូលរួមចំណែកក្នុងFARMC ដែលក្នុងនោះ១១នៃ១៧កៅអីតំណាងដោយអ្នកនេសាទ។ ជាចុងក្រោយការចូលរួមដោយសកម្មនៃអ្នករួមចំណែក ដទៃទៀតដូចជាមេដឹកនាំនយោបាយនៃក្រុងនិងខេត្ត អង្គការក្រៅរដ្ឋាភិបាល សហាគមន៍អ្នកផ្តល់អំណោយដូច LOGODEF/KAS សហាគមន៍អ៊ឺរ៉ុប ។ល។ និងការគាំទ្រយ៉ាងរឹងមាំនៃរដ្ឋាភិបាលជាតិជាពិសេសការិយាល័យនៃធនធានត្រីនិងទឹក។

### ឃ-ឱកាសនិងការលំបាក

គម្រោងសមុទ្រវប្បកម្មបានបង្ហាញថាការសហការ(រួមបញ្ចូលការខិតខំប្រឹងប្រែងល្អជាងបំបែក) រវាងការការពារនិងការគ្រប់គ្រងបរិស្ថាននិងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងរយៈពេលវែងនៃសហាគមន៍អាចជាដំណោះស្រាយដែលអាចសម្រេចបានដើម្បីដោះស្រាយភាពក្រីក្រ។ ហើយវាក៏ជាការបង្ហាញនៃភាពសំខាន់នៃដំណើរការរួមចំណែកក្នុងការសម្រេចបាននូវវត្ថុបំណងក្នុងរយៈវែង។ ចុងបញ្ចប់ តួនាទីដ៏សំខាន់នៃរដ្ឋាភិបាលក្នុងស្រុកក្នុងការសម្របសម្រួលការរៀបចំនិងការប្រតិបត្តិយ៉ាងយកចិត្តទុកដាក់នៃគម្រោងនិងការបែងចែកនៃជំនួយបច្ចេកទេសដោយរដ្ឋាភិបាលក្នុងស្រុកនិងអ្នកបរិច្ចាគ បានជួយឲ្យគម្រោងនេះទទួលបានភាពជោគជ័យ។

ទោះជាយ៉ាងណាក៏ដោយ មានការព្រួយបារម្ភអំពីនិរន្តរភាពនៃគម្រោងនេះ។ សំខាន់បំផុតនោះគឺឆន្ទៈនយោបាយនៃភាពជាអ្នកដឹកនាំនៃរដ្ឋាភិបាលមូលដ្ឋានដែលថាការគ្រប់គ្រងធនធានឆ្នេរនឹងមិនមែនបណ្តោះអាសន្នប៉ុន្តែគឺគោលនយោបាយរយៈពេលវែងដោយឥតគិតអំពីភាពជាអ្នកដឹកនាំនយោបាយនៃក្រុង។ ជាងនេះទៅទៀត វាមានសារៈសំខាន់ដែលផលប្រយោជន៍របស់អ្នករួមចំណែក ជាពិសេសអ្នកនេសាទនិងអ្នកចិញ្ចឹមត្រីត្រូវបានរក្សាដើម្បីធានាពីការចូលរួមនិងគាំទ្រយ៉ាងសកម្មនិងឥតឈប់ឈរ។

**កម្រងសំនួរណែនាំសម្រាប់អ្នកហាត់រៀន/អ្នកចូលរួម៖**

ក. តើបញ្ហាក្នុងស្រុកអ្វីដែលគម្រោងសមុទ្រវប្បកម្មបានខិតខំដោះស្រាយ?

ខ. តើវត្ថុបំណងនៃគម្រោងនេះមានអ្វីខ្លះ? តើធាតុសំខាន់ៗរបស់វាមានអ្វីខ្លះ?

គ. តើការប្រតិបត្តិនៃគម្រោងនេះប្រព្រឹត្តិទៅយ៉ាងដូចម្តេច?

ឃ. តើលទ្ធផលនៃគម្រោងនេះជាអ្វី?

ង. តើមានធាតុណាដែលមានលក្ខណៈបង្កើតថ្មីដែរឬទេ? ប្រសិនបើមាន ចូរបកស្រាយ។

ច. តើការលំបាកអ្វីនៃគម្រោងនេះដែលអ្នកអាចកំណត់បាន? បកស្រាយថាតើវាត្រូវបានដោះស្រាយយ៉ាងដូចម្តេចក្នុងគម្រោង។

ជ. តើមេរៀនសំខាន់អ្វីដែលអ្នកអាចទទួលបានពីការសិក្សានេះដែលនឹងមានប្រយោជន៍សម្រាប់គម្រោងដែលស្រដៀងគ្នានេះក្នុងពេលអនាគត?

### ៦-២-២ រៀបចំអ្នកលក់ដូរតាមដងផ្លូវនៅក្នុងទីក្រុងសូឡូ - យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុង

### ក- ការពណ៌នានិងសនិទានភាពនៃការអនុវត្តល្អ

Soloគឺជាទីក្រុងធំមួយនិងមានប្រជាជនច្រើនបំផុតក្នុងចំណោមខេត្តនៃចាវាJava កណ្តាល។ ឈ្មោះម្យ៉ាងទៀតសម្រាប់ទីក្រុងនេះគឺ Surakarta។ ក្នុងប្រទេសឥណ្ឌូនេស៊ី សូឡូគឺជាទីក្រុងធំបំផុតទី១០។ វាមានឈ្មោះល្បីជាមជ្ឈមណ្ឌលវប្បធម៌នៃJava ដោយវាធ្លាប់ជាមជ្ឈមណ្ឌលមួយសម្រាប់បង្កើតប្រពៃណីនិងនយោបាយរបស់Java ។ ភាពរុងរឿងនៃតំបន់នេះចាប់តាំងពីសតវត្សទី១៩បានផ្តល់បរិស្ថានដ៏ល្អដែលជំរុញឲ្យមានការរីកចម្រើននៃអក្សរសាស្ត្រ វប្បធម៌ សិល្បៈចម្អិនម្ហូបអាហារ រចនាបថ ស្ថាបត្យកម្ម និងការសំដែងរបៀបផ្សេងទៀតនៃវប្បធម៌និងសិល្បៈរបស់Java ។ សូឡូតំណាងឲ្យចរិកលក្ខណៈនៃទីក្រុងដែលល្បីដោយជំនាន់បួន គឺបុរាណ អាណានិគមន៍ ទំនើប និងបច្ចុប្បន្ននេះត្រៀមខ្លួនដើម្បីក្លាយជាទីក្រុងមួយសំខាន់សម្រាប់យុគសម័យអន្តរជាតិ។ ចរឹកលក្ខណៈពីរដំបូងគឺជាអត្តសញ្ញាណនៃសូឡូដែលជាទីក្រុងមួយ រីឯពីរទៀតគឺជាឥទ្ធិពលនៃសកលលោកនិយមដែលមានលើគ្រប់ទីក្រុងទាំងអស់ក្នុងពិភពលោក។

ដូចទីក្រុងដទៃទៀតនៅប្រទេសឥណ្ឌូនេស៊ី ទីក្រុងសូរាកាតា ឬ សូឡូ ជួបប្រទះនឹងបញ្ហាទីក្រុងដែលក្នុងនោះមានដូចជា អត្រាក្រីក្រនៅទីក្រុងមានខ្ពស់ សំណង់អនាធិបតេយ្យតំបន់គ្មានសណ្តាប់ធ្នាប់ ការប្រែក្លាយទីធ្លាសាធារណៈទៅជាឯកជន និងការគ្រប់គ្រងគ្មានគុណភាពនៃវិស័យក្រៅផ្លូវការរួមទាំងអ្នកលក់ដូរតាមផ្លូវ។ ការកើនឡើងយ៉ាងឆាប់រហ័សនៃអ្នកលក់ដូរតាមដងផ្លូវក្នុងទីក្រុងនានានៅប្រទេសឥណ្ឌូនេស៊ីចាប់ផ្តើមពីឆ្នាំ១៩៨៨ នៅពេលដែលជំនាន់ប្រធានាធិបតីSoehartoបានអនុញ្ញាតចលនាកំណែទម្រង់។ ម្យ៉ាងទៀតគឺវិបត្តិសេដ្ឋកិច្ចដែលលេបត្របាក់ភូមិភាគអាស៊ីក្នុងឆ្នាំ១៩៩៧-១៩៩៨ បាននាំទៅរកការកើនឡើងនៃអត្រានិកម្មភាព ដែលជំរុញឲ្យផ្នែកខ្លះនៃសង្គមប្រែក្លាយខ្លួនជាវិស័យឯកជនដើម្បីអាចរស់រានបាន។ វិស័យដែលរីកចម្រើនខ្លាំងបំផុតក្នុងចំណោមវិស័យទាំងនោះបន្ទាប់ពីឆ្នាំ១៩៩៨គឺវិស័យអ្នកលក់ដូរតាមដងផ្លូវ។

អ្នកលក់ដូរតាមដងផ្លូវបានជាបញ្ហាមួយសម្រាប់ទីក្រុងសូឡូយូរមកហើយ ដោយមូលហេតុមួយចំនួន ដែលក្នុងនោះមានដូចជាៈ

- អ្នកលក់ដូរតាមដងផ្លូវបានកាន់កាប់ទីធ្លាសាធារណៈជាច្រើន ដូចជាផ្លូវដើរ សួន ចិញ្ចើមផ្លូវ និងទីធ្លាកីឡា។
- អ្នកលក់ដូរតាមដងផ្លូវបានឈ្លានពាននិងកាន់កាប់សូម្បីតែតំបន់អភិរក្សនៅក្នុងទីក្រុងដូចជាបូជនីយស្ថាននិងអាគារប្រវត្តិសាស្ត្រ។
- ពួកគេធ្វើឲ្យទីក្រុងកខ្វក់ដោយបោះចោលកាកសំណល់របស់ពួកគេ ដែលមូលហេតុមួយផ្នែកមកពីចំនួនមានកំណត់នៃធុងសម្រាមដែលផ្តល់ឲ្យដោយរដ្ឋបាលក្រុងនៅពេលនោះ និងក៏ដោយសារតែចំនួនឡានដឹកសម្រាមមិនគ្រប់គ្រាន់ ប៉ុន្តែសំខាន់គឺមកពីការមិនយកចិត្តទុកដាក់យ៉ាងឥតសំចៃក្នុងការបោះចោលសម្រាមឲ្យត្រឹមត្រូវ។

ការគ្រប់គ្រងនៃអ្នកលក់តាមផ្លូវក្នុងទីក្រុងសូឡូចាប់ផ្តើមនៅក្នុងពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ និងត្រូវបានអនុវត្តដោយអភិបាលក្រុងបីរូបមុនលោកចូកូវីដូដូ ដែលជាអភិបាលក្រុងសូឡូបច្ចុប្បន្ននេះ។ មធ្យោបាយបញ្ចុះបញ្ចូលនិងវិធានការក្តៅ ដែលត្រូវបានប្រើប្រាស់នៅពេលនោះប៉ុន្តែហាក់បីដូចជាមិនមែនជាដំណោះស្រាយត្រឹមត្រូវ។ អ្នកលក់ដូរតាមផ្លូវគ្មានឆន្ទៈក្នុងការផ្លាស់កន្លែង និងបានធ្វើបាតុកម្មចំនួន១០នៅមុខការិយាល័យអភិបាលក្រុង។ អាគារមួយដែលមានគោលបំណងធ្វើជាទីផ្សារថ្មីត្រូវបានកសាងនៅឯ SemanggiPasar Kliwon ដើម្បីបំពេញចិត្តអ្នកលក់តាមដងផ្លូវឲ្យផ្លាស់ប្តូរកន្លែងចេញពី Monumen Banjarsari ប៉ុន្តែមិនមែនអ្នកលក់តាមដងផ្លូវទាំងអស់សុទ្ធតែចង់ផ្លាស់ទីនោះទេ។ ការពិតទៅចំនួនអ្នកលក់តាមផ្លូវបានកើនឡើងច្រើនជាងមុនទៀតនៅ បូជនីយស្ថាន។

ទោះជាយ៉ាងណាក៏ដោយ អ្នកគ្រប់គ្នាដែលត្រូវបានសម្ភាសក្នុងកំឡុងពេលអភិវឌ្ឍនៃការអនុវត្តល្អនេះយល់ស្របថាមានតែអភិបាលក្រុងJoko Widodo ទេដែលបានទទួលជោគជ័យក្នុងការបំលាស់ទីអ្នកលក់តាមដងផ្លូវដោយមិនបណ្តាលឲ្យមានជម្លោះជាមួយនឹងក្រុមអាជ្ញាធរ ក្នុងចំណោមអង្គការអ្នកលក់តាមដងផ្លូវនិងសាធារណៈជនដោយប្រើប្រាស់នូវ

មធ្យោបាយថ្មីៗដើម្បីបំពេញដោយជោគជ័យនូវកិច្ចការផ្លាស់ប្តូរទីកន្លែងនិងការគ្រប់គ្រងនៃអ្នកលក់តាមផ្លូវ។

លើសពីបញ្ហាក្នុងការស្វែងរកកន្លែងសមស្របដែលអាចឲ្យអ្នកលក់តាមផ្លូវអាចលក់ទំនិញដោយមិនបណ្តាលឲ្យបញ្ហាសម្រាមនិងសណ្តាប់ធ្នាប់សាធារណៈ មន្ត្រីទីក្រុងនេះក៏បានគិតផងដែរអំពីការជួយឲ្យពួកគេមានចំណូលច្រើនជាងមុន ឲ្យដូចអ្នកជំនួញ ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ពួកគេ។

**ខ-កម្មវិធីការគ្រប់គ្រងអ្នកលក់តាមផ្លូវៈ គន្លឹះសំខាន់ទៅកាន់យុទ្ធសាស្ត្រអភិវឌ្ឍទីក្រុង**

នៅពេលដែលលោកអភិបាលក្រុងចូកូ វីដូដូ Joko Widodo និងអភិបាលរងរបស់គាត់លោក រូឌី ហាឌីយាម៉ូ Rudy Hadyatmo កាន់កាប់ការគ្រប់គ្រងនៃរដ្ឋាភិបាលក្នុងស្រុកក្នុងឆ្នាំ២០០៥ ពួកគេបានបង្កើតកម្មវិធីចំនួនប្រាំ សម្រាប់កំឡុងឆ្នាំ ២០០៥-២០១០សម្រាប់ជាសសរគោលនៃរដ្ឋបាលរបស់ពួកគេ រួមមាន សុខភាព ការអប់រំ សុខមាលភាពសហគមន៍និងសេដ្ឋកិច្ច តុល្យភាពក្នុងការអភិវឌ្ឍនៃទីក្រុងសូឡូខាងជើងនិងខាងកើត ការគ្រប់គ្រងអ្នកលក់តាមផ្លូវនិងលំនៅដ្ឋានខុសច្បាប់។

រដ្ឋបាលទីក្រុងដែលស្ថិតក្រោមអំណាចរបស់លោកអភិបាលក្រុងចូកូ វីដូដូ Joko Widodo និងអភិបាលរងរបស់គាត់បានចាប់ផ្តើមការគ្រប់គ្រងនៃអ្នកលក់តាមផ្លូវដោយបានបង្កើតឲ្យមានយុទ្ធសាស្ត្រមួយស្របគ្នានឹងការព្រួយបារម្ភរបស់អ្នកលក់តាមផ្លូវ ជាពិសេសជាមួយនឹងអ្នកសម្របសម្រួលអ្នកលក់តាមដងផ្លូវពីគ្រប់កន្លែងទាំងអស់នៃទីក្រុង។ ការអញ្ជើញឲ្យទៅបរិភោគបាយល្ងាចនៅសាលាក្រុងនិងនៅជំណាក់ជាផ្លូវការនៃអភិបាលក្រុងក្នុងLoji Gandrung គឺមានគោលបំណងបង្កើតឲ្យមានសម្ព័ន្ធភាពមួយនិងបន្ធូរបន្ថយអកប្បកិរិយាប្រឈមមុខដាក់គ្នានៃអ្នកលក់តាមផ្លូវជាមួយនឹងគម្រោងដែលត្រូវបំលាស់ទីពួកគាត់។

យុទ្ធសាស្ត្រសម្ព័ន្ធភាពនៃរដ្ឋបាលសូឡូSolo ទទួលបានជោគជ័យនៅពេលសមាគមន៍នៃអ្នកសម្របសម្រួលនៃអ្នកលក់តាមផ្លូវក្លាយជាមានឆន្ទៈក្នុងការទទួលយកផែនការរដ្ឋបាលទីក្រុងដើម្បីគ្រប់គ្រងអ្នកលក់តាមដងផ្លូវ។ សម្ព័ន្ធភាពនេះគឺមានភាព "ទន់ភ្លន់" និងគ្មាន

អ្នកតំណាងនៃអ្នកលក់តាមដងផ្លូវជារចនាសម្ព័ន្ធឬអង្គភាពជាផ្លូវការដែលបង្កើតដោយភាគីជាប់ពាក់ព័ន្ធក្នុងការគ្រប់គ្រងអ្នកលក់តាមផ្លូវទេ។ នេះមានន័យថា អ្នកប្រតិបត្តិជាផ្លូវការនៃផែនការនេះនិងនៃកម្មវិធីការគ្រប់គ្រងអ្នកលក់តាមផ្លូវគឺជារដ្ឋបាលទីក្រុងសូឡូSolo។

កម្មវិធីការគ្រប់គ្រងអ្នកលក់តាមផ្លូវនៃរដ្ឋបាលទីក្រុងសូឡូSoloត្រូវបានដើរមុនដោយការបង្កើតឲ្យមាននៃក្រុមបច្ចេកទេសនិងក្រុមមិនមែនបច្ចេកទេសមួយ។ ក្រុមបច្ចេកទេសនេះត្រូវបានចាត់ឲ្យស្វែងរកដំណោះស្រាយសម្រាប់បញ្ហាបច្ចេកទេសដូចជាការស្វែងរកកន្លែងល្អសម្រាប់អ្នកលក់តាមផ្លូវ រៀបចំប្លង់នៃគម្រោង ស្វែងរកការអនុញ្ញាតពីស្ថាបត្យកម្មនៃអាគារ ជ្រើសរើសសម្ភារៈសាងសង់ ការត្រួតពិនិត្យសំណង់ សម្រួលចរាចរ ។ល។ រីឯក្រុមមិនមែនបច្ចេកទេសវិញត្រូវបានប្រគល់សិទ្ធិក្នុងការស្វែងរកដំណោះស្រាយសម្រាប់បញ្ហាទូទៅក្នុងសង្គម សេដ្ឋកិច្ច និងសហគមន៍ ដូចជាការបដិសេធការទទួលយកទីកន្លែងថ្មី ជៀសវាងជម្លោះខ្សែឈរនិងខ្សែដេក និងផ្សេងៗទៀត។

រដ្ឋបាលទីក្រុងសូឡូSoloបានផ្តល់ដំណោះស្រាយប្រាំសម្រាប់អ្នកលក់តាមដងផ្លូវ មាន ៖ ការបំលាស់ទី ជម្រក តង់ រទេះ និងសណ្តាប់ធ្នាប់។ ដំណោះស្រាយបួនត្រូវបានបរិយាយក្នុងដំណោះស្រាយ១៣ដោយផ្អែកលើចំនួននៃក្រុមការងារនៃរដ្ឋបាលទីក្រុង៖

១. ការបំលាស់ទីដោយផ្តល់ឲ្យនូវតូបដល់អ្នកលក់តាមផ្លូវ ដូចត្រូវបានធ្វើឡើងក្នុងតំបន់នៃសាកលវិទ្យាល័យ ឬក៏នៅ ប៉ាសាណូទូហាចូPasar Notoharjo។

២. ការបំលាស់ទីដោយផ្តល់នូវជម្រកដល់អ្នកលក់តាមផ្លូវ ដូចត្រូវបានធ្វើនៅតំបន់ជិតសូឡូSolo Square ជុំវិញតំបន់Griyan។

៣. តង់ គឺការផ្តល់តង់ដែលមានពណ៌ ការរចនាម៉ូដ និងទំហំដីដូចគ្នា ដូចដែលបានផ្តល់ឲ្យទៅអ្នកលក់នៅមុខផ្សារPGS Batik ជិតក្លោងទ្វាខាងជើងនៃSolo Palace។

៤. រទេះ គឺការផ្តល់រទេះធ្វើអំពីដែកឬល្បាយនៃឈើនិងក្តារ ដូចបានផ្តល់ទៅឲ្យអ្នកលក់តាមផ្លូវនៅកន្លែងមួយចំនួនតាមផ្លូវអ្នកថ្មើរជើងនៃJalan Slamet Riyadi។

៥. ជំនួយដោយផ្តល់នូវឧបករណ៍ ដូចជាកៅអី។

៦. ការហ្វឹកហាត់ និងការផ្លាស់ប្តូរអាកប្បកិរិយាធ្វើជំនួញដែលរួមបញ្ចូលការហ្វឹកហាត់ខាងចាត់ការ ការហ្វឹកហាត់ខាងការគ្រប់គ្រងសម្រាប់ជំនួញតូច

៧. ជំនួយដោយផ្តល់ជាទុន

៨. ហេដ្ឋារចនាសម្ព័ន្ធដើម្បីការចូលទៅកាន់ទីតាំងថ្មី ឧទាហរណ៍ សំណង់នៃផ្លូវថ្នល់ដែលសម្របសម្រួលជាមួយនឹងសេវាកម្មការងារសាធារណៈ

៩. ការដាក់ឲ្យប្រើប្រាស់នៃគមនាគមន៍សាធារណៈដើម្បីបម្រើឲ្យទីតាំងថ្មីនៃអ្នកលក់តាមផ្លូវ ឧទាហរណ៍ ផ្លូវមួយដែលឆ្លងកាត់ដោយPasar Notoharjo

១០. ជំនួយតាមរយៈការលើកតម្កើនឬជំរុញដែលតែងតែធ្វើឡើងដោយលោកអភិបាលក្រុងនៃសូឡូSolo, Joko Widodo ដែលជាអ្នកតែងតែដឹកនាំគណៈប្រតិភូតំណាងពីតំបន់ក្រៅសូឡូSoloទៅកាន់កន្លែងតាំងទីលំនៅថ្មី ដូចជាPasar Notoharjo ដែលត្រូវបានសម្របសម្រួលដោយសេវាកម្មគមនាគមន៍។

១១. ការដឹកជញ្ជូនដោយឥតគិតថ្លៃសម្រាប់ការតាំងទីលំនៅថ្មីនិងការចំណាយដោយចៃដន្យផ្សេងៗសម្រាប់អ្នកលក់តាមផ្លូវដែលមានឆន្ទៈក្នុងការផ្លាស់ទីដែលត្រូវបានសម្របសម្រួលដោយភ្នាក់ងារប៉ូលីសសេវាស៊ីវិល។

១២. ជំនួយក្នុងការដឹកជញ្ជូនទៅទីកន្លែងថ្មី សម្របសម្រួលដោយ ភ្នាក់ងារប៉ូលីសសេវាស៊ីវិល

១៣. ជំនួយដោយផ្តល់ឆ្នាំនៅទីតាំងចាស់និងទីតាំងថ្មីក្នុងកំឡុងពេលផ្លាស់ដែលត្រូវបានធ្វើឡើងដោយ ភ្នាក់ងារប៉ូលីសសេវាស៊ីវិល

ដំណោះស្រាយដែលបានរៀបរាប់ទាំង១៣ខាងលើក្រោយមកត្រូវបានកាត់បន្ថយមកត្រឹមតែបួនដំណោះស្រាយប៉ុណ្ណោះសម្រាប់ដោះស្រាយអ្នកលក់តាមផ្លូវក្នុងទីក្រុងសូឡូSolo គឺ

បំលាស់ទីទៅកាន់ទីតាំងថ្មី និងរៀបចំលំនៅដ្ឋានមួយ ផ្តល់តង់ និងផ្តល់រទេះ។ ប្រសិនបើជំហានទាំងបួននេះមិនទទួលបានជោគជ័យទេ អភិបាលក្រុងមានជម្រើសចុងក្រោយមួយគឺអនុម័តច្បាប់យ៉ាងតឹងរឹងនិងចេញបញ្ជានៅក្នុងក្រុង។ ប្រធាន ភ្នាក់ងារប៉ូលីសសេវាស៊ីវិលបកស្រាយថាគ្មានដំណោះស្រាយតែមួយណាមួយដើម្បីដោះស្រាយបញ្ហាអ្នកលក់តាមផ្លូវនោះទេ ហើយវាតែងតែជាការបញ្ចូលគ្នានៃដំណោះស្រាយមួយចំនួន។ ជាឧទាហរណ៍ការបំលាស់ទីតាំងទៅកាន់ផ្សារNotoharjoទាមទារឲ្យមានដំណោះស្រាយប្រាំមួយធ្វើការជាមួយគ្នា។

មធ្យោបាយថ្មីៗដែលបានបង្កើតដោយ Jokowi ដែលចាប់ផ្តើមក្នុងឆ្នាំ២០០៥ប្រែក្លាយទៅជាដំណោះស្រាយដែលមានគំនិតច្នៃប្រឌិតដែលចាំបាច់សម្រាប់ដោះស្រាយបញ្ហាអ្នកលក់តាមផ្លូវ។ ដូចនៅឆ្នាំ២០០៦ អ្នកលក់តាមផ្លូវដែលបានចុះបញ្ជីក្នុងរដ្ឋបាលទីក្រុងមានចំនួន ៥,៧១៨ ហើយចំនួននេះត្រូវបានគេប៉ាន់ស្មានថានឹងកើនឡើងលើស៦,០០០ទៅទៀតនៅមុនខែកក្កដា ឆ្នាំ២០១០។ អ្នកលក់ចំនួន៦២%កំពុងស្ថិតក្នុងការគ្រប់គ្រងនៃរដ្ឋាភិបាលដោយដោយគ្រោងការណ៍និងដំណោះស្រាយផ្សេងៗ។ ចំនួណ៣៨%ទៀតនឹងត្រូវបានដោះស្រាយទាំងស្រុងនៅមុនដំណាច់ឆ្នាំ២០១០ នេះបើយោងតាមសម្តីរបស់អភិបាលក្រុងSolo។

សមិទ្ធផលមួយដែលគួរឲ្យកត់សម្គាល់គឺការផ្លាស់ទីនៃអ្នកលក់តាមផ្លូវចំនួន៨៩៨នាក់ពី Monumen Perjuangan ′45 Banjarsari ទៅ Pasar Notoharjo ដោយមិនមានបង្កឲ្យមានជម្លោះខ្សែដេករវាងអ្នកលក់នឹងសហគមន៍ឡើយ ហើយក៏មិនមានជម្លោះខ្សែឈរពាក់ព័ន្ធនឹងអ្នកលក់និងភ្នាក់ងារប៉ូលីសសេវាស៊ីវិលនៃ Kota Solo និងបរិធាន(រចនាសម្ព័ន្ធនិងមធ្យោបាយនៃប្រតិបត្តិការ)រដ្ឋាភិបាលដទៃ។ នៅថ្ងៃត្រូវផ្លាស់ទី អ្នកលក់តាមដងផ្លូវបានស្លៀកពាក់សំលៀកបំពាក់ជប៉ុននិងធ្វើការសំដែងតាមផ្លូវទៅកាន់ទីកន្លែងថ្មី។

ប្រសិនបើមិនធ្លាប់មានពីមុនមកទេ ការខិតខំប្រឹងប្រែងសម្រាប់ការផ្លាស់ទីតាំងដោយសន្តិភាពនិងសណ្តាប់ធ្នាប់នៃអ្នកលក់តាមផ្លូវពី Banjarsari ទៅកាន់ Notoharjo គឺកម្រនឹងមានណាស់នៅក្នុងកម្មវិធីគ្រប់គ្រងអ្នកលក់តាមផ្លូវនៅក្នុងប្រទេសឥណ្ឌូនេស៊ី។ សឹងតែការផ្លាស់ទីតាំងទាំងអស់នៃអ្នកលក់តាមផ្លូវក្នុងទីក្រុងឬទីតាំងដែលមានមនុស្សរស់នៅយ៉ាងក្រាស់

ក្រែលបានបញ្ចប់ដោយជម្លោះខាងផ្លូវកាយជាប់ទាក់ទងនឹងអ្នកលក់តាមផ្លូវ អាជ្ញាធររដ្ឋាភិបាលនិងនគរបាលឬទាហាន។

១ កត្តាជោគជ័យនៃការអនុវត្តល្អ៖

- **ភាពចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់ជីវិតដែលគុណភាពល្អប្រសើរជាងមុន**

  សេដ្ឋកិច្ចទំនើបបានសន្មតទុកជាមុនថាការកែលម្អក្នុងកម្រិតជីវភាពរស់នៅគឺអាចទៅរួចប្រសិនបើមានការអភិវឌ្ឍសេដ្ឋកិច្ច ដែលតែងតែនាំទៅកាន់លក្ខខ័ណ្ឌរស់នៅល្អជាងមុន។ ហេតុដូចនេះហើយ ចំណុចសំខាន់គឺការអភិវឌ្ឍដែលមានតុល្យភាពនិងនិរន្តរភាពដែលគិតគូរទៅលើការរីកចម្រើននៃស្តង់ដារមនុស្ស ដូចជាក្នុងផ្នែកនៃគុណភាពជីវិតនៃប្រទេសមួយឬសហគមន៍មួយ។ ការប្រតិបត្តិដ៏ជោគជ័យនៃការបំលាស់ទីអ្នកលក់តាមផ្លូវនៃទីក្រុងសូឡូSolo ដោយជៀសវាងជម្លោះខ្សែឈរនិងដេកបានបង្ហាញថាការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានអាចកើតមានដោយកែលម្អគុណភាពនៃជីវិតនៃវិស័យដែលដាច់ឆ្ងាយ។

- **ការបង្កើតប្រាក់ចំណូលនាំមកនូវស្តង់ដាររស់នៅល្អប្រសើរជាងមុននៃអ្នកលក់តាមផ្លូវ**

  ជោគជ័យមួយទៀតក្នុងការគ្រប់គ្រងនៃអ្នកលក់តាមផ្លូវនៅ Kota Solo គឺបានរីកចម្រើនជាងមុននៃស្តង់ដាររស់នៅនៃអ្នកលក់តាមផ្លូវមួយចំនួនធំដែលត្រូវបានបំលាស់ទីឬដោយបានចូលរួមក្នុងគម្រោងការ ការអភិវឌ្ឍ។ ជាឧទាហរណ៍ ប្រធានJokoនៃសមាគមន៍អ្នកលក់ទីផ្សារKlithikan Notoharjo បានអះអាងថាស្ថានការណ៍នៃប្រាក់ចំណូលនៃអ្នកលក់តាមផ្លូវភាគច្រើនដែលបានផ្លាស់ទីពីបូជនីយដ្ឋានBanjarsari ទៅទីផ្សារKlithikanបានរីកចម្រើនប្រហាក់ប្រហែលទៅ នឹងឈ្នួញ។ នេះបានសេចក្តីថាប្រាក់ចំណូលរបស់ពួកគេបច្ចុប្បន្ននេះគឺខ្ពស់ជាងប្រាក់

ចំណូលនៃអ្នកលក់តាមផ្លូវធម្មតាច្រើន។ ជាការពិត គាត់បានបន្ថែមសហសេវិកផ្សាររបស់គាត់ដែលជួញដូរគ្រឿងបន្លាស់សម្រាប់រថយន្តទទួលបានអត្រាការលក់ដាច់ប្រចាំខែខ្ពស់ឈានដល់ខ្ទង់ពាន់លានរូបី rupiah។ ចំនួនតិចតួចនៃអ្នកជួញដូរនៅផ្សារKlithikan (អ្នកលក់តាមផ្លូវដែលបានផ្លាស់ទី)ដែលរស់នៅក្នុងអាគារខ្ពស់ៗដែលរដ្ឋបាលទីក្រុង Surakartaធ្វើឲ្យមានតម្លៃថោកសម្រាប់ពួកគេគឺជាភ័ស្តុតាងមួយដែលបញ្ជាក់ថាអ្នកលក់តាមផ្លូវធម្មតារកប្រាក់ចំណូលបានច្រើនជាងមួយលានរូពីIDRក្នុងមួយខែ ដែលជាចំណូលអតិបរមាសម្រាប់ភាពមានសិទ្ធិទទួលបានសម្បទានផ្ទះ។

ការបង្កើតប្រាក់ចំណូលសម្រាប់អ្នកលក់តាមផ្លូវបានត្រូវគាំទ្រដោយកម្មវិធីគ្រប់គ្រងអ្នកលក់តាមផ្លូវដែលមានតំលាភាពនិងភាពត្រឹមត្រូវ។ ឈ្មួញ(អ្នកលក់តាមផ្លូវដែលត្រូវបានផ្លាស់ទី)មិនដែលត្រូវបានបង្ខំឲ្យបង់ថ្លៃអ្វីផ្សេងក្រៅពីអ្វីដែលបានចែងក្នុងកិច្ចសន្យានោះទេ។ បុគ្គលិកនៃសេវាកម្មទីផ្សារដែលបានកំណត់ដោយរដ្ឋបាលទីក្រុងបានបំពេញការងាររបស់ពួកគេបានយ៉ាងល្អនិងសុទ្ធតែត្រូវបានគ្រប់គ្រងទៅតាមខសន្យាដែលមាន ដូចជា ការផ្លាស់ទីតាំងឥតគិតថ្លៃ តង់ ។ល។

- **ការកើនឡើងការបង្កើតប្រាក់ចំណូលមូលដ្ឋាន**

លោកអភិបាលក្រុងចូកូ វីដូដូJoko Widodo បានពន្យល់ថាចាត់តាំងពីការប្រតិបត្តិនៃគម្រោងការគ្រប់គ្រងសម្រាប់ទីផ្សារបុរាណនិងអ្នកលក់តាមផ្លូវក្នុងដើមឆ្នាំ២០០៦ មានការកើនឡើងនៃប្រាក់ចំណូលមូលដ្ឋាននៃ Kota Solo ដែលបង្កើតដោយសេវាកម្មការគ្រប់គ្រងទីផ្សារ។ ការកើនឡើងមានចំនួនពី៧.៨ពាន់លានរូពីIDR ក្នុងឆ្នាំ២០០៦ ទៅ ១៨.២ពាន់លានរូពីIDRក្នុងឆ្នាំ២០១០។

- **ការល្អប្រសើរឡើងនៃគុណភាពជិវិតនៅទីក្រុង**

ក្រៅពីការសម្រេចបានការធ្វើផែនការទំហំទីក្រុង ភាពទាក់ទងនៃជោគជ័យការគ្រប់គ្រងអ្នកលក់តាមផ្លូវក្នុងទីក្រុងសូឡូSoloចំពោះជីវភាពនៃប្រជាជនមូលដ្ឋានមានក្នុងផ្នែកដូចជា៖

- ការបង្កើតសង្គមមួយជោគជ័យទាំងផ្នែកចិត្តសាស្ត្រនិងផ្នែករូបសាស្ត្រដោយបង្កើតឡើងជាថ្មីនៃទីធ្លាសាធារណៈជាទីដែលប្រជាពលរដ្ឋអាចជួបគ្នាជាមួយសមាជិកនៃសហាគមន៍របស់ពួកគេ ធ្វើការប្រាស្រ័យទាក់ទង និងអភិវឌ្ឍខ្លួនរបស់ពួកគេនិងគ្រួសាររបស់ពួកគេ និងសមាជិកសហាគមន៍អាចប្រមូលផ្តុំនៅទីធ្លាក្រុងដែលមានសុវត្ថិភាព ផាសុខភាពនិងប្រកបដោយភាពរីករាយ។

- គុណភាពដែលល្អប្រសើរជាងមុននៃបរិស្ថានទីក្រុង ជាពិសេសខ្យល់អាកាសដែលមានគុណភាពខ្ពស់ជាងមុន គឺទទួលបានដោយការថយចុះនៃការស្ទះចរាចរបន្ទាប់ពីការផ្លាស់ទីតាំងនៃអ្នកលក់តាមផ្លូវ។

- ការទទួលបានមកវិញនូវសិទ្ធិរបស់ប្រជាពលរដ្ឋលើទីធ្លាសាធារណៈ ដែលជាទីកន្លែងមានសុវត្ថិភាព ផាសុខភាពនិងជួយទ្រទង់ជីវិត ដោយហេតុនោះធ្វើឲ្យទីក្រុងសូឡូSoloក្លាយជាទីក្រុងមួយដែលមានលក្ខណៈរួសរាយទៅប្រជាជននៅទីនោះណាស់។

- ការផ្លាស់ទីតាំងនេះបានធ្វើឲ្យមានការកែលម្អនៃគុណភាពជីវិតនៃអ្នកលក់តាមផ្លូវពីព្រោះបច្ចុប្បន្ននេះពួកគេមានលំនៅដ្ឋានខ្ពស់ៗនិងទំនើបដែលមានតម្លៃថោកដែលផ្តល់ដោយរដ្ឋាភិបាល។

**២ វិធានការសម្រាប់ភាពជោគជ័យនៃការគ្រប់គ្រងអ្នកលក់តាមផ្លូវ**

មេរៀនដែលអាចទទួលបានពីភាពជោគជ័យនៃសូឡូSoloគឺវិធានការខុសគ្នាដែលប្រើប្រាស់ដោយរដ្ឋបាលទីក្រុងដើម្បីដោះស្រាយបញ្ហាដែលងាយផ្លាស់ប្តូរនិងដែលគួរឲ្យរំខាននេះ។ វិធានការដែលបានធ្វើឲ្យជោគជ័យដល់ការផ្លាស់ទីតាំងនេះមានដូចខាងក្រោម៖

- ផែនការការគ្រប់គ្រងអ្នកលក់តាមផ្លូវគួរតែត្រូវបានបំពាក់ជាមួយនឹងផែនទីដែលមានលក្ខណៈលំអិតបន្តិច រួមទាំងការអះអាងហេតុផលដែលត្រូវបានវាយតម្លៃរួច គឺមានសេចក្តីពន្យល់ជាស្រេចដែលច្បាស់លាស់ និងគួរឲ្យជឿចំពោះភាពអាចសម្រេចបាននៃផែនការបំលាស់ទីតាំង។
- ដំណាក់កាលនិមួយៗគួរតែមានតម្លាភាពនិងអាចរកបានយ៉ាងទូលាយដោយអ្នកលក់តាមផ្លូវ អង្គការក្រៅរដ្ឋាភិបាល និងសាធារណៈ និង ប្រសិនបើចាំបាច់ សមាជិកបុគ្គលិកទំនាក់ទំនងសាធារណៈពិសេសត្រូវចាត់តាំងដើម្បីកាន់កាប់កម្មវិធីនេះសម្រាប់ជាការប្រទាក់ជាមួយនឹងភាគីខាងក្រៅ។
- លះបង់សមាជិកបុគ្គលិកទាំងអស់នៃរដ្ឋបាលមូលដ្ឋានដើម្បីប្រតិបត្តិកម្មវិធីការគ្រប់គ្រងអ្នកលក់តាមផ្លូវបានទាំងស្រុង។
- ឯកទេសកម្មនៃឈ្មួញដោយប្រើប្រាស់មធ្យោបាយគ្រប់បែបយ៉ាងជាពិសេសមធ្យោបាយបែបវប្បធម៌(ប្រសិនបើមាន) ប៉ុន្តែជាមួយនឹងភាពគង់វង្ស។
- សង្គមបូនីយកម្មទៅលើប្រព័ន្ធសារពត៌មានជាមួយនឹងហេតុផលអះអាងគឺទំនាក់ទំនងល្អនៃសារពត៌មានជាមួយនឹងសេចក្តីបញ្ជាក់ច្បាស់លាស់និងមានតម្លាភាព។
- សង្គមបូនីយកម្មទៅលើក្រុមសង្គមស៊ីវិល ជាក់ស្តែងគឺអង្គការក្រៅរដ្ឋាភិបាលនិងអ្នកសកម្មនិយមមូលនិធិសង្គមក៏ដូចជាអ្នកដទៃទៀត។

- បង្ហាញថាការផ្លាស់ទីតាំងមិននាំឲ្យខាតបង់ដល់ចំណូលប៉ុន្តែដើម្បីការកើនឡើងនៃប្រាក់ចំណូលនិងកន្លែងសមរម្យមួយសម្រាប់ធ្វើអាជីវកម្ម។
- ធ្វើឲ្យជាប់ពាក់ព័ន្ធពីភ្នាក់ងាររដ្ឋាភិបាលទាំងអស់ ចំណែកឯកម្មវិធីអ្នកលក់តាមផ្លូវគួរតែជាផ្នែកមួយនៃកម្មវីធីដែលមានស្រាប់នៃភ្នាក់ងាររដ្ឋាភិបាលទាំងឡាយ។ (យុទ្ធសាស្ត្រការសំដៅទៅរកកន្លែងតែមួយដែលអ្នករួមចំណែកទាំងអស់សុទ្ធតែជាផ្នែកមួយនៃដំណើរការទាំងមូល)។

**គ- ឱកាសនិងការលំបាក**

មធ្យោបាយតាមបែបមានការចូលរួមមានមូលដ្ឋានជាវប្បធម៌នៃរដ្ឋបាលទីក្រុងក្លាយទៅជាវិធីមួយដ៏មានការច្នៃប្រឌិតដើម្បីអ្នកលក់តាមផ្លូវមានការទុកចិត្តក្នុងការផ្លាស់ទីតាំងនៃអាជីវកម្មរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើតាមមធ្យោបាយនេះប្រហែលជាមិនអាចមានភាពជោគជ័យនៅក្នុងបរិស្ថានវប្បធម៌ដទៃ។ ហេតុនេះ វាមានការចាំបាច់ក្នុងការពិនិត្យមើលលើមធ្យោបាយណាដែលអាចមានប្រសិទ្ធិភាពក្នុងសហគមន៍ណាមួយ។ ជាងនេះទៅទៀត និរន្តរភាពនៃកម្មវិធីអភិវឌ្ឍដែលកំពុងតែល្អនិងស្ថិតក្នុងស្ថានភាពត្រឹមត្រូវប្រហែលជាមិនអាចសម្រេចបានក្នុងរយៈពេលយូរក្រោយអណត្តិនៃរដ្ឋបាលទីក្រុងបច្ចុប្បន្ននេះ។ មានផ្លូវមួយដើម្បីបញ្ចូលកម្មវិធីនេះចូលក្នុងស្ថាប័នគឺផ្តល់គ្រោងបទបញ្ញាស្របច្បាប់ដែលមានសារៈសំខាន់ដើម្បីធានានិរន្តរភាពវាជាយូរអង្វែង។

ទំហំសមត្ថភាពនៃការអនុវត្តល្អសម្រាប់ប្រទេសដទៃទៀតត្រូវពឹងផ្អែកទៅលើរចនាសម្ព័ន្ធនៃសង្គមសេដ្ឋកិច្ចនិងក្របខ័ណ្ឌច្បាប់នៅក្នុងប្រទេសដែលធ្វើតាម។ ហេតុនេះហើយ ការកែតម្រូវខ្លះៗគួរតែមានដើម្បីឲ្យស្របតាមលក្ខខណ្ឌទូទៅនៅក្នុងទីក្រុងដែលជាទីកន្លែងដែលការគ្រប់គ្រងអ្នកលក់តាមផ្លូវត្រូវអនុវត្ត។ ជាងនេះទៅទៀត ដំណោះស្រាយដ៏ជោគជ័យសម្រាប់បញ្ហានេះទៅលើអ្នកលក់នៅផ្សារប្រហែលជាអាចធ្វើឲ្យប្រជាជននៅតាមជនបទមានសេចក្តីក្លាហានក្នុងការមកកាន់ទីក្រុងដែលអាចធ្វើឲ្យបញ្ហានេះកាន់តែអាក្រក់ថែមទៀត។

**កម្រងសំនួរណែនាំសម្រាប់អ្នកហាត់រៀន/អ្នកចូលរួម៖**

ក. តើបញ្ហាមូលដ្ឋានអ្វីដែលការគ្រប់គ្រងនៃអ្នកលក់តាមផ្លូវខិតខំដោះស្រាយ?

ខ. តើកម្មវត្ថុនៃគម្រោងនោះមានអ្វីខ្លះ? តើធាតុសំខាន់ៗរបស់វាមានអ្វីខ្លះ?

គ. តើគម្រោងនោះត្រូវបានប្រតិបត្តិយ៉ាងដូចម្តេច?

ង. តើអ្វីខ្លះជាលទ្ធផលនៃគម្រោងនោះ?

ច. តើគម្រោងនោះមានធាតុថ្មីៗដែលឬទេ? ចូរបកស្រាយប្រសិនបើមាន។

ឆ. តើមានការលំបាកអ្វីខ្លះនៃគម្រោងដែលអ្នកអាចកំណត់បាន? ចូរបកស្រាយថាតើការលំបាក់ទាំងនោះត្រូវបានដោះស្រាយយ៉ាងដូចម្តេចនៅក្នុងគម្រោងនោះ។

ជ. តើមានមេរៀនសំខាន់ៗអ្វីខ្លះដែលអ្នកអាចទាញចេញពីការសិក្សានេះដែលអាចជាផលប្រយោជន៍នៅក្នុងគម្រោងស្រដៀងគ្នានៅពេលអនាគត?

### ៦-២-៣ វិនិយោគសារជាថ្មីលើក្រុងភូកេតចាស់៖ ទេសចរណ៍វប្បធម៌ជាយុទ្ធសាស្ត្រអភិវឌ្ឍន៍

#### ក- សវតានិងភាពសមហេតុផលនៃការអនុវត្តល្អ

ក្រុងភូកេតមានទីតាំងស្ថិតនៅភាគខាងអាគ្នេយ៍នៃភូកេត មានផ្ទៃដីគ្របដណ្តប់លើដី១២គីឡូម៉ែតការ៉េ។ ទាំងអស់មានក្រុមគ្រួសារសរុប២០,៨៧៧ដែលមានប្រជាជនសរុបចំនួន ១៧,៥៨៣នាក់ (ប្រុស ៣៤,២០៧ និងស្រី ៤០,៣៦៧) រួមទាំងជនជាតិមិនមែនថៃ។ ដង់ស៊ីតេប្រជាជនមានចំនួន៦,២១៦នាក់ក្នុងមួយគីឡូម៉ែតការ៉េ។ នៅចំកណ្តាលនៃក្រុងមានមជ្ឈមណ្ឌលពាណិជ្ជកម្មនិងជំនួញ។ តំបន់ដែលនៅជិតគឺក្រុងចាស់សម្រាប់ជាលំនៅឯកជន។ តំបន់កាន់តែក្នុងកាន់តែមានដង់ស៊ីតេខ្ពស់។ ពួកគេភាគច្រើនជាអ្នកជំនួញ។ ផ្លូវថ្នល់ស្ថិតក្នុងតំបន់ទីក្រុងមានលក្ខណៈតូចនិងចង្អៀត។ នៅក្រុងនេះមាននិយោជកសរុប១,០៩៥។ ក្នុងឆ្នាំសារពើពន្ធ២០០៨ ប្រាក់ចំណូលមានចំនួន៧២៩,១៦៤,២៩៦.១៩បាត្រ និងចំណាយមាន៧៥២,៨១៤,១២២.៩៤បាត្រ។

ខេត្តភូកេត ដែលជាកោះមួយនៃភាគខាងត្បូងប្រទេសថៃ ត្រូវបានស្គាល់ជាលក្ខណៈសកលដោយឆ្នេរខ្សាច់ដ៏ស្រស់ស្អាតនៅជុំវិញកោះនេះ។ កន្លែងកម្សាន្ត សណ្ឋាគារមួយចំនួនធំ និងបរិក្ខារទេសចរណ៍ផ្សេងទៀតបានលេចឡើងតាមតំបន់ជុំវិញឆ្នេរនៃកោះភូកេត។ ប៉ុន្តែក្រុងភូកេតមិនមានសកម្មភាពទេសចរណ៍ច្រើននោះទេ បើប្រៀបធៀបនឹងឆ្នេរនៅតាមច្រាំងសមុទ្រ។

ផ្នែកមួយនៃក្រុងភូកេតគឺទីក្រុងចាស់ដែលគ្របដណ្តប់លើផ្ទៃដី ២១០រ៉ៃ Rais (83.03 acre)ដែលមិនមែនជាដីធំប៉ុន្មានទេប៉ុន្តែវាធ្លាប់ជាមជ្ឈមណ្ឌលពាណិជ្ជកម្ម។ វិថីខ្លះនៃតំបន់នេះមើលទៅពិតជាចាស់ដោយសារតែរចនាបថនៃអាគារ ហើយវាមានសក្តានុពលផ្នែកទេសចរណ៍សម្រាប់ធ្វើការអភិវឌ្ឍ។ ហេតុនេះ ក្រុងភូកេតបានសម្រេចចិត្តថានឹងវិនិយោគក្នុងការរៀបចំឡើងវិញនូវទីក្រុងចាស់នេះដើម្បីលើកកម្ពស់វាដោយការអភិរក្សសំណង់អាគារចាស់ៗដែលមានរចនាបថស្ថាបត្យកម្មប្លែកដែលត្រូវបានគេស្គាល់ថាជាSino-Portuguese (a.k.a. Sino-Colonial)និងទំនៀមទំលាប់ចាស់(the Malay-Chinese, a.k.a. Straits Chinese)

សម្រាប់ការទស្សនាជាត្រួសៗនៃទេសចរណ៍វប្បធម៌ក្នុងក្រុងភូកេត។ ជាមួយនឹងការអភិរក្ស ការវិនិយោគក៏បានលើកកម្ពស់ដល់ការចូលរួមពីប្រជាជន ការយល់ដឹងរបស់ប្រជាជន ទេសចរណ៍វិប្បធម៌ និងការកើនឡើងសេដ្ឋកិច្ចផងដែរ។

គម្រោងមួយដែលមានឈ្មោះថា ការអភិរក្សក្រុងចាស់ភូកេតនិងការអភិវឌ្ឍ ត្រូវបានបង្កើត។ ដោយមានការសហការគ្នាជាមួយនឹងក្រុងភូកេត គម្រោងនេះមានបំណងធ្វើការជាមួយសហគមន៍ មូលដ្ឋាននិងអង្គការដែលមានតួនាទីឈានមុខក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ នៃការអភិរក្សនៃស្ថាបត្យកម្មសំនង់អាគារនៃទីក្រុងចាស់ ជាមួយនិងការអភិវឌ្ឍតំបន់នោះក្នុងគោលដៅសមរម្យមួយ ក្រោមការត្រួតពិនិត្យយ៉ាងជិតស្និទ្ធនៃអ្នកជំនាញស្ថាបត្យកម្ម Sino-Portunese។

ខ- ទេសចរណ៍វប្បធម៌ជាយុទ្ធសាស្ត្រអភិវិឌ្ឍន៍ដែលមានការចូលរួម

ដោយរងឥទ្ធិពលឋានលេខា (topography) វប្បធម៌ ទំនៀមទំលាប់ និងជីវិភាពនៃទីក្រុងភូកេត រដ្ឋបាលនៃរដ្ឋាភិបាលភូកេតមានទស្សនវិស័យមួយសម្រាប់ការអភិវឌ្ឍក្រុងភូកេតថាវានឹងតែងតែជាទីក្រុងដែលពោរពេញដោយភាពរីករាយនិងនៅតែសមរម្យសម្រាប់ការរស់នៅជានិរន្តរភាព។ ដឹកនាំដោយគោលនយោបាយប្រាំបីសម្រាប់សុភមង្គលនៃប្រជាជនដែលមួយក្នុងចំណោមនោះគឺលើកកម្ពស់សេដ្ឋកិច្ចរបស់ប្រជាជនសាមញ្ញ ទីក្រុងភូកេតអភិវឌ្ឍវិស័យទេសចរណ៍និងសកម្មភាពជំនួញរបស់ខ្លួនដោយប្រើប្រាស់អត្តសញ្ញាណពិតប្រាកដរបស់ខ្លួន ដូចជាស្ថាបត្យកម្មដ៏កម្រ របៀបរស់នៅ រូបមន្តធ្វើម្ហូប ការដែលមានចិត្តទូលាយនៃប្រជាជនជាកម្លាំងទាក់ទាញ។

តាំងពីពេលនោះមក ទីក្រុងភូកេតបានផ្តួចផ្តើមសកម្មភាពមួយចំនួនដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាជន ដើម្បីស្រលាញ់និងយកចិត្តទុកដាក់សម្រាប់ក្រុងចាស់ និងដើម្បីលើកកម្ពស់វិស័យទេសចរណ៍ក្នុងទីប្រជុំជនភូកេតសម្រាប់ការពង្រឹងសេដ្ឋកិច្ចដូចខាងក្រោម៖

- ពិធីបុណ្យនៃក្រុងចាស់របស់ភូកេតមានការតាំងពិព័ណ៌ វេទិកាសម្រាប់ការសន្ទនាក្រុងចាស់ ការសម្តែងភ្លើងនិងសម្លេង ការសម្តែងប្រពៃណី និងហាងម្ហូបក្នុងស្រុកតាមផ្លូវThalang។

- ប្រពៃណីក្នុងស្រុកនិងការសន្ទនាជាលក្ខណៈទំនៀមទំលាប់ដូចជាក្បួនអ្នកថែរក្សាអ្នកជំនឿលើវិញ្ញាណ បុណ្យព្រះខែ ក្បួនបុព្វជន បុណ្យអ្នកបួស និងក្បួនអ្នកបង្កើតភូកេត។
- ការបង្កើត "មូលនិធិភូកេតចាស់" ដោយបណ្តាញនៃសម្ព័ន្ធមិត្តមួយនៃសហាគមន៍ ដែលមានបំណងក្នុងការចូលរួមចំណែកពីសាធារណៈក្នុងការអភិរក្សស្ថាបត្យកម្ម វប្បធម៌ និងជីវភាពរស់នៅ។
- ការរៀបចំពិធីបុណ្យ "ភូកេតឆ្នាំ-ម្សិលមិញ" ដើម្បីនាំមកនូវភ្ញៀវកាន់តែច្រើនចូលទៅក្នុងតំបន់ទីប្រជុំជន។
- ការលើកកម្ពស់ការប្រារព្ធពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីនៃភូកេតដើម្បីបង្ហាញពីអត្តសញ្ញាណនៃរបៀបរស់នៅនិងវប្បធម៌នៃភូកេត។
- ការថែរក្សានៃសម្លៀកបំពាក់ Nyonya (សម្លៀកបំពាក់ប្រពៃណីPeranakan)
- ការបង្កើតក្រុមអ្នកនេសាទទំហំតូចនៅ Ban Ko Jan ជិត Sapan Hin សម្រាប់សកម្មភាពសេដ្ឋកិច្ចច្រាំងសមុទ្រ និងជាបណ្តាញទីផ្សារបន្ថែមសម្រាប់ត្រីដែលចាប់បាន ម្លោះហើយវាជួយបង្កើតប្រាក់ចំណូលនិងការសន្សំ។
- ការហ្វឹកហាត់មគ្គុទេសក៍ទេសចរណ៍ស្ម័គ្រចិត្តនិងការអភិវឌ្ឍនៃសក្តានុពលសហាគមន៍មូលដ្ឋានឲ្យក្លាយជាម្ចាស់ផ្ទះល្អដើម្បីពង្រឹងសមត្ថភាពវិស័យទេសចរណ៍។

ជាងនេះទៅទៀត ទីក្រុងភូកេតបានវិនិយោគលើកម្មវិធីការកែលម្អបរិស្ថាននិងទេសភាពទីក្រុងដើម្បីធានានូវបរិយាកាសសប្បាយរីករាយនិងស្រស់ស្អាត និងធានាការពេញចិត្តរបស់ភ្ញៀវក្នុងការមកទស្សនាក្រុងភូកេតដែលស្អាត ងាយស្រួលនិងគួរជាទីចូលចិត្ត ឧទាហរណ៍ ការកែលម្អប្រព័ន្ធទឹកសាធារណៈ ការគ្រប់គ្រងសំណល់រឹងនិងធនធានថាមពលបៃតង ថាមពលក្រោមដី ។ល។ ដើម្បីនាំមកនូវភាពទាក់ទាញនៃវិថីនៃក្រុងភូកេត ការវិនិយោគលើបច្ចេកវិទ្យា

គមនាគមន៍ទំនើប ការវិនិយោគលើទំនាក់ទំនងសាធារណៈ ការអប់រំ ដូចជាការហ្វឹកហាត់ជំនាញភាសាបរទេស បច្ចេកវិទ្យាអន្តរគមនាគមន៍ ។ល។

ទីក្រុងភូកេតក៏បានធ្វើផែនការរយៈពេលវែងពីការវិនិយោគវិស័យទេសចរណ៍ដើម្បីធ្វើឲ្យវិស័យទេសចរណ៍នៅភូកេតមានភាពជឿនលឿន ឧទាហរណ៍ការបង្កើតឲ្យមានសារមន្ទីរសម្រាប់ការអប់រំនិងទេសចរណ៍ ដូចជាសារមន្ទីរ Ban Kao សារមន្ទីរThaihua ដែលធ្លាប់ជាសាលារៀនពីមុនមក; ឧទាហរណ៍មួយទៀតគឺការបង្កើតឲ្យមានមជ្ឈមណ្ឌលពត៌មានសម្រាប់ភ្ញៀវទេសចរក្នុងតំបន់ក្រុងចាស់ដើម្បីឲ្យមានភាពងាយស្រួលដល់ភ្ញៀវទេសចរដែលចូលចិត្តទេសភាពក្នុងការដើរហើរនៅក្នុងក្រុងចាស់ភូកេត ហើយការនេះបានគ្រប់គ្រងវិស័យទេសចរណ៍ក្នុងលក្ខណៈនិរន្តរភាព ដូចនេះហើយក្រុងចាស់ភូកេតបានក្លាយជាតំបន់ទេសចរណ៍ដ៏សំខាន់មួយនៃខេត្តនេះ។ នៅពេលទស្សនាភូកេត អ្វីដែលត្រូវតែទស្សនានោះគឺក្រុងចាស់នៃភូកេតពីព្រោះវាល្បីខាងស្ថាបត្យកម្ម Sino-Portuguese របៀបរបបរស់នៅ និងរូបមន្តធ្វើម្ហូបក្នុងស្រុក។ ភាពជោគជ័យនេះបានជំរុញឲ្យសេដ្ឋកិច្ចមូលដ្ឋានមានការរីកលូតលាស់ និងអ្វីដែលអាចមើលឃើញផ្ទាល់នោះគឺការត្រឡប់មកវិញនូវភូកេតជំនាន់ថ្មីទៅកាន់តំបន់ក្រុងចាស់ដើម្បីចាប់ផ្តើមឬធ្វើសារជាថ្មីនូវសកម្មភាពជំនួញរបស់ខ្លួន ធ្វើឲ្យថ្មីឡើងវិញនៃផ្ទះ Sino-Portuguese របស់ពួកគេឲ្យទៅបន្សីជាមួយនឹងបរិយាកាសក្រុងចាស់ និងដាក់លក់ច្រើនជាងមុននូវផលិតផលបុរាណរបស់ពួកគេ។

១ មរតកប្រវត្តិសាស្រ្តនិងស្ថាប្យកម្មដ៏សម្បូរបែបនៃភូកេតជាការទាក់ទាញទេសចរ

ភូកេត ដែលជា"គុជនៃ Andaman" គឺមិនត្រឹមតែជារម្មណីយដ្ឋានឆ្នេរសមុទ្រនោះទេ។ វាមានប្រវត្តិសាស្រ្តយ៉ាងសម្បូរបែបថាជាប្រទេសនៃការជីកយកសំណប៉ាហាំង មានប្រជាជនជាជនជាតិ Siamese ចិនម៉ាឡេឥណ្ឌា Erasians និង sea gypsies។ សហាគមន៍មួយដែលកម្រក្នុងភូកេតគឺ "Baba" ជាមួយនិងរបៀបរបបរស់នៅ ភាសា សម្លៀកបំពាក់និងម្ហូបអាហារតាមបែបរបស់ពួកគេ។ គ្រិះនៃសហាគមន៍នេះត្រូវបានបង្កើតឡើងដោយសម្ព័ន្ធដើម ចន្លោះអ្នកជីករ៉ែសំណប៉ាហាំងHokkien និងស្រ្តីSiamese។ មរតកBabaដែលខុសប្លែកពីគេនេះអាចឃើញបាននៅក្នុងក្រុងចាស់ភូកេត។

ចាត់តាំងពីទសវត្សឆ្នាំ១៨២០ ការជីករករ៉ែនៅក្នុងភូកេតគឺនៅក្នុងដៃនៃអ្នកផ្សងព្រេងជនជាតិចិនដែលមកពីតំបន់តាំងទីលំនៅBritish Striats ជាពីសេសគឺPenang ។ កំឡុងពេលនោះ ការរែងរកមាសបានរីករាលដាលពីផ្ទៃកខាងក្នុងនៃKathuទៅដល់ឈូងសមុទ្រTongkah និង ប្រហែលជាឆ្នាំ១៨៥០ ក្រុងTongkahត្រូវបានបង្កើត។ ការតាំងទីលំនៅនេះបានបង្កើតគ្រិះជាប្រវត្តិសាស្ត្រនៃក្រុងភូកេតសព្វថ្ងៃនេះ។

នៅដើមសតវត្សទី២០ អរិយធមិមួយធំគ្រាន់បើដែលបង្កើតដោយ Phraya Rassada Nupradit (Khaw Sim Bee na Ranong) ក្នុងកំឡុងពេលនៃអណត្តិរបស់គាត់ជាអគ្គស្នងការនៃភូកេត(១៩០០-១៩១៣) ។ គាត់បានធ្វើជីសម្បទានដ៏ធំមួយទៅឲ្យក្រុមហ៊ុនជីករ៉ែអូស្ត្រាលីអ៊ឺរ៉ុប Tongkah Harbour Dredging ជាថ្នូរនឹងមូលនិធិដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ផ្លូវថ្នល់ត្រូវបានសាងសង់ ព្រៃកជីកត្រូវបានយកចេញនូវដីល្បាក់ដែលបង្គរទុក និង អាគារសាធារណៈមួយចំនួនត្រូវបានសាងសង់។ ដោយសារតែភូកេតដែលមានសុវត្ថិភាពជាងមុន មានអ្នកជំនួញនិងក្រុមគ្រួសាររបស់គេច្រើនជាងមុន ជាពិសេសអ្នកដែលមកពី Penang បានតាំងទីលំនៅនៅភូកេត។ ដោយមានការថ្កុំថ្កើងជាងមុន សាលារៀននិងប្រាសាទមានការសាងសង់។

ជាមួយនឹងការសម្ភោធន៍ជើងហោះហើរផ្ទាល់រវាងអ៊ឺរ៉ុបនិងបាងកកនៅដើមទសវត្សឆ្នាំ ១៩៧០ ភូកេតបានចាប់ផ្តើមក្លាយជាគោលដៅនៃទេសចរ។ ដប់ឆ្នាំក្រោយមក ទីផ្សារសំណប៉ាហាំងបានរលំប៉ុន្តែជាសំណាងសេដ្ឋកិច្ចត្រូវបានសង្គ្រោះដោយការរីកចម្រើននៃវិស័យទេសចរណ៍ជំនួសវិញ។ តំបន់ជីករ៉ែពីមុនមួយចំនួនធំត្រូវបានប្រែក្លាយជារមនីយដ្ឋានដែលប្រណិតៗ។ ចំណែកឯក្រុងចាស់ត្រូវបានចៀសវាងដោយឧស្សាហកម្មទេសចរណ៍រហូតមកពេលថ្មីៗនេះ។

## មរតកស្ថាបត្យកម្ម

មរតកវប្បធមិនៃភូកេតគឺជាការឆ្លុះបញ្ចាំងមួយនៃភាពរុងរឿងក្នុងជំនាន់សំណប៉ាហាំងមានការរីកចម្រើន។ ទេសភាពទីក្រុងគឺប្លែកក្នុងប្រទេសថៃ ប៉ុន្តែវាតំណាងឲ្យការតាំងទីលំនៅនៃ British Striats ដូចជាPenang Malaca និងសឹង្ហបុរី។ ស្ថាបត្យកម្មនោះភាគច្រើន

ត្រូវបានឲ្យឈ្មោះថា "Sino-Portuguese"ដោយស្ថាបត្យករក្រុងបាងកកបច្ចុប្បន្ន។ ក្រុងភូកេត ត្រូវបានគេយកធ្វើជាគម្រូក្រោយអាណានិគមអង់គ្លេសលើ Penang នៅក្នុងប្រទេសម៉ាឡេស៊ី និងវាគឺជាដើមកំណើតនៃឥទ្ធិពលរបស់ពួកអឺរ៉ុបទៅលើស្ថាបត្យកម្មរបស់ខ្លួន។ ហាង ផ្ទះ និង វីឡានៅភូកេតតំណាងឲ្យអ្វីទាំងនោះនៅក្នុងPenang ក្នុងលក្ខណៈជាទម្រង់ សម្ភារៈ និង រចនាបថជាមួយនឹងប្រធានក្បាច់ថៃម្តងម្កាល។ ស្ថាបត្យកម្មរបស់ថៃកើតឡើងក្នុងទសវត្សឆ្នាំ ១៩៣០ និងចាប់តាំងពីពេលនោះមក ស្ថាបត្យកម្មភូកេតបានចាប់ផ្តើមឃ្លាតចេញពីរចនាបថ Penang។

ក្រុងភូកេតបានធ្វើទំនើបកម្មជាមួយនឹងកោះទាំងមូល។ នៅមជ្ឈមណ្ឌលប្រវត្តិសាស្ត្រ ផ្លូវដែលចង្អៀតត្រូវមកទទួលកម្រិតចរាចរណ៍ដែលមានលក្ខណៈទំនើប ក្នុងពេលជាមួយគ្នា ផ្លូវដើរទាំងប្រាំគឺមិនអាចចូលទៅបានក្នុងផ្នែកខ្លះ។ ទេសភាពតាមផ្លូវភាគច្រើនគឺល្អពេញ លេញ ទោះបីជាមានការបាក់បែកនៅទីកន្លែងខ្លះៗព្រោះតែមានការចាក់បំពេញបែបទំនើប និងផ្លាកផ្សាយពាណិជ្ជកម្មនានាក៏ដោយ។ ជាទូទៅ ចរិកលក្ខណៈនៃក្រុងចាស់ភូកេតគឺ ពិសេសនិងមានភាពទាក់ទាញគ្រប់គ្រាន់សម្រាប់ទាក់ទាញភ្ញៀវទេសចរទាំងជនជាតិថៃនិង ជនបរទេស។

ទោះបីជាក្រុងចាស់លែងជាមជ្ឈមណ្ឌលពាណិជ្ជកម្មនៃភូកេតហើយក្តី ភាគច្រើននៃ ផ្ទះហាងទំនិញ គឺនៅតែមានមុខងារជាហាងលក់ទំនិញនិងជាលំនៅដ្ឋាន។ ទីកន្លែងសម្រាប់ បរិភោគក្នុងភូកេតនិងក្រុងចាស់គឺមិនមានការលើកលែងដែរ។ នៅផ្លូវសំខាន់ ផ្លូវ Thalang នៅ តែត្រូវគេស្គាល់ថាជាតំបន់ជំនួញមួយចំនួន ជាពិសេសគឺវាយនភ័ណ្ឌផ្ទិតក្រណាត់។ នៅពេល ដែលពាណិជ្ជកម្មផ្សេងទៀតច្រើនតែជាអ្នកផ្គត់ផ្គង់ លក់ដុំ ឈ្មួញសំនប៉ាហាំង ហាង គ្រឿងចក្រធុនធ្ងន់ និងអ្នកផ្គត់ផ្គង់គ្រឿងម៉ាស៊ីន បច្ចុប្បន្ននេះហាងលក់វត្ថុបុរាណ ហាងកាហ្វេ និងភោជនីយដ្ឋានបែបអឺរ៉ុបកំពុងតែរីកលូតលាស់ក្នុងកម្រិតយឺតៗប៉ុន្តែមានភាពស្រស់ស្អាត។

### ២ សកម្មភាពប្រតិបត្តិការអនុវត្តិល្អនៃភូកេត

ដំបូងឡើយក្នុងឆ្នាំ១៩៩២ ក្រុងភូកេតព្រួយបារម្ភអំពីតំបន់ក្រុងចាស់របស់ខ្លួននៅពេល ដែលផ្ទះហាងត្រូវបានគេមិនអើពើ បោះបង់ចោល និងបិទចោលទោះបីជាវាជាតំបន់មាន

សក្តានុពលខាងទេសចរណ៍។ តាមរយៈដេប៉ាដឹមង់បរិស្ថានទីក្រុង GTZ បានស្វែងរកគោលដៅមួយសម្រាប់គម្រោងអភិរក្សទៅលើការគ្រប់គ្រងបរិស្ថានទៅតាមមធ្យោបាយការរួមចំណែក។ រួចGTZនិងក្រុងភូកេតក្នុងឋានៈជាគម្រោងការអភិរក្សសាកល្បង បានចាប់ផ្តើមកម្មវិធីមួយឈ្មោះថាការអភិរក្សនិងការរីកចម្រើននៃបរិស្ថានស្ថាបត្យកម្មក្នុងក្រុងចាស់ភូកេត។ វត្ថុបំណងមាន ១) ដើម្បីលើកស្ទួយវិស័យសេដ្ឋកិច្ចក្នុងក្រុងចាស់ភូកេត, ២) ដើម្បីអភិរក្សបរិស្ថានស្ថាបត្យកម្ម, ៣) ដើម្បីការពាររៀបរបបរស់នៅតាមបែបចាស់ ទំនៀមទំលាប់វិប្បធម៌និងជីវភាពនៃភូកេតដ៏ពិតប្រាកដ និង៤) ដើម្បីលើកកម្ពស់ការយល់ដឹងផ្នែកបញ្ហាការថែរក្សាការពារវប្បធម៌។

ពីមុនភាគីបីជាអ្នកដើរតួសំខាន់; GTZ ក្រុងភូកេត និងសាស្ត្រាចារ្យស្ថាបត្យកម្មបណ្ឌិត Yongthanit Pimonsathean និងអ្នកជំនាញមកពីសាកលវិទ្យាល័យKing Mongkut Ladkrabang ដែលឧបត្ថម្ភដោយក្រសួងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន។ ក្រោយមកមានក្រុមស៊ីវិល សមាគមន៍ និងមូលនិធិមួយចំនួនទៀតបានចូលរួមជាមួយនិងក្រុងភូកេតក្នុងការចូលរួមចំណែកការខិតខំប្រឹងប្រែងអភិរក្សបែបនេះ។ ឧទាហរណ៍មួយចំនួនពីក្រុមទាំងនេះគឺមានមូលនិធិភូកេតចាស់ សមាគមន៍ Peranakan ។ល។

ទោះបីជាមួយភាគធំនៃហាងផ្ទះចាស់ក្នុងក្រុងចាស់ភូកេតគឺមានម្ចាស់ ហើយផ្ទះទាំងនោះត្រូវបានថែរក្សាយ៉ាងល្អ ចំនួនរបស់ពួកវាដែលកំពុងតែឈានចូលទៅក្នុងការពុកផុយនោះគឺមិនអាចធ្វេសប្រហែសបានទេ។ ដើម្បីឲ្យយល់កាន់តែច្បាស់ វាមានសារៈសំខាន់ណាស់ដែលត្រូវដឹងពីប្រវត្តិសង្ខេបខ្លះៗមុននឹងដឹងពីមរតកស្ថាបត្យកម្មរបស់វា។

ចំពោះការអភិរក្សក្រុងចាស់ដែលផ្តើមគំនិតដោយ GTZ ក្រុងភូកេតជាអង្គការគន្លិះសម្រាប់ធ្វើអន្តរាគមន៍មួយចំនួន បានទទួលការគាំទ្រដោយភាគីសម្របសម្រួលជាច្រើន។ ជាឧទាហរណ៍ អាជ្ញាធរអគ្គីសនីខេត្ត(Provincial Electricity Authority) អង្គការទូរស័ព្ទនៃប្រទេសថៃ និងក្រុងភូកេតបានរួមគ្នាវិនិយោគ១០, ២.៤, និង៤.៧លានបាត្រ រៀងគ្នា សម្រាប់រ៉ាប់រងការកែលម្អខាងសោភ័ណ្ឌភាពនៃការទុកដាក់វាល់ខ្សែភ្លើងឬខ្សែកាបចូលក្នុងដី។ ការកែលម្អផ្នែករូបសាស្ត្រនិងការជួសជុលខាងអាគារត្រូវបានគាំទ្រដោយក្រុងភូកេត។ ហើយកម្មវិធីដើរតាមផ្លូវប្រចាំសប្តាហ៍ត្រូវបានផ្តួចផ្តើមនិងគាំទ្រពីក្រសួងវប្បធម៌ជាមួយនឹង

ថវិការ៨លានបាត្រតាមរយៈការិយាល័យខេត្ត។ ក្រុមស៊ីវិលផ្សេងទៀតធ្លាប់មានការបរិច្ចាគច្រើនខាងហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុទៅកាន់ការអភិរក្សក្រុងចាស់ផងដែរ។

សកម្មភាពការប្រតិបត្តិអាចបែងចែកទៅជាមួយក្រុមៈ

១) ការអភិវឌ្ឍទិន្នន័យនៃស្ថាបត្យកម្ម បរិស្ថានរូបសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធនៃក្រុងចាស់ភូកេត។

២) ការបង្កើតអង្គភាពរដ្ឋបាល; គណៈកម្មាធិការប្រតិបត្តិពហុភាគី, មូលនិធិភូកេតចាស់, សហគមន៍ក្រុងចាស់។

៣) លើកកម្ពស់ការយល់ដឹងចំនេះដឹង និងការឃើញតាមគុណតម្លៃនៃក្រុងចាស់ជាមួយនិងសកម្មភាពបង្កើតប្រាក់ចំណូលដូចជា "ភូកេតកាលពីអតីតកាល" ការអប់រំវិជ្ជាជីវៈនៃបញ្ញាក្នុងស្រុក ឧទហរណ៍ដូចជារបៀបផ្ចិតក្រណាត់ រូបមន្តធ្វើម្ហូប មគ្គុទេសន៍ទេសចរ ។ល។

៤) ការកែលម្អផលិតកម្មសារពត៌មានទំនាក់ទំនងសាធារណៈ និងភាពទាក់ទាញទេសចរបន្ថែម។ សាលាក្រុងបានគាំទ្រដោយខិតប័ណ្ណ កម្មវិធីទូរទស្សន៍ ការវិនិយោគក្នុងការអភិវឌ្ឍរូបសាស្ត្រ ដូចជាការប្រែក្លាយសាលារៀនចាស់មួយទៅជាសារៈមន្ទីរ។

ដោយគម្រោងនេះមានអង្គភាពសម្របសម្រួល និងការត្រួតពិនិត្យពីគណៈកម្មការប្រតិបត្តិការផ្តល់យោបល់ គម្រោងក្រុងចាស់ភូកេតមានក្រុមអ្នកជំនាញមួយក្រុមមកពីសាលាក្រុង។ ក្រុមនេះក៏បានទទួលការគាំទ្រសម្រាប់ការរៀបចំគម្រោងសកម្មភាពពីអ្នកឯកទេសដទៃទៀតជុំវិញក្រុងភូកេត។

កម្មវត្ថុនៃគម្រោងនិង ភាពអាចបញ្ជូនបានត្រូវបានបែងចែកជាក្រុមដូចខាងក្រោមៈ (ក) ក្រុមការចូលរួមនៃអ្នករួមចំណែក កំណត់អ្នករួមចំណែកជាវិស័យទេសចរណ៍ដែលបានចូលរួមក្នុងការពិភាក្សាអំពីសមត្ថភាពនៃការអភិវឌ្ឍទីក្រុង។ ការចូលរួមនៃអ្នកតំណាងពីតំបន់ភូមិសាស្ត្រផ្សេងៗនិងជាមួយនឹងចំណាប់អារម្មណ៍ផ្សេងគ្នា គឺជាកត្តាមូលដ្ឋានសម្រាប់ការ

ជោគជ័យក្នុងការប្រតិបត្តិគម្រោងនេះ (ខ) ក្រុមតម្រូវការទីផ្សារ វាយតម្លៃទៅលើតម្រូវការនៃសេវាកម្មបន្ទាប់បន្សំ និងវិភាគពីមូលហេតុដែលប៉ះពាល់តម្រូវការ (គ) ក្រុមនិរន្តរភាពខាងហិរញ្ញវត្ថុ ធ្វើការសិក្សាស្រាវជ្រាវជាស្តង់ដារពីគម្រូហិរញ្ញវត្ថុដទៃទៀតដែលប្រតិបត្តិដោយភ្នាក់ងារបន្ទាប់បន្សំដែលទាក់ទង (ឃ) ក្រុមការរៀបចំនិងការប្រតិបត្តិ ធ្វើរបាយការណ៍លើរចនាសម្ព័ន្ធអង្គការនិងគម្រូហិរញ្ញវត្ថុដែលមានប្រសិទ្ធភាពបំផុត ជាមួយនិងចំនួនបុគ្គលិកដែលត្រូវការ ក៏ដូចជាជំហានសម្រាប់ប្រតិបត្តិការរបស់វា។

គ- សម្មិទ្ធផលការអនុវត្តល្អនៃភូកេត

- សហគមន៍ក្នុងក្រុងចាស់និងក្នុងទីប្រជុំជនបានក្លាយជាអ្នកសកម្មមុនក្នុងការអភិរក្សនៃក្រុងចាស់សម្រាប់ភាពទាក់ទាញវប្បធម៌សម្រាប់វិស័យទេសចរណ៍ភូកេត។ ដំបូងឡើយគឺម្ចាស់ឬអ្នកជួលដែលខិតខំផ្លាស់ថ្មីអាគារក្នុងក្រុងចាស់ឲ្យមានលក្ខណៈដូចទៅនឹងសភាពដើមទោះបីត្រូវចំណាយខ្ពស់សម្រាប់ការសាងសង់ក៏ដោយ។ ក្រោយមកក្នុងឆ្នាំ១៩៩០ សមាគមន៍ស្ថាបត្យកម្មSiamបានប្រគល់រង្វាន់H.R.H. ដោយព្រះអង្គម្ចាស់ក្សត្រីSirindhornទៅកាន់អ្នកជួលសម្រាប់ការខិតខំអភិរក្សដ៏ល្អ។

- ប្រជាជននៅក្នុងក្រុងចាស់បានចូលរួមក្នុងសកម្មភាពអភិរក្សអាគារនិងទំនៀមទំលាប់ចាស់ៗ ឧទាហរណ៍ ដូចជាសំលៀកបំពាក់ រូបមន្តធ្វើម្ហូប ពិធីមង្គលការ ពិធីសាសនា ។ល។ ដែលទាំងនេះមានការទាក់ទាញខ្លាំងសម្រាប់ទេសចរ ហេតុនេះហើយបង្កើតប្រាក់ចំណូលបន្ថែម។ ក្នុងឆ្នាំ១៩៩៧ ក្រុមនេះបានទទួលការសរសើរពីគណៈកម្មាធិការអភិរក្សមរតកថៃសម្រាប់កិច្ចការអភិរក្សស្ថាបត្យកម្មរបស់ពួកគេ។

- សហការរវាងរដ្ឋាភិបាល វិស័យឯកជន និងប្រជាជនក្នុងការអភិរក្សនិងការអភិវឌ្ឍន៍នៃក្រុងចាស់ដើម្បីរក្សាអត្តសញ្ញាណនិងមោទនភាពទីជំនាន់មួយទៅជំនាន់មួយ។ ក្នុងឆ្នាំ២០០០ សាលាក្រុងបានឈ្នះរង្វាន់មួយពីមូលនិធិអភិវឌ្ឍន៍ក្រុងគឺឋានៈ ទីក្រុងនៃអត្តសញ្ញាណ។

- ការវិលត្រឡប់មកវិញនៃអ្នកជំនាន់ក្រោយទៅកាន់ភូកេត។កាលពីអតីតកាល អ្នកជំនាន់វ័យក្មេងនឹងមិនត្រឡប់មកភូកេតដើម្បីរស់នៅវិញទេក្រោយពេលដែលពួកគេ

ត្រូវបានបញ្ជូនទៅសិក្សានៅកន្លែងផ្សេង ប៉ុន្តែក្រោយពេលក្រុងចាស់ត្រូវបានអភិវឌ្ឍ អ្នកជំនាន់វ័យក្មេងបានចាប់ផ្តើមត្រឡប់មកវិញសម្រាប់ការពង្រីកអាជីវកម្មរបស់ឪពុកម្តាយពួកគេឬចាប់ផ្តើមអាជីវកម្មមួយទាក់ទាងនឹងវិស័យទេសចរណ៍ដោយខ្លួនឯងផ្ទាល់ ដូចជាភោជនីយដ្ឋាន សណ្ឋាគារ ហាងរូបថត ។ល។ ពួកគេទទួលបានចំណូលជាមធ្យម១០០០ដុល្លាសហរដ្ឋអាមេរិចក្នុងមួយខែ។

- **តម្លៃនៃអចលនទ្រព្យបានឡើងខ្ពស់យ៉ាងរហ័ស។ អ្នកវិនិយោគពីក្រៅតំបន់ទាំងជនជាតិថៃនិងបរទេសបានមានចំណាប់អារម្មណ៍ក្នុងការវិនិយោគនៅតំបន់អភិវឌ្ឍ ហើយសាលាក្រុងអាចទទួលបានចំណូលពីពន្ធនៅថ្ងៃអនាគត។**

ចំពោះស្តង់ដារស់នៅនៃប្រជាជនមូលដ្ឋាន ការអភិវឌ្ឍនេះបាននាំមកនូវការពេញចិត្តជាលទ្ធផលនៃអ្វីដែលពួកគេបានធ្វើសម្រាប់ការអភិរក្សនៃក្រុងចាស់:

- **បរិស្ថានរូបសាស្ត្រត្រូវបានអភិវឌ្ឍយ៉ាងល្អ ដូចជាផ្លូវសម្រាប់ដើរ ការដាក់ខ្សែភ្លើងក្នុងដី ការគ្រប់គ្រងរន្ទះបាញ់និងទឹកជំនន់ និងការគ្រប់គ្រងសំណល់រឹង បានធ្វើឲ្យគុណភាពនៃជីវិតនៃអ្នកមូលដ្ឋានមានភាពល្អប្រសើរឡើង។**
- **ក្រុងចាស់បានក្លាយជាចំនុចទាក់ទាញទេសចរដ៏ល្បីល្បាញ ទាក់ទាញភ្ញៀវទេសចរបានច្រើនជាងពីអតីតកាលដែលកាលនោះមានតែតំបន់មាត់ឆ្នេរទេដែលមានមនុស្សច្រើន។ ប្រជាជនមូលដ្ឋានអាចរកបានប្រាក់ចំណូលច្រើនជាងមុន ហើយសេដ្ឋកិច្ចជាទូទៅគឺមានការកែលម្អ។**

### ឃ- ឱកាសនិងការលំបាក

ការចូលរួមគឺជាគន្លឹះ។ រដ្ឋាភិបាល ឯកជន និងសង្គមស៊ីវិលគឺជាអ្នកដើរតួនាទីជាពិសេសសង្គមស៊ីវិលដែលទើបតែបង្កើតគឺមូលនិធិក្រុងចាស់និងសហគមន៍ក្រុងចាស់ភូកេតគឺជាម្ចាស់ពិតប្រាកដនិងអ្នកជួលដែលរស់នៅទីនោះ។ ពួកគេចូលរួមការសន្ទនានិងជួយវិនិយោគតាំងពីដើមដើម្បីអភិវឌ្ឍយ៉ាងសកម្មនូវផ្ទះជាទីស្រលាញ់របស់ពួកគេ ជាមួយនឹងការវាយតម្លៃនិងការកែលម្អជាលំដាប់។ គម្រូការអភិវឌ្ឍនេះគួរតែមាននិរន្តរភាពពិតប្រាកដ។

ការចូលរួមពីប្រជាជនហាក់បីដូចជាដំណើរការដែលល្អប៉ុន្តែត្រូវចំណាយពេលច្រើននៃគម្រោងដែលជោគជ័យមួយ។ ក្នុងករណីនេះ ដើម្បីទទួលបានការជឿជាក់និងការចូលរួមពីប្រជាជនសាលាក្រុងភូកេតបានចំណាយអស់ពេលជាច្រើន។ ការទទួលបានការចូលរួមពីប្រជាជនគឺជាផ្នែកមួយដ៏លំបាកនៃការអនុវត្តនេះ។ ប៉ុន្តែនៅពេលដែលសម្រេចបាន ការអភិវឌ្ឍគឺធានាថានឹងទទួលបានជោគជ័យដោយរលូន។

បច្ចុប្បន្ននេះ ទីក្រុងតាមបណ្ដាប្រទេសអាស៊ានដែលជំរុញដោយកំលាំងសេដ្ឋកិច្ចនិងការរីកចម្រើនផ្នែកបច្ចេកវិទ្យា កំពុងអភិវឌ្ឍក្នុងល្បឿនលឿន។ មជ្ឈមណ្ឌលពាណិជ្ជកម្មទំនើបនិងថ្មីៗត្រូវបានបង្កើត ធ្វើឲ្យផ្នែកចាស់ៗនៃក្រុងត្រូវបានបោះបង់ចោលឬដល់ថ្នាក់ត្រូវកំទិចចោលទោះបីវាមានតម្លៃខាងប្រវត្តិសាស្ត្រច្រើនឬតិចក្ដី។ ជាងនេះទៅទៀត ផ្នែកថ្មីនិងទំនើបនៃក្រុងដែលគ្មានអត្តសញ្ញាណអ្វី គឺទាក់ទាញណាស់ដែលប្រជាជនចាកចេញពីផ្ទះរបស់ខ្លួនហើយរើមកនៅក្នុងក្រុង។

គម្រូនេះអាចជាឧទាហរណ៍ដ៏ល្អមួយសម្រាប់រដ្ឋបាលមូលដ្ឋានក្នុងការយកចិត្តទុកដាក់ដល់ផ្នែកមានតម្លៃខាងប្រវត្តិសាស្ត្រនៃក្រុង។ មិនត្រឹមតែសង្កត់ធ្ងន់ទៅលើអត្តសញ្ញាណរបស់ខ្លួននិងធ្វើឲ្យអ្នករស់នៅមានមោទនភាពនឹងតំបន់របស់ពួកគេ ប៉ុន្តែវាក៏បានបង្កើតកំលាំងជំរុញសេដ្ឋកិច្ចថ្មីមួយតាមរយៈវិស័យកសិកម្ម។

**កម្រងសំនួរណែនាំសម្រាប់អ្នកហាត់រៀន/អ្នកចូលរួម៖**

ក. តើបញ្ហាមូលដ្ឋានអ្វីដែលការគ្រប់គ្រងនៃអ្នកលក់តាមផ្លូវខិតខំដោះស្រាយ?

ខ. តើកម្មវត្ថុនៃគម្រោងនោះមានអ្វីខ្លះ? តើធាតុសំខាន់ៗរបស់វាមានអ្វីខ្លះ?

គ. តើគម្រោងនោះត្រូវបានប្រតិបត្តិយ៉ាងដូចម្តេច?

ង. តើអ្វីខ្លះជាលទ្ធផលនៃគម្រោងនោះ?

ច. តើគម្រោងនោះមានធាតុថ្មីៗដែលឬទេ? ចូរបកស្រាយប្រសិនបើមាន។

ឆ. តើមានការលំបាកអ្វីខ្លះនៃគម្រោងដែលអ្នកអាចកំណត់បាន? ចូរបកស្រាយថាតើការលំបាកទាំងនោះត្រូវបានដោះស្រាយយ៉ាងដូចម្តេចនៅក្នុងគម្រោងនោះ។

ជ. តើមានមេរៀនសំខាន់ៗអ្វីខ្លះដែលអ្នកអាចទាញចេញពីការសិក្សានេះដែលអាចជាផលប្រយោជន៍នៅក្នុងគម្រោងស្រដៀងគ្នានៅពេលអនាគត?

## ៦-៣ មេរៀនពីករណីការសិក្សាទាំងបី

### ប្រសិទ្ធភាពនិងភាពផ្តល់ឲ្យនូវផលល្អ

- រួមចំណែកធ្វើឲ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច (ការរីកចម្រើននៃពាណិជ្ជកម្មមូលដ្ឋាន; ការកើនឡើងនៃប្រាក់ចំណូលរបស់សហគ្រិនក្នុងស្រុក)។
- ការផ្តល់សិទ្ធិអំណាចនិងការចូលរួមនៃប្រជាជនដែលជាពិសេសគឺក្រុមប្រជាជនក្រីក្រនិងដាច់ស្រយាលក្នុងអភិបាលកិច្ចមូលដ្ឋានដូចជា ប្រជាជនជាផ្នែកមួយនៃដំណើរការសម្រេចចិត្ត; ប្រជាជនជាអ្នកផលិតដ៏សំខាន់ អ្នកផ្តល់សេវាកម្មដ៏សំខាន់។
- អភិរក្សនិងការការពារនៃបរិស្ថាន ដូចជាការគ្រប់គ្រងធនធានឆ្នេរ។
- អភិរក្សនិងការការពារនៃមរតកវប្បធម៌ ដូចជាទីកន្លែងឬក្រុងប្រវត្តិសាស្ត្រនិងចំណាស់។
- ការប្រើប្រាស់គោលការណ៍ការយកមកវិញនូវប្រាក់ដើម។

### និរន្តរភាពនៃផាតុចេញ

- វិនិយោគនិងភាពជាម្ចាស់ដោយអ្នករួមចំណែកច្រើនភាគី (រដ្ឋាភិបាលមូលដ្ឋាន កសិករ អ្នកនេសាទ សហគ្រិនមូលដ្ឋាន)
- គម្រោងជាសហគ្រាសដែលទ្រទ្រង់ដោយខ្លួនឯង
- ការប្រើប្រាស់នៃធនធាននិងជំនាញមូលដ្ឋាន និងការគោរពចំពោះបរិស្ថាន
- ការសម្របសម្រួលយ៉ាងរឹងមាំរវាងរដ្ឋាភិបាលមូលដ្ឋាននិងវិស័យឯកជន

# ជំពូកទី ៤

# ការផ្ទេរទស្សនៈ៖ ការបណ្តុះបណ្តាល ការតាមដាន និងការរាយការណ៍ នៃការអនុវត្តតាមការអនុវត្តន៍ល្អ

ដោយ Susanne Stephan and EriTrinurini-Adhi

# ជំពូកទី ៤

## ការផ្ទេរទស្សនៈ ការបណ្តុះបណ្តាល ការតាមដាន និងការរាយការណ៍នៃការអនុវត្តតាមការអនុវត្តន៍ល្អ

### មាតិកា


៧-១ គោលបំណង និង សារតា

៧-២ អភិក្រមនៃការផ្ទេរទស្សនទាន

៧-២-១ សកម្មភាពត្រៀមរៀបចំ

៧-២-២ ការអភិវឌ្ឍន៍ការផ្ទេរទស្សនៈទាន-អភិក្រមសម្របសម្រួល

៧-៣ វគ្គបណ្តុះបណ្តាលសម្រាប់អ្នកពាក់ព័ន្ធមូលដ្ឋាន

៧-៤ ការត្រួតពិនិត្យ និងការរាយការណ៍

៧-៤-១ និយមន័យ និង សេចក្តីផ្តើមនៃការត្រួតពិនិត្យគម្រោង

៧-៤-២ ការតាមដានទីក្រុងសាកល្បង

## ៧-១ គោលបំណង និង សារតា

គម្រោង DELGOSEA បានធ្វើឲ្យកម្មវិធីហ្វឹកហ្វឺនឲ្យមានភាពធំទូលាយសម្រាប់អ្នកសម្របសម្រួលជាច្រើន។ កម្មវិធីសិក្សានិងសេចក្តីណែនាំការបង្រៀន មិនមែនជាផ្នែកនៃការបោះពុម្ពផ្សាយសៀវភៅនេះទេ ប៉ុន្តែអាចទាញយកពត៌មានទាំងនោះបានតាមរយៈគេហទំព័រ www.delgosea.eu.

ក្រោយពីបានហ្វឹកហាត់ជាអ្នកសម្របសម្រួល អ្នកជំនាញទាំងនោះបានត្រៀមខ្លួនជាស្រេច សម្រាប់ជួយគាំទ្ររដ្ឋាភិបាលក្នុងតំបន់ក្នុងការអនុវត្តតាមការអនុវត្តន៍ល្អ ទៅលើអភិបាលកិច្ចមូលដ្ឋាន។ ក្នុងដំណាក់កាលនេះ រដ្ឋាភិបាលក្នុងតំបន់បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់ជាមួយនឹងគម្រោង និងបានជ្រើសរើសរួមទាំងបានសិក្សាយ៉ាងទូលំទូលាយអំពី ការអនុវត្តន៍ល្អ ពីប្រទេសដទៃ ដែលប្រទេសទាំងនោះមានបំណងធ្វើតាមក្នុងតំបន់របស់ពួកគេ។ ក្នុងករណីខ្លះទៀត ជំហានដំបូងសម្រាប់ការអនុវត្តឡើងវិញនៃការអនុវត្តន៍ល្អអាចត្រូវបានយកមកប្រើប្រាស់រួចទៅហើយ។

មុនពេលការអនុវត្តឡើងវិញអាចចាប់ផ្តើមបាន ការសំខាន់បំផុតនោះគឺការបកប្រែការអនុវត្តន៍ល្អទៅតាម វប្បធម៌ នយោបាយ និង លក្ខខណ្ឌគម្រោងស្របច្បាប់ជាក់លាក់នៃប្រទេសសាកល្បងនីមួយៗ។ ក្រោយពីការផ្ទេរទស្សនៈ ត្រូវបានបង្កើតឡើង ការហ្វឹកហ្វឺនជាបន្តបន្ទាប់ សម្រាប់អ្នកចូលរួមក្នុងតំបន់អាចនឹងត្រូវការ។ដំណើរការក្នុងការផលិតឡើងវិញត្រូវមានការតាមដាន និងរាយការណ៍សកម្មភាពជាច្រើន។

ដូច្នេះជំពូកនេះមានគោលបំណង ពង្រីកបន្ថែមចំនេះដឹងរបស់អ្នកសម្របសម្រួលក្នុងការ ជួយទ្រទ្រង់រដ្ឋាភិបាលក្នុងតំបន់នៅពេលនិង រួមជាមួយ

- ដំណើរការក្នុងការអភិវឌ្ឍន៍ការផ្ទេរទស្សនៈ
- ការហ្វឹកហាត់របស់អ្នកចូលរួមក្នុងតំបន់ និង
- ការត្រួតពិនិត្យ និង រាយការណ៍តាមក្រោយ។

ការអនុវត្តតាមអាចកើតឡើងនិងសំរេចទាំងស្រុងបានមិនមែនដោយពឹងទៅលើចំណេះដឹងរបស់អ្នកសម្របសម្រួលតែមួយមុខនោះទេ។ ដើម្បីបង្កើតនិរន្តភាព និង ធានាភាព

ជាម្ចាស់ការ ពោលគឺកត្តាទាំងអស់ត្រូវតែចូលរួមសហការគ្នា។ បណ្តាញនៃអញ្ញាធររដ្ឋាភិបាលក្នុងតំបន់ សមាគមន៍រដ្ឋាភិបាលក្នុងតំបន់ វិទ្យាស្ថានអប់រំ និង NGOs ត្រូវបានបង្កើតឡើងដោយគម្រោងនេះ ដើម្បីជួយដល់ភាពជោគជ័យនៃការអនុវត្តតាម បណ្តាការអនុវត្តន៍ល្អនានាដែលគម្រោងមាន។

## និយមន័យនៃ អ្នកសម្របសម្រួល

សម្រាប់ការអនុវត្តតាមការអនុវត្តន៍ល្អ ជំនួយការបច្ចេកទេសនឹងត្រូវបានផ្តល់ និងជួយគាំទ្រដល់ទីក្រុងសាកល្បងក្នុងដំណើរការការអនុវត្តន៍តាមនេះដោយ ក្នុងន័យបច្ចេកទេសរបស់គម្រោងDELGOSEA មនុស្សម្នាក់នេះត្រូវបានហៅថា **អ្នកសម្របសម្រួលប្រចាំទីក្រុងសាកល្បង។**

## វិធីសាស្រ្តសម្របសម្រួល

**វិធីសាស្រ្តសម្របសម្រួល**គឺមានភាពសមស្របនៅពេលដែលអង្គភាព ខ្វល់ខ្វាយពាក់ពន្ធ័មិនត្រឹមតែពីការសម្រេចចិត្តនោះទេ គឺថែមទាំងរបៀបនៃការសម្រេចចិត្តទៀតផង។ មានន័យថាគោលដៅនៃការអនុវត្តន៍តាមការអនុវត្តន៍ល្អ មិនត្រឹមតែបន្ថែមភាពច្នៃប្រឌិតនោះទេ លើសពីនេះវាមានបំនងចង់បង្កើនសមត្ថភាពនៃអភិបាលកិច្ចមូលដ្ឋានសាកល្បង។

- "បុគ្គលណាដែលអាចធ្វើឲ្យក្រុម រឺអង្គភាពធ្វើការអស់ពីលទ្ធភាពជាង មានសាមគ្គីភាព និងអាចទទួលបានភាពស៊ីចង្វាក់គ្នា គឺជា'content neutral' party ដែលមិនប្រកាន់បក្សពួក រឺ បង្ហាញ រឺ គាំទ្រគំនិតក្នុងពេលប្រជុំ អាចគាំទ្រនីតិវិធីដោយយុត្តិធម៌ដោយបើកចំហនិងរាប់បញ្ចូលដើម្បីសម្រេចការងារក្រុម។
- អ្នកដែលមានចំណែកក្នុងការបង្កើតstructure and processto interactions ធ្វើឲ្យក្រុមអាចដំណើរការបានដោយមានប្រសិទ្ធភាព និងធ្វើការសម្រេចចិត្តប្រកបដោយគុណភាពខ្ពស់។ អ្នកជួយ និងអ្នកជំរុញ ដែលមានគោលដៅរួមគាំទ្រអ្នកដែលសម្រេចបានសកម្មភាពដ៏អស្ចារ្យ។
- ការងាររបស់អ្នកសម្របសម្រួលគឺគាំទ្រអ្នកចូលរួមទាំងអស់ឲ្យគិត និងអនុវត្តឲ្យល្អបំផុត។ ដើម្បីធ្វើវាអោយបាន អ្នកសម្របសម្រួលទាំងអស់ត្រូវជំរុញឲ្យមានការចូលរួម

ទាំងស្រុង ដោយបង្កើនការយល់ដឹងទៅវិញទៅមក និងអប់រំការចែករំលែកការងារ។ ដោយគាំទ្រអ្នកទាំងនោះឲ្យប្រឹងប្រែងគិត អ្នកសម្របសម្រួលអាចធ្វើឲ្យសមាជិកក្រុមស្វែងរកដំណោះស្រាយរួម និងបង្កើតការព្រមព្រៀងប្រកបដោយនិរន្តរភាព។

**៧-២ អភិក្រមនៃការផ្ទេរទស្សនទាន**

ពាក្យបច្ចេកទេស វិធីសាស្ត្រនៃការផ្ទេរទស្សនៈ គឺជាដំណើរការដែលក្នុងពេលចុងក្រោយបង្អស់នឹងទទួលបានទិន្នផល ដែលជាក្រដាសរាយរាប់យ៉ាងល្អិតល្អន់ អំពីផែនទីបង្ហាញផ្លូវសម្រាប់ទីក្រុងសាកល្បងសម្រាប់ឆ្នាំក្រោយៗទៀត។ ផែនទីនេះគឺជាការផ្ទេរទស្សនៈ។ ការផ្ទេរទស្សនៈនេះត្រូវទទួលការយល់ស្របដោយស្របច្បាប់ពី អ្នកសម្រេចចិត្តក្នុងតំបន់ និង ត្រូវរួមបញ្ចូលគ្នាទៅក្នុងផែនការការអភិវឌ្ឍន៍ជាទូទៅរបស់រដ្ឋាភិបាលមូលដ្ឋាន។

ជំហានសម្រាប់ការផ្ទេរទស្សនទានការអនុវត្តន៍ល្អ:

- ការវាយតម្លៃស្ថានភាពក្នុងទីក្រុងសាកល្បង (ការវាយតម្លៃមូលដ្ឋាន ភាពខុសគ្នារវាងការអនុវត្តន៍ល្អ និងទីក្រុងសាកល្បង តម្រូវឲ្យមានការផ្លាស់ប្តូរសម្រាប់ការអនុវត្តតាមការអនុវត្តន៍ល្អ ។ល។
- ការវិភាគអ្នកចូលរួម (តើអ្នកចូលរួមណាគួរចូលរួមក្នុងដំណើរការអនុវត្តតាមវីយុទ្ធសាស្ត្រសម្រាប់ការចូលរួមរបស់ប្រជាជន?)
- អត្ថន័យនៃគោលដៅ (តើអ្នកចង់សម្រេចបានអ្វី?)
- អត្ថន័យនៃលទ្ធផល និងទិន្នផល
- ការអភិវឌ្ឍន៍នៃផែនការសកម្មភាព រួមមានសកម្មភាព តារាងពេលវេលា អ្នកទទួលខុសត្រូវ សូចនាករ និងថវិការ
- ការកំនត់នៃហានិភ័យ និងការគ្រប់គ្រងហានិភ័យ (តើត្រូវគ្រប់គ្រងហានិភ័យដែលអាចកើតមានឡើងដោយរបៀបណា? ហើយត្រូវតបតនិងដោះស្រាយដោយរបៀបណា?)
- ការអភិវឌ្ឍន៍នៃប្រព័ន្ធតាមដាន
- ផលប៉ះពាល់ និងនិរន្តរ៍ភាព

ពត៌មានសំខាន់ផ្សេងទៀតមាន

- ការកំណត់នៃដៃគូយុទ្ធសាស្ត្រ
- ការអភិវឌ្ឍន៍នៃផែនការទំនាក់ទំនង

ដើម្បីផ្សព្វផ្សាយលទ្ធផលក្នុងទីក្រុងសាកល្បង ប៉ុន្តែក៏ឆ្លងកាត់ទៅកាន់ទីក្រុងសាកល្បងក្នុងប្រទេសផ្សេងៗដែរ។

តួនាទីសំខាន់នៃអ្នកសម្របសម្រួលក្នុងវិធីសាស្ត្រនៃការផ្ទេរទស្សនៈ អាចធ្វើឲ្យទីក្រុងសាកល្បងបង្កើតផែនការពិស្តារមួយ អំពីរបៀបនៃការអនុវត្តន៍ដែលបានជ្រើសរើស អាចយកមកអនុវត្តតាមទៅតាមតំបន់ជាក់លាក់។ ចំណែកដំណើរការ និងជំហានផ្សេងៗត្រូវបានបកស្រាយដូចខាងក្រោម៖

### ៧-២-១ សកម្មភាពត្រៀមរៀបចំ

១- ការព្រមព្រៀងគ្នារវាងរដ្ឋាភិបាលក្នុងតំបន់ សមាគមន៍រដ្ឋាភិបាលក្នុងតំបន់ និង គម្រោង DELGOSEA ទៅលើការប្តេជ្ញា និង ការផលិតឡើងវិញនៃការអនុវត្តន៍ល្អ សម្រាប់អភិបាលកិច្ចមូលដ្ឋានក្នុងរដ្ឋាភិបាលក្នុងតំបន់សាកល្បង។

២- ការជួបប្រជុំជាមួយអភិបាលក្រុង និង ក្រុមប្រឹក្សាក្នុងតំបន់៖ ទោះបីជា MoU បានចុះហត្ថលេខា ជាមួយរដ្ឋាភិបាលក្នុងតំបន់សាកល្បងទាំងនោះក៏ដោយ ការប្រជុំបន្ទាប់មកទៀតចាំបាច់ត្រូវមាន ដើម្បីរៀបចំផែនការឲ្យបានច្បាស់ មុនពេលការអនុវត្តន៍ឡើងវិញអាចចាប់ផ្តើមបាន។ ក្នុងពេលជួបប្រជុំចំនុចដូចខាងក្រោមគួរត្រូវបានលើកឡើង

- ការបន្តការគាំទ្រលើគោលនយោបាយនៅពេលការអនុវត្តតាមការអនុវត្តន៍ល្អ៖ តើមានឧបសគ្គណាខ្លះ ដែលអាចគិតទុកមុនថានឹងកើតចេញពីវិសាលគមគោលនយោបាយ? តើការបោះឆ្នោត និង រដ្ឋាភិបាលក្នុងតំបន់ថ្មីជះឥទ្ធិពលដល់ដំណើរការការអនុវត្តន៍ឡើងវិញ ដោយរបៀបណា? តើក្នុងដំណើរការអនុវត្តន៍ឡើងវិញអាចធ្វើឲ្យមាននិរន្តភាព និង អាចរួមបញ្ចូលក្នុងច្បាប់ក្នុងតំបន់បានដោយ របៀបណា?
- ថវិការក្នុងតំបន់សម្រាប់ប្រើប្រាស់មានគ្រប់គ្រាន់សម្រាប់ដំណើរការ ការអនុវត្តន៍តាម (ពេលវេលាអាចជាបញ្ហា ដោយសារចំនួនក្រុមគ្រួសារត្រូវបានទទួលស្គាល់មួយឆ្នាំមុន)។

- ការកំនត់នៃក្រុមការងារ/អ្នកចូលរួមមូលដ្ឋាន: តើអ្នកចូលរួមណាដែលពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍ការផ្ទេរទស្សន:? តើការចូលរួមរបស់ប្រជាជនអាចជឿទុកចិត្តបានដោយរបៀបណាក្នុងការអភិវឌ្ឍន៍ទស្សន:?
- សមត្ថភាព: តើអ្នកជំនាញប្រភេទណាដែលត្រូវការសម្រាប់ការអភិវឌ្ឍន៍ការផ្ទេរគោលគំនិត? តើទីក្រុងសាកល្បងមានតម្រូវការអ្វីខ្លះ? តើមានធនធានមនុស្សដែលអាចទទួលខុសត្រូវលើការងារមួយចំនួនបានរឺទេនៅក្នុងទីក្រុងសាកល្បង?
- ដំណើរការទំនាក់ទំនង: តើដំណើរការទំនាក់ទំនងរវាងគម្រោង រដ្ឋបាលមូលដ្ឋាន រដ្ឋាភិបាលមូលដ្ឋានសាកល្បង និង អ្នកសម្របសម្រួលគួរតែរៀបចំដោយរបៀបណា?
- កាលវិភាគសម្រាប់ការអភិវឌ្ឍន៍ការផ្ទេរគោលគំនិត។

### ៧-២-២ ការអភិវឌ្ឍន៍ការផ្ទេរទស្សនៈទាន-អភិក្រមសម្របសម្រួល

វិធីសាស្ត្រសម្របសម្រួល

#### ក- ការជ្រើសរើស និង តួនាទីរបស់អ្នកសម្របសម្រួល

ក្រោយពីបានជួបនិងផ្លាស់ប្តូរយោបល់ជាមួយអ្នកសម្រេចចិត្តក្នុងតំបន់រួចមក ជាការងាររបស់ក្រុម DELGOSEA ដើម្បីជ្រើសរើស អ្នកសម្របសម្រួលត្រឹមត្រូវសម្រាប់ទីក្រុងសាកល្បងនានា។ នៅទីនេះមិនត្រឹមតែគុណសម្បត្តិទេដែលមានសារៈសំខាន់ តែការផ្តុំចូលគ្នានូវលក្ខណៈសម្បត្តិផ្សេងៗក៏ចូលរួមចំនែកផងដែរ។ ក្នុងនោះតម្រូវការវប្បធម៌ និង ភាសាក៏មានមុខងារដ៏សំខាន់ដែរ។

ក្រៅពីនេះ តួនាទីជាក់លាក់របស់អ្នកសម្របសម្រួលនឹងត្រូវបានបង្ហាញ។ តួនាទីទាំងនោះ អាចខុសគ្នា ពីការសម្របសម្រួលដំណើរការទាំងមូល កំឡុងពេលការអភិវឌ្ឍន៍គោលគំនិត ពីការក្លាយជាអ្នកសម្របសម្រួលសិក្ខាសិលា ឬ ការដើរតួជាអ្នកសរសេរផ្នែករបស់មេរៀន ទាំងនោះ ក៏ពឹងផ្អែកយ៉ាងច្រើនទៅលើ សមត្ថភាពដែលទីក្រុងមាន។

### ខ- ការវិភាគពីសមាសភាពអ្នកពាក់ពន្ធ័

ការវិភាគអ្នកចូលរួមតាំងចិត្តដើម្បីរកឲ្យឃើញនូវមុខងារ តួនាទី និង ឧបសគ្គនៃគ្រឹះស្ថាន ដែលទទួលខុសត្រូវសម្រាប់ការធ្វើតាមការអនុវត្តន៍ល្អក្នុងទីក្រុងសាកល្បង។ ការវិភាគលើអ្នកពាក់ពន្ធ័ មិនគួរមានតែចំពោះគ្រឹះស្ថានរដ្ឋបាលមូលដ្ឋានប៉ុណ្ណោះទេ តែគួរត្រូវបានពង្រីកទៅដល់គ្រឹះស្ថានដទៃទៀត ដែលសំខាន់សម្រាប់ភាពជោគជ័យនៃការធ្វើតាមការអនុវត្តន៍ល្អ ដូចជា អ្នកតំណាងប្រជាជន អ្នកតំណាងនៃសង្គមស៊ីវិល និង សារពត៌មានក្នុងស្រុក។ ការវិភាគអ្នកចូលរួមនេះ នឹងមានសារៈសំខាន់ក្នុងការធានាទៅលើការចូលរួមរបស់ប្រជាជន ក្នុងដំណើរការអនុវត្តតាមនេះ។

### គ- សិក្ខាសាលាសម្រាប់ការអភិវឌ្ឍន៏ការផ្ទេរទស្សនៈ

**គោលបំណង៖** អ្នកចូលរួមទាំងអស់មានការយល់ដឹងច្បាស់ អំពីគោលដៅ លទ្ធផល ផែនការ រួមទាំងហានិភ័យដែលអាចកើតមានសម្រាប់ការការអនុវត្តតាមនៃការអនុវត្តន៍ល្អដែលបានជ្រើសរើស។

ក្រោយពីបានរកឃើញនូវអ្នកសម្របសម្រួលដែលជួយដល់ទីក្រុងសម្រាប់សាកល្បងក្នុងពេលអភិវឌ្ឍន៏ការផ្ទេរគោលគំនិត កាលវិភាគជាក់លាក់គួរត្រូវលើកយកមកពិភាក្សា និងយល់ស្របដោយក្រុមការងារអ្នកសម្របសម្រួល។

ជំហានដ៏សំខាន់គឺការរៀបចំសិក្ខាសាលាដើម្បីប្រមូលផ្តុំគំនិត សម្រាប់ការផ្ទេរគោលគំនិត។ ដោយគិតទៅលើលទ្ធផលនៃការវិភាគអ្នកមានចំណែក អ្នកចូលរួមសិក្ខាសាលាគួរតែត្រូវបានស្នើសុំនិងរកឃើញដោយក្រុមការងារមូលដ្ឋាន។ ជាមួយនឹងការធ្វើបែបនេះ វាធានាឲ្យបានថា អ្នកតំណាងមកពីក្រុមសំខាន់ៗ ដែលទទួលឥទ្ធិពលពីសកម្មភាពនៃការអនុវត្តន៍តាមនឹងត្រូវបានចូលរួមក្នុងសិក្ខាសាលានេះគួរមានរយៈពេល២ថ្ងៃ។

សិក្ខាសាលាបន្ថែមទៀត ដែលនៅក្នុងចំនោមអ្នករួមចំនែកមូលដ្ឋាន អាចត្រូវការសម្រាប់ការរៀបចំ រី សកម្មភាពបន្តមកទៀត។ ការសង្ខេបខាងក្រោមនឹងផ្តោតសំខាន់ទៅលើសិក្ខាសាលាគោលដែលដឹកនាំដោយអ្នកសម្របសម្រួល។ មានវិធីជាច្រើនដែលសិក្ខាសាលានេះអាចរៀបចំបានដោយវិធីសាស្រ្ត ដែលមានដូចខាងក្រោម៖

**១- ការវាយតម្លៃស្ថានភាពក្នុងទីក្រុងសាកល្បង** (ការវាយតម្លៃមូលដ្ឋាន ភាពខុសគ្នារវាងការអនុវត្តន៍ល្អ និងកន្លែងសាកល្បង តម្រូវឲ្យមានការផ្លាស់ប្តូរសម្រាប់ការចម្លងតាមការអនុវត្តន៍ល្អ ។ល។)

ជំហានដំបូងការអនុវត្តន៍ល្អ ដែលត្រូវបានជ្រើសរើសហើយ គួរយកមកធ្វើបទបង្ហាញម្តងទៀត។ អ្នកចូលរួមនឹងត្រូវសួរឲ្យសង្ខេបខ្លឹមសារនៃការអនុវត្តន៍ល្អ ឲ្យពិនិត្យទៅលើបរិស្ថាននយោបាយ និង វប្បធម៌ជាក់លាក់ ដែលការអនុវត្តន៍ល្អត្រូវបានយកមកប្រតិបត្តិ ការប្រមូលយកគំនិតច្នៃប្រឌិត ក៏ដូចជាគិតអំពីឧបសគ្គ និង ឱកាសក្នុងពេលប្រតិបត្តិ។

ក្នុងជំហានទី២ ពួកគេនឹងត្រូវបានសួរឲ្យធ្វើការវិភាគទៅលើភាពខុសគ្នារវាង ទីក្រុងនៃការអនុវត្តន៍ល្អ និង តំបន់របស់ពួកគេ។ តើការរៀបចំឡើងផ្នែកនយោបាយ ការអប់រំ និង វប្បធម៌ខុសគ្នា អាចជះឥទ្ធិពលយ៉ាងណាដល់ការធ្វើតាមការអនុវត្តន៍ល្អ? តើមានរយៈពេលយូរប៉ុណ្ណាទើប ការអនុវត្តន៍ល្អត្រូវបានទទួលយកក្នុងលក្ខខណ្ឌច្បាស់លាស់នៃទីក្រុងសាកល្បង?

**២- ការអភិវឌ្ឍន៍នៃគោលដៅ លទ្ធផល និងទិន្នផល**

ក្រោយពីការវិភាគការអនុវត្តន៍ល្អ និង ការវាយតម្លៃដែលអាចយកជាការបាន អ្នកចូលរួមនឹងត្រូវបានសួរ ដើម្បីអភិវឌ្ឍន៍កម្មវត្ថុ លទ្ធផល និង ទិន្នផល។ សំណួរសំខាន់គឺ អ្វីដែលពួកគេចង់ទទួលបានក្នុងរយៈពេលមួយ។ ថានានុក្រមនៃគោលបំណង ធ្វើទៅតាមគោលការណ៍នៃក្របខណ្ឌតកភាព។

**គោលបំណងជាទូទៅ**: ជាគោលបំណង ដែលគម្រោងគួរផ្តល់ជំនួយ។ តាមរយៈគម្រោង DELGOSEAគោលបំណងទូទៅអាចជាការចូលរួមក្នុងសេវាកម្មចែកចាយអោយកាន់តែប្រសើរនិងស្ថានភាពរស់នៅប្រសើរ សម្រាប់ប្រជាជនក្នុងស្រុក។

**គោលបំណងជាក់លាក់**: គឺគោលបំណង ដែលគម្រោងចង់សម្រេចបានទៅតាមតារាងពេលវេលា។ គោលបំណងជាក់លាក់ត្រូវតែមានភាពពិតប្រាកដ ច្បាស់លាស់ អាចសម្រេចបាន និង អាចវាស់វែងបាន។ ឧទាហរណ៍: ការបង្កើតឡើងនៃប្រព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិចសង្កត់ធ្ងន់ទៅលើ XXXXនៅផ្នែករដ្ឋាបាលក្រុងនៃXXXX។

**លទ្ធផល** គឺជាជំហានខុសៗគ្នា ដែលត្រូវការដើម្បីសម្រេចបាននូវគោលបំណងជាក់លាក់។ឧទាហរណ៍លទ្ធផលអាចជាសេវាកម្មមួយត្រូវបានរួមបញ្ចូលក្នុងប្រព័ន្ធអ៊ីនធឺណេត។

**ទិន្នផល** គឺជាគុណសម្បត្តិនៃលទ្ធផល និង សកម្មភាព។ ឧទាហរណ៍ ចំនួនមនុស្សត្រូវបានបង្ហាត់បង្រៀន ចំនួននៃប្រតិបត្តិការធ្វើឡើងដោយរដ្ឋាភិបាលអេឡិចត្រូនិច។

ការកំនត់ច្បាស់លាស់នៃគោលបំណងគម្រោង និង វិធីសាស្រ្តមានភាពផ្ទុយគ្នាពីរៈ ១) ទទួលយកវិធីសាស្រ្តដូចដែលបានបកស្រាយក្នុងគំរូការអនុវត្តន៍ល្អ រឺ ២) កែសម្រួលគំរូការអនុវត្តន៍ល្អទៅតាមលក្ខខណ្ឌមូលដ្ឋាន ដោយយកតែគំនិតសំខាន់ប៉ុណ្ណោះ និង ការតម្រង់ទិសពីទស្សនៈដើម។ វិធីសាស្រ្តកែសម្រួល អាចនាំឲ្យគំរូខុសគ្នាជាមួយនឹងមាតិកា ទម្រង់ សូម្បីតែលទ្ធផល។ ទាំងអស់នេះ នឹងត្រូវបានពិភាក្សាយ៉ាងហ្មត់ចត់ជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗដែលចូលរួមក្នុងសិក្ខាសាលា។

**៣- ផែនការសកម្មភាព**

ផែនការសកម្មភាព ត្រូវបានយកមកពីគោលបំណង លទ្ធផល និងទិន្នផល។ អ្នកចូលរួមនឹងត្រូវបានសួរ ដើម្បីកំណត់ឲ្យច្បាស់ពីសកម្មភាព ដែលនឹងត្រូវការដើម្បីសម្រេចបានលទ្ធផល។ សកម្មភាពនឹងត្រូវបានផ្តុំក្នុងលទ្ធផលនៃគម្រោង។ សម្រាប់សកម្មភាពនីមួយៗ ពេលវេលា ភាគីទទួលខុសត្រូវ រួមទាំងគម្រោងថវិការនឹងត្រូវបានកំនត់។ គ្រោងការណ៍ខាងក្រោមអាចជាឧបករណ៍សំខាន់មួយ សម្រាប់ការបង្កើតផែនការសកម្មភាព

| **លទ្ធផលរំពឹងទុក** | **ផែនការសកម្មភាព** PLANNED ACTIVITIES | **ពេលវេលា** TIMEFRAME | | | | **អ្នកទទួលខុសត្រូវ** RESPONSIBLE PARTY | **ផែនការថវិការ** PLANNED BUDGET | |
|---|---|---|---|---|---|---|---|---|
| | *associated actions* | Q1 | Q2 | Q3 | Q4 | | Funding Source | Amount |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Result 1:<br><br>*Indicators:* | - Action<br><br>- Action | | | | | | | |
| | - Action<br><br>- Action | | | | | | | |
| | - Action<br><br>- Action | | | | | | | |
| Result 2<br><br>*Indicators:* | - Action<br><br>- Action | | | | | | | |
| | - Action<br><br>- Action | | | | | | | |
| | - Action<br><br>- Action | | | | | | | |
| | | | | | | | | |

### ៤- ការកំណត់ហានិភ័យ និងការគ្រប់គ្រងហានិភ័យ

ដោយធ្វើទៅតាមផែនការសកម្មភាពហានិភ័យអាចរាំងស្ទះសមិទ្ធផលនៃផែនការសកម្មភាពគួរយកមកពិនិត្យមើល។ ហានិភ័យអាចបណ្តាលមកពីការជះឥទ្ធិពលពីកត្តាខាងក្រៅ (គ្រោះធម្មជាតិ អស្ថេរភាពនយោបាយ) រឺកត្តាខាងក្នុង (រចនាសម្ព័ន្ធក្នុងការសម្រេចចិត្តមិនច្បាស់លាស់ គ្មានការប្តេជ្ញាចិត្តពីអ្នកចូលរួមសំខាន់ៗ)។យុទ្ធសាស្ត្រដើម្បីឆ្លើយតបនឹងហានិភ័យនីមួយៗ គួរត្រូវបានបរិយាយយ៉ាងល្អិតល្អន់។

### ៥- ការត្រួតពិនិត្យផ្ទៃក្នុង

ក្នុងជំពូក ៤.៤ បានវែកញែកយ៉ាងល្អិតល្អន់ជាមួយនឹងការត្រួតពិនិត្យគម្រោងដោយអ្នកសម្របសម្រួល។ បន្ថែមទៅលើការត្រួតពិនិត្យ ដែលធ្វើដោយអ្នកសម្របសម្រួលប្រចាំទីក្រុងសាកល្បងផ្ទាល់នឹងត្រូវស្ថិតនៅក្នុងតំបន់សមស្របសម្រាប់ប្រព័ន្ធត្រួតពិនិត្យដែលធានាទៅលើផែនការថ្មីៗ និង ប្រសិនបើចាំបាច់ត្រូវចាត់វិធានការដោះស្រាយ។ គម្រោងជាច្រើនមិនអាចសម្រេចបានដោយសារខ្វះការត្រួតពិនិត្យ និង សកម្មភាពភាពបន្ទាប់បន្សំនោះទេ។ ក្នុងសិក្ខាសាលាវាមិនអាចមានពេលគ្រប់គ្រាន់ទេសម្រាប់ធ្វើការពិភាក្សាឲ្យបានច្បាស់ ពីការបង្កើតការត្រួតពិនិត្យនៅក្នុងទីក្រុងសាកល្បងនីមួយៗ។ ដោយឡែកអ្នកចូលរួមគួរចាប់អារម្មណ៍ទៅលើភាពចាំបាច់ និងគួរតម្រូវឲ្យកត់សំគាល់លើទស្សនៈដែលអាចបញ្ចូលទៅក្នុងការផ្ទេរទស្សនៈនៅវគ្គបន្ទាប់ទៀត។ បើសិនជាចាំបាច់ អ្នកសម្របសម្រួលអាចជួយគាំទ្របន្ថែមបន្ទាប់ពីសិក្ខាសាលា។

### ៦- និរន្តរភាព និងផលប៉ះពាល់

ក្នុងពេលពិភាក្សាពីគម្រោងការអនុវត្តតាម វាមានសារៈសំខាន់ណាស់ក្នុងការយកចិត្តទុកដាក់លើនិរន្តរភាព និង ផលប៉ះពាល់នៃដំណើរការការអនុវត្តតាម ដែលអាចជះឥទ្ធិពលដល់ប្រជាជនក្នុងមូលដ្ឋាន។ បញ្ហាចំបងគឺ គម្រោងអាចមាននិរន្តរភាពដោយរបៀបណាបើគិតពីការប្តូរផ្លាស់នៃបរិស្ថាន។ តើជំហានណាខ្លះត្រូវការយកមកធានាពីនិរន្តរភាព ឧទាហរណ៍ ក្រៅពីល័ក្ខខណ្ឌនយោបាយរបស់អ្នកមានសិទ្ធិសម្រេចចិត្ត?

វាក៏សំខាន់ដែរក្នុងការពិភាក្សាពីការជះឥទ្ធិពល។ តើការអនុវត្តតាមបានជះឥទ្ធិពលអ្វីខ្លះ? ដល់ជីវភាពរបស់ប្រជាជន? តើគម្រោងអាចធានាបានដោយរបៀបណាថា គោលដៅទូទៅដើម្បីធ្វើឲ្យជីវភាពរបស់ប្រជាជនមានភាពប្រសើរឡើង នឹងមិនប៉ះពាល់និងមានទំនាស់? ជាថ្មីម្តងទៀត សំណួរទាំងនេះអាចគ្រាន់តែយកមកពិភាក្សាដំបូងប៉ុណ្ណោះក្នុងសិក្ខាសាលា ហើយយើងនឹងត្រូវការសំណួរផ្សេងទៀត។

### ៧- ការសរសេររបាយការណ៍ និងការអនុម័តទស្សនៈ

**លទ្ធផល**:ឯកសារ ដែលមានអត្ថន័យយ៉ាងទូលំទូលាយ បានបង្ហាញយ៉ាងច្បាស់លាស់អំពីគំរូនៃការអនុវត្តន៍តាម គោលបំណង លទ្ធផលនិងផែនការសកម្មភាព ផែនការថវិការ រួមទាំងបញ្ហាប្រឈមដែលអាចកើតមាន ការត្រួតពិនិត្យផ្ទៃក្នុង និង ការធ្វើឲ្យមាននិរន្តរភាព។

បន្ទាប់ពីសិក្ខាសាលាបញ្ចប់ភ្លាម អ្នកសម្របសម្រួលនឹងរៀបចំតារាងនៃទិន្នន័យ និងពត៌មាន ដែលខ្វះហើយវានឹងត្រូវបានប្រមូលនិងបន្ថែមដោយក្រុមការងារមូលដ្ឋាន។ ក្រុមការងារមូលដ្ឋានអាចនឹងតម្រូវឲ្យសង្ខេបគំនិតរបស់ពួកគេ ទៅលើការត្រួតពិនិត្យផ្ទៃក្នុង រួមទាំងនិរន្តរភាព និង ការជះឥទ្ធិពល។ ពួកគេត្រូវតែធ្វើការយ៉ាងជិតស្និទ្ធជាមួយមូលដ្ឋានស្រុករបស់ពួកគេ ដើម្បីធានាឲ្យបាននូវវិធីសាស្ត្ររួមគ្នាមួយ និង ការព្រមព្រៀងចុងក្រោយមួយ។

ផ្អែកទៅលើវត្ថុធាតុដើម ដែលប្រមូលបានពីសិក្ខាសាលា២ថ្ងៃ អ្នកសម្របសម្រួល រឺ អ្នកសរសេរ នឹងចាប់ផ្តើមរៀបចំការព្រាងលើកដំបូង នៃឯកសារការផ្ទេរទស្សនៈ។

ការព្រាងនេះនឹងដាក់បញ្ជូនទៅក្នុងការងារមូលដ្ឋានសម្រាប់មតិបន្ថែម។ ប៉ុន្មានសប្តាហ៍ក្រោយ ឯកសារនេះនឹងត្រូវបានពិនិត្យរហូតដល់កំណែចុងក្រោយត្រូវបានទទួលស្គាល់។

ក្នុងកំណែចុងក្រោយនឹងត្រូវបានបោះពុម្ពផ្សាយ និង ទទួលស្គាល់ជាផ្លូវការដោយអភិបាលក្រុង រឺសមាជិកក្រុមប្រឹក្សា។ វាជាមូលដ្ឋានច្បាប់សម្រាប់ប្រតិបត្តិក្នុងឆ្នាំក្រោយៗទៀត។

គួរកត់សំគាល់ផងដែរថា ការផ្ទេរទស្សនៈនឹងត្រូវបានផ្សព្វផ្សាយរវាងប្រទេសដែលចូលរួមក្នុងសកម្មភាពនេះ។ ទស្សនៈទាំងអស់នឹងត្រូវបានបកប្រែជាភាសាអង់គ្លេសសម្រាប់ជាការចែករំលែកឲ្យគ្នាទៅវិញទៅមក។ ទោះបីជាការផ្ទេរទស្សនៈត្រូវតម្រូវទៅតាមស្ថានភាពនៃប្រទេសសាកល្បងក៏ដោយ ក៏ពួកគេកំពុងជួបប្រទះបញ្ហារួម អញ្ចឹងហើយគឺមានសារសំខាន់សម្រាប់ការផ្ទេរទស្សនឆ្លងប្រទេស។

## ៧-៣ វគ្គបណ្តុះបណ្តាលសម្រាប់អ្នកពាក់ព័ន្ធមូលដ្ឋាន

**គោលបំណង** ដើម្បីផ្តល់គុណសម្បត្តិអ្នកចូលរួមឈានមុខក្នុងការអនុវត្តតាមការអនុវត្តន៍ល្អតាមទីក្រុងសាកល្បងសម្រាប់ការសម្រេចចិត្ត និងការចូលរួមក្នុងដំណើរការផ្ទេរ។

ដោយសារផែនការសកម្មភាពជាផ្នែកនៃការផ្ទេរទស្សនៈ ការវាយតម្លៃជាការចាំបាច់ដើម្បីកំណត់តម្រូវការក្នុងការបង្ហាត់បង្រៀនរបស់អ្នករួមចំណែកមូលដ្ឋាន។ គួរកត់សំគាល់

ដែរថា ផ្នែកសំខាន់នៃការបង្ហាត់បង្រៀនដល់អ្នករួមចំណែកមូលដ្ឋាន នឹងផ្អែកទៅតាមកម្មវិធីបង្ហាត់បង្រៀនរៀបចំដោយក្រុមការងារអន្តរជាតិក្នុងសកម្មភាពដើម។ សៀវភៅនេះនឹងដើរតួជាធនធានចំបងសម្រាប់ការបង្ហាត់បង្រៀន។ ការបោះពុម្ពផ្សាយទាំងពីរ នឹងអាចរកបាននៅក្នុងភាសាផ្សេងៗ។

យ៉ាងណាមិញ កម្មវិធីបង្ហាត់បង្រៀនអាចទទួលយក និង ធ្វើឲ្យច្បាស់លាស់ជាងនេះ ផ្អែកតាមតម្រូវការរបស់ទីក្រុងសាកល្បងនីមួយៗ។ វាជាតួនាទីរបស់អ្នកសម្របសម្រួលជាមួយនឹងការគាំទ្ររបស់ក្រុម DELGOSEAក្នុងការទទួលយកកម្មវិធីសិក្សា និងការរៀបចំការបង្ហាត់បង្រៀន។ វគ្គសិក្សានឹងត្រូវធ្វើឡើងក្នុងបរិវេណរដ្ឋបាលភូមិ ឃុំ។ ជាមធ្យមអ្នកសម្របសម្រួលមាន៣នាក់ នឹងចូលរួមក្នុងវគ្គសិក្សានៅក្នុងទីក្រុងសាកល្បងនិមួយៗរយះពេល៦ថ្ងៃ។

ទីក្រុងសាកល្បងនឹងត្រូវកំណត់អ្នកចូលរួមក្នុងវគ្គសិក្សា ដោយរួមបញ្ចូលថាអ្នកទាំងអស់ដែលពាក់ព័ន្ធក្នុងការអនុវត្តតាមការអនុវត្តល្អគួរតែបានចូលរួម។ ជាមធ្យមអ្នកបម្រើការស៊ីវិល៦នាក់ និង អ្នកតំណាងសង្គមស៊ីវិល១០នាក់ គួរទទួលបានការបង្ហាត់បង្រៀន២ដងសម្រាប់រយះពេល៣ថ្ងៃ ទៅលើការផ្ទេរទស្សនៈ រួមបញ្ចូលទាំងផែនការសកម្មភាព។ ការបង្ហាត់បង្រៀនអាចធ្វើឡើងក្នុងក្រុមតូចៗនៃ អ្នកចូលរួម៥ ទៅ ៦នាក់ក្នុងករណី ការផ្ទេរទស្សនៈគ្របដណ្តប់លើខ្លឹមសារដែលបានកំណត់។ ក្នុងករណីផ្សេងទៀតអាចនឹងត្រូវការអ្នកចូលរួមច្រើនក្នុង១ក្រុម។ ចំនួនជាក់លាក់របស់ អ្នកបម្រើការស៊ីវិលជាក់លាក់នៃរដ្ឋបាលភូមិ ស្រុក និង អ្នកតំណាងសង្គមស៊ីវិល អាចធ្វើទៅតាមតម្រូវការនិងអាទិភាពសម្រាប់តម្រូវភាពពេញលេញលក្ខណៈសម្បត្តិរបស់ទីក្រុងសាកល្បង។ ក្នុងករណីណាក៏ដោយត្រូវមានការធានាថាអ្នកទទួលខុសត្រូវសំខាន់ក្នុងរដ្ឋបាលខេត្ត–ក្រុង និង អ្នកតំណាងសង្គមស៊ីវិលបានចូលរួម។

ប្រសិនបើអាចត្រូវមានការចូលរួមពី អ្នកនយោបាយដែលមានសិទ្ធិសម្រេចចំនួន ១០នាក់ជាមធ្យម ត្រូវមានតំណាងឲ្យក្រុមអ្នកនយោបាយពាក់ព័ន្ធ និង ជាមធ្យមអ្នកកាសែតចំនួន២នាក់ ពីប្រព័ន្ធសារពតិមានក្នុងស្រុក ដែលគួរចូលរួមពីក្នុងទីក្រុងសាកល្បងនិមួយៗ

២ដង រយៈពេល៤ម៉ោង នៅក្នុងវគ្គសិក្សាដើម្បីទទួលបាននូវការណែនាំពីគោលបំណងសំខាន់ និង ទស្សនវិជ្ជានៃការផ្ទេរទស្សនៈ រួមទាំងការសង្ខេបទិដ្ឋភាពទូទៅនៃផែនការការប្រតិបត្តិ។

ចំនុចខាងក្រោមនេះត្រូវបានប្រើប្រាស់សំរាប់ការជ្រើសរើសអ្នកតំណាងសង្គមស៊ីវិលនៅក្នុងវគ្គបណ្តុះបណ្តាល ក៏ប៉ុន្តែគោលការណ៍មួយចំនួនទៀតក៏អាចប្រើប្រាស់បានដែរ

- ប្រសិនបើពួកគេជាតំណាងនៃអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក នោះពួកគាត់ត្រូវជ្រើសរើសចេញពីក្រុមដែលធ្លាប់សហការជាមួយរដ្ឋបាលក្នុងស្រុក
- ក៏ដូចគ្នាដែរសំរាប់អ្នកតំណាងសមាគមអាជីវកម្មឬផ្នែកឯកជន
- យ៉ាងហោចណាស់ក៏ត្រូវមានអ្នកតំណាងមួយរូបដែលមានបទពិសោធន៍ពីមុន
- ក្រុមអ្នកតំណាងទាំងនោះអាចរួមបញ្ចូលពលរដ្ឋ ដែលបានចូលនិវត្តន៍ពីសេវារដ្ឋបាលមូលដ្ឋាន និងមានជំនាញបទពិសោធន៍ខ្ពស់ រួមទាំងពេលវេលាដើម្បីប្តេជ្ញាខ្លួនឯងក្នុងដំណើរការផ្ទេរ
- អ្នកដឹកនាំសាសនាគឺជាក្រុមអ្នកតំណាងមួយ ដែលមានឥទ្ធិពលក្នុងសហគមន៍ប្រកបដោយភាពជឿទុកចិត្តខ្ពស់ និងការទទួលស្គាល់ពីសហគមន៍
- **អ្នកតំណាងទាំងអស់គួរគិតពិចារណាទៅលើការមិនប្រកាន់បក្សពួកជាមួយនឹងការទទួលយកប្រជាសាស្រ្តមូលដ្ឋាន។**
- **យ៉ាងតិចបំផុតពាក់កណ្តាលនៃអ្នកតំណាងសង្គមស៊ីវិលត្រូវតែជាស្រ្តីដើម្បីចូលរួមក្នុងទស្សនៈនៃស្រ្តីនិងបង្ហាញតម្រូវការក្នុងដំណើរការការផ្ទេរឲ្យបានគ្រប់គ្រាន់។**

ទីបញ្ចប់នៃវគ្គសិក្សា ការវាយតម្លៃត្រូវបានធ្វើឡើងដោយចែកកម្រងសំណួរទៅឲ្យអ្នកចូលរួម។ អ្នកសម្របសម្រួលគួរសង្ខេបលទ្ធផលសំខាន់ និងដាក់ស្នើរួមគ្នាជាមួយរបាយការណ៍បេសកកម្មទៅឲ្យក្រុមDELGOSEA។ លទ្ធផលនឹងត្រូវបានចែករំលែកជាមួយទីក្រុងសាកល្បង និង អង្គភាពរដ្ឋាភិបាលមូលដ្ឋាន។

## ៧-៤ ការត្រួតពិនិត្យ និងការរាយការណ៍

**គោលបំណង** ដើម្បីតាមដានដំណើរការធ្វើតាម និង បើសិនជាចាំបាច់ កែតម្រូវផែនការសកម្មភាព រឺប្រើវិធីសាស្រ្តបន្ធូរបន្ថយ។

## ៧-៤-១ និយមន័យ និង សេចក្តីផ្តើមនៃការត្រួតពិនិត្យគម្រោង

ការត្រួតពិនិត្យរួមមានដំណើរការទាំងឡាយ ដែលធ្វើឡើងដើម្បីតាមដានការប្រតិបត្តិគម្រោង ដើម្បីឲ្យបញ្ហាអាចកំនត់បានតាមពេលវេលា និងសកម្មភាពកែតម្រូវអាចធ្វើបាន។ ផលប្រយោជន៍សំខាន់គឺសកម្មភាពគម្រោងត្រូវបានតាមដាន និងវាស់វែងជាប្រចាំដើម្បីកំនត់អថេរភាពពីផែនការគ្រប់គ្រងគម្រោង។

ការត្រួតពិនិត្យរួមបញ្ចូលះ

- ថ្លឹងថ្លែងសកម្មភាពដំណើរការគម្រោង (តើយើងនៅឯណា?)
- អង្កេតអថេរគម្រោង (ថ្លៃដើម កំលាំង ឱកាស។ល។)
- កំណត់សកម្មភាពកែតម្រូវ ដើម្បីដោះស្រាយបញ្ហា និងហានិភ័យឲ្យបានសមស្រប (តើយើងអាចត្រលប់មកភាពដើមវិញបានដោយរបៀបណា?)
    - ជះឥទ្ធិពលទៅលើកត្តា ដែលអាចជៀសវាង និងគ្រប់គ្រងបាននូវការផ្លាស់ប្តូរមិនចាំបាច់នានា ដូច្នេះមានតែការផ្លាស់ប្តូរសមស្របប៉ុណ្ណោះត្រូវបានអនុវត្ត។

ក្នុងគម្រោងច្រើនផ្នែកដូចការធ្វើតាមការអនុវត្តន៍ល្អ ដំណើរការតាមដានផ្តល់មតិយោបល់ដើម្បីអនុវត្តន៍សកម្មភាពកែតម្រូវ រឺបង្ការក្នុងការអនុឡោមគម្រោងជាមួយនឹងផែនការគ្រប់គ្រងគម្រោង។

និយមន័យនៃដំណាក់កាលសម្រេចបានលទ្ធផលរបស់គម្រោងអាចជាឧបករណ៍បន្ថែមក្នុងការតាមដាន។ Milestonesកំណត់ការសម្រេចបានព្រឹត្តិការណ៍សំខាន់ ។ លទ្ធផលនិមួយៗមានរយៈពេលសូន្យ ហើយគ្មានការប្រឹងប្រែង មានន័យថាគ្មានការងារ ដែលទាក់ទងជាមួយនឹងលទ្ធផល។ វាជាទង់ក្នុងផែនការណ៍ ដើម្បីបង្ហាញថាផ្នែកមួយចំនួនត្រូវបានបំពេញរួច។ ជាធម្មតាលទ្ធផលកំណត់មុនត្រូវបានប្រើជាចំនុចកំនត់ ដើម្បីដឹងថាគម្រោងកំពុងដំណើរការតាមការគ្រង ទុក រឺគម្រោងនោះត្រូវការពិនិត្យឡើងវិញ។

លក្ខខណ្ឌដំបូងសម្រាប់ប្រព័ន្ធតាមដានតាមទម្រង់មាន

- របាយការណ៍ច្បាស់លាស់នៃគោលដៅដែលអាចវាស់វែងបានសម្រាប់គម្រោង និងផ្នែកតូចៗនៃគម្រោង ដែលសូចនាករអាចត្រូវបានកំណត់។

- **សំណុំនៃសូចនាករ** រួមមាន ធាតុចូលនៃទំនិញ និងសេវាកម្មដែលបង្កើតដោយគម្រោង និងឥទ្ធិពលមកលើអ្នកទទួលផល។
- **ការរំពឹងទុកសម្រាប់ការប្រមូលទិន្នន័យ និងរៀបចំកំនត់ត្រាគម្រោង** ដើម្បីឲ្យមានភាពស៊ីចង្វាក់គ្នារវាងទិន្នន័យសម្រាប់សូចនាករ និងស្ថិតិដែលមានស្រាប់ ហើយឲ្យទិន្នន័យសម្រាប់ប្រើប្រាស់មានតម្លៃសមរម្យ។
- **ការរៀបចំស្ថាប័នសម្រាប់ការប្រមូល វិភាគ និងរាយការណ៍ទិន្នន័យគម្រោង និងសម្រាប់វិនិយោគទៅលើអាគារ** ដើម្បីរក្សាគម្រោង។
- **សំណើរសម្រាប់ទទួលបានមតិយោបល់មកលើរបកគំហើញ សម្រាប់ការធ្វើការសម្រេចចិត្ត។**

### ៧-៤-២ ការតាមដានទីក្រុងសាកល្បង

សេចក្តីផ្តើមនៃប្រព័ន្ធតាមដានគួរជាដំណើរការរួមគ្នារវាងអ្នកសម្របសម្រួល និងទីក្រុងសាកល្បង។ វាសំខាន់ណាស់ក្នុងការយល់ស្របយកមូលដ្ឋានគោលរួមគ្នាមួយសម្រាប់ការតាមដាន។ អភិក្រមតាមបែបជាដំណាក់កាលត្រូវបានដាក់ជាអនុសាសន៍ មានន័យថាផែនការតាមដានត្រូវបានកំនត់ច្បាស់លាស់សម្រាប់រយៈពេលពាក់កណ្តាលដំបូងនៃការអនុវត្តន៍ការផ្ទេរ (ឧ. ៨ទៅ៩ខែ)។ ផែនការថ្មី ដែលផ្តោតទៅលើរយៈពេលពាក់កណ្តាលបន្ទាប់ត្រូវបន្តក្រោយពេលរយៈពេលដំបូងបានបញ្ចប់។

ក្នុងឧបសម្ព័ន្ធរបស់ជំពូកនេះបែបបទសម្រាប់ធ្វើការរាយការណ៍ត្រូវបានបង្ហាញ។ បែបបទនោះរួមមានផ្នែកអត្ថាធិប្បាយ រួមទាំងការរៀបចំជាតារាងម៉ាទ្រីកផងដែរ។ តារាងនោះចែកចេញជាគោលដៅទូទៅ គោលដៅជាក់លាក់ និង កម្រងសកម្មភាពទៅតាមលទ្ធផល។ នៅពេលរៀបចំតារាងតាមដាន គោលដៅ លទ្ធផល និងសកម្មភាព ដែលជាផ្នែកនៃការផ្ទេរទស្សនៈមានភាពស្រពិចស្រពិលពេក។ ដូចដែលបានចែងនៅក្នុងសេចក្តីផ្តើម ការតាមដានអាចធ្វើឡើងបានលុះត្រាតែគោលដៅ លទ្ធផល និងសកម្មភាពត្រូវបានកំណត់រួច។ បើគ្មាននោះទេ វាសឹងតែមិនអាចកំណត់សូចនាករបាន។

សេចក្តីផ្តើមនៃការតាមដានគម្រោងទៅឲ្យទីក្រុងសាកល្បង អាចធ្វើទៅបានដោយជំហានផ្សេងៗគ្នា។ ជាការពិតណាស់ការប្រជុំត្រូវការចូលរួមពីអ្នកចូលរួមសំខាន់។ ជំហានខ្លះត្រូវបានបង្ហាញនៅខាងក្រោមនេះ

- ការបង្ហាញពីបែបបទនៃការតាមដានទៅឲ្យទីក្រុងសាកល្បង។ ការកំណត់នៃបុគ្គលសំខាន់ដែលត្រូវចូលរួមក្នុងដំណើរការតាមដានចំពោះមុខឲ្យទីក្រុងសាកល្បង។
- ត្រួតពិនិត្យមើលគោលបំណង លទ្ធផល និងសកម្មភាព។ បង្ហាញភស្តុតាងបើសិនលទ្ធផលដែលបានកំនត់មានភាពច្បាស់លាស់សម្រាប់ការតាមដាន។ ពុំនោះទេត្រូវបែងចែកលទ្ធផលទៅជាជំហានតូចៗ និងតាមក្របខ័ណ្ឌពេលវេលា។
- និយមន័យនៃសូចនាករ និងប្រភពនៃព័ត៌មាន។ តើយើងអាចវាស់ស្ទង់ដឹងពីគោលបំណង រឺលទ្ធផលត្រូវបានសម្រេចបានដោយរបៀបណា? ទិន្នន័យមូលដ្ឋានត្រូវតែពិភាក្សា។ តើអ្វីអាចជាប្រភពមានប្រយោជន៍ ដើម្បីប្រមូលពត៌មាន (ប្រភពនៃព័ត៌មាន)? តើនរណានឹងទទួលខុសត្រូវការប្រមូលទិន្នន័យ? តើទិន្នន័យនឹងត្រូវបានធ្វើឲ្យប្រើប្រាស់បានដោយវិធីណា (ឯកសារ រឺ តាមអ៊ីម៉ែល)?
- ហានិភ័យខាងក្នុង និងខាងក្រៅ តើអ្វីអាចជាហានិភ័យ ដែលរារាំងដំណើរការធ្វើតាម? គិតពីវិធីសាស្រ្តបន្ធូរបន្ថយ។
- ការព្រមព្រៀង និងការសម្រេចចុងក្រោយនៃផែនការតាមដានមួយឆ្នាំដោយអ្នកសម្រេចចិត្តមូលដ្ឋាន
- ការឈរឈ្មោះអ្នកទទួលខុសត្រូវទៅលើការតាមដានចំពោះមុខឲ្យទីក្រុង សាកល្បង។
- ការព្រមព្រៀងទៅលើការចុះទស្សនៈកិច្ចដោយអ្នកសម្របសម្រួលក្នុងការត្រួតពិនិត្យ។ កាលបរិច្ឆេទសម្រាប់ឆ្នាំដំបូងថេរ។

| | | | | | |
|---|---|---|---|---|---|
| Name of Pilot City, Country: | | | | | |
| Name of Reporter: | | | | | |
| Thematic Area: | | | | | |
| Project Title: | | | | | |
| Monitoring Period: | | | | | |
| **Overall objective** | Indicators<br>(baseline data needed) | Sources of Information | Status quo at the beginning of the project | Status in August 2012 | |
| The improvement of living conditions of disadvantaged groups through increased participation of people in local planning and decision-making | *e.g. poverty rate at the beginning of the project in certain areas; number of consultations where people could participate; existence of planning mechanisms and elected bodies…* | | | | |
| **Specific Objective**<br>(as stated in the project design) | Indicators<br>(as stated in the project design) | Sources of Information | Possible Risks (external and internal) | | |
| | | | | | |
| **Results**<br>(as stated in the project design) | Indicators<br>(as stated in the project design) | Sources of Information | | | |

| | | | | | | |
|---|---|---|---|---|---|---|
| **Result I:** | | | | | | |
| *Please list all activities which lead to result I:* | Planned in month | Executed in month | Sources of Information | Steps achieved - until last period | Steps achieved –in current period | Problem faced and follow up action |
| Activity 1 | | | | | | |
| Activity 2 | | | | | | |
| Activity 3 | | | | | | |
| Activity 4 | | | | | | |
| **Results** (as stated in the project design) | Indicators (as stated in the project design) | | Sources of Information | | | |
| **Result II:** | | | | | | |
| *Please list all activities which lead to result II:* | Planned in month | Executed in month | Sources of Information | Steps achieved - until last period | Steps achieved –in current period | Problem faced and follow up action |
| Activity 1 | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| Activity 2 | | | | | | |
| Activity 3 | | | | | | |
| Activity 4 | | | | | | |
| **Results**<br>(as stated in the project design) | Indicators<br>(as stated in the project design) | | Sources of Information | | | |
| **Result III:** | | | | | | |
| *Please list all activities which lead to result III:* | Planned in month | Executed in month | Sources of Information | Steps achieved - until last period | Steps achieved –in current period | Problem faced and follow up action |
| Activity 1 | | | | | | |
| Activity 2 | | | | | | |
| Activity 3 | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| Activity 4 | | | | | | |
| **Results**<br>(as stated in the project design) | Indicators<br>(as stated in the project design) | | Sources of Information | | | |
| **Result IV:** | | | | | | |
| *Please list all activities which lead to result IV:* | Planned in month | Executed in month | Sources of Information | Steps achieved - until last period | Steps achieved –in current period | Problem faced and follow up action |
| Activity 1: training | | | | | | |
| Activity 2 | | | | | | |
| Activity 3 | | | | | | |
| Activity 4 | | | | | | |

**Management Structure of BP's Replication Project**

